អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2018, 16:00
CMS/CFO: Sann Rada

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E367/4.1.6 | 01210164-01210255 | 22/01/2018 | ☐ កែលើឯកសារដើម<br>☒ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| ជំនួសឯកសារមិនទាន់កែតម្រូវដោយឯកសារដែលបានកែតម្រូវរួច។ |

| សេចក្តីលម្អិតនៃការកែតម្រូវ៖ |
|---|
| |

ស្នើដោយ៖ អង្គភាពបកប្រែភាសា — ហត្ថលេខា៖

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ — ហត្ថលេខា៖

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ — ហត្ថលេខា៖

# ព្រឹត្តិបត្រ
# របស់អ្នកស្រាវជ្រាវពាក់ព័ន្ធពីអាស៊ី

ការចេញផ្សាយរបស់ព្រឹត្តិបត្រ BCAS មុនៗ ដែលបានចុះផ្សាយនៅលើគេហទំព័រនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងនៃការប្រើប្រាស់ដែលមិនមែនពាណិជ្ជកម្មតែប៉ុណ្ណោះ។ សូមបញ្ជាក់ថា រាល់រូបថត និងក្រាហ្វិកផ្សេងៗទៀតដែលបានចុះផ្សាយនៅក្នុងអត្ថបទនេះ មិនត្រូវផលិតឡើងវិញក្រៅពីសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនឡើយ។ រក្សាសិទ្ធគ្រប់យ៉ាង។

<u>មាតិកា</u>

វ៉ុល ២០ លេខ ៤៖ ពីខែ តុលា ដល់ខែ ធ្នូ ឆ្នាំ ១៩៨៨

- Ben Kiernan - កុមារកំព្រាពីអំពើប្រល័យពូជសាសន៍៖ ប្រជាជនចាមមូស្លីមក្នុងប្រទេសកម្ពុជាក្រោមរបប ប៉ុល ពត
- Rob Steven - ការវិនិយោគផ្ទាល់ពីបរទេសរបស់ជប៉ុននៅក្នុងតំបន់អាស៊ីអាគ្នេយ៍៖ ពីអាស៊ានទៅចាស៊ាន
- Gary Brown - NCND មិនដែលកើតឡើងម្តងទៀត៖ ការស្លាប់ក្នុងអត្ថបទនៅក្របមុខ
- Paul Kelemen - របៀបដែល ប៉ុល ពត បានឡើងកាន់អំណាច/អត្ថបទពិនិត្យមើលឡើងវិញ
- Timothy Brook - តើខ្មែរស្រឡាយត្រូវតែក្លាយជាម្ចាស់កម្មសិទ្ធិដីធ្លីមែនឬ?/អត្ថបទពិនិត្យមើលឡើងវិញ

*[រូបភាព]*

BCAS/ការសិក្សាសំខាន់ៗពីអាស៊ី
www.bcasnet.org

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

Original EN: 01199562-01199594

# កុមារកំព្រាពីអំពើប្រល័យពូជសាសន៍៖ ប្រជាជនចាមមូស្លីមក្នុងប្រទេសកម្ពុជាក្រោមរបប ប៉ុល ពត

**ដោយលោក Ben Kiernan**

*មិនមានរបបច្រើនទេនៅក្នុងប្រវត្តិសាស្ត្រដែលដូចគ្នានឹងរបប ប៉ុល ពត សូម្បីតែរបបដែលដឹកនាំដោយអ្នកដែលមិនជឿសាសនាក្តី ដែលអាចលុបបំបាត់សាសនាចោលបានដោយជោគជ័យ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការប្រតិបត្តិសាសនាទាំងអស់ត្រូវបានហាមឃាត់ និងរងការបង្ក្រាបយ៉ាងមានប្រសិទ្ធភាព ដែលពេលខ្លះដោយប្រើអំពើហិង្សាទៀតផង។ ពុទ្ធសាសនា សាសនាឥស្លាម និងគ្រិស្តសាសនាត្រូវបានបំបាត់ចោលទាំងអស់ ដោយប្រើកម្លាំងដូចគ្នា ដែលត្រូវបានប្រើដើម្បីបំផ្លាញចោលទាំងទំនៀមទម្លាប់ប្រពៃណី និងអញ្ញទិដ្ឋិក្បត់ ដូចជា "មូលធននិយម" និង លទ្ធិកុម្មុយនីស្ត_បែប "សេរីនិយម"។ ជារួម មនុស្សជាងមួយលាននាក់បានបាត់បង់ជីវិត។ ការសិក្សានេះស្វែងយល់អំពីផលប៉ះពាល់នៃការសម្លាប់រង្គាល និងការបង្ក្រាបរយៈពេលបួនឆ្នាំលើក្រុមជនជាតិភាគតិចមូស្លីម ដែល_អាចអះអាងបានថាបានទទួលរងនូវការបង្ក្រាបច្រើនជាងក្រុមជនជាតិភាគច្រើនជាពុទ្ធសាសនិកខ្មែរទៅទៀត នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ភស្តុតាងដែលបញ្ជាក់ពីរឿងនេះត្រូវបានកំណត់យ៉ាងពិស្តារ ដោយ_ផ្អែកលើបទសម្ភាសន៍ជាមួយប្រជាជនចាមដែលនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យជាង ១០០នាក់។ ករណីនៃការចងក្រងជាឯកសារ គឺមានភាពទន់ខ្សោយ ប៉ុន្តែចំនួនដ៏ច្រើននៃសាក្សីដែលឃើញហេតុការណ៍_ផ្ទាល់ភ្នែក គឺជារឿងដែលមិនអាចប្រកែកបាន ហើយ អាចសន្និដ្ឋានបានពីចេតនានាំផ្លូវ តាមរយៈអ្វីដែលបាន_កើតឡើងនៅទូទាំងប្រទេស។ ការសន្និដ្ឋានរបស់ខ្ញុំគឺថា ការប៉ុនប៉ងរបស់របប ប៉ុល ពត ដែលមិនត្រឹមតែដើម្បី_បំផ្លាញសាសនាឥស្លាមប៉ុណ្ណោះទេ តែថែមទាំងដើម្បីបំបាត់ចោល សហគមន៍ចាមតែម្តង គឺជាអំពើប្រល័យពូជសាសន៍ដូចបានចែងនៅក្នុងច្បាប់អន្តរជាតិ៖ អំពើនានា ដូចជា "ការសម្លាប់សមាជិកនៃក្រុម" ដែលធ្វើឡើងដោយមាន "ចេតនាចង់បំផ្លាញចោលទាំងស្រុង ឬដោយផ្នែកនូវក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ជាដើម"។*

Formatted: Condensed by 0.8 pt

## I. សេចក្តីផ្តើម៖ ជនជាតិចាមនៅក្នុងប្រវត្តិសាស្ត្រ

នៅក្នុងអត្ថបទដែលគួរឲ្យកត់សម្គាល់មួយចុះផ្សាយលើកដំបូងនៅឆ្នាំ ១៩៣៣ លោក Paul Mus បានវិភាគពីទំនៀមទម្លាប់សាសនារបស់ប្រជាជនមួយក្រុមដែលលោកហៅថា "កូនចៅដែលបាត់បង់នៃវប្បធម៌

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ឥណ្ឌា"[1]។ ប្រជាជនទាំងនេះគឺប្រជាជនចាម។ ប្រទេសរបស់ពួកគេដែលមានឈ្មោះថា ចម្ប៉ា ធ្លាប់ជារដ្ឋមួយក្នុងចំណោមរដ្ឋដែលគោរពសាសនាហិណ្ឌូ និងពុទ្ធសាសនានៅតំបន់អាស៊ីអាគ្នេយ៍រវាងពីសតវត្សរ៍ ទី ៣ ដល់ទី ១៥ ប៉ុន្តែនៅក្នុងឆ្នាំ ១៤៧១ រដ្ឋនេះត្រូវរងការរុករាន និងបំបែកចេញពីគ្នាដោយនគរវៀតណាម។

នៅឆ្នាំ ១៩៧០ ប្រជាជនចាមចំនួន ៦០.០០០ នាក់ បានរស់នៅលើទឹកដីពីបុរាណរបស់ខ្លួននៅក្នុងប្រទេសវៀតណាមខាងត្បូង។ ប៉ុន្តែ ប្រជាជនចាមចំនួន ២០០.០០០ នាក់ទៀតបានរស់នៅក្នុងប្រទេសកម្ពុជាដែលជាកន្លែងរត់គេចខ្លួន និងជ្រកកោនដោយដូនតារបស់គេ។ នៅទីនោះពួកគេបានជ្រើសយកសាសនាឥស្លាម និងបានរៀបការជាមួយ "ប្រជាជនម៉ាឡេ" នៅក្នុងប្រទេសកម្ពុជាដើម្បីបង្កើតជាសហគមន៍មូស្លីមយ៉ាងមុតមាំដែលខុសគ្នាពីប្រជាជនខ្មែរកាន់ពុទ្ធសាសនាយ៉ាងច្រើនលើសលប់នោះ។ ប្រជាជនចាមគឺជា "ជនជាតិដើមភាគតិចដែលធំជាងគេនៅក្នុងប្រទេសកម្ពុជា"[2]។ មុនពេលពិចារណាពីជោគវាសនារបស់ពួកគេពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ យើងចាំបាច់ត្រូវពិនិត្យមើលជាមុនសិនពីប្រវត្តិសាស្ត្ររបស់ជនជាតិចាម និងតួនាទីរបស់ពួកគេ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។

ពីសតវត្សរ៍ទី ៣ ជនជាតិចាមស្ថិតក្នុងចំណោមប្រជាជនអាស៊ីអាគ្នេយ៍ដំបូងគេដែលបានទទួលឥទ្ធិពលពីវប្បធម៌ឥណ្ឌា។ នេះអាចឆ្លុះបញ្ចាំងពីស្ថានភាពរីកចម្រើនគួរសមនៃស្ថាប័នសង្គមរបស់ពួកគេផ្ទាល់[3]។ តាមពិតទៅ ប្រាសាទចាមនៅសតវត្សរ៍ទី ៦ ឈ្មោះ មីសុន គឺជាវិមានស្ថាបត្យកម្មចាស់ជាងគេ នៅតំបន់អាស៊ីអាគ្នេយ៍ ហើយសូម្បីតែប្រទេសឥណ្ឌាខ្លួនឯងក៏មានវិមានមុននេះមិនច្រើនទេ[4]។ នៅពេលដែលប្រជាជនចិនបានវាយ

---

[1] Paul Mus, "*វប្បធម៌ឥណ្ឌា និងជនជាតិដើមនៅក្នុងប្រទេសចម្ប៉ា*" *ព្រឹត្តិបត្រសាលាបារាំងពីអាស៊ីខាងកើត-(BEFEO)* XXXIII (ឆ្នាំ ១៩៣៣) ទំព័រ ៣៦៧-៤១០។ ចេញផ្សាយនៅក្នុងការបកប្រែជាភាសាអង់គ្លេសដោយ I.W Mabbett ថា *ប្រទេសឥណ្ឌាពីទស្សនៈអាស៊ីខាងកើត៖ វប្បធម៌ឥណ្ឌា និងជនជាតិដើមនៅក្នុងប្រទេសចម្ប៉ា* កែសម្រួលដោយ I.W Mabbett និង David P. Chandler, ឯកសារសាកលវិទ្យាល័យ Monash ស្តីពីតំបន់អាស៊ីអាគ្នេយ៍ លេខ ៣ (មែលបួន ឆ្នាំ ១៩៧៥)។ សូមមើលទំព័រ៥៣។

[2] Michael Vickery, ប្រទេសកម្ពុជា ឆ្នាំ ១៩៧៥-១៩៨២ (ស៊ីដនី៖ Allen and Unwin, និងបូស្តុន៖ South End, ឆ្នាំ ១៩៨៤), ទំព័រ ១១។

[3] Mus, "វប្បធម៌ឥណ្ឌា"

[4] George Maspero, *នគរចម្ប៉ា*, ប៉ារីស ឆ្នាំ ១៩២៨។ ការបកប្រែជំពូក ១ (សាកលវិទ្យាល័យយេល ការសិក្សាពីតំបន់អាស៊ីអាគ្នេយ៍ (៩៤៩) ទំព័រ ៤៩។

Deleted: *ចាម្ប៉ា*

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01199562-01199594

ជោគជ័យលើប្រទេសចម្ប៉ាមួយរយៈក្នុងឆ្នាំ ៦០៥ ពួកគេបានរឹបអូសយកស្នាដៃចំនួន ១.៣៥០ ស្តីពីពុទ្ធសាសនា ដែលបានសរសេរជាភាសាចាម[5]។

*[រូបភាព]*

រូបថតដោយ B.P. Groslier* (រូបភាព និងចំណងជើងនេះគឺបានមកពី *Bernard Philippe Groslier,* ឥណ្ឌូចិន, បានបកប្រែពីភាសាបារាំងដោយលោក *James Hogarth (Cleveland* និងញូវយ៉ក៖ *The World Publishing Company,* ឆ្នាំ ១៩៦៦)។ រូបទី ៦៥ ក្នុងទំព័រ ១២៣ ទំព័រ ៧៧ និង ២៧១)។

*អគ្គបទរបស់ចាមនៃព្រះសិវៈក្នុងសាសនាហិណ្ឌូនៅលើអាសនៈធ្វើពីថ្មភក់ ដែលកសាងឡើងក្នុងសតវត្សរ៍ទី ៩ នៅដុងដួងក្នុងឥន្ទ្របុរៈ នៅក្នុងទីតាំងដែលឥឡូវនេះជា វៀតណាម នៅវៀតណាមខាងត្បូង។ នៅឆ្នាំ ៩៨២ ប្រជាជនវៀតណាមបានកាន់កាប់ឥន្ទ្របុរៈ ហើយប្រជាជនចាមបានធ្លាក់ទៅវិជ័យ នៅតំបន់ប៊ិញឌិញ វៀតណាមខាងត្បូង។*

ព្រះនៃប្រជាជនឥណ្ឌាត្រូវបានប្រជាជនចាម "ត្រូវបានកែប្រែសញ្ជាតិ" ខណៈដែលព្រះនៅលើផែនដីនៅក្នុងប្រទេសត្រូវបានធ្វើឱ្យទៅជាហិណ្ឌូ។ ទេវធីតារបស់ប្រជាជនចាមនៅញ៉ាត្រាងដែលមានឈ្មោះថា ពោធិ៍ឥន្ទនាគា បន្តិចម្តងៗត្រូវបានគេមើលឃើញថាជា អុម៉ា ដែលជាមហេសីរបស់ព្រះសិវៈក្នុងសាសនាហិណ្ឌូ។ បើតាមពាក្យរបស់លោក Paul Mus សាសនាក្នុងស្រុក "បានទទួលស្គាល់ខ្លួនឯង" ថាស្ថិតនៅក្នុងសាសនាហិណ្ឌូ និងពុទ្ធសាសនា[6]។ ស្ថាបត្យកម្មរបស់ចាមមិនត្រឹមតែប្រាសចាកពីឥទ្ធិពលរបស់ឥណ្ឌាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រាសចាកពីឥទ្ធិពលរបស់វៀតណាម ចិន ឥណ្ឌូនេស៊ី ម៉ាឡេ និងខ្មែរផងដែរ។ បណ្តុំប្រាសាទមួយរបស់ចាមនៅសតវត្សរ៍ទី ៩ ត្រូវបានគេរៀបរាប់ថា "អាចជាបទពិសោធន៍ខាងសាភ័ណភាពដ៏ល្អប្លែកគេដែលកសាងឡើងដោយពុទ្ធសាសនា"[7]។ លោក Paul Mus ទាញការយកចិត្តទុកដាក់របស់អ្នកអានទៅរកអគារចាមគួរឱ្យកត់សម្គាល់ដើម្បីស្វែងយល់គំនិតអរូបី និងទស្សនវិជ្ជា[8]។ លោកបាននិយាយថា ចម្ប៉ា "បានទទួលកាលពីអតីត

[5] Ian W. Mabbett, "ពុទ្ធសាសនានៅប្រទេសចម្ប៉ា" ក្នុង D.G. Marr និង A.C. Milner (eds.), *បន់អាស៊ីនៅសតវត្សរ៍ទី ៩ ដល់ទី ១៤*(កង់បេរ៉ា៖ សាកលវិទ្យាល័យជាតិអូស្ត្រាលី (៩៨៦) ទំព័រ ២៨៩-៣១៣ នៅទំព័រ ២៩៥។

[6] Mus, "វប្បធម៌ឥណ្ឌា" ទំព័រ ៤, ៣៧។

[7] Mabbett, "ពុទ្ធសាសនា ទំព័រ ២៩៩ ដកស្រង់ពី Boisselier។

[8] Mus, "វប្បធម៌ឥណ្ឌា" ទំព័រ ៥២។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

កាលនូវឥទ្ធិពលគ្រប់យ៉ាងដែលមានសម្រាប់ឲ្យខ្លួនទទួលយកបាន ដោយការចម្លងដោយផ្ទាល់” ហើយបាន កំណត់របៀបធ្វើការក្នុងរបៀបថ្មីមួយ ដោយធ្វើការផ្លាស់ប្តូរភាសាចាមទៅជាភាសាត្រង់ៗ និងផលិតក្រៀម ភាសាខាងវប្បធម៌ផ្ទាល់ខ្លួន។ ប៉ុន្តែលោកបានបន្តថា៖ “តើប្រទេសនេះនឹងក្លាយទៅជាយ៉ាងណា? នេះគឺជា លទ្ធភាពមួយដែលនៅតែផ្តល់ភាពរំភើបដល់ក្តីស្រមៃរបស់យើង ប៉ុន្តែវាត្រូវបានសម្លាប់ចោលទាំងនៅជាទារកដ៏តូច ដោយសារថ្មីដែដ៏ឃោរឃៅនៃប្រវត្តិសាស្ត្រ”[9]។

**ដូច្នេះ នៅក្នុងករណីអ្នកជម្លៀសពីទីក្រុង និងប្រជាជនចិន ទំនាក់ទំនងខ្លះជាមួយនឹងប្រជាជនមូលដ្ឋាន ផ្តល់ផលល្អដល់ពួកគេ។ ប៉ុន្តែវាមិនបានជួយសង្គ្រោះប្រជាជនចាមដែលត្រូវបានគេកំណត់ជាគោលដៅ ដើម្បីកម្ទេចចោលបានទេ ថ្វីបើពួកគេភាគច្រើនជាប្រជាជនមូលដ្ឋានក៏ដោយ។ ការសម្លាប់រង្គាលលើ ប្រជាជនចាមទាំងនេះនៅពាក់កណ្តាលឆ្នាំ ១៩៧៨ នៅទីនោះគឺជាផ្នែកមួយនៃយុទ្ធនាការនៃការសម្លាប់ បំផុតពូជ។**

ខ្ញុំនឹងត្រឡប់ទៅចំណុចស្តីអំពី “ការសម្លាប់” បញ្ញវ័ន្តរបស់ចម្ប៉ានៅក្នុងឆ្នាំ ១៤៧១ ដោយគ្រាន់តែកត់សម្គាល់នៅទីនេះនូវចំណុចផ្ទុយគ្នារបស់លោក Gerard Moussay ដែលថា អក្សរសាស្ត្រចាម “យ៉ាងច្រើន” គឺនៅតែមានសេសសល់ក្នុងតំបន់ផានរ៉ាង យ៉ាងហោចណាស់ប្រាំសតវត្សរ៍ក្រោយមក[10]។

ភាគច្រើននៃសតវត្សរ៍ទី ១២ ចម្ប៉ាបានចូលប្រឡូកក្នុងសង្គ្រាមប្រឆាំងនឹងនគរខ្មែរ។ នៅឆ្នាំ ១១៧៨ កងទ័ពចាមបានជិះទូកឡើងតាមទន្លេមេគង្គដោយមានជំនួយពីនាវិកចិន បានកាន់កាប់អង្គរ និងបានធ្វើគត់ស្តេចខ្មែរ។ ប្រជាជនខ្មែរបានប្រមូលជាក្រុមឡើងវិញ ហើយវាយត្រឡប់បកវិញ ដោយធ្វើគត់ស្តេចចាម “ដោយព្រួញរាប់រយលានដើម”[11] ហើយក្រោយមកបានកាន់កាប់រាជធានីរបស់ចាមបានមួយរយៈ។ ប៉ុន្តែរាជធានីរបស់ចាមនៅបន្តយូរជាងអង្គរ ដែលត្រូវបានប្រជាជនខ្មែរបោះបង់ចោលដោយសារការវាយប្រហាររបស់ថៃនៅ ក្នុងឆ្នាំ ១៤៣២។

---

[9] ដូចឯកសារខាងលើ ទំព័រ ៥៣, ៥៤។

[10] G. Moussay, “រឿងរ៉ាវនៃជនជាតិចាមក្នុងពេលបច្ចុប្បន្ន” ព្រឹត្តិបត្រនៃសមាគមសិក្សាពីឥណ្ឌូចិននៅសៃហ្គន៤៦ (ឆ្នាំ ១៩៧១) ។ ទំព័រ ៣-១០ នៅទំព័រ ១០។

[11] David P. Chandler, ប្រវត្តិសាស្ត្រកម្ពុជា (Boulder, CO៖ Westview,ឆ្នាំ ១៩៨៣) ទំព័រ ៥៨។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ចម្ប៉ាមិនមែនជារដ្ឋកណ្ដាលដ៏មានអនុភាពទេ។ ដូចគ្នានឹងក្រុមនយោបាយផ្សេងទៀតនៅតំបន់អាស៊ីអាគ្នេយ៍ដែរ វាគឺជាការប្រមូលផ្ដុំតំបន់អំណាចក្នុងតំបន់ដែលងាយនឹងបែកបាក់។ លោក Claude Jacques បានជឿថា "ទឹកដីចាមមានការបែកបាក់ច្រើនជាងអត់"[12]។ ប្រការនេះមិនបានបដិសេធថា អំណាចចាមធ្លាប់ទៅដល់ចំណុចកំពូលរបស់ខ្លួនទេ។ នៅឆ្នាំ ១៣៧១ កងទ័ពជើងទឹកចាមបានវាយលុក និងកាន់កាប់រាជធានីវៀតណាម។ ប៉ុន្តែ តាមពិតទៅ ជាងមួយសតវត្សរ៍ក្រោយមក វៀតណាមបានប្រែប្រួលស្ថានការណ៍ទាំងស្រុងដោយលុកលុយវិជ័យដោយប្រើកងទ័ព ២៥០.០០០ នាក់។ ស្ដេចចាមព្រះនាម បានឡាត្រាទ័ន ត្រូវបានចាប់ខ្លួន និងធ្វើគត់ រួមទាំងប្រជាជនរបស់ទ្រង់ប្រមាណជាង ៥០.០០០ នាក់ទៀតផង"[13]។

ចម្ប៉ាត្រូវបានវៀតណាមដែលទទួលបានជ័យជំនះបែងចែកឲ្យទៅជាក្សត្របុរីចំនួនបី។ កសិករវៀតណាមបានផ្លាស់ទីមកភាគខាងត្បូងតាមបណ្ដោយឆ្នេរសមុទ្រ។ ចាប់ពីឆ្នាំ ១៦៩៣ ស្ដេចចាមត្រូវបានស្ដេចវៀតណាមចាត់ទុកថាជាមន្ត្រីមូលដ្ឋាន។ នៅឆ្នាំ ១៧៧០ នាវិកបារាំងបានចូលមើលព្រះរាជវាំងចាម[14]។ ពួកគេបានរាយការណ៍ "បល្ល័ង្ករបស់ស្ដេចគឺជាកំណល់ទ្រជើងដ៏សាមញ្ញ"។ ស្ដេចចាមបានចូលរួមក្នុងបដិវត្តន៍តៃសឺនដែលបានផ្ទុះឡើងនៅប្រទេសវៀតណាមក្នុងឆ្នាំ ១៧៧១ ប៉ុន្តែក្រោយមក ទ្រង់យល់ថា ខ្លួនទ្រង់ហាក់ជាជនចម្លែកចំពោះភាគីទាំងពីរនៅក្នុងជម្លោះនេះ។ នៅពេលដែលពួកតៃសឺនទទួលជ័យជម្នះ មេដឹកនាំរបស់ពួកគេបានតែងតាំងខ្លួនឯងជាស្ដេចរបស់វៀតណាមនៅវិជ័យ ដែលជាទីតាំងនៃអតីតរាជធានីចាម[15]។ ការធ្វើបែបនេះហាក់ដូចជាការទទួលស្គាល់កេរដំណែលចម្ប៉ា ប៉ុន្តែវាក៏ជាការអះអាងរបស់វៀតណាមដ៏មានប្រសិទ្ធភាពចំពោះការកាន់កាប់របស់ខ្លួនលើទឹកដីនេះផងដែរ។

---

[12] Claude Jacques, "ប្រភពស្ដីពីសកម្មភាពសេដ្ឋកិច្ចនៅក្នុងទឹកដីខ្មែរ និងចាម" នៅក្នុង Marr និង Milne, *អាស៊ីអាគ្នេយ៍*, ទំព័រ ៣៣៣។

[13] Chester Bain, *វៀតណាម៖ ឫសគល់នៃជម្លោះ* (Englewood Cliffs, NJ៖ ឆ្នាំ ១៩៦៧) ទំព័រ ៦៦ និង Jean Chesneaux, *ប្រជាជាតិវៀតណាម៖ ការរួមចំណែកដល់ប្រវត្តិសាស្ត្រ*, បានបកប្រែជាភាសាអង់គ្លេសដោយ Malcolm Salmon (ស៊ីដនី៖ Current Book Distributors, ឆ្នាំ ១៩៦៦) ទំព័រ ២៩។

[14] Maspero, *នគរ*, ទំព័រ ២៨។

[15] Chesneaux, *ប្រជាជាតិវៀតណាម* ទំព័រ ៤២។ ពោធិ៍ ធម្មា "ស្ដីពីការនិរទេសស្ដេចចាមមួយអង្គនៅកម្ពុជា" BEFEO LXXII (ឆ្នាំ ១៩៨៣) ទំព័រ ២៥៣-៦៦។ A.B. Woodside, លំនាំវៀតណាម និងចិន (ខេមប្រ៊ីជ, MA៖ សាកលវិទ្យាល័យហាវើដ ឆ្នាំ ១៩៧១) ទំព័រ ២៣។

Deleted: Unrevised translation. A revised translation will be provided upon request.

*[រូបភាព]*

*ដោយក្តីគោរពពី Ben Kiernan** (ផែនទីនេះគឺជាច្បាប់ចម្លងនៃផែនទីក្នុងបណ្ណាសារជ្ឍនៅទីក្រុងឡាអេ។)

*ចំណែកនេះនៃផែនទីហូឡង់របស់ឥណ្ឌូចិនក្នុងឆ្នាំ ១៦៥៨-៥៩ បង្ហាញ ចម្ប៉ា ដែលត្រូវបានប្រកបជា Tsiompa ។*

ទោះបីជាមានការបំផ្លិចបំផ្លាញព្រះរាជវាំង និងពិធីក្នុងរាជវង្សរបស់ខ្លួនក្តី ក៏ជីវិតសាសនារបស់ជនជាតិចាមនៅតែបន្ត។ ទេវធីតាក្នុងស្រុកពីដើមនៅញ៉ាត្រាងដែលមានឈ្មោះថា ពោធិ៍ឥន្ទនាគា លែងត្រូវបានគេមើលឃើញថាជាមហេសីរបស់ព្រះសិវៈ ព្រះនាម អុម៉ា ទៀតហើយ "ដោយត្រឡប់ទៅស្ថានភាពដំបូងរបស់នាង"[16] ។ ព្រះសិវៈ ខ្លួនទ្រង់ ត្រូវបានជំនួសដោយ ពោធិ៍ក្លូនហ្គារ៉ាយ ដែលជាស្តេចចាមដែលទទួលបានការគោរពជាអាទិទេព។ ព្រះឥន្ទ្រក្នុងសាសនាហិណ្ឌូ ជាព្រះមួយអង្គដែលហាក់ដូចជាបានរស់រានមានជីវិតគួរឱ្យកត់សម្គាល់ក្នុងនាមជាព្រះរបស់ប្រជាជនចាមព្រះនាម (យាន) ឥន្ទ្រ[17]។ ប៉ុន្តែពុទ្ធសាសនាបានបាត់ខ្លួនទាំងស្រុងតែម្តង។ ដូចគ្នានឹងកន្លែងដទៃទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែរ សាសនាឥស្លាមហាក់ដូចជាបានជំនួសពុទ្ធសាសនា។

មានប្រវត្តិដ៏វែងនៃសាសនាឥស្លាមនៅចម្ប៉ារួចទៅហើយ។ សិលាចារឹកជាភាសាអារ៉ាប់នៅសតវត្សរ៍ទី ១១ ចំនួនពីរ បង្ហាញពីអត្ថិភាពនៃសហគមន៍ពាណិជ្ជកម្មមូស្លីមបរទេសមួយនៅចម្ប៉ានៅពេលនោះ។ ប៉ុន្តែ វាមិនទំនងទេថា ប្រជាជនចាមជាច្រើនត្រូវបានកែប្រែឱ្យទៅកាន់សាសនាឥស្លាម មុនពេលនៃការដណ្តើមបានជោគជ័យលើនគររបស់ពួកគេក្នុងឆ្នាំ ១៤៧១[18]។ តាមពិតទៅ គ្មានកំណត់ត្រានៃស្តេចមូស្លីមនៅចម្ប៉ាទេ មុនឆ្នាំ ១៦៧៦។ នៅអត្រាណាមួយ ដូចដែលបានបង្ហាញដោយលោក Michael Vickery ត្រូវបានដឹងតិចតួចណាស់ សូម្បីតែពីព្រឹត្តិការណ៍នៅកម្ពុជាចាប់ពីការកាន់កាប់របស់ថៃមកលើអង្គរនៅឆ្នាំ ១៤៣២ រហូតដល់

---

[16] Mus, "វប្បធម៌ឥណ្ឌា" ទំព័រ ៣៦, ៣៨។

[17] ដូចឯកសារខាងលើ ទំព័រ ៥១។ ចំពោះ ពោធិ៍ក្លូនហ្គារ៉ាយ សូមមើល G.E. Marrison "ជនជាតិចាមនៅម៉ាឡាកា" ទស្សនាវដ្តីសាខាម៉ាឡាយ៉ារបស់សង្គមភូមិន្ទអាស៊ី ២៤, ១ (ឆ្នាំ ១៩៥១), ទំព័រ ៩០-៩៨ នៅទំព័រ ៩៥។

[18] Pierre-Yves Manguin, ក្នុងការសិក្សាដ៏គួរឱ្យជឿជាក់ "ការចូលមកដល់នៃសាសនាអ៊ីស្លាមក្នុងប្រទេសចម្ប៉ា" *BEFEO* LXVI (ឆ្នាំ ១៩៧៩) ទំព័រ ២៥៥-៨៧ កំណត់ថា អ៊ីស្លាមនីយកម្មលើប្រទេសចម្ប៉ាគឺប្រហែលជានៅដំណាក់កាលខ្លះរវាងឆ្នាំ ១៦៤៤ ដល់ឆ្នាំ ១៦៧៦។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ឆ្នាំ ១៥៩០ នៅពេលដែលកងទ័ពថៃឈ្លានពានជាថ្មីម្តងទៀត និងបន្ទាប់មកកាន់កាប់រាជធានីខ្មែរគឺ លង្វែក[19]។ ការយល់ដឹងឲ្យច្រើនជាងនេះពីប្រវត្តិសាស្ត្ររបស់ចម្ប៉ានៅក្នុងអំឡុងពេលនោះគឺជាការលំបាកណាស់។

ទន្ទឹមគ្នានេះដែរ ពាណិជ្ជករមូស្លីមបានបង្ហាញខ្លួននៅលើឆាកកម្ពុជា។ មានសង្កាត់ម៉ាឡេមួយ (ក៏ដូចជាអារ៉ាប់) នៅក្នុងក្រុងលង្វែក នៅចុងទសវត្សរ៍ឆ្នាំ ១៥៩០។ នៅទសវត្សរ៍ឆ្នាំ ១៦២០ គេឃើញមានការកើនឡើងយ៉ាងច្រើននៃឥទ្ធិពលម៉ាឡេនៅកម្ពុជា។ នៅក្នុងអំឡុងពេលនេះ នៅក្នុងពង្សាវតាខ្មែរ មានទីក្រុងសំខាន់ពីរ ដែលត្រូវបានដាក់ឈ្មោះ (ឬប្តូរឈ្មោះ) ថា កំពង់[20] ដែលជាពាក្យម៉ាឡេមានន័យថា ភូមិ ដែលបានក្លាយជាភាសាខ្មែរថា កំពង់ផែ។ ក្រោយមកទៀត មជ្ឈមណ្ឌលមួយក្នុងចំណោមមជ្ឈមណ្ឌលតាមដងទន្លេរបស់កម្ពុជាបានរីកចម្រើន ដោយប្រើឈ្មោះថា កំពង់ចាម ឬកំពង់ផែចាម ហើយឥឡូវនេះ វាគឺជាទីរួមខេត្តនៃខេត្តធំបំផុតមួយរបស់ប្រទេសកម្ពុជា។ គេអាចសន្និដ្ឋានថា ពាណិជ្ជករម៉ាឡេបានជ្រៀតចូលទៅដែនដីខាងក្នុង ដោយសារនេះគឺជាអំឡុងពេលនៃការកើនឡើងខាងសកម្មភាពពាណិជ្ជកម្ម។

នៅឆ្នាំ ១៦២៣ ស្តេចខ្មែរព្រះនាម ជ័យ ជេដ្ឋា បានអនុញ្ញាតឲ្យឈ្មួញហូឡង់បង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មមួយនៅកម្ពុជា ហើយមិនយូរប៉ុន្មានអ្នកជំនួញអង់គ្លេសបានមកដល់ផងដែរ។ ទ្រង់ក៏បានបោះកាក់ថ្មី ហើយអនុញ្ញាតឲ្យស្តេចវៀតណាមបើកផ្នែកគយមួយនៅតាមភូមិនៅសៃហ្គន។ នៅទសវត្សរ៍ឆ្នាំ ១៦៣០ ក្នុងពង្សាវតាខ្មែរ ប្រជាជនចិនជាច្រើនបានមកដល់កម្ពុជា[21]។ នៅខែ កក្កដា ឆ្នាំ ១៦៣៩ ភ្នាក់ងារហូឡង់_នៅក្នុងរាជធានីភ្នំពេញបានទិញស្បែកក្តាន់យ៉ាងតិច ១២៥.០០០ ស្បែក សម្រាប់នាំចេញទៅកាន់ប្រទេសជប៉ុន។ នៅពេលជាមួយគ្នានោះដែរ មាននាវាព័រទុយហ្គាល់ចំនួន ៧ បានទិញទំនិញនៅកម្ពុជា[22]។

នៅឆ្នាំ ១៦៤២ ព្រះអង្គម្ចាស់ខ្មែរវ័យក្មេងមួយអង្គ ព្រះនាម ពញាច័ន្ទ បានដណ្តើមយករាជ្យបល្ល័ង្ក ដោយធ្វើគត់ស្តេច ដែលត្រូវជាបិតារបស់ទ្រង់ ដោយមានជំនួយពីអ្នកគាំទ្រម៉ាឡេ[23]។ ឥទ្ធិពលមូស្លីមនៅកម្ពុជា

---

[19] Michael Vickery, *ប្រទេសកម្ពុជាក្រោយសម័យអង្គរ៖ ភ័ស្តុតាងកាលប្រវត្តិសម្រាប់សតវត្សរ៍ទី ១៤ ដល់ទី ១៦* (និក្ខេបបទថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យយេល ឆ្នាំ ១៩៧៧)។

[20] ម៉ាក់ ភឿន, ពង្សាវតាកម្ពុជា (ពីឆ្នាំ ១៥៩៤ ដល់ឆ្នាំ ១៦៧៧)។ (ប៉ារីស៖ សាលាបារាំងពីអាស៊ីខាងកើត ឆ្នាំ ១៩៨១) ទំព័រ ៤០៦, ១៣១។

[21] ដូចឯកសារខាងលើ ទំព័រ ២៧៨, ទំព័រ ១៦៦-៦៧។

[22] សូមមើល W.J.M. Buch, "ក្រុមហ៊ុនឥណ្ឌា ហូឡង់ និងឥណ្ឌូចិន" *BEFEO* XXXVII (ឆ្នាំ ១៩៣៧) ទំព័រ ១២១-២៣៧ នៅទំព័រ ២០៧។

[23] ម៉ាក់ ភឿន, ពង្សាវតាកម្ពុជា ទំព័រ ១៨៥, ៣៤២។

Deleted: *Unrevised translation. A revised translation will be provided upon request.*

បានឈានដល់ចំណុចកំពូលរបស់ខ្លួន នៅពេលដែលស្តេចអង្គនេះ "បានយល់ព្រមចូលសាសនាចាមម៉ាឡេ" ដូចដែលពង្សាវតាខ្មែរបានកត់ត្រាទុកក្រោយមក។ ពញាច័ន្ទបានប្តូរព្រះនាមទៅជា អ៊ីប្រាហ៊ីម។

មួយឆ្នាំក្រោយមក អ៊ីប្រាហ៊ីម បានធ្លាក់ចូលទៅក្នុងសង្គ្រាមដ៏ខ្លាំងប្រឆាំងនឹងក្រុមហ៊ុនឥណ្ឌាខាងកើតរបស់ប្រទេសហូឡង់។ នៅក្នុងការប្រយុទ្ធសំខាន់ពីរនៅលើទន្លេមេគង្គនៅឆ្នាំ ១៦៤៣-៤៤ ជនជាតិ ហូឡង់ចំនួន ១៥៦ នាក់ត្រូវបានសម្លាប់ ៥០ នាក់ត្រូវបានចាប់ខ្លួន និង ៨០ នាក់បានរងរបួស។ ជនជាតិខ្មែរជាងមួយពាន់នាក់ត្រូវបានសម្លាប់ ប៉ុន្តែកងទ័ពរបស់ អ៊ីប្រាហ៊ីម បានចាប់បាននាវាហូឡង់ចំនួនពីរ ដែលសម្ព័ន្ធ_មិត្តម៉ាឡេរបស់ទ្រង់ ព្រមទាំងជនជាតិព័រទុយហ្គាល់ និងជប៉ុន បានជិះនាវាប្រយុទ្ធឲ្យទ្រង់[24]។

ប៉ុន្តែ អ៊ីប្រាហ៊ីម បានបង្កសត្រូវរបស់ខ្មែរ ដែលនៅទីបំផុតបានផ្តួលរំលំទ្រង់ដោយមានជំនួយពីវៀតណាម។ ស្តេចមូស្លីមតែមួយអង្គរបស់កម្ពុជាគឺ អ៊ីប្រាហ៊ីម ត្រូវបានចាប់ខ្លួន និងបានសុគត់នៅទីក្រុងវេ ក្នុងឆ្នាំ ១៦៥០។ ៩ ឆ្នាំក្រោយមក អតីតអ្នកគាំទ្ររបស់ទ្រង់បានបះបោរ ប៉ុន្តែត្រូវបានកម្ចាត់ ហើយ ២.០០០-៣.០០០ នាក់ក្នុងចំណោមពួកគេ រួមបញ្ចូលទាំងជនជាតិចាមជាង ៧០០ នាក់ បានភៀសខ្លួនចូលទៅក្នុងប្រទេសថៃ។ ទោះយ៉ាងណា ឥទ្ធិពលចាមនៅព្រះរាជវាំងខ្មែរបានបន្តរហូតដល់មានអាណាព្យាបាលបារាំងនៅឆ្នាំ ១៨៦៣[25]។

ខណៈពេលនោះ នៅប្រទេសចម្ប៉ាជិតខាង "ស្ទើរតែទាំងអស់" នៃប្រជាជនត្រូវបានគេនិយាយថាជាម៉ូស្លីមនៅឆ្នាំ ១៦៧៥។ នៅឆ្នាំបន្ទាប់ ស្តេចចាមព្រះនាម ពោធិ៍សូត គឺជាមូស្លីមផងដែរ ប៉ុន្តែ គេមិនច្បាស់ទេថានៅពេលណាដែលទ្រង់បានប្រែក្លាយទៅជាមូស្លីមនោះ[26]។ លោក Pierre-Yves Manguin រៀបរាប់អំពីឥស្លាមនីយកម្មលើប្រទេសចម្ប៉ាថាជាដំណើរការមួយដែលក្នុងនោះ "អ្នកជំនួញនៃទីក្រុងកំពង់ផែមួយត្រូវប្រែក្លាយឲ្យទៅជាឥស្លាម និងបាននាំមកជាមួយនូវអធិបតេយ្យភាព ដែលភាគច្រើនពឹងផ្អែកលើវា។ នៅឆ្នាំ ១៦០៧ នាវាហូឡង់មួយបានជួបជាមួយមន្ត្រីជាន់ខ្ពស់ចាមមូស្លីម (*orang kaya*) ដែលបានរាយការណ៍ថា ទោះបីជាស្តេច ពោធិ៍ និត មិនមែនជាមូស្លីមក្តី ក៏ព្រះអនុជរបស់ទ្រង់ ដែលព្រះអង្គម្ចាស់នឹងត្រូវឡើងសោយរាជ្យ "ប្រាថ្នាចង់កាន់សាសនារបស់ Moors ប៉ុន្តែ ទ្រង់មិនហ៊ាន ដោយសារតែព្រះរាមរបស់ទ្រង់"។ ដំណាក់កាលដ៏សំខាន់

---

[24] Buch, "ក្រុមហ៊ុនឥណ្ឌា" ទំព័រ ២១៩-២១។

[25] Marcel Ner, "ជនមូស្លីមនៅឥណ្ឌូចិនក្រោមការគ្រប់គ្រងរបស់បារាំង" *BEFEO* XLI, ២ (ឆ្នាំ ១៩៤១) ទំព័រ ១៥១-២០១ នៅទំព័រ ១៦៩, ១៩៦។

[26] Manguin, "ការចូលមកដល់នៃសាសនាអ៊ីស្លាម" ទំព័រ ២៧១។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

បានមកដល់ ប៉ុន្តែនគរហិណ្ឌូមិនត្រូវបានកែប្រែយ៉ាងឆាប់រហ័សទេ។ នៅឆ្នាំ ១៦៤៤ ស្តេចចាមព្រះនាម ពោធិ៍រ៉ាមោ (ប្រហែលឆ្នាំ ១៦២៧-៥១) បានប្រាប់ភ្ញៀវទេសចរជនជាតិហូឡង់ថា ស្តេចមូស្លីមខ្មែរព្រះនាម អ៊ីប្រាហ៊ីម បានប្រព្រឹត្តក្បត់ដើម្បីទទួលបានអំណាច ហើយថាសម្ព័ន្ធភាពរវាងនគរទាំងពីរឥឡូវនេះ បានបាក់បែកហើយ។ បើតាមប្រពៃណីចាម ពោធិ៍រ៉ាមោ បានបញ្ចប់ដំណាក់កាលនៃការឈ្លោះប្រកែករវាងហិណ្ឌូ និងចាមមូស្លីម និងបញ្ចុះបញ្ចូលឲ្យមានការចូលរួមក្នុងពិធីគ្នាទៅវិញទៅមក។ ពោធិ៍រ៉ាមោ គឺជាហិណ្ឌូ ប៉ុន្តែមហេសីរបស់ទ្រង់ជាមូស្លីម។ អ្នកស្នងតំណែងរបស់ទ្រង់គឺ ពោធិ៍នរោត្ត មានមហេសីពីរនាក់ ម្នាក់ជាហិណ្ឌូ និងម្នាក់ទៀតជាមូស្លីម។ ទោះយ៉ាងណា អ្នកស្នងតំណែងរបស់ ពោធិ៍នរោត្ត គឺ ពោធិ៍សូត (ប្រហែលឆ្នាំ ១៦៦០-៩២) មើលទៅគឺស្តេចទីមួយដែលកាន់សាសនាឥស្លាម។

> **បន្ទាប់ពីបានឯករាជ្យនៅឆ្នាំ ១៩៥៤ ប្រជាជនចាមត្រូវបានផ្តល់នូវឋានៈថ្មីមួយ ដែលមិនត្រឹមត្រូវដូចគ្នា៖ របប សីហនុ បានហៅពួកគេជាផ្លូវការថាជា "ខ្មែរឥស្លាម"។ ថ្មីម្តងទៀត ដើមកំណើតជាតិពន្ធុរបស់ពួកគេត្រូវបានបដិសេធ។ ក្នុងន័យទូលាយ ប្រជាជនចាមបានក្លាយជាជនរងគ្រោះនៃប្រវត្តិសាស្ត្រ។**

គេមិនច្បាស់ទេថា ស្តេចចាមក្រោយៗមកជាមូស្លីមដែរឬយ៉ាងណា ប៉ុន្តែ ទំនងជាដូច្នោះ។ ទីសក្ការៈចាមចុងក្រោយបានបង្ហាញ "ឆន្ទៈយ៉ាងមុតមាំក្នុងការលុបចោលរូបមនុស្ស" ដែលដូចគ្នាជាខ្លាំងទៅនឹងប្រពៃណីឥស្លាម។ ភ្ញៀវទេសចរបារាំងនៅឆ្នាំ ១៧២០ បានរកឃើញថា សាសនាឥស្លាមគឺជា "សាសនាលេចធ្លោមួយ" នៅក្នុងប្រទេសចម្ប៉ា ប៉ុន្តែថា "សរណវត្ថុបូជានៅតែមាននៅទីនោះផងដែរ"[27]។ មកទល់ឆ្នាំ ១៩៤០ ក្នុងចំណោមប្រជាជនចាម ១៥.០០០ នាក់ដែលនៅតែរស់នៅវៀតណាមភាគខាងត្បូង មានចំនួន៦.០០០ នាក់ជាម៉ូស្លីម។ ពួកគេបានរស់នៅក្នុងភូមិចាម ដែលនៅជិតសមុទ្រ និងនៅជិតរាជធានីចាមចាស់នៅផានរ៉ាង។ សម្រាប់ពួកគេ ទេវធីតាលើផែនដីក្នុងស្រុកគឺ ពោធិ៍ឥន្ទ្រនាគា លែងជាមហេសីរបស់ព្រះសិវៈគឺ អុម៉ា ទៀតហើយ ប៉ុន្តែឥឡូវនេះ ទ្រង់ត្រូវបានគេកំណត់ថាជា ពោធិ៍ហាវៈ ឬនាងអេវ៉ា ជាប្រពន្ធរបស់ព្យាការីមូស្លីម ពោធិ៍អាដាម[28]។

---

[27] ដូចឯកសារខាងលើ ទំព័រ ២៧០-៧៧។

[28] Ner, "ជនមូស្លីម" ទំព័រ ១៥៤; A. Cabaton, "ឥណ្ឌូចិន" *សព្វវចនាធិប្បាយនៃសាសនាអ៊ីស្លាម* (,ឡេដិន៖ Bril ឆ្នាំ ១៩៧១) វ៉ុល III ទំព័រ ១២០៨-១២ នៅទំព័រ ១២១០។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

លោក Manguin រៀបរាប់អំពី “ការបាត់ខ្លួន” របស់ចម្ប៉ាបន្ទាប់ពីឆ្នាំ ១៤៧១ ថាជាទេវកថាមួយ។ ក្នុងឆ្នាំ ១៥៩៤ ជនជាតិចាមនៅតែខ្លាំងគ្រប់គ្រាន់ដើម្បីជួយដល់រដ្ឋម៉ាឡេនៅ Johor ទប់ទល់នឹងការវាយប្រហាររបស់ពួកព័រទុយហ្គាល់ ហើយឈ្មួញចាម “បានបន្តចេញចូលញឹកញាប់នៅកំពង់ផែនៃតំបន់អាស៊ីអាគ្នេយ៍ពេញមួយសតវត្សរ៍ទី ១៧”[29]។ ដូចដែលយើងបានឃើញ ជីវិតវប្បធម៌របស់ចម្ប៉ាបានបន្តអភិវឌ្ឍដោយស្វ័យត ហើយសឹងតែមានទឹកដីចាមដាច់ដោយឡែក ដែលមិនត្រូវបានកាន់កាប់ដោយផ្ទាល់រហូតដល់ឆ្នាំ ១៨៣៤-៣៦ ឬតាមដំណើររឿងមួយ រហូតដល់ចុងឆ្នាំ ១៨៨៣ ក្នុងអំឡុងពេលនៃការដំណើរកាន់កាប់របស់បារាំង[30]។ នៅឆ្នាំ ១៦៩១-៩៧ វៀតណាមបានកាន់កាប់លើក្រុងកំពង់ផែរបស់ចាមចុងក្រោយ ក្នុងនោះរួមទាំង ផានរ៉ាង ប៉ុន្តែសូម្បីតែបន្ទាប់ពីនោះមកក្តី ក៏ចម្ប៉ាបានបន្តមានអត្ថិភាពអស់រយៈពេលជិតពីរសតវត្សរ៍ទៀត។

ពួកវៀតណាមបានកាន់កាប់ផានរ៉ាង នៅឆ្នាំ ១៦៩៣ ដែលធ្វើឱ្យជនភៀសខ្លួនចាមជាង ៥.០០០ នាក់ (រួមទាំងភាគច្រើននៃរាជវង្សចាម) ផ្លាស់ទីចូលទៅក្នុងប្រទេសកម្ពុជា។ ពួកគេបានតាំងទីលំនៅនៅជិតលង្វែក[31] ហើយកូនចៅរបស់ពួកគេនាពេលនោះបង្កើតបានជាសហគមន៍ដោយឡែកនៃប្រជាជនចាមដែលនៅតែប្រើអក្ខរក្រមចាម និងប្រតិបត្តិទម្រង់ហិណ្ឌូនៃសាសនាឥស្លាម[32]។ ប៉ុន្តែ ប្រហែលជាការធ្វើចំណាកស្រុករបស់ចាមធំជាងគេមកកម្ពុជាបានកើតឡើងនៅចុងទសវត្សរ៍ឆ្នាំ ១៧៩០ ពេលដែលស្តេច ពោធិ៍កាស៊ីប្រី បានដឹកនាំអ្នកដើរតាមទ្រង់នៅទីនោះមុនពេលការបរាជ័យនៃបដិវត្តន៍តៃស៊ឺនក្នុងប្រទេសវៀតណាម[33]។ ពួកគេជាក់ស្តែងបានសាងសង់វិហារឥស្លាមចាស់ជាងគេនៅប្រទេសកម្ពុជាគឺ វិហារឥស្លាម Noor Alihsan ដែលត្រូវបានកសាងឡើងនៅច្រាំងចំរេះ នៅចម្ងាយប្រាំពីរគីឡូម៉ែត្រភាគខាងជើងនៃរាជធានីភ្នំពេញ ក្នុងឆ្នាំ ១៨៣១។ ទោះយ៉ាងណា ប្រជាជនចាមមិនត្រូវបានធ្វើសមាហរណកម្មលឿនទៅក្នុងសង្គមកម្ពុជាទេ។ នៅ_ពេលដែលកង

---

[29] Manguin, “ការចូលមកដល់នៃសាសនាអ៊ីស្លាម” ទំព័រ ២៧៦-៧៨។

[30] ពោធិ៍ ធម្មា, “ស្តីពីការនិរទេស” ទំព័រ ២៥៤, លេខ ៥; និង M.A. Jaspan, “ការវិវឌ្ឍន៍ថ្មីក្នុងចំណោមជនជាតិចាមនៅតំបន់ឥណ្ឌូចិន៖ ការរស់ឡើងវិញរបស់ចម្ប៉ា” *កិច្ចការអាស៊ី* (ឡុងដ៍) វ៉ុល I (ឆ្នាំ ១៩៧០) ទំព័រ ១៧០-៧៦ នៅទំព័រ ១៧១។

[31] D. G.E. Hall, *ប្រវត្តិសាស្ត្រនៃតំបន់អាស៊ីអាគ្នេយ៍* (ឡុងដ៍ ឆ្នាំ ១៩៨៥) ទំព័រ ៤៦២។

[32] Juliette Baccot (Françoise Corrèze), *On G'nur និង Cay នៅអូឫស្សី៖ ការសំយោគសាសនាក្នុងភូមិចាមមួយនៃប្រទេសកម្ពុជា* (ប៉ារីស៖ មហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ឆ្នាំ ១៩៦៨) ទំព័រ ៤០៩។

[33] Jean Delvert, *កសិករកម្ពុជា* (ប៉ារីស៖ Mouton ឆ្នាំ ១៩៦០) ទំព័រ ២២។ សូមមើលផងដែរ ពោធិ៍ ធម្មា, “ស្តីពីការនិរទេស” ទំព័រ ២៥៣-៦៦។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

កម្លាំងវៀតណាមបានចូលលុកលុយប្រទេសកម្ពុជាក្នុងទសវត្សរ៍ឆ្នាំ ១៨៣០ "គេអាចរើសបានតែទាហានស៊ីឈ្នួលចាមប៉ុណ្ណោះ"[34]។ នៅឆ្នាំ ១៨៥៨ ជាថ្មីម្ដងទៀត អ្នកស្រុកជនជាតិមូស្លីមបានបះបោរ ប្រឆាំងនឹងអាជ្ញាធរខ្មែរនៅភាគខាងកើតនៃខេត្តត្បូងឃ្មុំ។ ពួកគេត្រូវបានកម្ចាត់ដោយស្ដេចអង្គដួង "នៅក្នុងខ្សែប្រយុទ្ធស៊ីសាច់ហុតឈាម" នៅលើទន្លេមេគង្គ។ ភាគច្រើននៃប្រជាជនចាម និងប្រជាជនម៉ាឡេនៅត្បូងឃ្មុំត្រូវចាប់ខ្លួន និងដឹក "ទៅបណ្ដាខេត្តភាគខាងលិច"[35]។ ប៉ុន្តែបន្ទាប់ពីការបង្កើតអាណាព្យាបាលបារាំងនៅកម្ពុជា ការបះបោរប្រឆាំងនឹងបារាំងនៅឆ្នាំ ១៨៦៥-៦៧ បានទាក់ទាញការគាំទ្រពីប្រជាជនចាម ព្រមទាំងប្រជាជនខ្មែរ និងប្រជាជនវៀតណាម[36]។

នៅឆ្នាំ ១៨៧៤ បារាំងបានធ្វើជំរឿនប្រជាជនលើកដំបូងលើដែនដីអាណាព្យាបាលរបស់ពួកគេ និងបានរាប់ឃើញប្រជាជនចាមចំនួន ២៥.៥៩៩ នាក់ ត្រូវជា ៣ ភាគរយនៃប្រជាជនក្នុងប្រទេសកម្ពុជា[37]។ នៅក្នុងឆ្នាំ ១៩៣៦ ចំនួនប្រជាជនចាមនៅកម្ពុជាត្រូវបានគេប៉ាន់ប្រមាណថាមានចំនួន ៨៨.០០០ នាក់ ហើយមកដល់ឆ្នាំ ១៩៧៥ គឺមានចំនួន ២៥០.០០០ នាក់។ មកដល់ឆ្នាំ ១៩៧៩ បើតាមធម្មតាចំនួនរបស់ពួកគេគួរតែឈានដល់យ៉ាងហោចណាស់ ២៦០.០០០ នាក់[38]។

---

[34] David P. Chandler, *ប្រវត្តិសាស្ត្រកម្ពុជា* ទំព័រ ២១៦។

[35] L. Loubet, *ឯកលេខនានៃខេត្តកំពង់ចាម* (ប៉ារីស៖ A. Portail, ឆ្នាំ ១៩៣៩) ទំព័រ ១២។

[36] Jean Moura, នគរកម្ពុជា (ប៉ារីស៖ E. Leroux, ឆ្នាំ ១៨៨៣) ទំព័រ ១៦៣។

[37] Delvert, *កសិករកម្ពុជា* ទំព័រ ២២។ ចំពោះតួលេខជំរឿនផ្លូវការ សូមមើល Poree, Guy និង Maspero, Eveline, *ជីវិតសង្គម និងទំនៀមទម្លាប់ខ្មែរ* (ប៉ារីស៖ Payot, ឆ្នាំ ១៩៣៨) បកប្រែពីភាសាបារាំងដោយ Keith Botsford (ឯកសារតំបន់ស្ដីពីទំនាក់ទំនងមនុស្ស ឆ្នាំ ១៩៥២) ទំព័រ ១២។

[38] ការប៉ាន់ប្រមាណពីរចុងក្រោយបានផ្អែកលើតួលេខជំរឿនឆ្នាំ ១៩៣៦ ថាមាន ៧៣.០០០ នាក់ លៃតម្រូវសម្រាប់កំហុសទៅ ៨៨.០០០ នាក់។ (សូមមើល Ner, "ជនមូស្លីម" ទំព័រ ១៨០។ គ្មានការប៉ាន់ប្រមាណជាបន្តបន្ទាប់ដែលត្រឹមត្រូវ ដោយសារជនជាតិចាមមិនត្រូវញែកចេញពីជនជាតិខ្មែរទេក្នុងជំរឿនឆ្នាំ ១៩៦២។ J. Migozzi, ក្នុង *កម្ពុជា៖ ការពិត និងបញ្ហានៃចំនួនប្រជាជន* [ប៉ារីស ៖ CNRS, ឆ្នាំ ១៩៧៣] ផ្ដល់នូវតួលេខ ១៥០.០០០ នាក់សម្រាប់ឆ្នាំ ១៩៦៨ ប៉ុន្តែមិនបានផ្ដល់ប្រភពនៃតួលេខនេះទេ)។ ការប៉ាន់ប្រមាណឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ សន្មតយកអត្រាកំណើនពីឆ្នាំ ១៩៣៦-៧៥ ក្នុងអត្រា ២,៧ ភាគរយក្នុងមួយឆ្នាំ ជាអត្រាមធ្យមដែលបានស្នើដោយការស្រាវជ្រាវរបស់ J. Migozzi, ទំព័រ ២០៧-១២, ២២៦, កែសម្រួលសម្រាប់រយៈពេលដំបូងដោយការស្រាវជ្រាវថ្មីៗរបស់លោក Marcel Ner, "ជនមូស្លីម" ទំព័រ ១៧៩-៨០ ប៉ុន្តែត្រឹម ១ ភាគរយនៅក្នុងឆ្នាំ ១៩៧៥-៧៨)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ប្រជាជនចាមនៅកម្ពុជាតែងតែប្រមូលផ្ដុំគ្នានៅក្នុងភូមិជាង ៧០ នៅតាមដងទន្លេ ឬច្រាំងទន្លេមេគង្គ និងទន្លេសាបក្នុងខេត្តកំពង់ចាមនៅភាគខាងកើត និងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់នៅភាគខាងលិច[39]។ ពួកគេភាគច្រើនជាអ្នកនេសាទ ដែលធ្វើការនេសាទជាលក្ខណៈគ្រួសារខ្នាតតូចតាមទន្លេ។

*[រូបភាព]*

*រូបថតដោយ Ben Kierman*

*ថាបចាមនៅផានរ៉ាង នៅវៀតណាមខាងត្បូង ឆ្នាំ ១៩៧៥*

ប្រជាជនមូស្លីមបានប្រមូលផ្ដុំគ្នា ស្ទើរតែក្លាយជាក្រុមភាគច្រើន នៅក្នុងស្រុកតែមួយគត់នៃប្រទេសកម្ពុជា នោះគឺស្រុកក្រូចឆ្មារ នៅភាគខាងជើងខេត្តកំពង់ចាម។ ពួកគេបានរស់នៅជាមួយគ្នាតាមភូមិធំៗ ដោយសងផ្ទះជាប់ៗគ្នា។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ ប្រជាជនចាមនៅទីនោះមានចំនួនច្រើនជាង ២០.០០០នាក់នៅក្នុង "សហគមន៍ដ៏ធំ"។ លោក Jean Delvert បានសរសេរពីប្រជាជនទាំងនេះថា៖ "ជនជាតិចាមជាអ្នកចម្ការ (ថ្នាំជក់ ពោត) និងធ្វើស្រែប្រាំង។ ពួកគេនេសាទជាលក្ខណៈគ្រួសារដោយប្រើឈ្នក់ និងផ្នង។ ឬពួកគេជាអ្នកកាប់សត្វលក់ និងអ្នកប្រមាញ់។ គ្រួសាររបស់ពួកគេត្បាញកប្បាស និងសូត្រ ..."[40]។

***គ្មានប្រជាជនចាមណាម្នាក់ត្រូវគេដាក់នៅក្នុងក្រុមទីបី ដែលជាក្រុម "ពេញសិទ្ធិ" ដែលគេអនុគ្រោះឱ្យច្រើនបំផុតនោះទេ។ ហេតុនេះហើយបានជាប្រជាជនចាម ក៏ដូចជាជនដែលគេជម្លៀសពីទីក្រុងដែរ ត្រូវបានច្រានចោលត្រង់ៗមិនឱ្យមានសិទ្ធិសេរីភាពឡើយ។ ទន្ទឹមនឹងនេះដែរ ខ្មែរដែលមិនមែនជាមូស្លីមត្រូវបាននាំទៅរស់នៅក្នុងភូមិចាមដែលត្រូវរងការជម្លៀសនៅឃុំបឹង។***

[39] Delvert, *កសិករកម្ពុជា* ទំព័រ ២២-២៣។ (នៅឆ្នាំ ១៩៧៥ មានភូមិមូស្លីមចំនួន ១១៨ ភូមិ (ដែលមានវិហារអ៊ីស្លាម) នៅក្នុងប្រទេសកម្ពុជា។ ក្នុងនោះរួមទាំងភូមិ "ម៉ាឡេ" ៣៥ ភូមិនៅខេត្តកំពត។ បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយមេដឹកនាំចាមនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា៖ ទេព អ៊ីប្រាហ៊ីម ច្រាំងចំរេះ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៨៦ និង ម៉ាត់ លី នៅទីក្រុងភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៨៦)។ សូមមើលទំព័រ ១១ នៃលេខនេះសម្រាប់ផែនទីប្រទេសកម្ពុជា។

[40] ដូចឯកសារខាងលើ ទំព័រ ៦០៥, ៦១០-១១។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ប្រជាជនចាមផ្សេងទៀតគឺពាណិជ្ជករលក់សត្វផ្តាច់មុខនៅតំបន់ទីក្រុងភ្នំពេញ ក្នុងនោះរួមមានការធ្វើពាណិជ្ជកម្មនាំចេញផងដែរ។ ទោះយ៉ាងណា ការផ្តាច់មុខបែបនេះបណ្តាលឱ្យមានភាពតានតឹងក្នុងសង្គមតិចតួចប៉ុណ្ណោះ។ ពុទ្ធសាសនិកខ្មែរជាញឹកញាប់បានពេញចិត្តក្នុងការលក់សត្វទៅឱ្យប្រជាជនចាម។ ដូចដែលអ្នកនិពន្ធបារាំងបានអធិប្បាយថា កសិករខ្មែរ "ជឿថា គាត់មិនត្រូវរំលោភសិក្ខាបទនៃសាសនារបស់គាត់ដែលហាម_គាត់មិនឱ្យសម្លាប់សត្វរបស់ខ្លួនដើម្បីហូបខ្លួនឯងទេ"។ អ្នកនិពន្ធដដែលបានចង្អុលបង្ហាញថា ហានិភ័យដែលបង្កឡើងដោយការដកចេញនូវភាពផ្តាច់មុខរបស់ប្រជាជនចាម ដែលជា "អន្តរការីដែលប្រហែលជាមិនគួរឱ្យចូលចិត្ត តែពិតជាមានប្រយោជន៍" រវាងកសិករ និងបរិភោគសាច់គោ[41]។

ជនមូស្លីមនៅកម្ពុជាទាំងអស់ជានិកាយស៊ុននីចាស់នៃក្រុម Shafi'i នៃច្បាប់សាសនាឥស្លាម។ ពួកគេត្រូវបានរៀបរាប់ថាជាអ្នកជឿស៊ុប[42]។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ក្នុងខេត្តកំពង់ចាម មានវិហារឥស្លាម ៤០ សម្រាប់ប្រជាជនម៉ូស្លីមជាង ៣៣.០០០ នាក់[43]។ មកទល់ឆ្នាំ ១៩៤០ មានហាតជី ឬជនជាតិចាមដែលបានធ្វើធម្មយាត្រាទៅកាន់ក្រុង Mecca ជាង ៥០០ នាក់នៅកម្ពុជា[44]។ មកទល់ទសវត្សរ៍ឆ្នាំ ១៩៧០ មានប្រជាជនចាមជាង ៨០ នាក់ បានធ្វើដំណើរទៅទីនោះតាមជើងហោះហើរជាលក្ខណៈជួលប្រចាំឆ្នាំពីក្រុមហ៊ុនអាកាសចរណ៍ឆេកូស្លូវ៉ាគី[45]។ មានហាតជី ប្រហែលជាង ១.០០០ នាក់ នៅកម្ពុជាមកទល់ឆ្នាំ ១៩៧៥។ ប្រជាជនចាម ២៥ នាក់ក៏បានបញ្ចប់ការសិក្សាពីមជ្ឈមណ្ឌល រៀនសូត្រពីសាសនាឥស្លាមលំដាប់ពិភពលោកនានា ក្នុងនោះមានទាំង ៩ នាក់ដែលបានបញ្ចប់ការសិក្សារយៈពេល ៦ ទៅ ៧ ឆ្នាំនៅសាកលវិទ្យាល័យ Al-Azhar របស់ប្រទេសអេហ្ស៊ីប ក្នុងទីក្រុងគែរ។ មាននិស្សិតម្នាក់សម្រេចចិត្តបន្តរស់នៅក្នុងទីក្រុងគែរ ដើម្បីក្លាយ_ជាអ្នកស្រាវជ្រាវខាងឥស្លាមសាសនា[46]។ នៅឆ្នាំ ១៩៤០ លោក Marcel Ner បានកត់សម្គាល់ឃើញថា បុរស_ម្នាក់ក្នុងចំណោមបុរសជនជាតិចាម ៥០ នាក់នៅកម្ពុជាធ្លាប់បានទៅទីក្រុង Mecca។

---

[41] R. Jauffret, "លទ្ធភាពនៃការកើនឡើងសត្វគោ និងក្របីតាមបណ្តាខេត្តដែលជាប់ចំណាត់ថ្នាក់លើគេខាងការចិញ្ចឹមសត្វនៅប្រទេសកម្ពុជា (កណ្តាល-កំពង់ស្ពឺ-កំពង់ឆ្នាំង)" *ព្រឹត្តិបត្រសេដ្ឋកិច្ចនៅឥណ្ឌូចិន* (ខែ វិច្ឆិកា ឆ្នាំ ១៩៣៩) ទំព័រ ១០០៧-៣៥ នៅទំព័រ ១០១៦។

[42] Delvert, *កសិករកម្ពុជា* ទំព័រ ២៣។

[43] Loubet, *ឯកលេខនា* ទំព័រ ៦១, ២០៨។

[44] Delvert, *កសិករកម្ពុជា* ទំព័រ ២៣។

[45] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយជនជាតិចាមនៅច្រាំងចំរេះ ថ្ងៃទី ១៥ ខែ កញ្ញា ១៩៨០។

[46] ដូចឯកសារខាងលើ និងបទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ទូន អ៊ីប្រាហ៊ីម នៅទីក្រុងភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៨០។

Deleted: ណិជ្ជ

Deleted: *Unrevised translation. A revised translation will be provided upon request.*

ទោះយ៉ាងណា រឿងនេះមិនសូវត្រូវបានកោតសរសើរទេដោយប្រជាជនខ្មែរដែលជាក្រុមភាគច្រើន កាន់ពុទ្ធសាសនារបស់ខ្លួនដែលបានខណ្ឌចែកចេញពីប្រជាជនចាម។ សូម្បីតែទិដ្ឋភាពសហជីវិតមួយចំនួននៃទំនាក់ទំនងខ្មែរចាមក៏មានមូលដ្ឋានលើភាពចម្លែកផងដែរ។ លោក Michael Vickery បានសង្ខេបរឿងនេះដូចតទៅ៖

> ប្រជាជនចាមជាច្រើនបានអះអាងថា មុនពេលសង្គ្រាម ពួកគេត្រូវបានប្រជាជនខ្មែរមើលងាយ និងរើសអើង ហើយអារម្មណ៍អាក្រក់រវាងក្រុមទាំងពីរក្នុងសង្គមកម្ពុជាពិតជាបានកើតមាននៅក្នុងតំបន់មួយចំនួន។ ប្រជាជនខ្មែរជាច្រើនសម្លឹងទៅប្រជាជនចាមដោយមានល្បាយនៃការកោតសរសើរ និងការភ័យខ្លាច។ ពួកគេត្រូវបានជឿថាចេះមន្តអាគម (អំពើ) ហើយស្ត្រីនៅទីក្រុងភ្នំពេញធ្លាប់ឆ្លងទៅជ្រោយចង្វារ ដែលជាសហគមន៍ចាមនៅលើជ្រោយដែលទន្លេមេគង្គ និងទន្លេសាបប្រសព្វគ្នា ដើម្បីទាយពីអនាគត សូមទឹកមន្តស្នេហ៍សម្រាប់ដាក់ឲ្យប្តី ឬមនុស្សជាទីស្រឡាញ់ ដាក់អំពើលើសត្រូវ[47]។

នៅតំបន់ជនបទជាច្រើន ទំនាក់ទំនងខ្មែរចាមគឺជិតស្និទ្ធជាងនៅតំបន់ទីក្រុង។ នៅជិតអតីតរាជធានីរាជវង្សខ្មែរនៅឧដុង្គ មានភូមិចាមចំនួនពីរ ក្នុងនោះនៅក្នុងភូមិមួយ ភាសាប្រចាំថ្ងៃគឺភាសាខ្មែរ។ នៅក្នុងភូមិទាំងពីរនេះ ដូចដែលលោក Marcel Ner បានកត់ត្រាទុកក្នុងឆ្នាំ ១៩៤០ អាពាហ៍ពិពាហ៍លាយបញ្ចូលគ្នានៃប្រជាជនចាមជាមួយប្រជាជនខ្មែរ វៀតណាម ឬចិន គឺមាន "ច្រើនណាស់ (ប្រហែល ១០%)" ហើយតែងតែនាំឲ្យមានការផ្លាស់ប្រែជំនឿរបស់ដៃគូមកកាន់សាសនាឥស្លាម។ ដូចគ្នានេះដែរ នៅខេត្តកំពត ជាងពាក់កណ្តាលនៃប្រជាជនម៉ូស្លីមបានបោះបង់ភាសាដើមរបស់ពួកគេ មកប្រើភាសាខ្មែរវិញ ហើយអ្នកដែលនៅសល់ក៏អាចនិយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញផងដែរ។ លោក Ner បានអធិប្បាយថា ប្រជាជនចាម និងខ្មែរនៅក្នុងខេត្តកំពតបានផ្សារភ្ជាប់គ្នាដោយ "ភាសា របៀបរស់នៅ អត្ថិភាពរួមគ្នាជាយូរអង្វែង និងការយល់ពីគ្នាបានយ៉ាងល្អ" ហើយ "ត្រឹមតែញែកពីគ្នាដោយសាសនាតែប៉ុណ្ណោះ"។ តាមពិតទៅ លោក Ner បានចាត់ទុកទំនាក់ទំនងខ្មែរចាមជាទូទៅថាជាសហជីវិតដ៏សប្បាយរីករាយមួយ។ "ប្រជាជនខ្មែរចុះសម្រុងយ៉ាងល្អជាមួយពួកគេ។ ពួកគេមានអារម្មណ៍ថា ពួកគេបាននាំធាតុមួយនៃសកម្មភាពដែលប្រទេសនេះត្រូវការ ហើយខ្ញុំមិនដែលបានឮការបញ្ចេញមតិពីការភ័យខ្លាច ឬការទើសទល់ចិត្តដែល ពួកគេជាញឹកញាប់បង្ហាញអំពីក្រុមផ្សេងទៀតទេ"[48]។

នៅក្នុងការសិក្សាដ៏ហ្មត់ចត់របស់គាត់អំពីប្រជាជនចាម លោក Ner បានលើកពីចំណុចសំខាន់មួយទៀត។ លោកបានច្រានចោលនូវការទទួលយកទស្សនៈដែលថា ប្រជាជនចាមគឺជា "សំណល់ជាតិពន្ធុដែលកំពុង

---

[47] Michael Vickery, *ប្រទេសកម្ពុជា* ឆ្នាំ ១៩៧៥-១៩៨២ ទំព័រ ១៨១។

[48] Ner, "ជនមូស្លីម" ទំព័រ ១៦៩, ១៧៥, ១៩២, ១៩៤-៩៥។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ឈានទៅរកការបាត់ខ្លួន” ដែលគ្រាន់តែជាទីចាប់អារម្មណ៍របស់អ្នកស្រាវជ្រាវតែប៉ុណ្ណោះ។ លោក Ner បានបង្ហាញពីរបៀបដែលប្រជាជនចាម “បានកើនចំនួនយ៉ាងឆាប់រហ័ស” ហើយនឹងកាន់តែកើនឡើង លឿនជាងមុនទៀត បើអត្រាស្លាប់របស់ទារកដ៏ខ្ពស់របស់ពួកគេត្រូវបានកាត់បន្ថយដោយថ្នាំរបស់លោកខាងលិច។ គាត់បានបង្ហាញថា តួលេខជាផ្លូវការបានវាយតម្លៃទាបពីចំនួនរបស់ពួកគេដល់ទៅ ២០ ភាគរយ។ គាត់បាន_និយាយថា ប្រជាជនចាម “កើនឡើងយ៉ាងខ្លាំង ... ដែលគួរឲ្យកត់សម្គាល់ផងដែរសម្រាប់ភាពរឹងមាំ ភាពជិត_ស្និទ្ធ និងថាមពលរបស់ពួកគេ”[49]។

សូមកត់ចំណាំនូវពាក្យរបស់អ្នកស្រាវជ្រាវជនជាតិអង់គ្លេសម្នាក់ ដែលបានសរសេរបន្តិចក្រោយមកនៅឆ្នាំ ១៩៥០៖ “ឥឡូវនេះ ប្រជាជនចាមគ្រាន់តែជាអ្នកសំណល់ដែលធ្លាក់ចុះ ... ជាពូជសាសន៍ដែលកំពុងបាត់ខ្លួន”។ អ្នកនិពន្ធដដែលនេះ ភ្លាមៗបានបង្ហាញពីភាពផ្ទុយគ្នានៃស្ថានភាពបច្ចុប្បន្នរបស់ពួកគេទៅនឹងប្រវត្តិសាស្ត្រដ៏រុងរឿងមួយ៖ “ប៉ុន្តែការវិនាសនៃអរិយធម៌របស់ពួកគេ នៅក្នុងទម្រង់ដ៏ទូលំទូលាយដែលនៅសេសសល់នៅភាគខាងត្បូងឥណ្ឌូចិន គឺរឹមានដែលបង្ហាញពីភាពអស្ចារ្យរបស់ពួកគេកាលពីអតីតកាល ...។ ប្រជាជនចាម ... ធ្លាប់ជាប្រជាជាតិមួយដ៏អស្ចារ្យ ហើយអតីតកាលរបស់ពួកគេត្រូវបានជួយសង្គ្រោះពីការភ្លេចបាត់ដោយការងាររបស់បុរាណវិទូជាច្រើន និងប្រវត្តិវិទូនៅប៉ុន្មានឆ្នាំចុងក្រោយនេះ”[50]។

ទស្សនៈនេះគឺមានច្រើនណាស់។ លោក Antoine Cabaton បានអះអាងថា មានពេលមួយ “ប្រជាជនចាមជាប្រទេសមហាអំណាចមួយនៅឥណ្ឌូចិន” ប៉ុន្តែឥឡូវនេះ “មានតែវត្ថុបុរាណដ៏ឈឺចាប់មួយចំនួនរបស់ពូជសាសន៍នេះប៉ុណ្ណោះ” ដែលនៅសេសសល់។ គាត់បានត្អូញត្អែរពី “ការចុះអន់ថយដ៏កំសត់នៃពូជសាសន៍_ដែលធ្លាក់ចុះនេះ”[51]។ ថ្មីៗនេះ លោក Gérard Moussay បានថ្លែងដោយខុសឆ្គងថា មានតែនៅតំបន់ផានរ៉ាង_ទេ ដែលប្រជាជនចាមនៅតែប្រើអក្ខរក្រមសំស្ក្រឹតដើមរបស់ពួកគេ ដោយអះអាងថាវាគឺ “ពិតជាទ្រព្យសម្បត្តិ_តែមួយគត់ដែលប្រជាជនចាមបានរក្សាទុកពីអតីតកាលដ៏រុងរឿងរបស់ខ្លួន”[52]។ អតីតកាលដ៏រុងរឿងនេះ ដូចដែល

---

[49] ដូចឯកសារខាងលើ ទំព័រ ១៧៩-៨១។

[50] Marrison, “ចាម” ទំព័រ ៩០, ៩៨។

[51] Antoine Cabaton, “ចាម” *សព្វវចនាធិប្បាយនៃសាសនា និងជាតិពន្ធុ* ៣ (ឆ្នាំ ១៩១០) ទំព័រ ៣៤១-៤២។

[52] Moussay, “រឿងរ៉ាវ” ទំព័រ ១០។ ការយល់ច្រឡំស្រដៀងគ្នានៃប្រវត្តិសាស្ត្រកម្ពុជាដោយរបប ប៉ុល ពត ត្រូវបានពិភាក្សានៅក្នុង Ben Kiernan, “William Shawcross, ការធ្លាក់ចុះនៃប្រទេសកម្ពុជា” ព្រឹត្តិបត្ររបស់អ្នកស្រាវជ្រាវពាក់ព័ន្ធពីអាស៊ី វ៉ុល ១៨ លេខ ១ (ឆ្នាំ ១៩៨៦) ទំព័រ ៥៦-៦៣។ សូមមើលផងដែរ David P. Chandler, “មើលឃើញពណ៌ក្រហម៖ ទស្សនៈពីប្រវត្តិសាស្ត្រកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ” នៅក្នុង D.P. Chandler និង Ben Kiernan (eds.), បដិវត្តន៍ និងផលវិបាករបស់វាក្នុង

Deleted: *Unrevised translation. A revised translation will be provided upon request.*

បុរាណវិទ្យាបានជួយសង្គ្រោះវាពីដីឥដ្ឋ ត្រឹមតែបញ្ជាក់អនាគតដ៏វិនាសរបស់ពួកគេប៉ុណ្ណោះ។ "ប្រវត្តិសាស្ត្រ" បានចង្អុលដោយមិនអាចប្រឆាំងបានទៅកន្លែងបញ្ចុះសពរបស់ជាតិសាសន៍។

លោក O.W. Wolters បានបង្ហាញថា ឥណ្ឌានីយកម្មនៃនគរដើមនៅតំបន់អាស៊ីអាគ្នេយ៍ត្រូវបានគេយល់ខុសទ្វេដង។ ភាពអន់ថយនៃតំបន់អាស៊ីអាគ្នេយ៍មុនពេលមានឥណ្ឌានីយកម្មត្រូវបានគេបំផ្លើស ហើយមជ្ឈការនីយកម្ម និងអនុភាពនៃនគរឥណ្ឌានីយកម្មក៏ដូច្នេះដែរ[53]។ ដូចគ្នានេះដែរ ប្រជាជនចាមក្នុង សតវត្សរ៍ ទី ២០ បានរងគ្រោះពីរឿងមិនពិតដ៏ធំពីរ។ អំណាច និងភាពរុងរឿងនៃ "អាណាចក្រ" ចម្ប៉ាត្រូវបានគេ បំផ្លើស ហើយមានស្ថានភាពបច្ចុប្បន្នរបស់ពួកគេក៏ដូច្នេះដែរ។

ពិតណាស់ នេះមិនមែនជាអ្វីដែលចំឡែកនោះទេ។ ជនជាតិដើមតាស្មានីទទួលនូវ "បន្ទុកនៃប្រវត្តិសាស្ត្រ" ស្រដៀងគ្នានេះដែរ។ លោកស្រី Lyndall Ryan បានកត់សម្គាល់ឃើញពីរបៀបដែលលោក James Bonwick នៅក្នុង *ដំណាក់កាលចុងក្រោយនៃជនជាតិតាស្មានី* ក្នុងឆ្នាំ ១៨៧០ "សន្និដ្ឋានថា ជនជាតិដើមតាស្មានីជាវីរបុរសនៅសម័យបុរាណ ដែលនៅពេលត្រូវផ្តួលរំលំដោយទុច្ចរិត បានវិនាសបាត់បង់ទៅ"។ នាងបានបន្ថែមទៀតថា នៅក្នុងសតវត្សទី ២០៖ "ដោយសារតែវាត្រូវបានគេជឿជាសកលថា ពួកគេបានបាត់ខ្លួនពីប្រវត្តិសាស្ត្រ ទើបជនជាតិដើមតាស្មានីដែលរស់រានមានជីវិតត្រូវតស៊ូដើម្បីទទួលបានការទទួលស្គាល់ ... ពុំមាននរណាម្នាក់ជឿថាពួកគេមានអត្ថិភាពទេ ...។ ដើម្បីបង្ហាញពួកគេបានរស់រានមានជីវិត និងអាចទទួលបានការតបស្នងមួយចំនួនសម្រាប់ការខាតបង់ដីធ្លីគឺជារឿងបរាជ័យមួយ"[54]។

យើងនឹងមើលឃើញពីរបៀបដែលទស្សនៈស្រមើលស្រមៃបែបនេះ អំពីសេចក្តីវិនាសរបស់ប្រជាជនចាមជំរុញឲ្យពួកគេបាត់បង់សិទ្ធិនៅឆ្នាំ ១៩៧៥-៧៩។ សម្រាប់ភាគច្រើននៃសតវត្សរ៍ទី ២០ ប្រជាជនចាមនៅកម្ពុជាមិនត្រូវបានគេទទួលស្គាល់ថាមានអត្ថិភាពទេ (ហើយដូច្នេះ ដូចគ្នានឹងប្រជាជនតាស្មានីដែរ អត្ថិភាពរបស់ពួកគេត្រូវបានបដិសេធ)។ តាមពិតទៅ ពួកគេត្រូវបានអាណានិគមនិយមបារាំងហៅថា "ប្រជាជនម៉ាឡេ"។ លោក Ner បានថ្លែងបញ្ចប់ក្នុងការសិក្សារបស់គាត់ដោយប្រើប្រាស់ពាក្យទទូចសម្រាប់ប្រជាជនចាមថា ៖ "ពួកគេកាន់តែលែងត្រូវបានគេស្គាល់ ឬយល់។ វាទៅជាទម្លាប់ក្នុងការហៅពួកគេថា "ប្រជាជនម៉ាឡេ"

---

ប្រទេសកម្ពុជា៖ អត្ថបទចំនួនប្រាំបី សាកលវិទ្យាល័យយេល ការសិក្សាពីតំបន់អាស៊ីអាគ្នេយ៍ ឯកលេខនាលេខ ២៥ (New Haven, ឆ្នាំ ១៩៨៣) ទំព័រ ៣៤-៥៦។

[53] O.W. Wolters, *ប្រវត្តិសាស្ត្រ វប្បធម៌ និងតំបន់នៅក្នុងទស្សនៈរបស់តំបន់អាស៊ីអាគ្នេយ៍* (សិង្ហបុរី ឆ្នាំ ១៩៨២) ទំព័រ ១២-១៤។

[54] Lyndall Ryan, *ជនជាតិដើមតាស្មានី* (St. Lucia, ឆ្នាំ ១៩៨២) ទំព័រ ១-៣។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ហើយការស្រាវជ្រាវគួរឱ្យគោរពបំផុត និងថ្មីៗបានបង្កើតកំហុសដ៏គួរឱ្យឆ្ងល់បំផុតអំពីពួកគេ"[55]។ បន្ទាប់ពីបានឯករាជ្យនៅឆ្នាំ ១៩៥៤ ប្រជាជនចាមត្រូវបានផ្តល់នូវឋានៈថ្មីមួយ ដែលមិនត្រឹមត្រូវដូចគ្នា៖ របប សីហនុ បានហៅពួកគេជាផ្លូវការថាជា "ខ្មែរឥស្លាម"។ ថ្មីម្តងទៀត ដើមកំណើតជាតិពន្ធុរបស់ពួកគេ_ត្រូវបានបដិសេធ។ ក្នុងន័យទូលាយ ប្រជាជនចាមបានក្លាយជាជនរងគ្រោះនៃប្រវត្តិសាស្ត្រ។

## II. ប្រជាជនចាមក្នុងវិស័យនយោបាយ

ដោយសារភាគច្រើនខ្លួនជាប្រជាជនជនបទ ប្រជាជនមូស្លីមនៅកម្ពុជាកម្របានលេចធ្លោក្នុងវិស័យនយោបាយណាស់ លើកលែងតែម្តងម្កាល នៅក្នុងកងកម្លាំងប្រដាប់អាវុធ។ ជាឧទាហរណ៍ គេមិនឃើញមានប្រជាជនចាម ឬប្រជាជនមូស្លីមដទៃទៀតធ្វើជាសមាជិករដ្ឋសភានៃប្រទេសនេះឡើយនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០។ ប៉ុន្តែ ចលនារំដោះនៅសម័យក្រោយសង្គ្រាម យ៉ាងហោចណាស់មានផលប៉ះពាល់មួយចំនួនទៅលើប្រជាជនចាម។

ក្នុងអំឡុងពេលខែ កុម្ភៈ ទៅខែ មីនា ឆ្នាំ ១៩៦៥ ខណៈដែលកងទ័ពជើងគោកសហរដ្ឋអាមេរិកបានចូលមកដល់វៀតណាមខាងត្បូង ព្រះអង្គម្ចាស់នរោត្តម សីហនុ បានរៀបចំសន្និសីទមួយសម្រាប់ប្រជាជនឥណ្ឌូចិននៅក្នុងរាជធានីភ្នំពេញ។ ក្រុមកុម្មុយនីស្ត និងក្រុមអព្យាក្រឹតនិយមមកពីប្រទេសវៀតណាម និងឡាវត្រូវបានអញ្ជើញឱ្យចូលរួម តែក៏មានការអញ្ជើញគណៈកម្មាធិការស្រមោលរាប់សិបដែលអះអាងថាជាតំណាងឱ្យប្រជាជនចាម និងក្រុមជនជាតិភាគតិចជាច្រើនផ្សេងទៀតនៅក្នុងតំបន់នេះ។ ពួកគេភាគច្រើនត្រូវបានឧបត្ថម្ភដោយឧត្តមសេនីយ៍ លន់ នល់ និង "អនុប្រធានរបស់គាត់សម្រាប់កិច្ចការដ៏ចម្លែកទាំងនេះគឺលោកវរសេនីយ៍ឯក ឡេស កាសេម ដែលមានដើមកំណើតជាប្រជាជនចាម"។ លោក Charles Meyer បានបន្តថា៖

> នៅទីនេះ យើងបានស្វែងយល់ពីផ្នែកមួយនៃ "គំនិតនយោបាយដ៏អស្ចារ្យ" ដែលជាការបង្រួបបង្រួមដោយកម្ពុជានូវអ្វីដែលគេហៅថា ប្រជាជនខ្មែរមនទាំងអស់ប្រឆាំងនឹងវៀតណាម។ ដូច្នេះ មនុស្សចម្លែកដូចលោក លន់ នល់ បានទាញយកការស្រាវជ្រាវវិទ្យាសាស្ត្រពីសាវតារវប្បធម៌រួមនៃប្រជាជនអូស្ត្រូអាស៊ី ដែលគាត់នៅក្នុងការផ្សំសំឡេងផ្ទាល់របស់គាត់បង្កើតជា "អូស្ត្រ៊ាន" (sic) ដើម្បីផ្តល់នូវមូល

[55] Ner, "ជនមូស្លីម" ទំព័រ ១៩៧។

Deleted: *Unrevised translation. A revised translation will be provided upon request.*

> ហេតុសម្រាប់ក្តីសុបិនរបស់គាត់ ...។ ការបញ្ជូនរដ្ឋទូតរបស់គាត់ទៅប្រជាជនមនក្នុងប្រទេសភូមា និងទៅកាន់ប្រជាជនចាមជាច្រើនពាន់នាក់នៅលើឆ្នេរអណ្ណាម គឺជារឿងរវើរវាយដែលគ្មានប្រយោជន៍[56]។

ពេលដែលលោក លន់ នល់ បានដណ្តើមអំណាចពី សីហនុ ប្រាំឆ្នាំក្រោយមក គាត់បានបន្តស្វែងរកបុព្វហេតុ "មនខ្មែរ" របស់គាត់ដោយធ្វើការផ្សព្វផ្សាយ ដែលបណ្តាលឱ្យអាម៉ាស់ដល់សម្ព័ន្ធមិត្តអាមេរិកនិងសម្ព័ន្ធមិត្តផ្សេងទៀតរបស់គាត់។ ពេលដែលសង្គ្រាមរីករាលដាល កងកម្លាំងប្រដាប់អាវុធរបស់គាត់បានកើនចំនួនយ៉ាងឆាប់រហ័ស ហើយលោកវរសេនីយ៍ឯក ឡេស កាសេម ត្រូវបានផ្តល់តួនាទីឱ្យដឹកនាំកងវរសេនាតូចចាមមួយដាច់ដោយឡែក។ ក្នុងអំឡុងរយៈពេលឆ្នាំ ១៩៧០-៧២ កងវរសេនាតូចនេះ "ត្រូវបានគេរាយការណ៍ថាបានបំផ្លាញ និងសម្លាប់ជាប្រព័ន្ធនូវភូមិ "ខ្មែរក្រហម" ដែលពួកគេកាន់កាប់បាន។ ក្រោយពីដឹងឮគ្រប់គ្នាពីសកម្មភាពរបស់ពួកគេបែបនេះ ទើបនៅទីបំផុតរដ្ឋាភិបាលបានដឹងថា ពួកគេផ្តល់ផលមិនល្អ ហើយកងវរសេនាតូចនេះត្រូវបានគេបែងចែកឱ្យចូលទៅក្នុងចំណោមអង្គភាពផ្សេងទៀត"[57]។ ទន្ទឹមគ្នានេះដែរ មាន_ប្រជាជនចាមជាច្រើនបានចូលរួមក្នុងបុព្វហេតុកុម្មុយនីស្ត។

នៅដើមឆ្នាំ ១៩៥០ អ្នកចាស់ទុំជាជនជាតិចាមម្នាក់ឈ្មោះថា សុះ ម៉ាន គឺជាប្រជាជនកម្ពុជាដំបូងគេម្នាក់ដែលចូលរួមក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលដឹកនាំដោយ ហូជីមិញ។ ក្នុងរយៈពេលបីឆ្នាំបន្ទាប់មក សុះ ម៉ាន បានបម្រើការជាអនុប្រធានគណៈកម្មាធិការកម្មករលួចលាក់ប្រឆាំងបារាំងនៅខេត្តកំពង់ចាម។ ពីខែ កក្កដា ឆ្នាំ ១៩៦៣ ដល់ខែ មេសា ឆ្នាំ ១៩៥៤ គាត់បានសិក្សានៅសាលាសង្គ្រាមទ័ពព្រៃតាយង្វៀន នៅតំបន់ខ្ពង់រាបកណ្តាលរបស់ប្រទេសវៀតណាម ដោយបញ្ចប់ការសិក្សាក្នុងឋានៈជាវរសេនីយ៍ត្រី[58]។ បន្ទាប់ពីការបរាជ័យរបស់បារាំង គាត់បានធ្វើដំណើរទៅទីក្រុងហាណូយ និងបានចាប់ផ្តើមសិក្សានយោបាយ និងលទ្ធិម៉ាក្សលេនីននិយម ដែលទីបំផុតបាននាំគាត់ទៅទីក្រុងម៉ូស្គូ និងក្នុងរយៈពេលពីរឆ្នាំទៅកាន់ទីក្រុងប៉េកាំង។ សុះ ម៉ាន បានត្រឡប់មកផ្ទះវិញនៅឆ្នាំ ១៩៧០ ហើយបានចូលរួមជាមួយគណៈកម្មាធិការភូមិភាគបូព៌ានៃគណបក្សកុម្មុយនីស្តកម្ពុជា។ គាត់ក៏បានបង្កើតផងដែរនូវចលនាឥស្លាមភូមិភាគបូព៌ា ដែលគាត់ដឹកនាំជាមួយនឹងកូនប្រុស

---

[56] Charles Meyer, ពីក្រោយស្នាមញញឹមខ្មែរ (ប៉ារីស៖ Pion, ឆ្នាំ ១៩៧១) ទំព័រ ២៦៩-៧០។ សូមមើលផងដែរមាន M.A. Jaspan, "ការអវិវឌ្ឍថ្មី"។

[57] Michael Vickery, *ប្រទេសកម្ពុជា* ឆ្នាំ ១៩៧៥-១៩៨២ ទំព័ ១១។

[58] សូមមើល Kiernan, *របៀបដែល ប៉ុល ពត បានឡើងកាន់អំណាច* (ឡុងដ៍៖ Verso, ឆ្នាំ ១៩៨៥) ទំព័រ ៩០, ១២៥។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

របស់គាត់ឈ្មោះ ម៉ាត់ លី (ដែលត្រូវបានចាប់ដាក់គុកដោយពួកបារាំង និងបន្ទាប់មកដោយ សីហនុ)។ សុះ ម៉ាន បានធ្វើដំណើរទូទាំងភូមិភាគ ដើម្បីនិយាយប្រាប់សហគមន៍ចាមអំពី “ភាពចាំបាច់នៃការធ្វើបដិវត្តន៍”[59]។

សុះ ម៉ាន គឺជា “បុគ្គលមានកិត្យានុភាព”[60] ប៉ុន្តែគឺជាជនពិសេសតែម្នាក់ប៉ុណ្ណោះ។ នៅភូមិភាគផ្សេងទៀតដែលមានប្រជាជនចាមប្រមូលផ្តុំ ដូចជានៅភូមិភាគនិរតី និងភូមិភាគឧត្តរ គ្មានអង្គភាពនយោបាយឥស្លាមណាដែលត្រូវបានអត់ឱនឲ្យដោយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលគ្រប់គ្រងតំបន់ទាំងនោះទេ សូម្បីតែក្នុងអំឡុងសង្គ្រាមប្រឆាំងនឹងសាធារណរដ្ឋខ្មែររបស់ លន់ នល់។ តាមពិតទៅ នៅភូមិភាគនិរតី ដែលជាបេះដូងនៃមជ្ឈិមបក្សរបស់ ប៉ុល ពត មានការវាយប្រហារដំបូងបំផុតលើវប្បធម៌ចាម។ ដំបូងឡើយ ស្ត្រីចាមត្រូវគេបង្ខំឲ្យកាត់សក់ឲ្យខ្លីតាមរចនាបថខ្មែរ មិនឲ្យទុកវែងតាមទម្លាប់របស់ពួកគេ។ បន្ទាប់មក សំលៀកបំពាក់ពិសេសរបស់ចាមតាមប្រពៃណីត្រូវបានហាមឃាត់ (រួមជាមួយសម្លៀកបំពាក់ស្រស់ស្អាតផ្សេងទៀតដែលប្រជាជនខ្មែរនិយម) ខណៈដែលពួកកសិករកាន់តែត្រូវគេបង្ខំឲ្យស្លៀកពាក់តែខោអាវខ្មៅប៉ុណ្ណោះ។ សកម្មភាពសាសនាត្រូវបានរឹតបន្តឹងផងដែរ។ បម្រាមទាំងនេះបានចាប់ផ្តើមតាំងពីពាក់កណ្តាលឆ្នាំ ១៩៧២ នៅភូមិភាគនិរតី[61] តាមការបញ្ជារបស់មេបញ្ជាការស្តេចត្រាញ់ធំរបស់ ប៉ុល ពត និងជាលេខាបក្សកុម្មុយ_នីស្តកម្ពុជានៅភូមិភាគនិរតីគឺ ម៉ុក។

ស្តេចត្រាញ់ដ៏សំខាន់ម្នាក់ទៀតនៃរបប ប៉ុល ពត គឺ កែ ពក ដែលមេបញ្ជាការយោធានៃភូមិភាគឧត្តរនៅពេលនោះ។ ប៉ុល ពត ខ្លួនគាត់មានមូលដ្ឋាននៅភូមិភាគឧត្តរក្នុងអំឡុងពេលសង្គ្រាមឆ្នាំ ១៩៧០-៧៥។ នៅខែ មេសា ឆ្នាំ ១៩៧៣ ឯកសារបក្សកុម្មុយនីស្តកម្ពុជាដែលមានចំណងជើងថា *ការវិភាគវណ្ណៈ និងការតស៊ូវណ្ណៈ* ត្រូវបានចែកដល់កម្មាភិបាលនៅទីនោះ។ ឯកសារនេះបានពិភាក្សាពីវណ្ណៈគ្រប់គ្រង និង វណ្ណៈ_អធនដែលត្រូវគេសង្កត់សង្កិន និងបានបន្តថា៖ “រាល់ជាតិសាសន៍ទាំងអស់មានកម្មករ ដូចជាតិសាសន៍កម្ពុជារបស់យើង

---

[59] Gaffar Peang-Meth, “អ៊ីស្លាម ជនរងគ្រោះមួយទៀតនៃសង្គ្រាមនៅកម្ពុជា” នៅក្នុង ឌុក រ៉ាស៊ី, *តំណាងខ្មែរនៅអង្គការសហប្រជាជាតិ* (ឡុងដ៍៖ ឆ្នាំ ១៩៧៤) ទំព័រ ២៥១-៥៥ នៅទំព័រ ២៥៣; បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ម៉ាត់ លី ជាកូនរបស់ សុះ ម៉ាន នៅទីក្រុងភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៨០ និងថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៨៦។

[60] Peang-Meth, “អ៊ីស្លាម” ទំព័រ ២៥៣។

[61] Kenneth K. Quinn, “កម្មវិធីខ្មែរក្រហមដើម្បីបង្កើតសង្គមកុម្មុយនីស្តនៅភាគខាងត្បូងប្រទេសកម្ពុជា” ឯកសារអេឡិចត្រូនិកមិនបានកំណត់ប្រភេទចេញពីកុងស៊ុលអាមេរិកនៅ Can Tho, ទៅក្រសួងការបរទេសអាមេរិក (ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៤) ៣៧ ទំព័រ នៅទំព័រ ២៣-២៦។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

លើកលែងតែខ្មែរឥស្លាមដែលរស់នៅមិនសូវលំបាក[62]។ ការវិភាគវណ្ណៈនេះហាក់ដូចជាប្រកាន់ពូជសាសន៍។ តើពិតជាគ្មានកម្មករក្នុងចំណោមប្រជាជនចាមមែនឬ? ពិតណាស់ សមាមាត្រប្រជាជនចាមមានច្រើនជាងប្រជាជនខ្មែរដែលមានទំនោរធ្វើជាអ្នកនេសាទ និងឈ្មួញតូចតាចឯករាជ្យ។ ប៉ុន្តែ មានកសិករចាមជាច្រើន ក៏ដូចជាកម្មករចាមជាច្រើន ជាឧទាហរណ៍នៅក្នុងចម្ការកៅស៊ូ[63]។ ប្រហែលជាមានសមាមាត្រកម្មករចាមច្រើនជាងខ្មែរ។ ប៉ុន្តែរូបភាពនៃប្រជាជនចាមជារួម ជាអ្នកនេសាទឯករាជ្យតូចតាច ហាក់គ្របដណ្ដប់លើការគិតរបស់ក្រុម ប៉ុល ពត អំពីក្រុមពូជសាសន៍ទាំងមូលនេះ។

តាមទស្សនៈខ្ញុំ សាច់រឿងដែលនៅពីក្រោយនៃពិភពទស្សនៈនយោបាយរបស់ក្រុម ប៉ុល ពត គឺជាការព្រួយបារម្ភពីភាពអស្ចារ្យខាងជាតិសាសន៍ និងពូជសាសន៍។ ការខ្វែងគំនិតគ្នាពីដំបូងរបស់ពួកគេជាមួយពួកកុម្មុយនីស្តវៀតណាមពាក់ព័ន្ធនឹងភាពអស្ចារ្យជានិមិត្តរូបនៃប្រាសាទអង្គរវត្ត និងទំហំនៃចំនួនប្រជាជនកម្ពុជា។ នៅក្នុងការប្រាសចេញមួយទៀតពីបញ្ហាវណ្ណៈដែលជាចំណុចសំខាន់នៃលទ្ធិម៉ាក្សនិយម ប៉ុល ពត ខ្លួនគាត់ធ្លាប់បានសរសេរក្រោមឈ្មោះក្លែងក្លាយថា "ខ្មែរដើម"[64]។ ចំណុចសំខាន់របស់គាត់ជាញឹកញាប់មានទំនោរទៅរកពូជសាសន៍ និងប្រវត្តិសាស្ត្រ។ ការពិតនេះមានផលប៉ះពាល់ជាពិសេសសម្រាប់ប្រជាជនចាម។ ម្យ៉ាង ពួកគេជាកូនចៅរបស់សត្រូវចាស់របស់វៀតណាម និងជាការរំលឹកពីអតីតកាលញាតិសន្តានដ៏រុងរឿងរបស់ប្រជាជនខ្មែរ។ ប៉ុន្តែម្យ៉ាងទៀត នៅក្នុងកែវភ្នែករបស់ក្រុម ប៉ុល ពត ពួកគេជាប្រផ្នូលនៃអនាគតកម្ពុជាដ៏ខ្មៅងងឹត ដែលបក្សកុម្មុយនីស្តកម្ពុជាបានកំណត់ចេញដោយចេតនាថាត្រូវលុបពីទំព័រប្រវត្តិសាស្ត្រ។ កម្ពុជានឹងមិនរលាយបាត់ដូចដែលចម្ប៉ាត្រូវគេអះអាងថារលាយនោះទេ។

ទស្សនៈផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាអំពីជនជាតិភាគតិចក្នុងស្រុករបស់ប្រទេសគឺថា ពួកគេមានច្រើនពូជសាសន៍ ប៉ុន្តែសរុបមកមានគ្នាត្រឹមតែមួយភាគរយនៃចំនួនប្រជាជនសរុប "៩៩ ភាគរយ" ជាជនជាតិខ្មែរ[65]។ ដូច្នេះ ជនជាតិចាម ចិន វៀតណាម និងក្រុមជនជាតិភាគតិចជាងម្ភៃក្រុមផ្សេងទៀត ដែលជាយូរមកបង្កើតជា ១៥ ភាគរយនៃចំនួនប្រជាជនកម្ពុជា ត្រូវបានសរសេរលុបចោលស្ទើរតែទាំងស្រុងដោយបក្សកុម្មុយនី

---

[62] ឯកសារបកប្រែជាភាសាអង់គ្លេសដោយ S.R. Heder។

[63] "នៅក្នុងឆ្នាំ ១៩៥៥ ក្នុងកម្មករចំនួន ១៥.000 នាក់ក្នុងចម្ការទាំងអស់នៅប្រទេសកម្ពុជា មាន ៤.២៤៧ នាក់ជាជនជាតិកម្ពុជា និង ៤.0២១ នាក់ជាជនជាតិខ្មែរអ៊ីស្លាម"។ Delvert, *កសិករកម្ពុជា* ទំព័រ ៥៩0-៩១។

[64] Kiernan, *របៀបដែល ប៉ុល ពត បានឡើងកាន់អំណាច* ទំព័រ ២៥-២៧, ៣0-៣២, ១១៩-២៤។

[65] *កម្ពុជាប្រជាធិបតេយ្យកំពុងឈានទៅមុខ* (ភ្នំពេញ ខែ សីហា ឆ្នាំ ១៩៧៧) ទំព័រ ៦។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ស្កកម្ពុជា។ នៅក្នុងករណីនៃជនជាតិចាម ការពន្យល់មានលក្ខណៈសាមញ្ញ៖ "ពូជសាសន៍ចាមត្រូវពួកវៀតណាមបំផ្លាញចោលហើយ"[66]។ នេះហាក់ដូចជាសេចក្តីថ្លែងការណ៍ជាផ្លូវការតែមួយគត់នៃរបប ប៉ុល ពត អំពីពួកគេ។ ផ្ទុយទៅវិញ វាងាយស្រួលផ្នែកនយោបាយសម្រាប់អ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលថា "គ្មាន" ចាមណាបានរស់រានមានជីវិតពីព្រឹត្តិការណ៍ឆ្នាំ ១៩៧១-១៦៩៣ ទេ។ អ្នកដែលបានរស់រានមានជីវិត (ហើយនៅក្នុងឆ្នាំ ១៩៧៥ ប្រហែលជាមានប្រជាជនចាមនៅកម្ពុជាតែឯងច្រើនជាងចំនួនដែលធ្លាប់មាននៅចម្ប៉ា) មិនត្រូវបានទទួលស្គាល់ឡើយ សូម្បីតែក្នុងនាមជាជនរងគ្រោះ។

កាន់តែអាក្រក់ទៅទៀត ប្រជាជនចាមក៏ជាខ្សែរយៈដ៏ខ្សោយនៅក្នុងរង្គរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដោយសារតែភាសា និងវប្បធម៌ដោយឡែក ភូមិធំ និងបណ្តាញ អង្គការជាតិដែលឯករាជ្យរបស់ពួកគេ ជនជាតិចាមអាចជាការគំរាមកំហែងដល់សង្គមដ៏ខ្លាំងដែលស្ថិតក្រោមត្រួតពិនិត្យយ៉ាងជិតដល់ ដែលអ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាគ្រោងនឹងបង្កើត។ មកទល់ឆ្នាំ ១៩៧៤ ពួកគេត្រូវបានមើលឃើញរួចទៅហើយថាជាឧបសគ្គមួយដល់ការបង្កើតសហករណ៍។ ឯកសារមួយទៀតរបស់ភូមិភាគឧត្តរនៃបក្សកុម្មុយនីស្តកម្ពុជា ចុះខែ កុម្ភៈ ឆ្នាំ ១៩៧៤ កត់ត្រាពីសេចក្តីសម្រេចពាក់ព័ន្ធនឹងមាត៌ាស្តីពីសហករណ៍បក្សក្នុងតំបន់ ៣១៖ "ទាក់ទងនឹងបងប្អូនជនជាតិខ្មែរឥស្លាម ត្រូវពន្យាពេលកុំទាន់ឲ្យពួកគេចូលរួម [សហករណ៍]។ ប៉ុន្តែស្របពេលគ្នានេះដែរ ត្រូវ_បន្តរៀបចំឲ្យពួកគេចូលក្នុងក្រុមប្រវាស់ដៃ ...។ *ទោះយ៉ាងណា ចាំបាច់ត្រូវបំបែកក្រុមនេះខ្លះ*។ មិនត្រូវឲ្យពួក_គេប្រមូលផ្តុំច្រើនពេកទេនៅក្នុងតំបន់មួយនោះទេ"[67]។ នេះគឺជាកំណត់ត្រាដំបូងស្តីពីសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាឲ្យបំបែកប្រជាជនចាម។

ដូចគ្នានេះដែរ ករណីដំបូងបំផុតនៃពួកចាមបះបោរប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាក៏បានកើតឡើងនៅតំបន់ ៣១ និងជាលទ្ធផលដោយផ្ទាល់នៃភាពតានតឹងជាមួយសហករណ៍ថ្មី។ ដូចដែលលោក Abdul-Gaffar Peang-Meth បានសរសេរនៅពាក់កណ្តាលឆ្នាំ ១៩៧៤ ថា៖

> ពួកអ្នកនេសាទខ្មែរមូស្លីម ត្រូវរងការបង្ខំឲ្យចុះបញ្ជីចំពោះផលនេសាទរបស់ពួកគេជាមួយសហករណ៍មូលដ្ឋានរបស់ពួកកុម្មុយនីស្ត និងលក់ផលនេសាទរបស់ពួកគេឲ្យសហករណ៍ក្នុងតម្លៃទាប។ ក្រោយមក អ្នកនេសាទត្រូវគេតម្រូវឲ្យទិញត្រីរបស់ពួកគេវិញពីសហករណ៍ក្នុងតម្លៃខ្ពស់ជាងមុនខ្លាំង។ នៅ

[66] *សៀវភៅខ្មៅ៖ ការពិត និងភស្តុតាងនៃសកម្មភាពឈ្លានពាន និងវាតទីរបស់វៀតណាមមកលើកម្ពុជា* (ភ្នំពេញ ខែ កញ្ញា ឆ្នាំ ១៩៧៨) ទំព័រ ៦។

[67] ឯកសារបកប្រែដោយ S.R. Heder។ ការគូសបញ្ជាក់ត្រូវបានបន្ថែម។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៤ ពេលដែលអ្នកនេសាទសម្ដែងការមិនសប្បាយចិត្ត របស់ខ្លួននៅក្នុងបាតុកម្មមួយ ពួកកុម្មុយនីស្តបានព្យាយាមបំបែកពួកគេតាមរយៈការសំដែងមតិ។ នៅពេលការធ្វើបែបនេះបានបរាជ័យ ពួកកុម្មុយនីស្តបានចាប់ផ្ដើមបាញ់ទៅលើបាតុករ ដែលបានសម្លាប់ និងបង្ករបួសដល់មនុស្សច្រើនជាង ១០០ នាក់[68]។

ព្រឹត្តិការណ៍ទាំងនេះបានកើតឡើងនៅលើច្រាំងខាងលិចនៃទន្លេមេគង្គ ភាគខាងជើងនៃក្រុងកំពង់ចាម។ នៅត្រើយម្ខាងទៀតនៃទន្លេក្នុងភូមិភាគបូព៌ា មាគ៌ាបក្សកុម្មុយនីស្តកម្ពុជាក៏កាន់តែតឹងរឹងផងដែរ។ អ្នកនិពន្ធដដែលបានបន្តថា៖

ដើម្បីយកឈ្នះលើទំនុកចិត្តរបស់ខ្មែរមូស្លីម សុះ ម៉ាន បានបន្តប្រតិបត្តិតាមជំនឿមូស្លីមរបស់គាត់។ ... ទោះយ៉ាងណា មកទល់ឆ្នាំ ១៩៧៣ សុះ ម៉ាន និងសហការីកុម្មុយនីស្តរបស់គាត់បានចាប់ផ្ដើមប្រកាសជាចំហអំពីលទ្ធិកុម្មុយនីស្ត និងបើកសាលាបណ្ដុះបណ្ដាលនយោបាយ និងរៀបចំសហករណ៍។ សំខាន់បំផុត ពួកគេបានចាប់ផ្ដើមប្រាប់ប្រជាជនថា ជនមូស្លីមលះបង់ពេលវេលាច្រើនពេកទៅលើបញ្ហាសាសនា និងមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់បដិវត្តន៍ ...។

*[រូបភាព]*

*រូបថតដោយ Judy Danielson ដោយមានការផ្ដល់ឱ្យពី Judy Danielson និង Eric Wright*

*ប្រជាជនចាមម៉ូស្លីមក្នុងសម្លៀកបំពាក់ប្រពៃណី តំណាងឱ្យជនជាតិភាគតិចចាមនៅក្នុងការសង្កេតទិវាឧសភានៅក្នុងរាជធានីភ្នំពេញនៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ១៩៨៦ ដែលឧបត្ថម្ភដោយរដ្ឋាភិបាល។ ដោយផ្ទុយគ្នាយ៉ាងខ្លាំងនឹងការបដិសេធរបស់របប ប៉ុល ពត ពីអត្តិភាពនៃជនជាតិចាម និងជនជាតិភាគតិចផ្សេងទៀត រដ្ឋាភិបាលបច្ចុប្បន្នជាក់ស្ដែងបានធ្វើឱ្យអ្នកតំណាងរបស់ក្រុមផ្សេងៗមានវត្តមាននៅក្នុងពិធីនានារបស់រដ្ឋាភិបាល។ ក្រៅពីប្រជាជនចាម គេអាចឃើញព្រះសង្ឃស្លៀកស្បង់ នៅជាមួយនឹងយុវជនផ្សេងទៀតមកពីក្រុមនិស្សិត និងក្រសួងរដ្ឋាភិបាលនានា។*

ចាប់ពីខែ តុលា ឆ្នាំ ១៩៧៣ ខ្មែរមូស្លីមបានធ្វើបាតុកម្មប្រឆាំងនឹងការសង្កត់សង្កិនរបស់ពួកកុម្មុយនីស្តលើជំនឿសាសនារបស់ពួកគេ តាមរយៈការវាយស្ដុះពិធីនៅក្នុងវិហារឥស្លាមតាមភូមិរបស់ពួកគេដើម្បីជា

[68] Peang-Meth, "អ៊ីស្លាម" ទំព័រ ២៥៣។

Deleted: *Unrevised translation. A revised translation will be provided upon request.*

សញ្ញានៃការតវ៉ា។ ពេលដែលពួកកុម្មុយនីស្តបានសង្កត់ធ្ងន់ថា ពួកគេនឹងមិនអនុញ្ញាតឲ្យមានការអធិដ្ឋានប្រាំដងក្នុងមួយថ្ងៃដូចដែលខ្មែរមូស្លីមបានទាមទារ អ្នកឈ្លានពានដែលបានចាប់ពង្រត់តែអ្នកភូមិដែលបានជ្រើសរើសបានចាប់ផ្ដើមចាប់ខ្លួនខ្មែរមូស្លីមដើម្បីជំរិតយកប្រាក់ ចាប់ផ្ដើមនៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៣។ មកដល់ពេលនោះ [ពាក់កណ្ដាលឆ្នាំ ១៩៧៤] មានខ្មែរមូស្លីមយ៉ាងហោចណាស់ ៣០០ នាក់ ត្រូវបានចាប់ខ្លួន ភាគច្រើនមកពីស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ភាគច្រើននៃមនុស្សដែលត្រូវចាប់ខ្លួននោះគឺជាអ្នកភូមិមូស្លីមដែលលេចធ្លោ និងជាមេដឹកនាំសាសនា ជាពិសេស គ្រូបង្រៀនគម្ពីរកូរ៉ាន[69]។

គេមិនបានដឹងទេពីការយល់ឃើញរបស់ សុះ ម៉ាន ចំពោះការបង្រ្កាបនេះ។ បើគាត់ពិតជាប្រឆាំងនឹងរឿងនេះមែន ក៏គាត់មិនអាចធ្វើអ្វីបានច្រើនដែរ។ ពេលនោះគាត់មានអាយុ ៧២ ឆ្នាំហើយ។ នៅខែ កញ្ញា ឆ្នាំ ១៩៧៤ ប៉ុល ពត បានចុះទៅដោយផ្ទាល់ដល់ភូមិភាគបូព៌ាដើម្បីចូលរួមសមាជបក្សតាមភូមិភាគ។ នៅខែដដែលនោះ ចលនាឥស្លាមភូមិភាគបូព៌ាត្រូវបានបំបែក ហើយ សុះ ម៉ាន ត្រូវគេបណ្ដេញចេញពីជីវិតនយោបាយ និងបង្ខាំងខ្លួននៅក្នុងភូមិមួយ។ ការបណ្ដេញរបស់គាត់គឺស្របគ្នាជាមួយនឹងការចាប់ខ្លួនក្នុងខែ សីហា ឆ្នាំ ១៩៧៤ នៃពួកកុម្មុយនីស្តខ្មែរ ៧១ នាក់ផ្សេងទៀតនៅភូមិភាគបូព៌ា ដែលបានទទួលការបណ្ដុះបណ្ដាលនៅទីក្រុងហាណូយ។ មនុស្ស ១០ នាក់ក្នុងចំណោមមនុស្សទាំង ៧១ នាក់នោះ បានបាត់ខ្លួនយ៉ាងឆាប់រហ័ស ដែលអាចត្រូវសម្លាប់ដោយកងកម្លាំងសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា[70]។

មកទល់ខែ ធ្នូ ឆ្នាំ ១៩៧៤ ការចាប់ខ្លួនមេដឹកនាំចាមនៅក្នុងភូមិទ្រា ស្រុកក្រូចឆ្មារ បានបង្កឲ្យមានការបះបោរមួយ[71]។ គេមិនបានដឹងទេពីចំនួនមនុស្សរបួស និងស្លាប់ ប៉ុន្តែដូចលោក James Fenton បានរាយការណ៍៖ “ក្រុមមួយដែលគេហៅថា ខ្មែរស បានបំបែកចេញពីពួកខ្មែរក្រហម ហើយចូលទៅក្នុងព្រៃ។ ខ្មែរសដែលមានមេដឹកនាំជាអតីតមន្ត្រីពួកកុម្មុយនីស្ត ភាគច្រើនជាចាមមូស្លីម។ ពួកគេគាំទ្រ សីហនុ និងប្រឆាំងនឹងការដាក់ទ្រព្យសម្បត្តិជារបស់សមូហភាព។ ពួកគេជឿត្រឹមតែការលប់បំបាត់ឈ្មួញកណ្ដាល”[72]។ គួរឲ្យចាប់អារម្មណ៍ណាស់ដែរ នេះគឺជាមាគ៌ាគោលនយោបាយរបស់វៀតណាមសម្រាប់កម្ពុជា នៅពេលនោះ។ តាមពិត

---

[69] ដូចឯកសារខាងលើ ទំព័រ ២៥៤។

[70] ម៉ាត់ លី បទសម្ភាសន៍ (សូមមើលកំណត់ចំណាំលេខ ៥៩); សូមមើលផងដែរ Kieman, *របៀបដែល ប៉ុល ពត បានឡើងកាន់អំណាច* ទំព័រ ៣៨៦-៨៧។

[71] ម៉ាត់ លី, បទសម្ភាសន៍ (សូមមើលកំណត់ចំណាំលេខ ៥៩)។

[72] James Fenton, *កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍* ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៤។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ទៅ ខ្មែរស នៅក្នុងតំបន់ផ្សេងទៀតត្រូវគេស្គាល់ថាទ័ពព្រៃគាំទ្រពួកវៀតណាម[73]។ ប៉ុន្តែ ពួកគេពុំបានរស់រានមានជីវិតទេនៅខាងក្នុងកម្ពុជាបន្ទាប់ពីឆ្នាំ ១៩៧៥។

ទោះយ៉ាងណា កូនប្រុសរបស់ សុះ ម៉ាន គឺ ម៉ាត់ លី បានរក្សាតំណែងរបស់គាត់ជាសមាជិកនៃគណៈកម្មាធិការនៃបក្សកុម្មុយនីស្តកម្ពុជានៅស្រុកត្បូងឃ្មុំ។ គាត់ប្រហែលជាជនជាតិចាមដែលមានឋានៈខ្ពស់ជាងគេនៅក្នុងប្រទេសនេះមកទល់ឆ្នាំ ១៩៧៥។ នៅកន្លែងផ្សេងទៀត មានការរឹតបន្តឹងយ៉ាងខ្លាំងលើការធ្វើដំណើរពាណិជ្ជកម្ម និងការសម្លាប់សត្វចិញ្ចឹម ដែលទាំងអស់នេះប៉ះពាល់ដល់ប្រជាជនចាម ប៉ុន្តែ ទាំងនេះជាញឹកញាប់ត្រូវគេមើលឃើញថាគ្រាន់តែជាវិធានការសម័យសង្គ្រាមប៉ុណ្ណោះ ហើយ នៅភូមិភាគបូព៌ា នៅមិនទាន់មានសញ្ញានៃគោលនយោបាយបក្សកុម្មុយនីស្តមួយដើម្បីបំបែកពួកចាម ពោលគឺបំផ្លាញពួកគេមិនឲ្យនៅជាសហគមន៍ទេ។ ប្រជាជនចាមជាច្រើនបានបន្តគាំទ្របដិវត្តន៍ និងសឹងតែបម្រើឲ្យបដិវត្តន៍ក្នុងនាមជាកម្មាភិបាល។ ម្នាក់ក្នុងចំណោមនិស្សិតដែលបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ Al-Azhar ក្នុងទីក្រុងគែរ ដែលរស់នៅត្បូងឃ្មុំពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៩ នៅចាំបានថា៖

> ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ជីវិតមានសភាពធម្មតា។ នៅមិនទាន់មានការធ្វើទុក្ខបុកម្នេញទេ។ ក្រោយមក ប្រជាជនជឿលើពួកខ្មែរក្រហម។ គ្រាប់បែករបស់អាមេរិកបានធ្លាក់មកលើភូមិខ្ញុំក្នុងឆ្នាំ ១៩៧១ ធ្វើឲ្យភូមិឆេះរាបដល់ដី ហើយសម្លាប់មនុស្សជាច្រើន។ អ្នកភូមិចាមខ្លះបានចូលរួមជាមួយពួកខ្មែរក្រហមដោយធ្វើជាទាហាន ...។ នៅក្នុងឆ្នាំ ១៩៧៤ មានការបង្កទុក្ខវេទនានៅកន្លែងខ្លះដូចជាភូមិទ្រា។ ប៉ុន្តែ វាមិនទាន់ធ្ងន់ធ្ងរទេ ទាល់តែដល់ពេលដែលគេលុបបំបាត់ចោលពុទ្ធសាសនា និងសាសនាឥស្លាមនៅចុងឆ្នាំ ១៩៧៥[74]។

## III. ប្រជាជនចាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

យើងឃើញហើយថា ប្រជាជនចាមជាច្រើនបានចូលរួមក្នុងចលនាខ្មែរក្រហមពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ហើយថា ក៏មានការបង្ក្រាបលើប្រជាជនចាម និងវប្បធម៌របស់ពួកគេ នៅតំបន់ខ្មែរក្រហមមួយចំនួនក្នុងអំឡុងពេលនោះផងដែរ។ ប៉ុន្តែ ទាល់តែដល់ឆ្នាំ ១៩៧៥ ទើបការលុបបំបាត់ជីវិតរបស់ប្រជាជនចាម

---

[73] សូមមើលជាឧទាហរណ៍ Donald Kirk, "ខ្មែរក្រហម៖ ជនបដិវត្តន៍ ឬភេរវករ" ឯកសារមិនបានចេញផ្សាយ ឆ្នាំ ១៩៧៤ ច្បាប់ចម្លងត្រូវប្រគល់ជូនដោយភាពសប្បុរសពីអ្នកនិពន្ធ។

[74] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ទូន អ៊ីប្រាហ៊ីម នៅទីក្រុងភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៨០។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ជាប្រព័ន្ធចាប់ផ្តើមយ៉ាងពិតប្រាកដ។ ប្រការនេះបានបង្កអោយមានការបះបោរដ៏កាចសាហាវភ្លាមៗ ដែលដូចយើងនឹងឃើញថាត្រូវបានលិចលង់ក្នុងថ្លុកឈាម។ សូម្បីតែបន្ទាប់ពីការបះបោរទាំងនេះត្រូវបានកម្ទេចរួចទៅហើយក៏ដោយ ក៏យុទ្ធនាការប្រឆាំងនឹងប្រជាជនចាមមិនបានបញ្ឈប់ដែរ។ របបកម្ពុជាប្រជាធិបតេយ្យបានសម្លាប់រង្គាលអ្នកភូមិចាម បានបំបែកអ្នកដែលនៅរស់ និងបានហាមឃាត់មិនឲ្យមានភាសា ទំនៀមទម្លាប់ និងសាសនាឥស្លាមទៀត។ វិធីសាស្ត្រ និងសង្វាក់នៃការបង្ក្រាបនេះបានប្រែប្រួលពីតំបន់មួយទៅតំបន់មួយ និងពីពេលមួយទៅពេលមួយ ដែលមួយផ្នែកឆ្លុះបញ្ចាំងពីភាពខុសគ្នានៅតាមមូលដ្ឋានដែលកំពុងបន្តកើតមាននៅ ក្នុងរង្វង់ចលនាខ្មែរក្រហម។ ប៉ុន្តែ វិធីមានសង្គតភាពនៃយុទ្ធនាការប្រល័យពូជសាសន៍ដែលរៀបចំឡើងដោយ ថ្នាក់មជ្ឈិមគឺច្បាស់លាស់។

## ក. ភូមិភាគបូព៌ា

### ១. ការបះបោរឆ្នាំ ១៩៧៥ នៅក្រូចឆ្មារ

សហគមន៍ចាមធំជាងគេនៅកម្ពុជា គឺនៅក្នុងតំបន់មួយដែលគេស្គាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា តំបន់ ២១ នៅក្នុងខេត្តកំពង់ចាម ភាគខាងកើតទន្លេមេគង្គ និងភាគខាងជើងនៃផ្លូវជាតិលេខ ៧។ តំបន់ ២១ រួមបញ្ចូលទាំងដីច្រាំងទន្លេដ៏មានជីជាតិនៃស្រុកក្រូចឆ្មារ ព្រមទាំងចម្ការកៅស៊ូជប់ និងដីសម្រាប់ដាំដុះស្រូវដ៏សម្បូរបែបនៅស្ទួង ដែលទាំងពីរនេះសុទ្ធតែស្ថិតនៅក្នុងស្រុកត្បូងឃ្មុំ។ ស្រុកទាំងពីរមានសហគមន៍ចាមធំៗជាច្រើនជាយូរមកហើយ។ ប៉ុន្តែស្រុកក្រូចឆ្មារ នៅភាគខាងជើងខេត្តកំពង់ចាមគឺជាស្រុកតែមួយគត់នៅកម្ពុជាដែលប្រជាជនចាមស្ទើរតែបង្កើតជាក្រុមជនជាតិភាគច្រើនទៅហើយ ដែលមានចំនួនប្រហែលជា ៣០.០០០ នាក់នៅត្រឹមទសវត្សរ៍ឆ្នាំ ១៩៧០។ នៅទីនេះ មានសហគមន៍ចាមធំៗចំនួនបួន នៅតាមបណ្តោយត្រើយខាងកើតនៃទន្លេមេគង្គដូចជា នៅទ្រា ស្វាយឃ្លាំង ជំនីក និងប៉ើស[75]។

*[រូបភាព]*

*ដោយមានការផ្តល់ឲ្យពី Ben Kiernan*

*បំណែងចែករដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៥-៧៩*

[75] Delvert, *កសិករកម្ពុជា* ទំព័រ ៦០៥។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ប្រជាជនទាំងអស់នេះបានស្ថិតក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហមជាលើកដំបូង នៅឆ្នាំ ១៩៧០ នៅពេលដែលរបប លន់ នល់ បានបាត់បង់ការគ្រប់គ្រងលើតំបន់ខាងលើទន្លេពីខេត្តកំពង់ចាមយ៉ាងលឿន។ "តំបន់រំដោះ" បែបនោះត្រូវបានគេស្គាល់នៅក្រោយឆ្នាំ ១៩៧៥ ថាជា "មូលដ្ឋាន" របស់ពួកខ្មែរក្រហម និង ប្រជាជននៅទីនោះថាជា "ប្រជាជនមូលដ្ឋាន" (ឬ "ប្រជាជនចាស់") ដែលបែងចែកដាច់ពី "ប្រជាជនថ្មី" ដែល បានរស់នៅក្រោមការគ្រប់គ្រងរបស់របប លន់ នល់ នៅក្នុងទីក្រុងរហូតដល់ឆ្នាំ ១៩៧៥។ ប្រជាជនថ្មី ដែល បន្ទាប់មកត្រូវបានជម្លៀសចេញពីទីក្រុងនានា ត្រូវបានគេហៅផងដែរថា "ប្រជាជនបញ្ញើ"។ តំបន់ដែលមាន ការប្រមូលផ្តុំប្រជាជនចាមធំជាងគេបំផុតនៅក្នុងប្រទេស ក៏ជាតំបន់ខ្លាំងក្លាបំផុតរបស់ពួកខ្មែរក្រហមផងដែរ រហូតដល់ឆ្នាំ ១៩៧៥។

នៅក្នុងសៀវភៅរបស់គាត់ *កម្ពុជាឆ្នាំសូន្យ* លោក Francois Ponchaud បានរាយការណ៍នូវរឿងមួយ ដែលដំណាលប្រាប់គាត់ដោយ ម៉ាត់ ស្លិម៉ាន ដែលជាជនជាតិចាមវ័យសែសិបឆ្នាំម្នាក់មកពីក្រូចឆ្មារ។ បងប្អូន ប្រុសចាមពីរនាក់ ដែលបានចូលរួមជាមួយកងទ័ពខ្មែរក្រហមបានវិលត្រឡប់ទៅភូមិរបស់ពួកគេវិញ បន្ទាប់_ពី ទទួលជ័យជម្នះ។

> យប់មួយ កូនប្រុសៗត្រឡប់មកផ្ទះវិញដើម្បីទៅជួបឪពុករបស់គេ ហើយបានប្រាប់គាត់នូវរាល់អំពើ សកម្មភាពរបស់ពួកគេ ដូចជា របៀបដែលពួកគេបានសម្លាប់ជនជាតិខ្មែរ ហូបសាច់ជ្រូក និងរំដោះ ប្រទេស។ ពួកគេប្រាប់គាត់ថា "មកជាមួយពួកយើងមក ហើយដើរតាមបដិវត្តន៍ទៅ"។ បុរសវ័យ ចំណាស់នោះមិនបាននិយាយអ្វីមួយម៉ាត់ទេ ប៉ុន្តែបានដើរចេញទៅក្រៅផ្ទះ រួចគាត់បានត្រឡប់មកវិញ ដោយមានកាន់កាំបិតធំមួយ ហើយបានសម្លាប់កូនប្រុសទាំងពីររបស់គាត់ទៅ។ គាត់បានគ្របសាក សពរបស់ពួកគេនឹងក្រណាត់ធំមួយផ្ទាំង ហើយបន្ទាប់មក បានទៅប្រាប់អ្នកជិតខាងរបស់គាត់ថា៖ "មកមើលសត្រូវពីរនាក់ដែលខ្ញុំបានសម្លាប់នេះមក!"
>
> នៅពេលដែលគាត់ទាញក្រណាត់គ្របចេញ មិត្តភក្តិរបស់គាត់បាននិយាយថា៖ "ប៉ុន្តែ ពួកគេ ទាំងពីរជាកូនរបស់ឯង!" គាត់បានឆ្លើយថា "ទេ ពួកគេមិនមែនទេ" ពួកគេជាសត្រូវនឹងប្រជាជនយើង និងសាសនាយើង ដូច្នេះហើយខ្ញុំក៏សម្លាប់ពួកគេទៅ"។ គាត់បានប្រាប់រឿងនេះដល់គេឯង ហើយអ្នក រាល់គ្នានិយាយថា គាត់ធ្វើនេះត្រឹមត្រូវហើយ ហើយពួកគេក៏បានសម្រេចចិត្តសម្លាប់ពួកខ្មែរក្រហម ទាំងអស់នៅក្នុងភូមិ។ ពួកគេបានធ្វើរឿងនេះនៅយប់នោះតែម្តង។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

នៅព្រឹកបន្ទាប់ បើយោងតាម ស្តិម៉ាន កងទ័ពខ្មែរក្រហមបានមកឡោមព័ទ្ធភូមិនោះ និងបានសម្លាប់រង្គាល "គ្រប់គ្នានៅក្នុងភូមិ ដោយកាំភ្លើងត្បាល់ កាំភ្លើងស្វ័យប្រវត្តិ និងចំពុះទុង"[76]។

ម៉ាត់ លី បានផ្តល់នូវដំណើររឿងផ្សេងគ្នាអំពីអ្វីដែលអាចនឹងជាព្រឹត្តិការណ៍ដូចគ្នានោះ។ គាត់បាននិយាយថា នៅខែ មិថុនា ឬកក្កដា ឆ្នាំ ១៩៧៥ អាជ្ញាធរខ្មែរក្រហមក្នុងស្រុកក្រូចឆ្មារប៉ុនប៉ងចង់ប្រមូលច្បាប់ចម្លងទាំងអស់នៃគម្ពីរកូរ៉ាននៅកោះផល ដែលជាភូមិចាមដ៏ធំមួយក្នុងឃុំរកាខ្នុរ នៅលើកោះមួយនៃទន្លេមេគង្គ។ ក្មេងស្រីចាមតម្រូវឲ្យកាត់សក់ឲ្យខ្លីតាមរចនាបថខ្មែរ។ អ្នកភូមិបានធ្វើបាតុកម្មតវ៉ា ហើយកងទ័ពខ្មែរក្រហមបានបាញ់ចូលទៅក្នុងហ្វូងមនុស្ស។ បន្ទាប់មក ចាមបានចាប់យកដាវ និងកាំបិត ហើយចាក់សម្លាប់កងទ័ពប្រាំមួយនាក់។ ពួកខ្មែរក្រហមដែលចង់សងសឹកបានសម្លាប់រង្គាលមនុស្សជាច្រើននាក់ និងបានលួចប្លន់ផ្ទះរបស់ពួកគេ។ អ្នកភូមិខ្លះបានរត់គេចខ្លួនដោយហែលទឹកទន្លេមេគង្គ និងសឹងតែអាចទៅដល់ប្រទេសវៀតណាមដោយសុវត្ថិភាពទៀតផង។ ម៉ាត់ លី បាននិយាយថា ពួកខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីកោះនេះ បានវាយកម្ទេចភូមិនោះចោល និងបានផ្លាស់ប្តូរឈ្មោះរបស់កោះនេះពីកោះផលទៅជាកោះផេះ។

ប្រាំពីរថ្ងៃក្រោយមក មានការផ្ទុះឡើងនូវអំពើហិង្សាមួយផ្សេងទៀតនៅភូមិស្វាយឃ្លាំង ដែលនៅក្បែរនោះ។ អ្នកភូមិដែលប្រដាប់ដោយកាំបិតបានសម្លាប់មេបញ្ជាការខ្មែរក្រហម និងទាហានពីរនាក់។ ម៉ាត់ លី បានបញ្ជាក់ថា ពួកកងទ័ពបានសងសឹកវិញដោយការសម្លាប់រង្គាលអ្នកភូមិ ៧០ ភាគរយ[77]។

យ៉ាសយ៉ា អាស្មាស់ ជនជាតិចាមម្នាក់បច្ចុប្បន្នរស់នៅក្នុងទីក្រុងញូវយ៉ក គឺជាសិស្សម្នាក់នៅ "សាលាមូលដ្ឋានសម្រាប់អ្នកសិក្សាឥស្លាមនៅកម្ពុជា" នៅភូមិជំនីក ក្នុងស្រុកក្រូចឆ្មាររហូតដល់ចុងឆ្នាំ ១៩៧៣ នៅពេលដែលគាត់បានភៀសខ្លួនទៅកាន់ប្រទេសវៀតណាម។ នៅឆ្នាំ ១៩៧៩ អាស្មាស់ បានវិលត្រឡប់មកតំបន់នេះវិញ និងបានទៅលេងកោះផល។ គាត់បានដឹងថា "គ្មាននរណាម្នាក់រស់នៅទីនោះ ទៀតឡើយ"។ ប៉ុន្តែគាត់បានឮដំណើររឿងដូចខាងក្រោមពីប្រជាជនចាមក្នុងស្រុក៖

---

[76] Francois Ponchaud, *កម្ពុជាឆ្នាំសូន្យ* (ឡុងដ៍ ឆ្នាំ ១៩៧៨) ទំព័រ ១៥៣-៥៤។

[77] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ម៉ាត់ លី (សូមមើលកំណត់ចំណាំលេខ ៥៩)។ ការសិក្សាផ្អែកជាចម្បងលើបទសម្ភាសន៍បន្ថែមទៀតចំនួន ២៩ ដែលបានធ្វើឡើងដោយអ្នកនិពន្ធជាមួយជនជាតិចាមដែលបានរស់ឆ្លងកាត់សម័យកម្ពុជាប្រជាធិបតេយ្យ។ បទសម្ភាសន៍ទាំងអស់ត្រូវបានថតសំឡេងទុកនៅក្នុងភូមិនានាក្នុងប្រទេសកម្ពុជា ភាគច្រើននៅក្នុងឆ្នាំ ១៩៨០។ បទសម្ភាសន៍រាប់សិបផ្សេងទៀតត្រូវបានធ្វើឡើងដោយមិនមានការថតសំឡេងទុក។ បទសម្ភាសន៍ចំនួន ៥០ បន្ថែមទៀតត្រូវបានធ្វើឡើងក្រោយមកជាមួយជនភៀសខ្លួនចាមដោយ Nate Thayer (ក្នុងប្រទេសថៃ) និង Dan Dickason (ក្នុងសហរដ្ឋអាមេរិក)។ ការថតសំឡេងនៃការសន្ទនាទាំងនេះបានបង្ហាញថាមានប្រយោជន៍ និងជំរុញដល់ការសិក្សាបន្ថែមទៀត។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ក្នុងពេលកន្លងមក មានគ្រួសារចាមប្រមាណ ៣៥០ គ្រួសាររស់នៅលើកោះផល ហើយកោះនេះអ៊ូអរណាស់។ នៅឆ្នាំ ១៩៧៥ ពួកខ្មែរក្រហមបានស្នើឱ្យមេដឹកនាំសាសនាចាមនៅក្នុងភូមិនោះបិទវិហារឥស្លាម និងសាលារៀនឥស្លាមក្នុងរយៈពេលមួយសប្តាហ៍។ ប្រជាជននៅក្នុងភូមិនោះគឺជាសហគមន៍ដ៏រឹងមាំ គឺជាអ្នកមានជំនឿយ៉ាងខ្លាំង ហើយពួកគេមិនបានបិទវិហារ ឬសាលាឥស្លាមនោះទេ។ ដូច្នេះ បន្ទាប់ពីមួយសប្តាហ៍ នៅពេលដែលពួកខ្មែរក្រហមចូលមកម្តងទៀត ក៏មានការប្រយុទ្ធគ្នា .... ប្រជាជនបានសម្លាប់ពួកខ្មែរក្រហមប្រាំនាក់ .... ពួកខ្មែរក្រហមបានបញ្ជូនកងទ័ពរាប់ពាន់នាក់ទៅកាន់ភូមិនោះ និងបានយកក្រុមគ្រួសារចាមទាំងអស់ចេញពីភូមិ .... ពួកគេបានបំផ្លាញភូមិទាំងមូលដោយប្រើកាំភ្លើងធំ។

ប្រជាជនជម្លៀសពីកោះផលមួយចំនួន ត្រូវបាននាំទៅភាគខាងត្បូងឆ្ពោះទៅតំបន់តំបែរគោកស្រុកនៃស្រុកត្បូងឃ្មុំ។ នៅទីនោះពួកគេបានប្រាប់បងប្អូនចាមម្នាក់ ឈ្មោះ សប់ ខាទីដយ៉ាស់ បន្ទាប់មក បងប្អូនចាមម្នាក់អាយុសែសិបប្រាំបួនឆ្នាំដែលជាអ្នកជម្លៀសចេញពីទីក្រុងភ្នំពេញ នូវអ្វីដែលបានកើតឡើង។ នាងនិយាយថា៖

> ពួកគេប្រឆាំងដោយសារតែពួកគេខឹងខ្លាំង។ ពួកគេបានជួបការលំបាកអស់រយៈពេលជាយូរមកហើយ ដោយធ្វើការជាមួយ ប៉ុល ពត អស់រយៈពេលជាច្រើនឆ្នាំ ដើម្បីប្រឆាំងទល់នឹងកងទ័ព លន់ នល់ ... ហេតុដូច្នេះ ពួកគេគួរណាស់តែមានមុខតំណែងកាន់អំណាចបន្ទាប់ពីទទួលបានជ័យជម្នះ។ ... ប្រជាជនចាមនៅក្នុងភូមិគឺជាពួកខ្មែរក្រហម។ ចាម និងខ្មែរគឺរាក់ទាក់នឹងគ្នាល្អណាស់។ ប៉ុន្តែនៅពេលដែលពួកគេបានឈ្នះ ពួកគេត្រូវបានគេដកហូតអាវុធ ហើយសាសនារបស់ពួកគេត្រូវបានលុបបំបាត់ចោល .... ចាមគឺជាទាហានខ្មែរក្រហម បន្ទាប់ពីបានកាន់កាប់ទីក្រុងភ្នំពេញ ពួកគេត្រូវបានគេដកហូតអាវុធ ពួកគេត្រូវបានប្រាប់ថាឱ្យធ្វើខ្លួនឱ្យសកម្ម ... [?] កាំភ្លើងទាំងអស់របស់ពួកគេត្រូវបានដកយកមកវិញពីប្រជាជនចាម។ ... ប្រជាជនក្នុងតំបន់ [ក៏] ខឹងផងដែរថា បន្ទាប់ពីការតស៊ូជាប់ជាមួយគ្នា [ជាមួយនឹងពួកខ្មែរក្រហម] ពួកគេឥឡូវនេះត្រូវហូបរួមគ្នា។ ប៉ុន្តែ នៅតែពួកខ្មែរក្រហមដកចេញនូវមនុស្សល្អ មនុស្សដែលរៀនសូត្រពីសាសនា ហើយយកពួកគេទៅសម្លាប់ចោលដដែល។

ប្រជាជនបានក្រោកឈរឡើងកាន់កាំបិត និងដាវប្រឆាំងនឹងពួកខ្មែរក្រហមនៅក្នុងភូមិនោះ [កោះផល]។ ការវាយប្រយុទ្ធគ្នាបានកើតឡើងនៅយប់មួយ ហើយពួកខ្មែរក្រហមចំនួន ២៨ នាក់ត្រូវបានសម្លាប់ដោយប្រជាជនចាម ដោយប្រើកាំបិត និងស្នឹង។ ពួកខ្មែរក្រហមក៏បានបាញ់តបទៅវិញដោយប្រើកាំភ្លើង ហើយប្រជាជនចាមជាច្រើនបានស្លាប់ ច្រើនជាងពួកខ្មែរក្រហមទៅទៀត។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

លុះនៅពេលព្រឹកព្រលឹម ពួកខ្មែរក្រហមបានចងប្រជាជន ហើយបាននាំពួកគេចេញទៅសម្លាប់នៅកណ្ដាលទន្លេ។ ប្រហែលជាមនុស្សរាប់រយនាក់បានស្លាប់ ទូកដែលដាក់មនុស្សពេញ ២ ឬ ៣ ត្រូវគេយកចេញជារៀងរាល់ថ្ងៃ។ សូម្បីតែអ្នកដែលឈឺនៅក្នុងផ្ទះរបស់ពួកគេក៏ត្រូវដាក់នៅលើទូក និងច្រានចូលទៅក្នុងទឹកដែរ។ នោះឯងជាអ្វីដែលខ្ញុំបានឮ។

កប់ ម៉ាត់ ប្រជាជនចាមម្នាក់មកពីខេត្តក្រចេះដែលកាន់តែនៅលើទន្លេមេគង្គទៀត ក៏បានឮអំពីការបះបោរនៅកោះផលនេះដែរ។ ក្នុងអាយុម្ភៃឆ្នាំនៅពេលនោះ ម៉ាត់ គឺជាប្រជាជនមូលដ្ឋានម្នាក់មកពីស្រុកឆ្លូង។ គាត់បាននិយាយថា ប្រជាជនចាមក្នុងមូលដ្ឋានជាច្រើនបានចូលប្រយុទ្ធក្នុងជួរកងទ័ព និងកងឈ្លបរបស់ខ្មែរក្រហម ហើយពួកគេបានបះបោរប្រឆាំង នៅពេលពួកគេដឹងពីផែនការរបស់របបកម្ពុជាប្រជាធិបតេយ្យក្នុងការហាមឃាត់មិនឱ្យមានសាសនា និងភាសារបស់ពួកគេ បង្ខំពួកគេឱ្យហូបសាច់ជ្រូក និងបំបែកសហគមន៍ចាម។ ម៉ាត់ និយាយថា នៅពេលងើបបះបោរនោះ ពួកខ្មែរក្រហមប្រហែលម្ភៃនាក់ និងប្រជាជនចាម_ហាសិប_នាក់ត្រូវបានសម្លាប់ ខណៈពេលដែលប្រជាជនចាមជាច្រើននាក់ផ្សេងទៀតត្រូវបានសម្លាប់នៅក្នុងការសងសឹកក្រោយមក។

លោក Ponchaud បានរាយការណ៍នូវដំណើររឿងមួយផ្សេងទៀតពីតំបន់តែមួយនោះ។ គាត់បាននិយាយថា នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ប្រជាជនចាមនៅភូមិទ្រា ស្រុកក្រូចឆ្មារ បានបះបោរ។ "បន្ទាប់មក ពួកខ្មែរក្រហមបានហែកភូមិនោះជាចំរៀកៗដោយប្រើ B-40s និងវាយកម្ទេចក្បាលអ្នកដែលនៅរស់រានមានជីវិតទាំងអស់ដោយចបត្រសេះ។ សាកសពត្រូវបានគេបោះចោលមួយឡែក និងទុកចោល។ ពួកគេថែមទាំងបានដោតក្បាលជាប់នឹងចម្រូងឫស្សី និងដាក់តាំងបង្ហាញក្បាលទាំងនោះតាមបណ្ដោយច្រាំងទន្លេមេគង្គទៀតផង"[78]។

នេះមិនទំនងជាដំណើររឿងដែលសាក្សីបានឃើញដោយផ្ទាល់ភ្នែកនោះឡើយ ហើយគេត្រូវតែថ្លែងថា ការទទួលបានដំណើររឿងមួយបែបនេះគឺជារឿងដែលមិនអាចទៅរួចឡើយ។ លទ្ធផលមួយគឺថា កងទ័ពដែលពិតជាបានចូលរួមយ៉ាងប្រាកដនៅក្នុងឧប្បត្តិហេតុនានានៃការបង្ក្រាប មិនត្រូវបានកំណត់អត្តសញ្ញាណបានឡើយ។ ពួកគេគួរណាស់តែជាកងទ័ពភូមិភាគបូព៌ា ប៉ុន្តែមិនថាពួកគេគឺជាកងកម្លាំងថ្នាក់ភូមិភាគ ឬថ្នាក់តំបន់នោះទេ គេនៅតែមិនស្គាល់ដដែល។ លោក ហែម សាមីន ដែលក្រោយមកជាអ្នកទោសនយោបាយនៅក្នុងភូមិភាគនោះ បានស្ដីបន្ទោសលើលេខាភូមិភាគបូព៌ារបស់បក្សកុម្មុយនីស្តកម្ពុជាដោយផ្ទាល់ថា៖ "សកម្មភាពលើជន

Formatted: Condensed by 0.4 pt
Formatted: Condensed by 0.4 pt
Formatted: Condensed by 0.4 pt

[78] Ponchaud, *កម្ពុជាឆ្នាំសូន្យ* ទំព័រ ១៥៣។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01199562-01199594

ជាតិចាម ជនជាតិមូស្លីមនៅតាមតំបន់នានាតាមបណ្ដោយច្រាំងទន្លេ ជុំវិញភូមិទ្រា និងកន្លែងផ្សេងៗទៀត គឺជាបញ្ជាមកពី សោ ភឹម។ គាត់គឺពិតជាសាហាវខ្លាំងណាស់”[79]។

ម្យ៉ាងវិញទៀត រដ្ឋបាលក្នុងតំបន់ ២១ ត្រូវតែទទួលខុសត្រូវយ៉ាងខ្លាំង។ តំបន់នេះត្រូវបានដឹកនាំដោយ សេង ហុង (ហៅ ចាន់) ដែលនៅចុងឆ្នាំ ១៩៧៥ ត្រូវបានគេតែងតាំងជាលេខារងតំបន់ ដែលជាក់ស្ដែងដោយ ប៉ុល ពត ជំនួសឲ្យ បេក្ខជន សោ ភឹម ខ្លួនឯង ក្នុងកំណែទម្រង់ដ៏សំខាន់មួយនៃគណៈកម្មាធិការបក្សតំបន់។ សេង ហុង គឺជាមេដឹកនាំភូមិភាគបូព៌ាតែម្នាក់គត់ដែលនៅរស់រានមានជីវិតឆ្លងផុតរបបកម្ពុជាប្រជាធិបតេយ្យ ដោយគ្មានការបះបោរ[80]។ បន្ទាប់ពីការឡើងកាន់តំណែងរបស់គាត់នៅចុងឆ្នាំ ១៩៧៥ សមាជិកថ្មីមួយរូបនៃគណៈកម្មាធិការបក្សតំបន់ ២១ គឺ អ៊ុច ប៊ុនឈឿន ដែលបានបះបោរនៅខែ ឧសភា ឆ្នាំ ១៩៧៨។ ដំណើររឿងនាឆ្នាំ ១៩៨០ របស់ ឈឿន គេចវេះពីការនិយាយរៀបរាប់អំពីអំពើហិង្សានៃការបង្ក្រាបប្រឆាំងនឹងប្រជាជនចាម នៅឆ្នាំ ១៩៧៥ ប៉ុន្តែបានសារភាពអំពីការលំបាកធ្ងន់ធ្ងរនានាដែលបានជួបប្រទះដោយប្រជាជនក្នុងស្រុកក្រូចឆ្មារថា៖ “នៅភូមិភាគបូព៌ាក៏លំបាកណាស់ដែរ ជាពិសេសសម្រាប់ប្រជាជនដែលរស់នៅតាមដងទន្លេ ដោយមានស្ថានភាពរស់នៅខ្វះខាតជាខ្លាំង .... តំបន់ដែលលំបាកជាងគេបំផុតក្នុងចំណោមតំបន់ទាំងអស់ គឺ ឆ្លូង/ក្រូចឆ្មារ ជាពិសេសក្រូចឆ្មារ។ នៅពេលដែលសួរជាពិសេសអំពីប្រជាជនចាម ឈឿន បានឆ្លើយតបដូចខាងក្រោម៖

> មិនមានគោលនយោបាយដែល [អនុញ្ញាតឲ្យមាន] ជនជាតិភាគតិចនោះទេ។ អ្នកគ្រប់គ្នាត្រូវគេដាក់ឲ្យនៅឡូកឡំជាមួយគ្នា។ មានពូជសាសន៍តែមួយគត់ គឺ ខ្មែរ ... ចាប់ពីការរំដោះនៅឆ្នាំ ១៩៧៥ មក។ ប៉ុល ពត គឺជិតស្និទ្ធខ្លាំងណាស់ទៅនឹងជនជាតិចារ៉ាយ និងជនជាតិភាគតិច [នៅតំបន់ខ្ពង់រាប] ផ្សេងទៀត ប៉ុន្តែគាត់បំបែកពូជសាសន៍ឥស្លាម។

មូលហេតុសម្រាប់រឿងនេះគឺថា ប្រជាជនមូស្លីមមានអង្គការមួយហៅថា “FULRO ចម្ប៉ា” ដើម្បីការពារផលប្រយោជន៍របស់ប្រជាជនមូស្លីម ដែលដឹកនាំដោយលោក ឡេស កាសេម អនុសេនីយ៍

Deleted: សៃ

[79] បទសម្ភាសន៍របស់ Stephen Heder ជាមួយ ហែម សាមីន នៅទីក្រុងភ្នំពេញ ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៨១។ ប្រតិចារឹក ត្រូវប្រគល់ជូនដោយភាពសប្បុរសពី Heder។

[80] សូមមើល Ben Kiernan, “មាន់ព្រៃ មាន់កសិដ្ឋាន និងក្អែកទឹក៖ ភូមិភាគបូព៌ារបស់កម្ពុជានៅក្រោមរបប ប៉ុល ពត” នៅក្នុង Chandler និង Kiernan, *បដិវត្តន៍* ទំព័រ ១៣៦-២១១ ជាពិសេស ទំព័រ ១៥៣ ff។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ឯកម្នាក់នៅទីក្រុងភ្នំពេញក្នុងរបប លន់ នល់។ ដូច្នេះ ប៉ុល ពត មិនជឿទុកចិត្តប្រជាជនមូស្លីមទេ។ បន្ទាប់ពីឆ្នាំ ១៩៧៥ នៅក្នុងកេរ្តិ៍ខ្មែររបស់អង្គការរដ្ឋ គឺគ្មានប្រជាជនមូស្លីមទេ[81]។

ភាពចលាចលដ៏អស្ចារ្យនៅតាមដងទន្លេមេគង្គក្នុងឆ្នាំ ១៩៧៥ គឺជាការឆ្លើយតបរបស់ប្រជាជនចាមក្នុងតំបន់ដែលពួកគេមានភាពខ្លាំងក្លាបំផុត ចំពោះយុទ្ធនាការរបស់រដ្ឋាភិបាលរបបកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងសាសនារបស់ពួកគេ រួមទាំងការធ្វើឃាតមេដឹកនាំរបស់ពួកគេទៀតផង។ ស្ថានីយសេអ៊ីអានៅស្ថានទូតអាមេរិកក្នុងទីក្រុងបាងកកបានអះអាងថា បានស្ទាក់ចាប់ការបញ្ជូនសារតាមវិទ្យុពីទីក្រុងភ្នំពេញដែលបញ្ជាឱ្យប្រហារជីវិតមេដឹកនាំចាមក្នុងភូមិនៅ "ផ្នែកកណ្តាលនៃប្រទេសកម្ពុជា"[82]។ រឿងនេះអាច ឬមិនអាចពន្យល់បានពីអំពើហិង្សាណាមួយនៅស្រុកក្រូចឆ្មារ ប៉ុន្តែវាបានបង្ហាញថា ការដឹកនាំរបស់ ប៉ុល ពត នៅក្នុងរដ្ឋធានីបានចូលរួមដោយផ្ទាល់នៅក្នុងការបង្ក្រាប សូម្បីតែនៅថ្នាក់ភូមិ។

នៅខែ ឧសភា ឆ្នាំ ១៩៧៨ នៅពេលដែលកងកម្លាំងសម្រាំងរបស់ភូមិភាគមជ្ឈិម និងភូមិភាគនិរតីរបស់ ប៉ុល ពត បានចូលមក និងបង្ក្រាបដោយហិង្សាលើភាគបូព៌ា ពួកគេមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើស្រុកក្រូចឆ្មារ។ អៀង ប្រជាជនខ្មែរតាមមូលដ្ឋានម្នាក់ ដែលបានធ្វើការឱ្យពួកខ្មែរក្រហមតាំងពីឆ្នាំ ១៩៧០ មកបានឱ្យដឹងថា ការធ្វើទុក្ខបុកម្នេញបានចាប់ផ្តើមនៅឆ្នាំ ១៩៧៥ ប៉ុន្តែ ការមកដល់នៃកងកម្លាំងភូមិភាគនិរតីនៅខែ ឧសភា ឆ្នាំ ១៩៧៨ នេះមានន័យថាស្មើនឹងការបង្ក្រាបយ៉ាងព្រៃផ្សៃ។ ពួកគេបានចាប់ផ្តើមដោយការចាប់ខ្លួន "កម្មាភិបាលទាំងអស់" និងសម្រេចឱ្យមាន "ការសម្លាប់ប្រជាជនដែលរក្សាទុកអំបិល ឬពោតនៅក្នុងផ្ទះរបស់ពួកគេ"។ "ពួកគេដេញតាមប្រជាជនកាត់តាមព្រៃ ប្រមាញ់ពួកគេតែម្តង"។

បើទោះបីជាការបង្ក្រាបប្រឆាំងនឹងប្រជាជនចាមនៅឆ្នាំ ១៩៧៥ ក្តី ក៏វាទំនងជាថា ជនជាតិចាមម្នាក់ដែលគ្មានឈ្មោះនៅតែជាសមាជិកនៃគណៈកម្មាធិស្រុកក្រូចឆ្មារបន្ទាប់ពីពេលនោះមក។ អៀង ទំនងជាសរសើរ សោ ភឹម តាមរបៀបនេះ។

សោ ភឹម គឺជាមនុស្សល្អម្នាក់។ បញ្ហាមុនឆ្នាំ ១៩៧៨ គឺបង្កឡើងដោយមេចៅហ្វាយស្រុកមួយចំនួនដែលធ្វើតាមបញ្ជារបស់ ប៉ុល ពត។ ... ចៅហ្វាយស្រុកខ្លះល្អ ខ្លះអាក្រក់ មុនឆ្នាំ ១៩៧៨។ នៅស្រុករបស់ខ្ញុំ ក្រូចឆ្មារ តា អៀម និងជនជាតិចាមម្នាក់ទៀតគឺជាសមាជិកនៃគណៈកម្មាធិការស្រុក។ ពួកគេ

[81] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ អ៊ុច ប៊ុនឈឿន នៅទីក្រុងភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៨០។

[82] Michael Vickery, "កម្ពុជាប្រជាធិបតេយ្យ៖ សេអ៊ីអាទៅកាន់ការជួយសង្គ្រោះ" *ព្រឹត្តិបត្ររបស់អ្នកស្រាវជ្រាវពាក់ព័ន្ធពីអាស៊ី* វ៉ុល ១៤ លេខ ៤ (ឆ្នាំ ១៩៨២) ទំព័រ ៤៥-៥៤ នៅទំព័រ ៤៧។

Deleted: *Unrevised translation. A revised translation will be provided upon request.*

ស្រឡាញ់ជាតិ និងប្រជាជនណាស់។ ... គ្រប់គ្នាចូលចិត្ត [អៀម] ណាស់នៅក្នុងស្រុកក្រូចឆ្មារ មិនដែលមានជម្លោះជាមួយគាត់នោះទេ។ ... អ្នកទាំងពីរនាក់នេះត្រឹមត្រូវ ចេះគួរសម។ ... នៅពេលដែលកងកម្លាំងភូមិភាគនិរតីចូលមកដល់ ពួកគេបានដុតអ្នកទាំងពីរនាក់នោះរហូតដល់ស្លាប់[83]។

**តារាង ១**

**ចំនួនអ្នកស្លាប់សរុបក្នុងចំណោមមេដឹកនាំឥស្លាមក្នុង**
**របបកម្ពុជាប្រជាធិបតេយ្យ**

| | |
|---|---|
| ហាក៏ម (មេដឹកនាំសហគមន៍) | ២០ នាក់នៅរស់ក្នុងចំណោម ១១៣ នាក់ |
| ហាក៏ម (អនុប្រធាន) | ២៥ នាក់នៅរស់ក្នុងចំណោម ២២៦ នាក់ |
| ហ័តជី (អ្នកធម្មយាត្រាទៅទីក្រុង Mecca) | ប្រហែលជា ៣០ នាក់នៅរស់ក្នុងចំណោម មនុស្សច្រើនជាង ១.០០០ នាក់ |
| គ្រូបង្រៀនសាសនានៅសាលាព្រះគម្ពីកូរ៉ាន | ៣៨ នាក់នៅរស់ក្នុងចំណោមប្រមាណ ៣០០ នាក់ |
| អ្នកបញ្ចប់ការសិក្សាពីវិទ្យាស្ថានឥស្លាមបរទេស | ២ នាក់នៅរស់ក្នុងចំណោម ២៥ នាក់ |
| សមាជិករបស់អង្គការឥស្លាមមជ្ឈិមនៅកម្ពុជា | ១ នាក់បាននៅរស់រានមានជីវិត |

ប្រភព៖ បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយនឹងមន្ត្រីចាមនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

## ២. ត្បូងឃ្មុំ

ដូចដែលយើងបានឃើញ សម្ព័ន្ធមិត្តរបស់ ប៉ុល ពត គឺ សេង ហុង (ហៅ ចាន់) គឺជាលេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំតំបន់ ២១ រហូតដល់ការឡើងតំណែងរបស់គាត់នៅចុងឆ្នាំ ១៩៧៥។ ដោយមានការបង្ក្រាបលើការបះបោរនៅពាក់កណ្តាលឆ្នាំ ១៩៧៥ ក្នុងស្រុកក្រូចឆ្មារ តំបន់ ២១ មានការសម្លាប់រង្គាលប្រជាជនចាមជាលើកដំបូងដោយរបបខ្មែរក្រហម។ ស្រុកផ្សេងទៀតក្នុងតំបន់ ២១ ដែលមានផ្ទះរបស់ប្រជាជនចាមជាច្រើនទៀតគឺត្បូងឃ្មុំ។

ពេលដែលអ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជារបស់ ប៉ុល ពត បានរំលាយចលនាឥស្លាមក្នុងភូមិភាគបូព៌ាក្នុងឆ្នាំ ១៩៧៤ ប្រធានចលនានេះ លោក សុះ ម៉ាន ត្រូវបានដាក់ក្រោមការឃុំខ្លួនក្នុងផ្ទះនិម្មិតនៅក្នុងភូមិមួយក្នុងស្រុកត្បូងឃ្មុំ តាមបណ្តោយផ្លូវជាតិលេខ ៧។ បើយោងតាមកូនប្រុសរបស់ ម៉ាន ឈ្មោះ ម៉ាត់ លី បានឱ្យ

[83] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ អៀង នៅកោះធំ ថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩៨០។ សូមមើលផ្នែក IIIA4 ដូចខាងក្រោម។

Deleted: ហាក់កែម

Deleted: ហាក់កែម

Deleted: *Unrevised translation. A revised translation will be provided upon request.*

ដឹងថា ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៤ សុះ ម៉ាន ទទួលបានទំនុកចិត្តពីមេដឹកនាំភូមិភាគបូព៌ារបស់បក្សកុម្មុយនីស្តកម្ពុជា សោ ភឹម ប៉ុន្តែ "ក្រោយមក សោ ភឹម បានស្តាប់បង្គាប់របស់ ប៉ុល ពត និងបានដក ទំនុកចិត្តរបស់គាត់វិញ ប៉ុន្តែបានកសាងផ្ទះមួយខ្ទង់ដែល សុះ ម៉ាន អាចរស់នៅបានដោយស្ងៀមស្ងាត់"។ ម៉ាន ត្រូវបានគេប្រាប់ថាគាត់ "ចាស់ពេក" មិនអាចធ្វើការឱ្យបដិវត្តន៍ទៀតបានទេ។ ទោះយ៉ាងណា នៅខែ កញ្ញា ឆ្នាំ ១៩៧៥ កូនប្រុសរបស់គាត់បាននិយាយថា មនុស្សចម្លែកពីរនាក់បានជិះម៉ូតូមកដល់ផ្ទះរបស់ ម៉ាន និងឱ្យ "ថ្នាំ" ទៅគាត់។ សុះ ម៉ាន បានទទួលយកថ្នាំ ហើយក៏បានស្លាប់នៅយប់នោះទៅ។ គាត់មានអាយុ ៧៣ឆ្នាំ[84]។ ដូចប្រជាជនចាមនៅស្រុកក្រូចឆ្មារដែរ ម៉ាត់ លី បានបន្តធ្វើជាសមាជិកគណៈកម្មាធិការស្រុកត្បូងឃ្មុំបន្តទៀតរហូតដល់ខែ ឧសភា ឆ្នាំ ១៩៧៨ ប៉ុន្តែបើយោងតាមលោក អ៊ុច ប៊ុនឈឿន សមាជិកនៃគណៈកម្មាធិការបក្សតំបន់ ២១ បានឱ្យដឹងថា លី ហាក់បីដូចជា "មនុស្សមានតែឈ្មោះ គឺគាត់គ្មានសេរីភាពទេ"[85]។ បើដូច្នេះ គាត់ជួបនឹងរឿងអាក្រក់មិនចាញ់ប្រជាជនចាមផ្សេងទៀតដែលនៅក្នុងតំបន់នោះទេ។

នៅខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ ការប្រតិបត្តិសាសនាត្រូវបានលុបបំបាត់ចោលនៅក្នុងស្រុកត្បូងឃ្មុំ ការហូបអាហាររួមគ្នាក៏ត្រូវបានដាក់ចេញ ហើយភូមិចាមនៅក្នុងតំបន់នោះក៏ត្រូវបានបំបែក។ បើយោងតាមលោក ទូន អ៊ីប្រាហ៊ីម ជនជាតិចាមម្នាក់ក្នុងតំបន់នោះដែលបានសិក្សានៅទីក្រុងគែរក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ បានឱ្យដឹងថា ទោះបីជាមិនទាន់មានការសម្លាប់ណាមួយកើតឡើងនៅក្នុងឃុំគរក្តី ក៏ការជម្លៀស និងបំបែកប្រជាជនចាមពីភូមិទាំងដប់ពីរក្នុងឃុំគរបង្ហាញថា "ប៉ុល ពត ចង់លុបបំបាត់ពូជសាសន៍ចាមចោល"។ គ្រួសារចាមជាងម្ភៃគ្រួសារត្រូវបានបណ្តេញចេញពីភូមិគរ ដែលធ្លាប់តែជាប្រជាជនចាមទាំងស្រុង។ ប្រាំគ្រួសារក្នុងចំណោមនោះត្រូវបានបញ្ជូនទៅភូមិធ្នង់ ដែលឆ្ងាយពីគ្នាបីគីឡូម៉ែត្រ ដែលសុទ្ធសឹងតែប្រជាជនខ្មែរ។ អ៊ីប្រាហ៊ីម បាននិយាយថា៖ "វាដូចជាប្រទេសដទៃមួយទៀតអញ្ចឹង។ គ្មានទំនាក់ទំនងជាមួយមនុស្សដែល_ត្រឡប់មកផ្ទះវិញទាល់តែសោះ លើកលែងតែនៅពេលដែលយើងត្រូវគេបញ្ជាឱ្យវិលត្រឡប់ទៅវិញដើម្បីចូល___រួមប្រជុំប៉ុណ្ណោះ"។ លើសពីនេះទៀត ក្រុមគ្រួសារខ្មែរមួយចំនួនក្នុងចំណោមគ្រួសារខ្មែរ ១០០ គ្រួសារ មកពី_ធ្នង់ត្រូវគេបញ្ជូនទៅភូមិគរ និងលាយឡំជាមួយប្រជាជនចាមដែលនៅសេសសល់នៅទីនោះ ដែលរាប់_បញ្ចូលទាំងហ៉ាតជីពីរនាក់ ដែលអ្នកទាំងពីរនាក់នោះនៅរស់រានមានជីវិតបានបួនឆ្នាំក្រោយមកទៀត។

[84] ម៉ាត់ លី, បទសម្ភាសន៍ (សូមមើលកំណត់ចំណាំលេខ ៥៩)។

[85] អ៊ុច ប៊ុនឈឿន, បទសម្ភាសន៍ (សូមមើលកំណត់ចំណាំលេខ ៨១)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ទោះជាយ៉ាងណា ភាគច្រើននៃប្រជាជនចាមដែលមកពីភូមិគរ ត្រូវបានបញ្ជូនតែម្តងឆ្លងកាត់ទន្លេមេគង្គទៅភូមិភាគកណ្តាល។ ប្រជាជនចាមទាំងនេះរួមបញ្ចូលទាំង ហ៉ាតជីប្រាំបួននាក់ ដែលម្នាក់ក្នុងចំណោមពួកគេគឺ ហ៉ាតជី សាអ៊ិ ដែលជាអតីតគ្រូបង្រៀនរបស់លោក ទូន អ៊ីប្រាហ៊ីម។ សាអ៊ិ ត្រូវបានគេសម្លាប់_នៅភូមិភាគកណ្តាល រួមជាមួយនឹងក្រុមគ្រួសាររបស់គាត់ ហើយ ហ៉ាតជីប្រាំបីនាក់ផ្សេងទៀត ដែលត្រូវគេជម្លៀសចេញពីភូមិគរក៏បានស្លាប់បាត់បង់ជីវិតនៅទីនោះផងដែរ។ អ៊ីប្រាហ៊ីម ក្រោយមកបានទទួលដំណឹង__ថា ម្នាក់ក្នុងចំណោមសមាជិកចំនួនប្រាំមួយនាក់ក្នុងគ្រួសាររបស់គាត់ក៏បានស្លាប់នៅទីនោះផងដែរ។

ទន្ទឹមនឹងនេះដែរ នៅក្នុងឃុំគរ ប្រជាជនចាមដែលបានចូលរួមជាមួយខ្មែរក្រហម និងដែលបានក្លាយជាប្រធានភូមិ សមាជិកគណៈកម្មាធិការភូមិ ឬប្រធានក្រុមការងារ ត្រូវបានគេដកចេញពីតំណែងទាំងនេះទាំងអស់ក្នុងអំឡុងឆ្នាំ ១៩៧៦។ នៅពាក់កណ្តាលឆ្នាំនោះ ការសម្លាប់ក៏បានចាប់ផ្តើម បើទោះបីជាមិនមានក្រុមជនជាតិពន្ធ ឬក្រុមការងារណាមួយត្រូវបានគេយកចេញទៅដើម្បីសម្លាប់ក៏ដោយ។ នៅចុងឆ្នាំ ១៩៧៦ ប្អូនប្រុសរបស់ អ៊ីប្រាហ៊ីម ត្រូវបានគេនាំចេញពីផ្ទះយកទៅសម្លាប់ចោល។

> នៅចុងឆ្នាំ ១៩៧៦ ប្រជាជនត្រូវបានគេនាំយកទៅឆ្ងាយតាមរទេះសេះ ហើយនៅចុងឆ្នាំ ១៩៧៧ ពួកគេនាំយកមនុស្សចេញទៅឆ្ងាយដោយប្រើឡានដឹកទំនិញ។ ឆ្នាំ ១៩៧៧ គឺជាឆ្នាំដែលគួរឱ្យភ័យខ្លាចខ្លាំងបំផុត។ ... ការសម្លាប់គឺក្លាយទៅជារឿងធម្មតាទូទៅ។ ... បន្ទាប់ពីការសម្លាប់ទាំងអស់នៅក្នុងឃុំរបស់យើងនៅឆ្នាំ ១៩៧៧ ពួកខ្មែរក្រហមអាចលែលកបន្ធូរបន្ថយការសម្លាប់ទាំងនេះបន្តិចនៅឆ្នាំ ១៩៧៨ ដោយសារតែពួកគេចាប់ផ្តើមជិះជាន់លើឃុំផ្សេងៗទៀត។

ឃុំមួយដែលនៅក្បែរនោះគឺ តំបែរ/គោកស្រុក កន្លែងដែល សប់ ខាទីជយ៉ាស់ បានមកដល់នៅខែ មិថុនា ឆ្នាំ ១៩៧៥ ជាមួយប្តីរបស់នាង កូនប្រុសពីរនាក់ កូនស្រីពីរនាក់ កូនប្រសារប្រុស និងចៅប្រុសរបស់នាង។ ម្តាយវ័យចំណាស់របស់នាង និងកូនប្រុសអាយុ ១៦ ឆ្នាំ ទាំងពីរនាក់បានស្លាប់នៅតាមផ្លូវធ្វើដំណើររយៈពេល ៥០ ថ្ងៃពីទីក្រុងភ្នំពេញ។ នៅខែ ឧសភា ក្រុមគ្រួសាររបស់នាងបានឆ្លងកាត់ភូមិចាមចំនួនពីរនៅភាគខាងកើតស្រុកត្បូងឃ្មុំ គឺភូមិបឹងព្រួល និងជីរោ។ នៅទីនោះធ្លាប់មានវិហារអ៊ីស្លាមចំនួនពីរ ប៉ុន្តែឥឡូវនេះត្រូវបានបំផ្លាញចោលអស់ហើយ។ អ្នកស្រុកបានប្រាប់ ខាទីជយ៉ាស់ ថា វិហារទាំងពីរនោះត្រូវបានរុះរើដោយពួកខ្មែរក្រហម នៅពេលដែលពួកគេបានគ្រប់គ្រងលើតំបន់នេះក្នុងឆ្នាំ ១៩៧៣-៧៤។ ជាក់ស្តែងឈើត្រូវបានគេប្រើប្រាស់ដើម្បីសាងសង់រោងបាយសម្រាប់ហូបរួមគ្នា។ ជីរោ គឺជាភូមិរបស់ម្តាយនាង៖ ក្រុមគ្រួសារចាមទាំង ១២០ គ្រួសារនៅ នៅទីនោះត្រូវបានជម្លៀសចេញ និងបំបែក។ រឿងដូចគ្នានេះដែរបានកើតឡើងចំពោះក្រុមគ្រួសារចាមចំនួន ២៨០ គ្រួសារ នៅភូមិថាមទូ ដែលនៅក្បែរនោះ។ ហាក់កែមម្នាក់មកពីភូមិបឹងព្រួល គឺ ហ៉

Deleted: *Unrevised translation. A revised translation will be provided upon request.*

តជី អ៊ីស្មាអែល និងប្រពន្ធរបស់គាត់ត្រូវបានបញ្ជូនទៅភាគខាងកើតទៅឃុំតំបែរ/គោកស្រុក រួមជាមួយនឹងក្រុមគ្រួសាររបស់ ខាទីដយ៉ាស់ និងប្រជាជនចាមផ្សេងទៀតជាច្រើន។ បន្ទាប់មក ពួកគេត្រូវបានដាក់ឲ្យនៅរួមគ្នាជាមួយប្រជាជនចាមដែលគេជម្លៀសចេញពីកោះផលនៅក្នុងស្រុកក្រូចឆ្មារ។

ពួកគេត្រូវបានបញ្ជូនទៅវាលអណ្ដើក ដែលជាភូមិ "ខ្មែរសុទ្ធ" ប៉ុន្តែមុនដំបូង ប្រជាជនចាមយ៉ាងហោចណាស់អាចប្រតិបត្តិសាសនាឥស្លាមរបស់ខ្លួនបាន។ បើទោះជាមានការហាមឃាត់ជាទូទៅពីសំណាក់ពួកខ្មែរក្រហមមិនឲ្យមានការអធិដ្ឋានក្តី ក៏មន្ត្រីមូលដ្ឋានប្រាប់ ខាទីដយ៉ាស់ ថា ប្រជាជនចាមអាចអធិដ្ឋានដាច់ឡែកពីគេបាន ដរាបណាវាមិនប៉ះពាល់ដល់ការអនុវត្តការងាររបស់ពួកគេ។ ខាទីដយ៉ាស់ ត្រូវគេដាក់ឲ្យធ្វើការជាអ្នកថែសំណាបស្រូវ ដើម្បីប្តូរមកវិញជារបបអង្ករ។ ហ៊ាតជី អ៊ីស្មាអែល សម្រាប់ការងារគាត់វិញ ត្រូវគេលើកលែងសូម្បីតែពីការងារ ដោយសារតែភក្តីភាពចំពោះសាសនារបស់គាត់ គាត់ត្រូវបានចាត់ទុកថា "មនុស្ស_ឆ្កួត" ដោយពួកខ្មែរក្រហម ហើយថែមទាំងឲ្យប្រពន្ធរបស់គាត់នៅផ្ទះថែទាំគាត់ទៀតផង។ ពួកគេនៅតែអាចនិយាយភាសាចាមជាមួយគ្នាទៅវិញទៅមកជាលក្ខណៈឯកជនដដែល គ្រាន់តែប្រឈមមុខនឹងការយកទៅ__កសាង ប្រសិនបើពួកខ្មែរក្រហមស្តាប់ឮពួកគេនិយាយ ហើយពួកគេក៏អាចស្លៀកសម្លៀកបំពាក់ប្រពៃណីចាម_ផងដែរ។

នៅខែ សីហា ឆ្នាំ ១៩៧៥ ប្តី និងកូនប្រសារប្រុសរបស់ ខាទីដយ៉ាស់ ត្រូវគេសម្លាប់។ ពួកគេទាំងពីរនាក់ត្រូវបានចាប់ខ្លួននៅថ្ងៃជាមួយគ្នា និងយកទៅ "កសាង" នៅក្នុងភូមិមួយក្បែរនោះ ប៉ុន្តែពួកគេមិនដែលបានត្រឡប់មកវិញទេ។ ខាទីដយ៉ាស់ និយាយថា ពួកខ្មែរក្រហមបានសន្មតថា ពួកគេធ្លាប់ជាទាហាន ឬប៉ូលីសក្នុងរបប លន់ នល់ ដោយសារតែសម្លៀកបំពាក់ពណ៌កាគីរបស់ពួកគេ។ តាមពិត ពួកគេទើបតែចាកចេញពីទីក្រុងភ្នំពេញ ដោយពាក់ឯកសណ្ឋានកាគីរបស់យានដ្ឋានដែលពួកគេធ្វើការជាអ្នករៀនធ្វើជាមួយ។ បន្ទាប់ពីពួកគេត្រូវបាននាំយកទៅ ខាទីដយ៉ាស់ និយាយថា៖ "ខ្ញុំបានសួរអ្នកស្រុក អ្នកជិតខាងរបស់ខ្ញុំ (ថាតើមានរឿងអ្វីកើតឡើងចំពោះពួកគេ)។ ពួកគេបាននិយាយថា៖ "មិនបាច់សង្ឃឹមទេ មីង។ ពួកគេមិនមែនទៅធ្វើអីទេ (ដូចជា "កសាង")។ ពួកគេទៅឲ្យគេសម្លាប់នឹងស្នឹង និងចប"។ ខាទីដយ៉ាស់ និងកូនស្រីរបស់នាងឥឡូវនេះគឺជាស្ត្រីមេម៉ាយ។ ពួកគេត្រូវមើលថែទាំចៅប្រុសម្នាក់អាយុបួនឆ្នាំ កូនស្រីម្នាក់ទៀតរបស់ ខាទីដយ៉ាស់ អាយុដប់មួយឆ្នាំ និងកូនប្រុសទាំងពីរ ដែលមានអាយុប្រាំបីឆ្នាំ និងបួនឆ្នាំ។

ក្រោយមកប្រហែលជាមួយឆ្នាំ នៅភូមិវាលអណ្ដើក ស្ថានភាពស្រាប់តែប្រែក្លាយកាន់តែអាក្រក់ឡើងៗសាជាថ្មីទៀត។ ពេលមួយនៅក្នុងឆមាសទីមួយនៃឆ្នាំ ១៩៧៦ កិច្ចប្រជុំបានប្រមូលហៅមនុស្សគ្រប់គ្នា ទាំង ខ្មែរ ចាម និងចិន ដែលរស់នៅក្នុងតំបន់នោះ។ មន្ត្រីខ្មែរក្រហមក្នុងមូលដ្ឋានជាច្រើនត្រូវបានអញ្ជើញ សូម្បីតែ

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ចៅហ្វាយស្រុក។ គេបានប្រាប់ទៅហ្វូងមនុស្សថា៖ “ឥឡូវនេះយើងកំពុងស្ថិតក្នុងឆ្នាំ ១៩៧៦ ហើយ យើងត្រូវតែដើរតាមផែនការផ្សេងមួយទៀត” ហើយ “គ្មានចាម គ្មានចិន ឬយួនអ្វីទេ។ គ្រប់គ្នាត្រូវចូលរួមដូចគ្នា តែមួយគឺជនជាតិខ្មែរ”។ ត្រូវតែមាន “សាសនាតែមួយគត់ គឺសាសនាខ្មែរ” បើទោះបីជា ខាទីដយ៉ាស់ បានកត់សម្គាល់ថា វត្តអារ៉ាមត្រូវបានបោសសម្អាតចោលគ្មានសល់យ៉ាងណាក៏ដោយ ហើយ “លែងមានសាសនាណាមួយ” ត្រូវបានអនុញ្ញាតឱ្យគោរពទៀតទេ។ ការធ្វើដំណើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយត្រូវបានហាមឃាត់។

ការនិយាយភាសាចាមត្រូវបានគេហាមឃាត់យ៉ាងច្បាស់៖ “យើងមិនត្រូវបានអនុញ្ញាតឱ្យប្រើពាក្យ [ចាម] *yas* [ម្តាយ] ឬ *chik* [ឪពុក] ដើម្បីហៅឪពុកម្តាយរបស់យើងឡើយ។ យើងត្រូវប្រើពាក្យ [ខ្មែរ] ម៉ែ និងពុក”។ បន្ថែមទៀត ការហូបអាហាររួមគ្នាឥឡូវនេះត្រូវបានគេដាក់ចេញ ហើយគេប្រាប់ប្រជាជនចាមថា ពួកគេត្រូវបរិភោគអាហារដូចគ្នា “ស្មើ” គ្នានឹងអ្នកផ្សេងៗទៀត។ ប្រជាជនចាមគ្រប់រូបត្រូវមានកាតព្វកិច្ចជួយចិញ្ចឹមជ្រូក ក្រុមចាមត្រូវប្តូរវេនគ្នារៀងរាល់សប្តាហ៍សម្រាប់ទ្រុងជ្រូកមួយ ហើយ ក្រុមខ្មែរនៅទ្រុងមួយទៀត។ ទោះជាយ៉ាងណា ចាស់ៗជនជាតិចាមត្រូវបានអនុញ្ញាតឱ្យតមមិនបរិភោគសាច់ជ្រូកបាន ដរាបណាពួកគេមិនប្រើប្រាស់ការខ្វះខាតអាហាររូបត្ថម្ភមិនដាច់ខាតរបស់ខ្លួនធ្វើជាហេតុផលមួយ ដើម្បីធ្វើការងារតិចនោះ។ ខាទីដយ៉ាស់ ខ្លួនឯងមិនចាំបាច់ត្រូវហូបមុខម្ហូបណាដែលដាក់សាច់ជ្រូកនោះឡើយ ព្រោះក្មួយប្រុសរបស់នាងគឺប្រធានកងរបស់នាង។ គេក៏ហាមឃាត់មិនឱ្យបង្រៀនជនជាតិចាមវ័យក្មេងៗឱ្យចៀសវាងហូបសាច់ជ្រូកផងដែរ។ ស្ត្រីចាមត្រូវបានហាមឃាត់មិនឱ្យទុកសក់វែងឡើយ។ សម្លៀកបំពាក់ និងបុណ្យសពតាមបែបប្រពៃណីចាមត្រូវបានហាមឃាត់មិនឱ្យមានផងដែរ។ នៅពេលសួរថា តើអ្វីទៅជាសាវតារនៅពីក្រោយការផ្លាស់ប្តូរទាំងនេះនៅក្នុងគោលនយោបាយនៅលើផ្នែកមួយនៃរបបខ្មែរក្រហម ខាទីដយ៉ាស់ បានរៀបរាប់អំពីការបះបោរនៅកោះផលកាលពីឆ្នាំមុន។

កូនស្រីដែលនៅលីវរបស់ ខាទីដយ៉ាស់ ត្រូវបានចុះឈ្មោះចូលក្នុងកងនារី និងនៅឆ្ងាយពីផ្ទះក្នុងរយៈពេលពីពីរទៅបីខែម្តង។ កូនក្មេងតូចៗក៏ត្រូវបាននាំយកទៅឆ្ងាយពីផ្ទះផងដែរ នាងអាចនឹងជួបពួកគេបានតែរៀងរាល់ពីរបីសប្តាហ៍ម្តងប៉ុណ្ណោះ។ ខាទីដយ៉ាស ខ្លួននាងផ្ទាល់ភាគច្រើនធ្វើការខាងច្រូតស្រូវសម្រាប់ពេលដែលនៅសល់នៃឆ្នាំ ១៩៧៦ ហើយនៅក្នុងឆ្នាំ ១៩៧៧ នាងបានដាំស្រូវ និងថែបន្លែផងដែរ។ របបអាហារទាបបំផុតជាងពេលណាៗទាំងអស់គឺនៅក្នុងឆ្នាំ ១៩៧៧។ នាងមានអាយុ ៥១ ឆ្នាំនៅពេលនោះ ប៉ុន្តែនាងត្រូវធ្វើការយ៉ាងលំបាក “រែក ៣០ អំរែករាល់ព្រឹក និង ៣០ អំរែករាល់ល្ងាច”។ អ្នករួមការងារម្នាក់ដែលជាស្ត្រីដែលមានអាយុ ៦២ ឆ្នាំ បានដួលស្លាប់ដោយសារតែការអស់កម្លាំង ខណៈពេលដែលកំពុងជីកដីដោយចបជីក។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

កូនស្រីមេម៉ាយរបស់ ខាទីដយ៉ាស់ ត្រូវបានគេបញ្ជូនឲ្យទៅកាប់ឈើនៅក្នុងព្រៃ។ នៅចុងឆ្នាំ ១៩៧៧ នាងត្រូវបានដើមឈើធ្លាក់សង្កត់លើ។ បន្ទាប់ពីក្អកធ្លាក់ឈាមអស់រយៈពេលប្រាំបួនខែ នាងបានស្លាប់ ដោយសារការរងរបួសរបស់នាង។ សូម្បីតែសមាជិកគ្រួសារក៏មិនត្រូវបានអនុញ្ញាតឲ្យទាមទារសាកសពរបស់នាងពីមន្ទីរពេទ្យបានដែរ។ ដោយទុករបបដ៏អាក្រក់នេះមួយឡែក គេមិនឃើញមានការសម្លាប់ទៅលើអ្នកភូមិឡើយបន្ទាប់ពីមានការសម្លាប់ពីរដងនៅខែ សីហា ឆ្នាំ ១៩៧៥ មក។ ប៉ុន្តែ មានម្តងនោះ ពួកទាហានខ្មែរក្រហមបានឃើញ ខាទីដយ៉ាស់ កំពុងអធិដ្ឋាន។ "ពួកគេបានមើលខ្ញុំ ហើយនិយាយថា៖ "លោកយាយ តើយាយចូលចិត្តកាំភ្លើង ឬចូលចិត្តអធិដ្ឋាន?" មានតែ ហ៉តជី អ៊ីស្មាអែល ប៉ុណ្ណោះដែលត្រូវបានគេអនុញ្ញាតឲ្យបន្តធ្វើអធិដ្ឋានប្រចាំថ្ងៃរបស់គាត់។

ទោះបីជាមានការបង្ក្រាបជាទូទៅលើវប្បធម៌ចាមក៏ដោយ ក៏ប្រជាជនចាមត្រូវតែចូលរួមកិច្ចប្រជុំដាច់ដោយឡែកពីប្រជាជនខ្មែរ ដែលផ្ទុយទៅវិញត្រូវគេបែងចែក ជាប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី។ (ជាក់ស្តែងប្រជាជនចាមនៅកោះផលលែងត្រូវបានគេចាត់ទុកថាជាប្រជាជនមូលដ្ឋានទៀតហើយ)។ នៅកន្លែងប្រជុំរបស់ពួកគេ ប្រជាជនខ្មែរត្រូវបានគេប្រាប់ តាមពាក្យរបស់ ខាទីដយ៉ាស ថា៖ "កុំទុកចិត្តចាម។ ពួកគេគឺដូចជាខ្មាំងសត្រូវដែលយើងធ្លាប់បានផ្តួលដូចនោះដែរ។ ... វាជារឿងធម្មតាដែលថា ខ្មាំងសត្រូវដែលត្រូវគេផ្តួលនឹងមិនដេកនៅស្ងៀមនោះទេ។ ... នៅក្នុងចិត្តរបស់ពួកគេ ពួកគេនៅតែជាជនក្បត់ចំពោះពួកយើង"។

នៅរវាងខែ ឧសភា ឆ្នាំ ១៩៧៨ ឧទ្ធម្ភាគចក្រមួយបានហោះនៅពីលើ និងបានទម្លាក់ខិត្តប័ណ្ណជាច្រើននៅក្នុងភូមិ។ ខិត្តប័ណ្ណទាំងនោះបានប្រកាសថា ពួកខ្មែរក្រហមភូមិភាគបូព៌ាត្រូវតែលុបបំបាត់ចោល ព្រោះពួកគេកំពុងធ្វើការជាមួយវៀតណាម ពោលគឺ "កំពុងជួយពួកគេជាមួយនឹងឱសថ ក្រណាត់ និងចបជីក"។ កងកម្លាំងភូមិភាគនិរតីបានមកដល់ជំនួសឲ្យក្រុមមន្ត្រី និងកងឈ្លបក្នុងមូលដ្ឋានជាច្រើន សូម្បីតែគ្រូបង្រៀនហើយក៏សម្លាប់ពួកគេចោល។ មន្ត្រីម្នាក់ក្នុងចំណោមមន្ត្រីថ្មីៗទាំងនេះឥឡូវនេះបានសម្រេចថា ហាក់កែម ហ៉តជី អ៊ីស្មាអែល បានប្រឆាំងនឹងបំរាមអំពីសាសនា ហើយដូច្នេះ គួរតែយកទៅធ្វើជាជី។ ទាំងគាត់ និងប្រពន្ធរបស់គាត់ត្រូវបានគេសម្លាប់ចោល។

នៅខែ កក្កដា ឆ្នាំ ១៩៧៨ ខាទីដយ៉ាស់ និងគ្រួសាររបស់នាងត្រូវបានគេបង្ខំឲ្យផ្លាស់ទីលំនៅជាថ្មីម្តងទៀត ត្រឡប់ទៅភូមិថាមទូ ក្នុងឃុំថ្មពេជ្រ។ ប៉ុន្តែ ការសម្លាប់មនុស្សនៅតែបន្តដដែលនៅទីនោះ។ ក្នុងរយៈពេលប្រាំមួយខែក្រោយ គ្រួសារចាមចំនួន ១២ គ្រួសារត្រូវបានសម្លាប់ចោល ដែលជាសរុបមានមនុស្ស៣០ នាក់។ ថាមទូ ជាអតីតភូមិចាមមួយដែលធ្លាប់ត្រូវបានគេបោសសម្អាត ប៉ុន្តែ ឥឡូវនេះត្រូវបានគេដាក់ឲ្យតាំងទីលំនៅជាថ្មីដោយ "គ្រួសារប្រហែលជា ២.០០០ គ្រួសារ" ដែលភាគច្រើនគឺជាប្រជាជនចាម ដែលប្រហែលជា

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ជនចំណូលថ្មីដូច ខាទីដយ៉ាស ដែរ។ សូម្បីតែពួកខ្មែរក្រហមខ្លះក៏ជាជនជាតិចាមដែរ ហើយជនជាតិចាមទាំងនោះដែលមិនចង់ហូបសាច់ជ្រូកត្រូវបានអនុញ្ញាតឲ្យប្តូរគ្នាជាមួយនឹងខ្មែរ។ (ផ្ទុយទៅវិញ នៅភូមិពើកដែលនៅក្បែរនោះ ជនជាតិចាមត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូក។) គេនៅតែហាមឃាត់មិនឲ្យនិយាយ ឬប្រតិបត្តិសាសនាចាមដដែល ប៉ុន្តែពួកមេដឹកនាំតំបន់ថ្មីៗ កងកម្លាំងភូមិភាគនិរតីដែលស្មោះត្រង់នឹង ប៉ុល ពត បានតំឡើងរបបអាហារ និងក៏បានផ្តល់នូវសម្លៀកបំពាក់ថ្មីៗផងដែរ។ ខាទីដយ៉ាស់ បានចង្អុលបង្ហាញថា ឆ្នាំ ១៩៧៨ គឺជាឆ្នាំដែលអាក្រក់បំផុតសម្រាប់ជនជាតិចាម នៅក្នុងលក្ខខណ្ឌនៃការសម្លាប់ និងថា ជនជាតិចាមត្រូវបានគេជ្រើសរើសយកទៅសម្លាប់ច្រើនជាងជនជាតិខ្មែរ។ នាងទម្លាក់ការទទួលខុសត្រូវចំពោះការសម្លាប់ដែលមានចំនួនកើនឡើងនេះលើកងកម្លាំងភូមិភាគនិរតី។

បន្ទាប់ពីការលុកលុយរបស់វៀតណាមនៅខែ មករា ឆ្នាំ ១៩៧៩ ខាទីដយ៉ាស់ រកឃើញថា កូនប្រុសអាយុ ២៤ ឆ្នាំរបស់នាងក៏ត្រូវបានគេសម្លាប់នៅភូមិភាគកណ្តាលក្នុងឆ្នាំ ១៩៧៧ ផងដែរ រួមជាមួយនឹងសាច់ថ្លៃរបស់គាត់ទាំងអស់។ បងប្រុសរបស់នាងក៏បានស្លាប់ដោយសារការអត់ឃ្លានផងដែរនៅក្នុងភូមិភាគដូចគ្នានៅក្នុងឆ្នាំដដែលនោះ ហើយនាងក៏បានបាត់បង់ក្មួយស្រី និងក្មួយប្រុសជាច្រើននាក់នៅក្នុងខេត្តសៀមរាបផងដែរក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

នៅខែ ធ្នូ ឆ្នាំ ១៩៧៨ អ្នកកាសែតជាតិអូស្ត្រាលីឈ្មោះ Wilfred Burchett បានទៅទស្សនាជំរំជនភៀសខ្លួនសម្រាប់ប្រជាជនកម្ពុជាក្នុងខេត្តតៃនិញប្រទេសវៀតណាម នៅក្នុងស្រមោលនៃ "ភ្នំ Black Virgin" ។ ជនភៀសខ្លួនចំនួន ៨.០០០ នាក់នៅទីនោះ គឺមានជនជាតិចាម ៦០០ នាក់។ Burchett បានសួរ សែន ម៉ាត់ អាយុ ៣៥ ឆ្នាំ ដែលជា "ជនជាតិចាមមាឌធំទាំម្នាក់" ដែលបានរត់គេចខ្លួនពីកម្ពុជាក្នុងខែ មីនា ឆ្នាំ ១៩៧៨ ថា ហេតុអ្វីបានជាគាត់បានចាកចេញ។ ម៉ាត់ បានឆ្លើយថា "ជនជាតិចាមត្រូវបានប្រល័យ" ដោយរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានលើកឡើងពីព្រឹត្តិការណ៍កោះផល ដែលក្នុងនោះគាត់បានអះអាងថា ជនជាតិចាមចំនួន ១.១០៨ នាក់ត្រូវបានសម្លាប់បន្ទាប់ពីបានជួបប្រជុំគ្នាដោយពួកខ្មែរក្រហមដើម្បី "ការពិគ្រោះយោបល់" ហើយបន្ទាប់មកបានបាញ់សម្លាប់ហ្វូងមនុស្សដោយកាំភ្លើងធំ និងកាំភ្លើងស្វ័យប្រវត្តិធំៗ។ គាត់បាននិយាយថា មានមនុស្សប្រាំបីនាក់ដែលបានរស់រានមានជីវិត និងបានរត់គេចខ្លួននៅយប់នោះក្រោយពីគេទុកឲ្យស្លាប់នៅនឹងកន្លែងនោះ។

ម៉ាត់ ក៏បានអះអាងផងដែរថា អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យបាន "បង្ខំយើងឲ្យហូបសាច់ជ្រូកក្នុងឱកាសដ៏កម្រនៅពេលដែលសាច់ជ្រូកមានសម្រាប់ហូប"។ គាត់បានបន្ថែមទៀតថា អ្វីដែលគួរឲ្យកត់សម្គាល់គឺពួកគេបានចោទប្រកាន់ពួកយើងថាទុកសក់វែងដូចវៀតណាម និងកំពុងស្ថិតនៅក្រោមឥទ្ធិពលរបស់វៀតណា

Deleted: *Unrevised translation. A revised translation will be provided upon request.*

ម”។ អ្វីដែលហួសចិត្ត ការកាន់កាប់របស់របបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងទំនាក់ទំនងជា ប្រវត្តិ សាស្ត្រ រវាងចាម និងវៀតណាម ពិតជាបានបង្កឲ្យមានទំនាក់ទំនងថ្មីមួយមែន។ ម៉ាត់ បាននិយាយថា “នៅឯព្រំដែនឯណោះ ជនជាតិវៀតណាមបានផ្តល់ឲ្យយើងនូវអ្វីដែលយើងត្រូវការជាចាំបាច់ សូម្បីតែលុយដើម្បីទិញរោងចក្រស្តដែក”។ Burchett បានមើល ម៉ាត់ និងជនជាតិចាមប្រាំមួយផ្សេងទៀតរំលាយគ្រាប់បែក និងសំបកគ្រាប់បែក ព្រមទាំងដំរាធ្វើជាក្បាលពូថៅ និងកាំបិតទៀតផង។ គាត់បានសរសេរថា “ពិតជាអាចឆ្នៃដាវឲ្យចេញជាផាលបានមែន”។ អ្វីដែលខ្ពស់នៅខាងលើពួកគេគឺជាភ្នំដែលយកឈ្មោះតាម “Black Virgin” (Ba Den) ដែលជាឈ្មោះវៀតណាមសម្រាប់ហៅអាទិទេពផែនដីចាមបុរាណគឺ ពោធិ៍ឥន្ទ្រនាគា[86]។

## ៣. ពារាំង

ក្នុងឆ្នាំ ១៩៧៥ លោក អ៊ែល យុសូហ្វ ដែលមានអាយុ ៤៥ ឆ្នាំនៅពេលនោះ ត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញ និងបានធ្វើដំណើរទៅមេស ព្រះចន្ទ នៅស្រុកពារាំង ខេត្តព្រៃវែង (តំបន់ ២២)។ គាត់បានដឹងថា ជនជាតិចាមលេចធ្លោពីរនាក់បានមកដល់ផងដែរនៅតំបន់ជិតនោះ។ ពួកគេទាំងពីរនាក់គឺ អ៊ីម៉ាម ហ័តជី រ៉េស ឡោះ ដែលជាអ្នកជំនាញច្បាប់ជាន់ខ្ពស់ឥស្លាមកម្ពុជា និង ទូន ហ័តជីស្រុង យុសូហ្វ ដែលជា ហាក់កែម នៃវិហារឥស្លាម Noor Alihsan ភាគខាងជើង ទីក្រុងភ្នំពេញ។ លោក យុសូហ្វ បានអះអាងថា នៅខែ កក្កដា ឬសីហា ឆ្នាំ ១៩៧៥ ឥស្សរជនឥស្លាមទាំងពីរនាក់នេះត្រូវបានគេសម្លាប់នៅភូមិស្វាយពុល ឃុំរកាន។

**តារាង ២**

**ឈ្មោះមន្ត្រីឥស្លាមដែលបានស្លាប់ក្នុង**
**របបកម្ពុជាប្រជាធិបតេយ្យ**

| **ឈ្មោះ** | **មុខតំណែង** | **មូលហេតុស្លាប់** | **ទីកន្លែង កាលបរិច្ឆេទស្លាប់** |
|---|---|---|---|
| អ៊ីម៉ាម ហ័តជី រ៉េស ឡោះ | អ្នកជំនាញច្បាប់ឥស្លាមជាន់ខ្ពស់ | ត្រូវគេបោះចូលក្នុងទឹកក្តៅកំពុងពុះ និងបន្ទាប់មកដោត | កូនហាម ពាមជីស្វរ ព្រៃវែង, ៨ តុលា ១៩៧៥ |

[86] Wilfred Burchett បានផ្តល់ជូនដោយភាពសប្បុរសដល់អ្នកនិពន្ធកំណត់ត្រានៃការសម្ភាសន៍របស់លោកនៅតាន់ចូវ តាយនិញ នៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ១៩៧៨។ ចំពោះ “Black Virgin” សូមមើល Thai Van Kiem, " Thien-Y-A-Na ឬ ពស់នាគ”*អាស៊ី*ល ៤ (ឆ្នាំ ១៩៥៤) ទំព័រ ៤០៦-១៣ នៅទំព័រ ៤០៨។

Deleted: ប្រវត្តិសាស្ត្រ

Deleted: ជាន់

Deleted: មខ្ពស់

Deleted: *Unrevised translation. A revised translation will be provided upon request.*

| | | | |
|---|---|---|---|
| | | ក្បាលជាប់នឹងចំរឹងដែក | |
| ហ៉ាតជី ស៊ូឡីម៉ាន់ ស៊ូគ្រី | អ្នកជំនាញច្បាប់ ថ្នាក់ទី ១ | ត្រូវគេវាយរហូតដល់ស្លាប់ និងបោះចូលប្រឡាយ | កាហៃ ព្រែកអញ្ចាញ កណ្តាល, សីហា ១៩៧៥ |
| ហ៉ាតជី ម៉ាត់ ស្លេះ ស៊ូឡីម៉ាន់ | អ្នកជំនាញច្បាប់ ថ្នាក់ទី ២ | ត្រូវគេធ្វើទារុណកម្ម និង ហូតយកពោះវៀនចេញ | បាត់ដំបង, ១០ សីហា ១៩៧៥ |
| ហ៉ាតជី ម៉ាត់ លី ហារុន | ប្រធានសមាគម ឥស្លាមនៅកម្ពុជា | ស្លាប់ដោយសារអត់ឃ្លាននៅ ក្នុងគុក | អន្លង់សែន កណ្តាល, ២៥ កញ្ញា ១៩៧៥ |
| ហ៉ាតជី ស្រុង យូសូហ្វ | សាស្ត្រាចារ្យផ្នែក ការសិក្សាឥស្លាម | ត្រូវគេសម្លាប់ | ពាមជរ កណ្តាល, ១៩ តុលា ១៩៧៥ |
| ម៉ាន់ សែត | ប្រធានសមាគម យុវជនឥស្លាម ច្រាំងចំរេះ | មិនដឹង | មិនដឹង |

ប្រភព៖ បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយនឹងមន្ត្រីចាមក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា

លោក អ៊ើល យូសូហ្វ មិនបានអះអាងថានឹងធ្វើជាសាក្សីនោះទេ ហើយសេចក្តីលម្អិតអាចនឹងមិនអាចទុកចិត្តបានឡើយ (សូមកត់ចំណាំភាពខុសគ្នាក្នុងតារាង ២ និង ៣) ប៉ុន្តែ គេមិនសង្ស័យទេថា រ៉េស ឡោះ និង ស្រុង យូសូហ្វ បានស្លាប់នៅក្នុងយុទ្ធនាការទូទាំងប្រទេសមួយពីខែ សីហា ដល់ខែ តុលា ឆ្នាំ ១៩៧៥ ដើម្បីបំបាត់ចោលនូវអ្នកដឹកនាំឥស្លាមនៅក្នុងប្រទេសនោះ (សូមមើលតារាង ១ ផងដែរ)។

ក្នុងឆ្នាំ ១៩៨០ លោក Frances Starner នៃកាសែត *Asiaweek* បានសម្ភាសស្ត្រីមេម៉ាយដែលជាប្រពន្ធលោក ស្រុង យូសូហ្វ ឈ្មោះ សុះ សា ពីតាស់ នៅវិហារឥស្លាម Noor Alihsan។ លោក Starner បានរាយការណ៍ថា៖

> ពេលដែលឪពុករបស់ពួកគេត្រូវបានគេនាំយកទៅ កូនច្បងទាំងបីនាក់របស់នាង ដែលទាំងអស់គ្នាមានវ័យខ្ទង់ម្ភៃឆ្នាំ និងប្អូនប្រុសអាយុ ១២ ឆ្នាំរបស់ពួកគេបានព្យាយាមរត់គេចខ្លួន។ នាងបាននិយាយថា ប៉ុន្តែទាហានខ្មែរក្រហមបានបន្តដេញសម្លាប់ពួកគេ។ បន្ទាប់មក នៅពេលដែលនាងឃើញគេចាប់មិត្តភក្តិ

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

នាងយកទៅ "ដោយគេចងដៃដើម្បីយកទៅសម្លាប់" នាងបានរត់គេចខ្លួនជាមួយនឹងកូនៗដែលនៅសល់របស់នាងចូលទៅក្នុងស្រុកមួយទៀត[87]។

លោក អ៊ែល យូសូហ្វ បានមកដល់ភូមិមេស ព្រះចន្ទ ជាមួយនឹងប្រជាជនថ្មីមកពីភ្នំពេញពី៣០ ទៅ ៤០ នាក់ផ្សេងទៀត ដោយចូលរួមជាមួយគ្រួសារអ្នកភូមិនៅទីនោះ ឬប្រជាជនមូលដ្ឋានចំនួន ៣០០ គ្រួសារ ដែលបានរស់នៅទីនោះជាយូរមកហើយនៅក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម។ មេឃុំ ដែលជាជនជាតិខ្មែរកាត់ចិនឈ្មោះថា អៀក បានប្រកាសថា៖ "ឥឡូវនេះ យើងកំពុងធ្វើបដិវត្តន៍។ គ្រប់គ្នានឹងក្លាយជាខ្មែរ"។

និយមន័យដែលមិនធម្មតានៃពាក្យថា "បដិវត្តន៍" នេះ គឺជាប្រផ្នូលអាក្រក់សម្រាប់ជនជាតិចាម។ ទោះជាយ៉ាងណា ជនចំណូលថ្មីម្នាក់ទៀត ឈ្មោះ អ៊ុង ប៊ុនហៀង បានរំលឹកថា អៀក គឺជាមនុស្ស "តឹងរឹង [ប៉ុន្តែ] មានចិត្តអាណិតអាសូរដល់ការលំបាករបស់ជនជម្លៀសទាំងអស់នេះ"[88]។ លោក អ៊ែល យូសូហ្វ បានបន្ថែមទៀតថា នៅឆ្នាំ ១៩៧៥ ពួកខ្មែរក្រហម "បានប្រើការបញ្ចុះបញ្ចូលក្នុងករណីខ្លះផងដែរ" បើទោះបីជាមាន_ការសម្លាប់ម្តងម្កាលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧ លើអ្នកដែលបានធ្វើអ្វីមួយ "ខុស" ដែលភាគច្រើនគឺជាប្រជាជនថ្មីក៏ដោយ។ គាត់បានបន្តថា នៅឆ្នាំ ១៩៧៦ ការដាក់សម្ពាធរបស់ពួកខ្មែរក្រហមលើប្រជាជន_ចាមសាមញ្ញបានចាប់ផ្តើម។ សាសនាត្រូវបានគេហាមឃាត់ រីឯភាសាចាមក៏ដូចគ្នា។ "ពួកគេបាននិយាយមកកាន់ពួកយើងថា៖ "ចាមដែលហូបសាច់ជ្រូក និងត្រៀមរួចរាល់ដើម្បីនឹងចិញ្ចឹម និងសម្លាប់ជ្រូក នឹងត្រូវ_បានទុកជីវិតឲ្យ""។ លោក អ៊ែល យូសូហ្វ បានកំណត់កាលបរិច្ឆេទនៃការកើតឡើងរឿងនេះនៅដើមឆ្នាំ ១៩៧៦ ប៉ុន្តែវាហាក់ដូចជាស្របគ្នាជាមួយនឹងការដាក់ចេញឲ្យមានការហូបអាហាររួមគ្នាបែបនោះដែរ។ បើយោងតាមដំណើររឿងរបស់លោក អ៊ុង ប៊ុនហៀង ការហូបអារហាររួមគ្នាបានចាប់ផ្តើមនៅឃុំមេស ព្រះចន្ទ នៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ១៩៧៦។ លោក អ៊ុង បានរៀបរាប់ប្រាប់លោក Martin Stuart-Fox អំពីផលប៉ះពាល់លើជនជាតិចាមដែលរស់នៅទីនោះ។

នៅពេលដែលការហូបអាហាររួមគ្នាត្រូវបានដាក់ចេញ ពួកគេត្រូវបានបង្ខំឲ្យហូបដូចអ្នកផ្សេងទៀតដែរ រួមទាំងបបររាវៗ ពេលខ្លះមានដុំខ្លាញ់ជ្រូកតូចៗខ្លះផង។ បុរស [ចាម] វ័យចំណាស់ពីរនាក់នៅក្នុងឃុំមេស ព្រះចន្ទ ប្រកែកមិនព្រមហូបជាមួយក្រុមអ្នកភូមិឯទៀតឡើយ។ បន្ទាប់ពីធ្វើពហិការមិន

---

[87] Frances Stamer, "ចាម៖ ជនម៉ូស្លីមដែលពិភពលោកភ្លេច" *Asiaweek*, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៨០ ទំព័រ ២៤-២៥។

[88] Martin Stuart-Fox និងអ៊ុង ប៊ុនហៀង, *បដិវត្តន៍កាប់សម្លាប់៖ ជីវិត និងសេចក្តីស្លាប់នៅកម្ពុជាក្នុងរបប ប៉ុល ពត* (ស៊ីដនី៖ APCOL, ឆ្នាំ ១៩៨៥) ទំព័រ ៤២។

Deleted: ទោះជា

Deleted: *Unrevised translation. A revised translation will be provided upon request.*

ហូបអាហាររួមគ្នាបានមួយសប្តាហ៍ អ្នកទាំងពីរត្រូវបានគេចាប់ខ្លួន និងបាញ់សម្លាប់ចោល ...។ ក្រោយមក យុវជនចាមម្នាក់ដែលត្រូវគេចាប់ថាបានចម្អិនសាច់មាន់នៅក្នុងផ្ទះរបស់ខ្លួនឯងត្រូវគេចាប់ខ្លួន និងបញ្ជូនទៅកាន់គុកស្វាយពុល។ ដូចអ្នកផ្សេងទៀតដែលគេបានបញ្ជូនទៅកសាងដែរ គេមិនដែលបានជួបគាត់ជាថ្មីម្តងទៀតឡើយ។

លោក Stuart-Fox បានសរសេរនៅត្រង់នេះថា "ការគាបសង្កត់លើជនជាតិចាមបានកើនឡើងជាលំដាប់ក្នុងអំឡុងពេលពីរឆ្នាំបន្ទាប់" (១៩៧៧-៧៨) ដូចគ្នាដែរសម្រាប់ជនជាតិភាគតិចផ្សេងទៀត។ "អ្នក_ណាក៏គេអាចចាប់ខ្លួនបានដែរ ពីបទប្រើប្រាស់ភាសាផ្សេងទៀតមិនមែនខ្មែរ ដែលជាវិន័យមួយដែលប្រើ សូម្បីតែក្នុងលក្ខណៈឯកជន និងដែលប៉ះពាល់ភាគច្រើនលើជនជាតិចិន និងជនជាតិចាម"[89]។

នៅឆ្នាំ ១៩៧៨ ស្រុកពារាំងបានជួបនឹងការសម្លាប់រង្គាលដ៏អាក្រក់បំផុតនៅក្នុងប្រទេស។ លោក អ៊ែល យុស្សូហ្វ បាននិយាយថា នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៧៨ "គ្រួសារចាម និងខ្មែរជាង ១០០ គ្រួសារ" ត្រូវសម្លាប់នៅជិតភូមិរបស់គាត់ដោយកងទ័ពរវជនភូមិភាគនិរតីរបស់ ប៉ុល ពត។ (គាត់បានកត់សម្គាល់ទាំងស្តាយក្រោយថា សូម្បីតែជនជាតិចាមដែលយល់ព្រមហូបសាច់ជ្រូកហើយក៏ដោយ ក៏ត្រូវគេសម្លាប់ចោលដែរនៅទីបំផុត។) លោក អ៊ឹង ប៊ុនហៀង បានដាក់ចំនួនសរុបនៃជនរងគ្រោះមកពីភូមិចំនួនប្រាំមួយក្នុងឃុំមេសរ ព្រះចន្ទ ត្រឹម ១.៥០០ នាក់ ដែលអ្នកទាំងអស់នេះត្រូវគេសម្លាប់ ក្នុងរយៈពេលប្រាំថ្ងៃក្នុងខែ កក្កដា ឬខែ សីហា ឆ្នាំ ១៩៧៨។ លោក ប៊ុនហៀង បានបាត់បង់សាច់ញាតិ៣០ នាក់នៅក្នុងការសម្លាប់រង្គាលមួយនោះ ដែលរួមទាំងក្មេងៗ ១៧ នាក់ផងដែរ។ ជនរងគ្រោះចែកជាពីរប្រភេទ។ ទីមួយ ប្រជាជនថ្មី ឬអតីតពួកអ្នករស់នៅតាមទីក្រុង ក្រៅពីអ្នកដែលមានសាច់ញាតិមួយចំនួនក្នុងចំណោមប្រជាជនមូលដ្ឋាន និងទីពីរ "ជនជាតិចិន និងចាមដែលគេចូលចិត្តជ្រើសរើសជាងគេ" សម្រាប់យកទៅសម្លាប់ "ទោះបីជាភាគច្រើនគឺ_សំដៅលើជនជាតិចិនដែលជា "ប្រជាជនថ្មី" ប៉ុណ្ណោះក្តី[90]។

ដូច្នេះ នៅក្នុងករណីអ្នកជម្លៀសពីទីក្រុង និងប្រជាជនចិន ទំនាក់ទំនងខ្លះជាមួយនឹងប្រជាជនមូលដ្ឋានផ្តល់ផលល្អដល់ពួកគេ។ ប៉ុន្តែវាមិនបានជួយសង្គ្រោះប្រជាជនចាមដែលត្រូវបានគេកំណត់ជាគោលដៅដើម្បីកម្ទេចចោលបានទេ ថ្វីបើពួកគេភាគច្រើនជាប្រជាជនមូលដ្ឋានក៏ដោយ។ ការសម្លាប់រង្គាលលើប្រជាជនចាមទាំងនេះនៅពាក់កណ្តាលឆ្នាំ ១៩៧៨ នៅទីនោះគឺជាផ្នែកមួយនៃយុទ្ធនាការនៃការសម្លាប់បំផុតពូជ។

---

[89] ដូចឯកសារខាងលើ ទំព័រ ៨៧, ១២៨។

[90] ដូចឯកសារខាងលើ ទំព័រ ១៤៦។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

**៤. កំពង់ត្របែក**

ធ្វើដំណើរបួនម៉ោងបញ្ច្រាសខ្សែទឹកពីព្រំដែនវៀតណាម និងវាលត្រែង ដែលពីមុនជាច្រាំងពោរពេញដោយជួរចម្ការស្វាយ ចេក ដូង ឫស្សី អម្ពិលទឹក និងដើមត្នោត អ្នកនឹងឃើញភូមិតូចមួយមានខ្ទមប្រក់ស្បូវដែលនៅប្រឡបនឹងមាត់ទន្លេត្របែក ដែលស្ងប់ស្ងាត់ក្រោមពន្លឺព្រះអាទិត្យដ៏ស្ងប់ស្ងាត់ពណ៌មាសនារសៀលជ្រេ។ ទឹកភក់ពណ៌ត្នោតស្ទើរតែនៅនឹងថ្កល់មិនប្រែប្រួល ទោះជានារីយើងដែលឈរនៅកន្សៃទូកឈើដ៏តូចវែង ដោលទូកយឺតៗបញ្ច្រាសទន្លេអែបនឹងច្រាំងភាគខាងលិច។ នៅចំពោះមុខខ្ទមនីមួយៗដែលនាងបានឆ្លងកាត់គឺជា_ទ្រូ ឫស្សី និងឧបករណ៍ធ្វើពីឈើសម្រាប់ចាប់ត្រីគ្រប់ប្រភេទ និងគ្រប់ទំហំ ដែលគេទាញឡើងដាក់លើផ្ទៃទឹកថ្លា ឬលិចពាក់កណ្ដាល និងបន្ទំជាមួយនឹងមែកឈើតូចៗ។

នេះគឺជាភូមិខ្មែរឥស្លាមនៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ វាគឺជាភូមិមួយក្នុងតំបន់ ២៤ ដែលខ្ញុំធ្លាប់បានទៅទស្សនាជាច្រើនដង ហើយខ្ញុំបានធ្វើការស្ទង់មតិក្នុងតំបន់នោះអំពីចំនួនមនុស្សស្លាប់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ ១៩៧០ មានគ្រួសារចាមជាង ១០០ គ្រួសារបានរស់នៅក្នុងភូមិនេះដែលប្រកបរបរនេសាទត្រីតាមបណ្ដោយដងទន្លេត្របែក។ ហាក់កែម ឬមេដឹកនាំសហគមន៍ ឈ្មោះ ហ៊័តជី អ៊ីស្មាអែល អាយុ ៧០ ឆ្នាំបានកើតនៅភូមិនេះ។ គាត់គឺជាអ្នកនេសាទម្នាក់ ហើយមានប្រពន្ធ និងកូនបួននាក់។ គាត់បានក្លាយជាហាក់កែម នៅឆ្នាំ ១៩៦៨ ហើយដូច្នេះ បានដឹកនាំប្រជាជនរបស់គាត់ឆ្លងកាត់រយៈពេលមួយទសវត្សរ៍នៃគ្រោះមហន្តរាយតែម្ដង។

ហ៊័តជី អ៊ីស្មាអែល និយាយថា ពួកខ្មែរក្រហមបានមកដល់ភូមិនេះជាលើកដំបូងនៅឆ្នាំ ១៩៧១ ប៉ុន្តែថាពួកគេមិនបានបៀតបៀន ឬការសម្លាប់ប្រជាជនទេរហូតដល់បួនឆ្នាំក្រោយមកទៀត។ ទន្ទឹមនឹងនេះដែរ ភូមិនេះត្រូវបានទម្លាក់គ្រាប់បែកជាច្រើនដងដោយយន្តហោះរបស់អាមេរិក និង លន់ នល់។ នៅខែ សីហា ឆ្នាំ ១៩៧២ ការវាយឆ្មក់ទម្លាក់គ្រាប់បែកបានបំផ្លាញវិហារឥស្លាម ហើយយ៉ាងហោចណាស់អ្នកភូមិ ៧ នាក់_បានស្លាប់។ ផ្ទះចំនួនមួយរយខ្ទងត្រូវបានបំផ្លាញដោយគ្រាប់បែក និងអគ្គីភ័យដែលពួកវាបង្កឡើង។ ហ៊័តជី អ៊ីស្មាអែល និយាយថា “បន្ទាប់មក ប្រជាជនទាំងអស់បានរត់គេច”។ “ពួកគេបានរត់ចូលទៅក្នុងវាលស្រែ និងស្នាក់នៅជាមួយសាច់ញាតិ ដែលនៅភូមិដទៃទៀត។ កូនប្រុសមួយចំនួនរបស់ពួកគេបានចូលរួមជាមួយកងទ័ពខ្មែរក្រហម ខណៈដែលមនុស្សជាច្រើននាក់ទៀតបានរត់ភៀសខ្លួនទៅទីក្រុងភ្នំពេញ។ ពេលដែលពួកខ្មែរក្រហមបានសញ្ជ័យវា និងបានឈ្នះសង្គ្រាម ប្រជាជននៃភូមិខ្មែរឥស្លាមបានត្រឡប់ទៅផ្ទះរបស់ពួកគេវិញ។

អ្វីដែលរង់ចាំពួកគេនៅទីនោះគឺរយៈពេលបួនឆ្នាំនៃការបង្អត់អាហារ និងការស្លាប់។ ហ៊័តជី អ៊ីស្មាអែល ប៉ាន់ប្រមាណថា គ្រួសារទាំងមូលប្រហែលជា ៣០ នាក់ ឬច្រើនជាងនេះ បានស្លាប់នៅត្រឹមឆ្នាំ ១៩៧៩ ដែល

Deleted: *Unrevised translation. A revised translation will be provided upon request.*

រួមមាន ១៨ ឬ ១៩គ្រួសារនៅក្នុងឆ្នាំ ១៩៧៨ តែឯង។ នៅត្រឹមខែ មករា ឆ្នាំ ១៩៨៦ មានគ្រួសារត្រឹមតែ ៧៤ ប៉ុណ្ណោះនៅក្នុងភូមិខ្មែរឥស្លាម ដោយរស់នៅក្នុងផ្ទះចំនួន ៤៩ ខ្នង។ ហ័តជី អ៊ីស្មាអែល និយាយថា ប្រជាជនចាម "ត្រូវបានគេធ្វើទុក្ខបុកម្នេញសឹងតែច្រើនជាងប្រជាជនភាគច្រើនទៀតផង" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

ការស្ទង់មតិមួយនៅខែ ធ្នូ ឆ្នាំ ១៩៨៦ ដែលធ្វើឡើងដោយនរវិទូ Gregory Stanton និងខ្ញុំ លើ គ្រួសារចាមចំនួន ៣៣ ក្នុងចំណោម ៤៩ នៅក្នុងភូមិនោះបានបង្ហាញថា គ្រួសារដែលនៅរស់រានមានជីវិតទាំងនោះដែលមានចំនួន ២២៣ នាក់នៅឆ្នាំ ១៩៧៥ បានបាត់បង់សមាជិកគ្រួសារចំនួន ៥៤ នាក់នៅត្រឹមឆ្នាំ ១៩៧៩។ ចំនួនអ្នកស្លាប់គឺស្មើនឹង ២៤ ភាគរយ។ ករណីនៃការស្លាប់ភាគច្រើនត្រូវបានគេសន្មតថាជាការសម្លាប់ដោយពួកខ្មែរក្រហម។ គ្រួសារចំនួន ៣៣ គ្រួសារ ដែលមានសមាជិក ៣៦ នាក់ត្រូវបានគេសម្លាប់។ យ៉ាងហោចណាស់ ២៣ នាក់ក្នុងចំណោមនេះត្រូវគេសម្លាប់ក្នុងឆ្នាំ ១៩៧៨ តែឯង ហើយយ៉ាងហោចណាស់ ១៥ នាក់ទៀតបានស្លាប់ដោយសារមូលហេតុផ្សេងៗទៀតនៅក្នុងឆ្នាំដដែលនោះ។ ហ័តជី អ៊ីស្មាអែល និងប្រពន្ធរបស់គាត់បានរួចរស់ជីវិត ប៉ុន្តែកូន ៣ នាក់ក្នុងចំណោមកូន ៤ នាក់របស់ពួកគេបានស្លាប់នៅក្នុងខេត្តពោធិ៍សាត់ នៅឆ្នាំ ១៩៧៨។

លើសពីនេះទៅទៀត ដូចដែល ហ័តជី អ៊ីស្មាអែល បានចង្អុលបង្ហាញ គ្រួសារប្រមាណជា ៣០ មិនមានសល់អ្នកនៅរស់រានមានជីវិតឡើយ។ ស្ត្រីវ័យចំណាស់ម្នាក់ ឈ្មោះ អៃ សាស់ អាយុ ៧៣ ឆ្នាំ ដែលបាននិយាយថា នាងឥឡូវនេះមានបញ្ហាផ្លូវចិត្ត បានអះអាងថាបានបាត់បង់ "ចៅ ៨០ នាក់" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងក្រុមគ្រួសារទាំងមូល ៣ គ្រួសារដែលមានសមាជិក ១២ នាក់ ១០ នាក់ និង ៩ នាក់។ ចំនួនអ្នកស្លាប់នៅក្នុងភូមិខ្មែរឥស្លាមនេះនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទំនងជាមានចំនួន ៤០ ទៅ ៥០ ភាគរយនៃចំនួនប្រជាជនសរុបក្នុងភូមិរបស់ខ្លួន ឬប្រហែល ៣០០ នាក់ ក្នុងចំណោម ៦៥០ នាក់។ ស្ត្រីនៅឆ្នាំ ១៩៨៦ មានចំនួន ៥៦ ភាគរយនៃចំនួនប្រជាជនសរុប (២០៧ ក្នុងចំណោម ៣៧១ នាក់) និងដោយគ្មានការសង្ស័យ គឺមានចំនួនជាង ៦០ ភាគរយនៃចំនួនប្រជាជនពេញវ័យ។ ស្ត្រីជាច្រើនគឺជាស្ត្រីមេម៉ាយ។

ហ័តជី អ៊ីស្មាអែល កត់សម្គាល់នូវលក្ខណៈសំខាន់ៗបីយ៉ាងនៃរយៈពេលពីរទៅបីឆ្នាំដំបូងនៃការគ្រប់គ្រងរបស់ពួកខ្មែរក្រហមគឺ ការបំផ្លាញសាសនា ការដាក់ចេញនូវការហូបអាហាររួមគ្នា និងតម្រូវការការងារដ៏យង់ឃ្នង។ ឆ្នាំចុងក្រោយនៃរបបខ្មែរក្រហមគឺឆ្នាំ ១៩៧៨ គឺគួរឲ្យគេកត់សម្គាល់ជាចម្បងពី ការសម្លាប់រង្គាល។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Original EN: 01199562-01199594

ហ័តជី អ៊ីស្មាអែល កំណត់ការចាប់ផ្ដើមការធ្វើទុក្ខបុកម្នេញរបស់ពួកខ្មែរក្រហមមកលើប្រជាជនរបស់ខ្លួនជាមួយនឹងការបំផ្លាញវិហារអ៊ីស្លាមដែលរងការខូចខាតមួយផ្នែកទៅហើយ និងការហាមឃាត់មិនឱ្យមានការប្រតិបត្តិសាសនានៅឆ្នាំ ១៩៧៤-៧៥។ នៅឆ្នាំ ១៩៧៤ ការបែកខ្ញែកនៃប្រជាជនចាមក៏បានចាប់ផ្ដើមឡើងផងដែរ ទោះបីជានៅក្នុងការបំផ្ទុះគ្រាប់បែកឆ្នាំ ១៩៧២ បានធ្វើឱ្យមានការបែកខ្ញែកជាទ្រង់ទ្រាយធំរួចទៅហើយក្ដី។ នៅពេលដែលសង្គ្រាមបានបញ្ចប់នៅក្នុងឆ្នាំ ១៩៧៥ ហើយប្រជាជនខ្មែរឥស្លាមបានវិលត្រឡប់ទៅភូមិរបស់ពួកគេវិញ ការបំបែកដ៏តឹងរឹងមួយត្រូវបានអនុវត្តឡើងភ្លាមៗ។ ដូចដែល អ៊ីស្មាអែល ប្រាប់រឿងនេះថា៖ “នៅក្នុងសម័យប៉ុល ពត ពួកយើងជាប្រជាជនចាមមិនត្រូវបានអនុញ្ញាតឱ្យរស់នៅជាមួយគ្នាឡើយ។ យើងត្រូវគេបំបែកឱ្យទៅនៅគ្រប់ភូមិ។ ៤ ឬ ៥ គ្រួសារត្រូវគេបញ្ជូននៅនេះ ៤ ឬ ៥ គ្រួសារទៅនោះ .... ១០ គ្រួសារត្រូវគេបញ្ជូនទៅភូមិមួយចំនួន ៣ គ្រួសារទៀតទៅភូមិផ្សេងទៀត”។

នៅឆ្នាំ ១៩៧៥ ផងដែរ គឺជាឆ្នាំនៃការសម្លាប់អ្នកភូមរបស់របបខ្មែរក្រហមជាលើកដំបូង។ ប្រជាជនជាច្រើននាក់ត្រូវគេសម្លាប់ដោយសារតែ “ចចេសរឹងរូស” (*s'tec sompoan*) នៅឆ្នាំដំបូងនោះ។ អ៊ីស្មាអែល រំលឹកថា៖ “នៅពេលដែលពួកគេបានហាមឃាត់មិនឱ្យមានសាសនា ប្រជាជនមិនយល់ព្រម។ ... មិនមានការតស៊ូណាមួយនៅទីនេះ ដូចនៅស្រុកក្រូចឆ្មារ និងពារាំងឡើយ។ ... យើងមិនហ៊ានបន្តសកម្មភាពសាសនាឡើយ ព្រោះពួកគេបានចូលមកមើលយើង ហើយនឹងយកយើងទៅសម្លាប់ចោល ប្រសិនបើយើងបានធ្វើមែន។

ការសម្លាប់បានកើនឡើងជាមួយនឹងការដាក់បញ្ចូលការហូបអាហាររួមគ្នាជាកំហិត នៅឆ្នាំ ១៩៧៦។ ការចម្អិនអាហារជាលក្ខណៈគ្រួសារត្រូវបានហាមឃាត់។ ប្រជាជនមូស្លីមជាច្រើននាក់ទៀតត្រូវបានសម្លាប់នៅឆ្នាំ ១៩៧៦ ឬឆ្នាំ ១៩៧៧ ដែលបានបញ្ជាក់ថា ពួកគេនឹងមិនហូបសាច់ជ្រូក។ នៅឆ្នាំ ១៩៧៨ យ៉ាងហោចណាស់មានប្រជាជនច្រើនដូចគ្នាបន្ថែមទៀតត្រូវបានសម្លាប់ដោយសារហេតុផលដូចគ្នានេះ។ ក្នុងចំណោមអ្នកទាំងនោះ ប្រុស ៥ នាក់ និងស្រី ៣ នាក់មកពីភូមិនោះត្រូវគេសម្លាប់ដោយសារពួកគេប្រឆាំងនឹងការហូបសាច់ជ្រូក។ សោកនាដកម្មនេះគឺថា សាច់ជ្រូកទោះយ៉ាងណាគឺកម្រនឹង (ប្រសិនបើមាន) មានឱ្យហូបណាស់នៅក្នុងរោងបាយរួមគ្នាដ៏រញ៉េរញ៉ៃនោះ។ វាហាក់ដូចជាមានការប្រឆាំងពីសំណាក់ប្រជាជនឥស្លាម ជាគោលការណ៍៖ “តាមពិតទៅ យើងមិនដែលឃើញសាច់ជ្រូកទេ ប៉ុន្តែវាគ្រាន់តែជាលេសរបស់ពួកខ្មែរក្រហម_ប៉ុណ្ណោះ ដើម្បីសម្លាប់អ្នកដែលនិយាយថា ពួកគេនឹងមិនហូបសាច់ជ្រូក”។ ទន្ទឹមនឹងនេះដែរ គ្រប់គ្នាតម្រូវ_ឱ្យប្រឹងប្រែងធ្វើការណាស់នៅតាមវាល។ “ពួកគេប្រើយើងឱ្យធ្វើស្រែ និងជីកប្រឡាយដោយឱ្យបាយតែពីរ_ស្លាបព្រាប៉ុណ្ណោះក្នុងមួយថ្ងៃ”។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ពីពាក់កណ្តាលឆ្នាំ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៧ របប ប៉ុល ពត បានបោសសម្អាតតំបន់ភាគខាងត្បូងនៃខេត្តព្រៃវែង ដែលគេស្គាល់ថាជាតំបន់ ២៤ ដែលជាតំបន់មួយក្នុងចំណោមតំបន់ទាំង ៥ នៃភូមិភាគបូព៌ានៃប្រទេស។ លេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំតំបន់នោះឈ្មោះ សួស ណូ (ហៅ ឈូក) ត្រូវគេចាប់ខ្លួននៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៦ និងក្រោយមកត្រូវគេសម្លាប់នៅក្នុងគុកទួលស្លែង។ លេខារងរបស់គាត់ ណាវ ជ័យ បានទៅតាមក្រោយគាត់នៅទីនោះដែរនៅខែ កក្កដា ឆ្នាំ ១៩៧៧។ មែនហើយនៅមុនពេលនោះ តំបន់នោះគឺស្ថិតនៅក្រោមការគ្រប់គ្រងដ៏តឹងរឹងពីកងកម្លាំងភូមិភាគនិរតីរបស់ ម៉ុក ដែលជាមេបញ្ជាការយោធាជាន់ខ្ពស់របស់ ប៉ុល ពត[91]។ “ម៉ុក ភ្លាមៗក្រោយមកបានបង្វែរការយកចិត្តទុកដាក់របស់គាត់លើអ្នកដឹកនាំភូមិភាគបូព៌ាគឺ សោ ភឹម។ ហ័តជី អ៊ីស្មាអែល ប្រៀបធៀបក្រុមទាំងពីរថា៖

> នៅក្នុងកងកម្លាំងភូមិភាគបូព៌ា មានប្រជាជនចាម កូនប្រុស [របស់យើង] ដែលបានចូលរួមក្រោយឆ្នាំ ១៩៧០ និងប្រជាជនចាមមួយចំនួនគឺជាកម្មាភិបាល។ កងកម្លាំងភូមិភាគបូព៌ាដឹកនាំដោយ សោ ភឹម។ ពួកគេបានលុបបំបាត់សាសនាចោល និងបានបង្កើតឲ្យមានការហូបអាហាររួមគ្នានៅឆ្នាំ ១៩៧៦។ រឿងនោះគឺអាក្រក់ខ្លាំងណាស់។ ប៉ុន្តែ [បើមិនដូច្នេះទេ] រឿងនេះមិនមែនជាបញ្ហាអ្វីច្រើននោះទេ។ ... សោ ភឹម មិនមែនជាអ្នកទទួលខុសត្រូវចំពោះការធ្វើទុក្ខបុកម្នេញ ឬការសម្លាប់មនុស្សឡើយ។ គឺ ប៉ុល ពត និងភូមិភាគនិរតីឯណោះទេដែលជាឃាតករ។ ពួកគេបានសម្លាប់កម្មាភិបាលចាម និងកម្មាភិបាលភូមិភាគបូព៌ាផ្សេងទៀត ដែលត្រូវបានគេសម្លាប់ក្នុងអំឡុងពេលដែល សោ ភឹម ត្រូវគេចាប់ខ្លួនយកទៅបាត់។ [សោ ភឹម បានធ្វើអត្តឃាតដើម្បីគេចពីការចាប់ខ្លួននៅថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ១៩៧៨]

វាក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតីផងដែរ ដែលប្រជាជនចាមក្នុងភូមិខ្មែរឥស្លាម រួមជាមួយនឹងប្រជាជនខ្មែរក្នុងតំបន់នេះជាច្រើនទៀត ត្រូវគេជម្លៀសចេញទៅទិសពាយព្យនៃប្រទេសកម្ពុជានៅខែ វិច្ឆិកា ឆ្នាំ ១៩៧៨។ ពួកគេមិនអាចឲ្យគេទុកចិត្តបានទេក្នុងការប្រឆាំងនឹងសត្រូវរបស់ ប៉ុល ពត គឺវៀតណាម និងសូម្បីតែមើលឃើញថាជាជនក្បត់ជាតិ ដូចជា សោ ភឹម ដែរ។ ហ័តជី អ៊ីស្មាអែល និយាយថា៖ “ប្រជាជនភូមិភាគបូព៌ាត្រូវគេហៅថា “ក្បាលយួនខ្លួនខ្មែរ”។ ប្រជាជនចាមក៏ត្រូវបានគេចោទប្រកាន់ពីបទនេះដែរគ្មានអីខុសគ្នាទេ”។ ហ័តជី អ៊ីស្មាអែល បន្តថា៖ “ប្រជាជនរាប់ពាន់នាក់ត្រូវគេចាប់យកទៅ។ មានតែពីរបីគ្រួសារប៉ុណ្ណោះដែលនៅទីនេះដើម្បីនេសាទឲ្យពួកខ្មែរក្រហម៖ ៣ គ្រួសារនោះគឺ ម៉ាត់ អិល លីទី និងគ្រួសារ

---

[91] សូមមើលលោក Ben Kiernan, “មាន់ព្រៃ” ទំព័រ ១៧៥-៨៦។

Deleted: *Unrevised translation. A revised translation will be provided upon request.*

របស់ពួកគេ។ ប្រជាជនចាមផ្សេងទៀតត្រូវបានជម្លៀសចេញទាំងអស់។ យើងបានចេញទៅទាំងអស់គ្នា ប៉ុន្តែត្រូវគេបំបែក (ជាថ្មីម្តងទៀត) នៅពេលដែលយើងទៅដល់ខេត្តពោធិ៍សាត់”។

កូនប្រុសម្នាក់របស់ ហ៊ាតជី អ៊ីស្មាអែល ត្រូវគេសម្លាប់ដោយកងទ័ពភូមិភាគនិរតីនៅមុនការជម្លៀសក្នុងឆ្នាំ ១៩៧៨។ កូនប្រុសពីរនាក់ផ្សេងទៀតត្រូវគេសម្លាប់នៅខេត្តពោធិ៍សាត់នៅដើមឆ្នាំ ១៩៧៩ ពីរបីថ្ងៃមុនពេលរបបនេះត្រូវបានផ្តួលរំលំ។ ពួកគេត្រូវបានគេដាក់ឱ្យធ្វើការនៅក្នុងឃ្លាំងស្រូវនៅតំបន់ដែលមានកូនភ្នំដែលគេស្គាល់ថាជា ភ្នំស្រាប។ ថ្ងៃមួយ ពួកគេត្រូវបានគេកោះហៅឱ្យមកប្រជុំធំដែលមានមនុស្ស ១៥០ នាក់ពាក់ព័ន្ធនឹងប្រជាជនមួយចំនួនដែលមកពីគ្រប់គ្រួសារក្នុងមូលដ្ឋាន។ ហ៊ាតជី អ៊ីស្មាអែល គិតថា រឿងនេះគឺប្រហែលជាថ្ងៃទី ២ ខែ មករា ឆ្នាំ ១៩៧៩។ នៅពេលពួកគេមកដល់ ពួកគេដឹងថា កងទ័ពភូមិភាគនិរតី_កំពុងរង់ចាំពួកគេ។

មានទាហានបី ឬបួននាក់ឈរនៅទីនោះជាមួយនឹងកាំភ្លើងអាកាបីដើម។ ពួកគេបានត្រឹមតែនិយាយពាក្យពីរបីម៉ាត់ប៉ុណ្ណោះនៅពេលពួកគេបានចាប់ផ្តើមបាញ់ប្រហារ។ មនុស្សជាច្រើនបានស្លាប់។ ក្នុងចំណោមមនុស្ស ១៥០ នាក់ មានតែ៣ នាក់ប៉ុណ្ណោះដែលបានរួចរស់ជីវិតត្រឡប់មកទីនេះវិញ។ គ្មាននរណាម្នាក់ក្នុងចំណោមប្រជាជនចាមជាង ៤០ នាក់នៅក្នុងក្រុមនោះបានរួចរស់ជីវិតនោះទេ។ ពួកគេទាំងអស់គ្នាគឺជាក្មេងៗនៅក្នុងភូមិនេះ បុរស និងស្ត្រីវ័យក្មេងដែលធ្លាប់ជាចុងភៅសម្រាប់ពួកខ្មែរក្រហម។

ពួកខ្មែរក្រហមបាននិយាយថា ជនជាតិខ្មែរមូស្លីមគឺសុទ្ធតែជាសត្រូវទាំងអស់ អ្នកដែលចចេសរឹងរូស។ យើងមិនបានដឹងថាវាមានន័យថាយ៉ាងម៉េចនោះទេ គ្រាន់តែដឹងថា គេនឹងសម្លាប់យើង បើយើងជាវា។ ...

អ្នកភូមិម្នាក់ទៀតបាននិយាយរឿងនេះតាមរបៀបនេះ៖

ពួកគេអាចវាយយើងបានប្រសិនបើពួកគេចង់ បើទោះបីជាយើងបានគោរពតាមច្បាប់របស់ពួកគេក៏ដោយ។ គ្មានច្បាប់អ្វីទាំងអស់។ បើសិនពួកគេចង់ឱ្យយើងដើរ យើងដើរ ចង់ឱ្យអង្គុយ អង្គុយ ចង់ឱ្យហូបហូប។ ហើយពួកគេនៅតែសម្លាប់ពួកយើងដដែល។ វាជាគ្រាន់តែថា បើពួកគេចង់សម្លាប់យើង ពួកគេនឹងចាប់ពួកយើងយកទៅ ហើយសម្លាប់ចោល។

ហ៊ាតជី អ៊ីស្មាអែល បន្តថា៖

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

> ពួកគេកាន់តែសម្លាប់មនុស្សខ្លាំងឡើងខណៈពេលដែល [កងកម្លាំងវៀតណាម និងហេង សំរិន] ជួរមុខកាន់តែខិតមកដល់។ ទីក្រុងភ្នំពេញត្រូវបានរំដោះនៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩ ឯខេត្តពោធិ៍សាត់គឺនៅថ្ងៃទី ១៧-១៩ ខែ មករា។ ពួកខ្មែរក្រហមស្ទើរតែបានសម្លាប់អ្នកគ្រប់គ្នានៅត្រឹមពេលនោះ។

នៅត្រឹមថ្ងៃទី ២០ ខែ មករា ហ័តជី អ៊ីស្មាអែល បានត្រៀមខ្លួនធ្វើដំណើររួចរាល់ត្រឡប់ទៅភូមិខ្មែរឥស្លាមវិញ។ គាត់គឺជាអ្នកទីមួយដែលវិលត្រឡប់មកវិញ។ "កន្លែងនោះគឺទទេស្អាត ... ខ្ញុំបានដេកនៅក្រោមដើមឈើមួយ គ្មានអ្វីមួយដូចជាផ្ទះដែលនៅសល់សម្រាប់ស្នាក់នៅទេ។

នៅមួយឆ្នាំក្រោយ មានគ្រួសារប្រហែល ៣០ គ្រួសារដែលបានត្រឡប់មកវិញ និងក្រោយមក មានអ្នកផ្សេងទៀតនៅពេលដែលពួកគេទទួលដំណឹងថា សាច់ញាតិរបស់ពួកគេនៅរស់រានមានជីវិត និងត្រឡប់ទៅផ្ទះវិញ។ ពួកគេបានសាងសង់ផ្ទះទាបៗ និងដោយមានជំនួយពីរដ្ឋាភិបាលថ្មី ពួកគេបានសង់វិហារឥស្លាមធ្វើពីឈើតូចមួយនៅលើសសរដែលមានកម្រាលធ្វើពីបន្ទះឫស្សី។ នៅលើធ្នឹម ជាភាសាខ្មែរ ពួកគេបានបិទភ្ជាប់សញ្ញាមួយដែលអាចធ្វើជាកសិណសាក្សីចំពោះការប្តេជ្ញាចិត្តរបស់ពួកគេ ដើម្បីរស់នៅជាសហគមន៍មួយ។ វាសរសេរថា "វប្បធម៌រំលំ ជាតិរលាយ"។ ហ័តជី អ៊ីស្មាអែល និយាយថា មានទារកចាម ១០០ នាក់បានកើតនៅក្នុងភូមិនោះចាប់តាំងពីឆ្នាំ ១៩៧៩ មក។

**៥. រមាសហែក**

ប្រហែលជាសហគមន៍ចាមដ៏តូចបំផុត និងដាច់ស្រយាលបំផុតនៅកម្ពុជាគឺជាគ្រួសារមួយក្នុងចំណោម ១២ គ្រួសារនៅក្បែរព្រំដែនវៀតណាម នៅភាគខាងជើងនៃខេត្តស្វាយរៀង (តំបន់ ២៣) ដែលជាប្រជាជនចាមតែមួយគ្រួសារគត់នៅក្នុងខេត្តនោះ។ គ្រួសារចាម ៩ គ្រួសាររស់នៅក្នុងភូមិតាកែវ ឃុំកំពង់ត្រាច ស្រុករមាសហែក និង ៣ គ្រួសារផ្សេងទៀតរស់នៅក្បែរៗនោះ។ ពួកគេគឺជាកសិករធ្វើស្រែ និងជាងដែក។ នៅក្នុងតំបន់នេះមុនឆ្នាំ ១៩៧០ គ្រួសារចាមចំនួន ៣២ គ្រួសាររស់នៅក្បែរៗគ្នាយ៉ាងចុះសម្រុងនឹងគ្នាជាមួយនឹងគ្រួសារខ្មែរជាង ១០០ គ្រួសារ។ ប្រជាជនចាមខ្លះគឺជាអ្នកនេសាទត្រី ខ្លះជាអ្នកដាំបន្លែយកទៅលក់នៅទីផ្សា និងខ្លះជាកសិករ។ ហាក់កែម របស់ពួកគេ គឺ តា ឡោះ គឺជាអ្នកស្រុកដើមនៅកំពង់ត្របែក និងបានទទួល_តំណែងនេះនៅកំពង់ត្រាច ក្នុងឆ្នាំ ១៩៦៨។

លោក សែន អូស្មាន់ អាយុ ៣៩ ឆ្នាំ កើតនៅភូមិតាកែវ និងនៅឆ្នាំ ១៩៧០ ជាសិស្សរបស់ តា ឡោះ និងគ្រូម្នាក់ទៀតឈ្មោះ អ៊ិល នៅសាលារៀនមូស្លីមក្នុងភូមិ។ មិនយូរប៉ុន្មានបន្ទាប់ពីរដ្ឋប្រហារយោធា លន់ នល់ ដែលបានទម្លាក់ព្រះអង្គម្ចាស់នរោត្តមសីហនុ ពួកខ្មែរក្រហមរាប់រយនាក់បានមកដល់ភូមិនេះ និងបានបង្កើតរដ្ឋបាលបះបោរមួយ។ ប៉ុន្តែដូចនៅខេត្តព្រៃវែងដែរ ពួកខ្មែរក្រហមមិនបានប៉ះពាល់ប្រជាជនទេក្នុងរយៈពេលប្រាំ

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ឆ្នាំក្រោយ។ លោក អូស្មាន់ និយាយថា “គ្មានការធ្វើទុក្ខបុកម្នេញ គ្មានសេដ្ឋកិច្ចរួម និងគ្មានការកាប់សម្លាប់នោះទេ”។ ប៉ុន្តែ មានសង្គ្រាម និងការទម្លាក់គ្រាប់បែកពីលើអាកាសរបស់អាមេរិក ដែលនាំមកនូវការភ័យខ្លាច និងទុក្ខលំបាកនៅក្នុងភូមិ។ ការវាយប្រហារដោយ បេ-៥២ នៅក្បែរនោះ បានសម្លាប់អ្នកភូមិជាច្រើននាក់ និងបន្សល់ទុករណ្ដៅគ្រាប់បែកជាច្រើន។ ទាហាននៃកងទ័ពក្រុងសៃហ្គនរបស់លោក Nguyen Van Thieu បានចុះចតជាឧទ្ធម្ភាគចក្រ និងបានចាប់យកស្ត្រីវ័យក្មេងក្នុងភូមិទៅ៖ “ពួកគេបានចាប់ចំរិតមនុស្សទាំងរស់នៅទីនេះ។ យើងមិនដឹងថាតើពួកគេស្លាប់ ឬក៏រស់នោះទេ។ រថក្រោះបានបាញ់រះមកលើប្រជាជន។ កងទ័ពជាច្រើននាក់បានឆ្លងកាត់ទីនេះ។ ប្រជាជនមួយចំនួនបានភៀសខ្លួន ហើយប្រជាជនជាច្រើនទៀតបានស្លាប់។ ... ការធ្វើទុក្ខបុកម្នេញភាគច្រើនគឺដោយសារកងកម្លាំងអាមេរិក និងកងកម្លាំងធៀវគី”។

លោក សែន អូស្មាន់ បានប៉ាន់ប្រមាណថា យ៉ាងហោចណាស់អ្នកភូមិ ៣០ នាក់បានស្លាប់ក្នុងការបំផ្ទុះគ្រាប់បែកនោះ ប៉ុន្តែគ្មានជនរងគ្រោះណាម្នាក់ជាប្រជាជនចាមឡើយ។ ប្រជាជនខ្មែរភាគច្រើនហាក់ដូចជាទទួលរងគ្រោះយ៉ាងខ្លាំង។ តាមពិតទៅ លោក អូស្មាន់ និយាយថា គ្មានប្រជាជនចាមណា ស្លាប់បាត់បង់ជីវិត ឬបាត់ខ្លួននៅក្នុងសង្គ្រាមឆ្នាំ ១៩៧០-៧៥ ឡើយ ប៉ុន្តែថា នៅត្រឹមចុងបញ្ចប់នៃសង្គ្រាម មានគ្រួសារត្រឹមតែ ៥០ គ្រួសារប៉ុណ្ណោះដែលមាននៅសល់ក្នុងភូមិ ដែលច្រើនជាងពាក់កណ្ដាលនៃពួកគេគឺជាប្រជាជនចាម។

អស់អ្នកដែលបានរស់រានមានជីវិតនៅក្នុងភូមិនេះ ទំនងជាបានក្លាយជាអ្នកគាំទ្ររបបខ្មែរក្រហមមួយផ្នែកដោយសារតែការរងទុក្ខលំបាករបស់ពួកគេ។ ពួកគេបានចូលរួមជាមួយ “ក្រុមប្រវាស់ដៃ” ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៧៣ តាមអ្នកញុះញង់របស់ពួកខ្មែរក្រហម។ អូស្មាន់ បានអះអាងថា៖ “នៅពេលនោះ (រហូតដល់ឆ្នាំ ១៩៧៥) ពួកខ្មែរក្រហមបានធ្វើស្រួលដាក់យើង គ្មានបញ្ហាអ្វីទេ។ ប្រជាជនចូលចិត្តអ្នកដែលមក ហើយមិនសម្លាប់ពួកគេ”។

ជីវិតសាសនា និងសង្គមក៏បានបន្ត “ធម្មតា” ដូចពីមុន។ សុះ ម៉ាន ជនកុម្មុយនីស្តចាមជើងចាស់ដែលបានរៀនសូត្រនៅហាណូយ (សូមមើលផ្នែកទី II និង IIIA2 ខាងលើ) បានទៅលេងភូមិតាកែវនៅក្នុងដំណាក់កាលមួយក្នុងអំឡុងសង្គ្រាមដើម្បីទៅជួបនឹង ហាក់កែម តា ឡោះ។ អូស្មាន់ បានរំលឹកថា៖ “[សុះ] ម៉ាន គឺជាអ្នកតំណាងឱ្យសាសនាឥស្លាមក្នុងភូមិភាគបូព៌ា។ ប្រជាជនចាមនៅទីនេះបានជឿលើគាត់។ ពួកគេអនុវត្តតាមទស្សនៈនយោបាយ [របស់គាត់]”។

លោក អូស្មាន់ និយាយថា បន្ទាប់ពីជ័យជម្នះរបស់ពួកខ្មែរក្រហមនៅខែ មេសា ឆ្នាំ ១៩៧៥ មានការផ្លាស់ប្ដូរដោយរលូនមួយទៅរកសន្តិភាពនៅក្នុងភូមិតាកែវ។ ទោះយ៉ាងណា នៅដើមឆ្នាំ ១៩៧៦ ការផ្លាស់ប្ដូរសំខាន់ៗពីរបានកើតឡើង។ សាលារៀនឥស្លាមក្នុងភូមិត្រូវបានបិទទ្វារ ហើយការអធិដ្ឋានត្រូវបានគេហាមឃាត់។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ពួកខ្មែរក្រហមក៏បានហាមឃាត់មិនឲ្យមានពុទ្ធសាសនាផងដែរ។ "ពួកគេនិយាយថា សាសនាគឺជាអំពើក្បត់ ក្បត់ប្រឆាំងនឹងបដិវត្តន៍ ប្រឆាំងនឹងមាក៌ាលេនីននិយម វាជាប្រព័ន្ធសក្តិភូមិមួយ។ ដូច្នេះ សាសនាមិនល្អទេ ហើយគេត្រូវតែលុបបំបាត់ចោល"។

ទីពីរ ការហូបរួមគ្នាត្រូវបានគេដាក់ចេញជាផ្នែកមួយនៃប្រព័ន្ធសេដ្ឋកិច្ចថ្មីរបស់ "សហករណ៍"។ ប្រព័ន្ធនេះបានទាមទារឲ្យមានការខិតខំធ្វើការ "ទាំងយប់ទាំងថ្ងៃដូចជាការធ្វើទារុណកម្មអញ្ចឹង ... ដោយគ្មានអាហារ ឬសម្លៀកបំពាក់ ឬដេក ឬថ្នាំសង្កូវគ្រប់គ្រាន់ឡើយ"។ ទោះយ៉ាងណា អ្វីដែលសំខាន់បំផុតសម្រាប់ប្រជាជនចាមនៅក្នុងរោងបាយរួមគ្នាដ៏រញ៉េរញ៉ៃនោះគឺ "ប្រជាជនចាមត្រូវហូប និងផឹកអ្វីដែលពួកគេមិនត្រូវ__បានអនុញ្ញាតឲ្យហូប និងផឹកបាន បើយោងតាមសាសនារបស់ពួកគេ។ "ប៉ុន្តែការដាក់ចេញថ្មីទាំងនេះមិនទាន់_បានអនុវត្តដោយអំពើហិង្សានៅឡើយទេ។

ក្នុងពេលជាមួយគ្នានោះ ខេត្តស្វាយរៀង ដែលគេស្គាល់ថាជាតំបន់ ២៣ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានធ្លាក់ក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលភូមិភាគនិរតី ដូចនៅតំបន់ ២៤ ជាប់នឹងខេត្តព្រៃវែងដែរ។ តំបន់ទាំងពីរនេះត្រូវបាននាំយកដោយយឺតៗមកឲ្យនៅក្រោមការឧបត្ថម្ភគាំទ្ររបស់ ម៉ុក និង_ត្រូវបានគេស្គាល់ថាជា "តំបន់ភ្លោះ"។

ពីដើមឆ្នាំ ១៩៧៧ ប្រជាជនចាមត្រូវបានគេ "បង្ខំជាខ្លាំង" ឲ្យហូបសាច់ជ្រូក។ រ៉េស សាន ដែលជាចាស់ទុំម្នាក់ក្នុងតំបន់នៅពេលនោះ និយាយប្រាប់ដំណើររឿងដូចនេះ៖

> សាច់ជ្រូកត្រូវបានគេដាក់ឲ្យហូបទាំងខ្មែរ និងចាម នៅក្នុងបបររាវៗ។ ម្ហូបអាហារគឺខ្សត់ណាស់ យើងមិនអាចហូបសាច់ជ្រូកបាន ប៉ុន្តែក៏មិនអាចរកវា [ដើម្បីចាប់យកចេញ] បានដែរ។ ប្រជាជនចាមត្រូវបានគេ "ដាក់មួយឡែក" ប្រសិនបើពួកគេមិនហូបសាច់ជ្រូកនោះ មានន័យថា ពួកគេនឹងត្រូវយកទៅសម្លាប់ចោល។ ... គេហៅយើងថា "អ្នកតវ៉ា" និង "ខ្មាំង" ប្រសិនបើយើងមិនហូបសាច់ជ្រូក។ ហាក់ កែម ឡោះ គឺជាមនុស្សម្នាក់ដែលត្រូវបានគេសម្លាប់ ដោយការបដិសេធមិនព្រមហូបសាច់ជ្រូក។

*[រូបភាព]*

*រូបថតដោយ Nguyen Van Ku ដោយមានការផ្តល់ជូនពី Kathleen Gough*

*ស្ត្រីចាមមូស្លីមកំពុងបំបៅដោះកូនរបស់នាងនៅដើមឆ្នាំ ១៩៨០។ ទារកដ៏រឹងមាំ និងមានសុខភាពល្អម្នាក់ ដូចជាទារកម្នាក់នេះមុខជានឹងក្លាយជាទារកដែលត្រូវគេស្វាគមន៍ជាពិសេសចំពោះប្រជាជនចាមនាពេលនោះ ដោយចាត់ទុកថា ក្នុងអំឡុងរបប ប៉ុល ពត (ខែ មេសា ឆ្នាំ ១៩៧៥-ខែ មករា*

Formatted: Condensed by 0.3 pt

Deleted: *Unrevised translation. A revised translation will be provided upon request.*

*ឆ្នាំ ១៩៧៩) ប្រជាជនចាមក្នុងប្រទេសកម្ពុជាដែលគេប៉ាន់ប្រមាណថាមានចំនួន ៩០.០០០ នាក់ ស្មើនឹងមួយភាគបីនៃប្រជាជនរបស់ខ្លួន បានស្លាប់នៅក្នុងដៃរបស់របបខ្មែរក្រហម។ បន្ទាប់ពីការដួលរលំនៃរបប ប៉ុល ពត អត្រាកំណើតប្រជាជនកម្ពុជាបានកើនឡើងយ៉ាងខ្លាំង ហើយក៏ភ្លាមៗស្រាប់តែមានចំនួនទារកយ៉ាងច្រើនក្រៃលែង។*

អូស្មាន់ បានចាត់ទុកអំឡុងពេលនោះថាជា "ការស្វែងរកខ្មាំង និងភ្នាក់ងារផ្ទៃក្នុង ពោលគឺ ខ្មាំងក្នុងពាក្យសម្ដី ខ្មាំងនៅកន្លែងការងារ [ប្រជាជន] អសកម្ម"៖ "ដូច្នេះប្រសិនបើយើងនិយាយអ្វីខុសតែបន្តិច ដូចជា "យើងទាំងអស់គ្នានឿយហត់" ពួកគេនឹងមកយកយើងទៅសម្លាប់ចោលហើយ។ តា ឡោះ តា មិត្ត គ្រូ អែល និងក្រុមគ្រួសារទាំងអស់របស់ពួកគេត្រូវបានគេមកយកទៅ ប្រមាណជិត ៣០ នាក់ ម្ដងម្នាក់ៗ"។

ស្ទើរតែភ្លាមៗនោះ សហគមន៍ចាមក្នុងភូមិតាកែវត្រូវបានបំបែក។ ដោយចាប់ផ្ដើមនៅខែ មករា ឬ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ "គ្រប់គ្នា" ត្រូវបានជម្លៀសចេញ រប៉ាត់រប៉ាយទៅភូមិផ្សេងៗប្រហែលជា ៦ នៅក្នុងស្រុក "ពីរ ឬបីគ្រួសារទៅភូមិនីមួយៗ ប៉ុន្តែពួកគេថែមទាំងត្រូវគេបំបែកពីគ្នាទៀតផងនៅក្នុងភូមិខ្មែរទាំងនោះ"។ គ្រួសារខ្មែរនៅខេត្តតាកែវក៏ត្រូវបានបំបែកផងដែរ ហើយអ្នកផ្សេងទៀតត្រូវគេនាំទៅរស់នៅទីនោះពីភូមិតាឃុប ដែលនៅក្បែរនោះ។ អូស្មាន់ និយាយទាំងក្រៀមក្រំថា៖ "ដូច្នេះនោះឯងគឺជាចុងបញ្ចប់នៃការរស់នៅក្បែរគ្នា មើលថែរក្សា និងយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។ វាត្រូវបានគេបំផ្លាញចោលទាំងស្រុង។ លែងមានការទុកចិត្តគ្នាទៀតហើយ។ យើងមានតែត្រូវគិតដល់មាគ៌ារបស់ ប៉ុល ពត តែប៉ុណ្ណឹង។ នោះហើយ_គឺជាជីវិត។

អូស្មាន់ ត្រូវគេបញ្ជូនទៅភូមិព្រែកជាយ។ គាត់និយាយថា អ្នកភូមិនៅភូមិតាកែវប្រហែល ៦០ នាក់ បានបាត់ខ្លួននៅឆ្នាំ ១៩៧៧ ឬ ១៩៧៨ បន្ទាប់ពីត្រូវបានជម្លៀសទៅភូមិផ្សេងទៀត និងមិនមានអ្នកទទួលខុសត្រូវ។ "ការធ្វើទារុណកម្មលើប្រជាជនឥស្លាមនៅតែបន្តកើនឡើង"។ "ពួកគេមិនដែលធ្លាប់ហូបសាច់ជ្រូកទេ។ ... អ្នកដែលបដិសេធមិនព្រមហូបសាច់ជ្រូកត្រូវគេហៅថាខ្មាំង "ខ្មាំងវណ្ណៈ" គឺជាអ្វីដែលពួកគេបាននិយាយ។ "អ្នកមិនបោះបង់ប្រពៃណី និងទម្លាប់របស់ប្រព័ន្ធសក្តិភូមិទេ។ នោះមានន័យថា អ្នកកំពុងតែប្រឆាំងនឹងបដិវត្តន៍ហើយ""។ រ៉េស សាន សម្រាប់ផ្នែកគាត់ ត្រូវគេបញ្ជូនទៅភូមិព្រៃស្វាយ។ នៅចុងឆ្នាំ ១៩៧៧ គាត់_បាននិយាយថា៖ "ខ្ញុំត្រូវគេចោទប្រកាន់ពីបទរង់ចាំពួកវៀតណាមមកដល់ មកសម្លាប់គោក្របីឱ្យពួកគេយក_ទៅជប់លៀងសប្បាយ។ ខ្ញុំមិនបាននិយាយអ្វីទាំងអស់"។ គាត់ត្រូវគេចាប់ខ្លួនជាមួយជនជាតិខ្មែរពីរនាក់ ដែល_មានម្នាក់ជាបុរសចំណាស់ និងដាក់ក្នុងគុកអស់រយៈពេលពីរសប្ដាហ៍។ នៅកន្លែងដែល សាន រស់នៅ មិនមានការសម្លាប់មនុស្សទេ។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

យោងតាម អូស្មាន់ ឆ្នាំ ១៩៧៨ គឺជាឆ្នាំ ដែលប្រជាជនចាម និងខ្មែរបានស្លាប់ ឬបាត់ខ្លួនក្នុងចំនួនដ៏ច្រើនបំផុត។ ឆ្នាំនោះជាឆ្នាំនៃការជម្លៀសប្រជាជនលើកទីពីរ ទៅភូមិភាគពាយ័ព្យនៃប្រទេស។ ថ្ងៃមួយនៅចុងឆ្នាំ ១៩៧៨ ៥ គ្រួសារត្រូវបានជម្លៀសចេញពីព្រែកជាយ ៣ ថ្ងៃក្រោយមក ៦ ឬ ៧ គ្រួសារទៀតបានទៅតាមក្រោយដែរ។ ពួកគេបានដើរមកទីក្រុងភ្នំពេញ ហើយបន្ទាប់មកធ្វើដំណើរតាមរថភ្លើងទៅស្រុកមោងឬស្សី។ អូស្មាន់ បានធ្វើដំណើរជាមួយឪពុកម្តាយ និងបងប្រុសម្នាក់របស់គាត់។ នៅរយៈពេលពី ៣ ទៅ ៤ ខែក្រោយកមកនៅទីនោះ គាត់បានឃើញប្រជាជនដែលត្រូវបានគេចាប់ចងជាសាធារណៈដោយពួកខ្មែរក្រហមនៅចំពោះមុខហ្វូងមនុស្ស ហើយគាត់បានដឹងថា ជនរងគ្រោះផ្សេងទៀតត្រូវគេចាប់ខ្លួនដោយសម្ងាត់។ ឪពុករបស់ អូស្មាន់ គឺ តាំ សែន បានរំលឹកថា "មនុស្សច្រើនមែនទែនបានស្លាប់ គឺ ៣០ ឬ ៤០ គ្រួសារក្នុងរយៈពេលប៉ុន្មានថ្ងៃ"។ ទោះយ៉ាងណា "យើងអាចរួចខ្លួនពីការមិនហូបសាច់ជ្រូក ... ប៉ុន្តែគេមិនអនុញ្ញាតឱ្យយើងប្រតិបត្តិសាសនាឡើយ។ ពួកខ្មែរក្រហមនឹងនិយាយថា៖ "តើអ្នកចង់អធិដ្ឋានសុំអី? ចង់សុំឱ្យពួកវៀតណាមមកឬ?""

ដោយសារតែជំនាញរបស់គាត់ជាជាងដែក តាំ សែន និងក្រុមគ្រួសាររបស់គាត់បានរួចរស់ជីវិតដោយគ្មានការប៉ះពាល់អ្វី។ ហើយក្រុមគ្រួសារចាម ២ គ្រួសារផ្សេងទៀតមកពីតាកែវ រួមទាំងគ្រួសាររបស់ រ៉េស សាន ក៏ដូចគ្នាដែរ។ នៅពេលដែលកងកម្លាំងវៀតណាមបានមកដល់តំបន់នេះ សាន បានធ្វើដំណើរត្រឡប់ទៅខេត្តស្វាយរៀងវិញ។ គាត់បានក្លាយជា ហាក់កែម សម្រាប់អ្នកភូមិមូស្លីមដែលនៅរស់រានមានជីវិតក្នុងភូមិតាកែវ និងជួយសាងសង់វិហារឥស្លាមធ្វើពីឈើតូចមួយក្នុងឆ្នាំ ១៩៨៤។ ឥឡូវនេះ ក្មេងៗចាមក្នុងភូមិតាកែវចូលរៀនភាសាខ្មែរនៅសាលារៀនក្នុងភូមិរៀងរាល់ព្រឹក ហើយ រ៉េស សាន បង្រៀនភាសាអារ៉ាប់ដល់ពួកគេនៅពេលរសៀល។

នៅត្រង់នេះ យើងធ្វើការសន្និដ្ឋានបញ្ចប់ការសិក្សារបស់យើងលើប្រជាជនចាមនៅភូមិភាគបូព៌ា។ វាជារឿងគួរឱ្យភ័យខ្លាច ប៉ុន្តែមុនពេលឆ្លងទៅព្រឹត្តិការណ៍នៅភូមិភាគផ្សេងៗទៀត ការកត់ត្រាអំពីគំនិតរបស់ប្រជាជនចាមពីរនាក់ទៀតដែលបានរស់នៅឆ្លងកាត់រឿងនេះគឺមានតម្លៃណាស់។ សារី ប៊ិន កាស៊ឹម មានអាយុ ១៥ ឆ្នាំនៅពេលដែលពួកខ្មែរក្រហមជម្លៀសគាត់ពីភ្នំពេញទៅភូមិភាគបូព៌ា ដែលគាត់បានរស់នៅទីនោះរយៈពេលមួយឆ្នាំមុននឹងត្រូវគេជម្លៀសចេញទៅភូមិភាគពាយ័ព្យជាថ្មីម្តងទៀត។ នៅឆ្នាំ ១៩៨៤ នៅជំរំ ណង សាម៉េត ជាប់នឹងព្រំដែនថៃ កាស៊ឹម បានប្រាប់លោក Nate Thayer ក្នុងបទសម្ភាសន៍មួយថា ប្រជាជនចាមមូលដ្ឋាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវគេប្រព្រឹត្តដាក់ល្អប្រសើរជាងប្រជាជនថ្មី ដូចជាខ្លួនគាត់ជាដើម "ជាពិសេសនៅភូមិភាគបូព៌ា"។ កាស៊ឹម បាននិយាយថា រឿងនេះស៊ីគ្នានឹងភាពលម្អៀងរបស់ពួកខ្មែរក្រហមចំពោះប្រជាកសិករមូលដ្ឋានជាទូទៅ។

Deleted: *Unrevised translation. A revised translation will be provided upon request.*

គុត អិល គឺជា ប្រជាជនមូលដ្ឋានវ័យក្មេងម្នាក់មកពីភូមិភាគបូព៌ា។ គាត់គឺជាកម្មករចម្ការកៅស៊ូវ័យ ១៦ ឆ្នាំម្នាក់នៅពេលដែលពួកខ្មែរក្រហមបានឈ្នះសង្គ្រាមក្នុងឆ្នាំ ១៩៧៥។ អិល បានបន្តរស់នៅក្នុងភូមិភាគបូព៌ានេះទៀតបន្ទាប់ពីភូមិភាគនេះត្រូវបានកាន់កាប់ដោយកងកម្លាំងភូមិភាគនិរតីក្នុងឆ្នាំ ១៩៧៨។ ភូមិរបស់គាត់ក្នុងតំបន់ ២១ មានប្រជាជន ៨០ គ្រួសារ ដែលក្នុងនោះមានប្រជាជនចាម ៥០ គ្រួសារ។ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧ អ្នកភូមិ ៦ នាក់ត្រូវបានសម្លាប់ដោយពួកខ្មែរក្រហមនៅភូមិភាគបូព៌ា ដែលភាគច្រើនដោយសារតែមិនបានប្រឹងប្រែងធ្វើការឲ្យបានគ្រប់គ្រាន់។ ប៉ុន្តែនៅឆ្នាំ ១៩៧៨ ដែលជាឆ្នាំអាក្រក់បំផុត នៅពេលដែលកងកម្លាំងភូមិភាគនិរតីគ្រប់គ្រង ដោយសារតែការបន្ថយរបបអាហារធ្ងន់ធ្ងរ និងក៏ដោយសារតែការសម្លាប់មនុស្សក្នុងចំនួនយ៉ាងច្រើនបានកើតឡើងនៅចុងឆ្នាំ ១៩៧៨ នៅពេលដែលអាជ្ញាធរភូមិភាគនិរតីបានសម្លាប់ប្រជាជន ១៣ គ្រួសារក្នុងភូមិ។ គុត អិល បានប្រាប់លោក Nate Thayer ថា តាមការយល់ឃើញរបស់គាត់ កងកម្លាំងភូមិភាគបូព៌ា នៅក្នុងភូមិរបស់គាត់ផ្ទាល់ "និងជាទូទៅ" បានប្រព្រឹត្តដាក់ប្រជាជនចាមល្អប្រសើរ_ជាងអ្វីដែលកងកម្លាំងភូមិភាគនិរតីបានប្រព្រឹត្តដាក់។

ដូចដែលយើងបានឃើញរួចហើយ ប្រជាជនចាមជាច្រើនមកពីតំបន់កោះផលក្នុងភូមិភាគបូព៌ាត្រូវគេជម្លៀសចេញដោយបង្ខំទៅកាន់ភូមិភាគឧត្តរ ឬទៅតំបន់ផ្សេងៗទៀតក្នុងភូមិភាគបូព៌ា។ នៅក្នុងករណីទាំងពីរនេះ ពួកគេត្រូវបានគេដកហូតឋានៈជាប្រជាជនមូលដ្ឋាន "ពេញសិទ្ធិ"។ នៅតំបន់ដែលមានប្រជាជនចាមផ្សេងៗទៀត ដូចជាកំពង់ត្របែក ប្រជាជនបានភៀសខ្លួនទៅកាន់ទីក្រុងភ្នំពេញក្នុងអំឡុងពេលសង្គ្រាមឆ្នាំ ១៩៧០-៧៥ ហើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការពិតនេះបានដកហូតឈ្មោះជាប្រជាជនមូលដ្ឋាន "ពេញសិទ្ធិ" ពីពួកគេ។ ទោះយ៉ាងណា ក្នុងអំឡុងពេលការធ្វើជំរឿនប្រជាជនរបស់យើងនៅក្នុងសហគមន៍កំពង់ត្របែក ស្ត្រីជាកសិករជនជាតិចាមម្នាក់បានអះអាងថា ខ្លួនបានទទួលឋានៈជាប្រជាជនមូលដ្ឋាន "ពេញ_សិទ្ធិ" នៅកន្លែងដទៃទៀតក្នុងតំបន់ ២៤ ហើយអ្នកផ្សេងទៀតបានបញ្ជាក់ថា ប្រជាជនចាមមួយចំនួនក៏ទទួល__បានដែរ។ ដូចដែលយើងនឹងមើលឃើញ មិនមានភ័ស្តុតាងណាបង្ហាញថា ប្រជាជនចាមរីករាយនឹងឋានៈ_បែបនោះក្នុងតំបន់ផ្សេងៗទៀតឡើយ។ នៅទីនោះ ប្រជាជនចាមមូលដ្ឋានទាំងអស់ (និងពិតណាស់ជាប្រជាជន "ថ្មី") ត្រូវបានគេដកហូតឋានៈ "ពេញសិទ្ធិ" នោះយ៉ាងជាក់ស្ដែង ដោយសារតែ បញ្ហានៃគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ។

### ខ. ភូមិភាគឧត្តរ (កណ្ដាល)

ឆ្លងកាត់ទន្លេមេគង្គ ពីភូមិភាគបូព៌ាគឺជាភូមិភាគឧត្តរដែលមិនសូវមានប្រជាជនរស់នៅកុះករបន្តិចដែលត្រូវបានប្ដូរឈ្មោះទៅភូមិភាគកណ្ដាលក្នុងឆ្នាំ ១៩៧៦។ វារួមផ្សំឡើងពីផ្នែកភាគខាងជើងនៃខេត្តកំពង់ចាម

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

(តំបន់ ៣១ របស់បក្សកុម្មុយនីស្តកម្ពុជានៅ ១៩៧០-៧៥) និងខេត្តកំពង់ធំ និងព្រះវិហារ។ ប្រជាជនចាមមិនសូវច្រើនទេរស់នៅទីនោះ។ ទោះជាយ៉ាងណា ពួកគេបានប្រមូលផ្តុំគ្នានៅក្នុងតំបន់ជាក់លាក់មួយចំនួន ហើយនៅឆ្នាំ ១៩៧៣-៧៤ យុទ្ធនាការរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងប្រជាជនចាមបានចាប់ផ្តើមនៅ_ទីនោះ។ លើសពីនេះទៀត ដូចដែលយើងបានដឹង ប្រជាជនចាមជាច្រើនមកពីភូមិភាគបូព៌ាត្រូវគេជម្លៀសចេញ_ពីទីនោះបន្ទាប់ពីការបះបោរនៅស្រុកក្រូចឆ្មារ ឆ្នាំ ១៩៧៥។

## ១. ខេត្តកំពង់ចាម

តំបន់ធំៗបីនៃការតាំងទីលំនៅរបស់ប្រជាជនចាម គឺនៅតាមច្រាំងទន្លេមេគង្គភាគខាងជើងទល់មុខនឹងភូមិភាគបូព៌ា; នៅតំបន់ចម្ការដី "ដីក្រហម" ដ៏មានជីជាតិនៃស្រុកចំការលើ; និងបន្តទៅភាគខាងជើងនៅក្នុងស្រុកបារាយណ៍ខេត្តកំពង់ធំ។ ក្រុមប្រជាជនចាមតូចៗជាងនេះត្រូវបានរកឃើញមានដែរនៅស្រុកផ្សេងៗទៀតផងដែរ។

មេដឹកនាំចាមម្នាក់បានប្រាប់ខ្ញុំនៅឆ្នាំ ១៩៨៦ ថា "ប្រជាជនចាមបានស្លាប់ច្រើនជាងគេបំផុតនៅក្នុងឃុំចំនួន ៦ ឬ ៧ នៅតាមបណ្តោយច្រាំងទន្លេមេគង្គភាគខាងជើងក្នុងខេត្តកំពង់ចាម។ ... មិនមែនមានគ្រួសារមួយបាននៅរស់រានមានជីវិតនោះទេ គឺមានតែមនុស្សម្នាក់ ឬពីរនាក់ប៉ុណ្ណោះដែលនៅរស់។ នេះគឺជាតំបន់មួយដែលពិតជារងការធ្វើទារុណកម្មមែនទែន[92]។

នៅឆ្នាំ ១៩៤០ លោក Marcel Ner បានរាយការណ៍ថា មានប្រជាជនចាម ៣៨០ គ្រួសារនៅក្នុងភូមិជាប់មាត់ទន្លេចំនួន ៣ ក្នុងស្រុកកងមាសនាភាគខាងជើងខេត្តកំពង់ចាម។ សហគមន៍ទាំងនេះទ្រទ្រង់សាលារៀនមូស្លីមចំនួន ២ ដែលនីមួយៗមានសិស្សចំនួន ៥០ នាក់[93]។ កំណើនប្រជាជនតាមធម្មតានឹងនាំឲ្យសហគមន៍ចាមទាំងនេះមានគ្រួសារសរុបប្រមាណ ១.២០០ គ្រួសារនៅត្រឹមឆ្នាំ ១៩៧៥។ នៅត្រឹមឆ្នាំ ១៩៧៥ ភូមិចាមចំនួន ៣ បានកើនឡើងដល់ទៅ ៥[94]។ ភូមិទាំងនេះត្រូវបានរួមបញ្ចូលទៅក្នុងតំបន់មួយដែលឥឡូវនេះត្រូវបានគេហៅថាតំបន់ ៤១ នៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ ១៩៧៩ "គ្មានអ្នកនៅរស់រានមានជីវិត" ពីភូមិអន្ទង់សទេ។ ប្រជាជននៅក្នុងភូមិនេះត្រូវគេបំបែកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងមានតែប្រជាជនចាមម្នាក់

---

[92] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ទេព អ៊ីប្រាហ៊ីម (សូមមើលកំណត់ចំណាំលេខ ៣៩)។

[93] Ner, "ជនមូស្លីម" ទំព័រ ១៧៥-៧៦។

[94] ភូមិទាំងប្រាំនេះរួមមាន អន្ទង់ស អង្គរបាន ខ្សាច់ស ស្វាយតាហែនក្រៅ និងស្វាយតាហែនក្នុង។ សូមមើល *ការបំផ្លាញសាសនាអ៊ីស្លាមក្នុងអតីតរបបកម្ពុជាប្រជាធិបតេយ្យ* (ភ្នំពេញ ឆ្នាំ ១៩៨៣) ទំព័រ ១៣។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

គត់ដែលនៅរស់រានមានជីវិត គឺបុរសម្នាក់ដែលបានទៅរស់នៅតែម្នាក់ឯងនៅក្នុងភូមិខ្មែរ និងបានដាក់ឈ្មោះខ្មែរថា ឈូក[95]។ នៅឆ្នាំ ១៩៨៣ របាយការណ៍មួយរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ស្ដីអំពីប្រជាជនចាមបានរាយការណ៍អំពី ក្រុមគ្រួសារចាមចំនួន ១.២០០ គ្រួសារនៅក្នុងភូមិទាំង ៥ តាមដងទន្លេមេគង្គថា៖ "បន្ទាប់ពីពួកគេមួយចំនួនត្រូវគេបំបែក ពួក ប៉ុល ពត និយមបានសម្លាប់រង្គាលប្រជាជនដែលនៅសេសសល់នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩៧៨។ រហូតមកដល់ពេលនេះ មានមនុស្សតែ ៤ នាក់ប៉ុណ្ណោះដែលត្រូវបានគេរកឃើញថានៅរស់រានមានជីវិត"។ លោកបណ្ឌិត ទិន យុស្វហ្វ អាប់ឌុលក្វាយ៉ូម ដែលឥឡូវជាមន្ត្រីរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា អះអាងថាបានឃើញពួកខ្មែរក្រហមនៅស្រុកកងមាសដុតកុមារចាម ៥ នាក់រហូតដល់ស្លាប់ផ្ទាល់នឹងភ្នែក[96]។ ជាអកុសល មិនមានព័ត៌មានបន្ថែមដែលគេអាចទទួលបានអំពីស្រុកកងមាសឡើយ ប្រហែលជាដោយសារតែទំហំនៃការសម្លាប់រង្គាលរបស់ប្រជាជនចាមនៅទីនោះ។

ស្រុកកំពង់សៀមដែលនៅជិតខាងនោះក៏ជាផ្នែកមួយនៃតំបន់ ៤១ ដែលស្ថិតនៅតាមបណ្ដោយច្រាំងទន្លេមេគង្គភាគខាងជើងដែរ។ លោក Ner បានរាយការណ៍នៅឆ្នាំ ១៩៤០ ថា មានប្រជាជនចាមចំនួន ៣.៨០០ នាក់នៅក្នុងស្រុក ដែលទ្រទ្រង់ដល់សាលារៀនមួយ"[97]។ នៅត្រឹមឆ្នាំ ១៩៧៥ ប្រជាជនចាមបានឈានដល់ ២.០០០ គ្រួសារ នៅក្នុងភូមិចំនួន ៧។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានអះអាងនៅឆ្នាំ ១៩៨៣ ថា "ប្រជាជនទាំងអស់បានស្លាប់"[98]។ គេមិនអាចបញ្ជាក់បានទេពីសេចក្ដីថ្លែងការណ៍នេះ ប៉ុន្តែដំណើររឿងឯករាជ្យមួយដែលគេអាចរកបានពីស្រុកកំពង់សៀមអាចផ្ដល់ជាយោបល់បាន។ នៅក្នុងភូមិជ្រនាងប្រជាជនខ្មែរ ១២ នាក់ត្រូវបានគេសម្លាប់នៅអំឡុងឆ្នាំ ១៩៧៥-៧៨ ក្នុងនោះមាន ៨ នាក់ជាប្រជាជនថ្មី។ ប៉ុន្តែនៅឆ្នាំ ១៩៧៧ តែឯង គ្រួសារចាម ១៣ គ្រួសារត្រូវបានសម្លាប់ សរុបទាំងអស់ជាង ៨០ នាក់។ ពួកគេក៏ជាប្រជាជនថ្មីដែរ និងធ្លាប់ចូលរួមជាមួយនឹងកងកម្លាំងប្រដាប់អាវុធ លន់ នល់។ ពួកគេត្រូវបានជម្លៀសចេញពីទី

[95] ទេព អ៊ីប្រាហ៊ីម, បទសម្ភាសន៍ (សូមមើលកំណត់ចំណាំលេខ ៣៩)។

[96] *ការបំផ្លាញសាសនាអ៊ីស្លាម* ទំព័រ ១៣, ១៩។

[97] Ner, "ជនមូស្លីម" ទំព័រ ១៧៦។

[98] *ការបំផ្លាញសាសនាអ៊ីស្លាម* ទំព័រ ១៣។ ភូមិទាំងអស់ចំនួន ៧ ត្រូវបានដាក់ឈ្មោះនៅទីនោះ។

Deleted: *Unrevised translation. A revised translation will be provided upon request.*

រួមខេត្តកំពង់ចាមដែលនៅក្បែរនោះក្នុងឆ្នាំ ១៩៧៥ យកទៅភូមិនោះនៅឆ្នាំ ១៩៧៦ ហើយពួកគេទាំងអស់ត្រូវបានសម្លាប់រង្គាលក្នុងឆ្នាំ ១៩៧៧[99]។

សាម៉ាស នី ដែលជាអ្នកនេសាទ និងកសិករជនជាតិចាមម្នាក់ មកពីច្រាំងចម្រេះក្នុងតំបន់ជាយក្រុងភាគខាងជើងនៃទីក្រុងភ្នំពេញ ត្រូវបានគេជម្លៀសចេញពីទីក្រុងនៅខែ មេសា ឆ្នាំ ១៩៧៥។ កូនៗរបស់គាត់ ៣ នាក់ត្រូវបានសម្លាប់ដោយពួកខ្មែរក្រហមក្នុងអំឡុងពេលជម្លៀសនោះ។ ជាមួយនឹងបងប្អូនប្រុសស្រី ៣ នាក់ និងកូនប្រុសច្បង រួមជាមួយកូនប្រសារស្រីរបស់គាត់ម្នាក់ដែលនៅ នី បានធ្វើដំណើរទៅបាធាយក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម (តំបន់ ៤១)។ គាត់និយាយថា ចៅហ្វាយស្រុកខ្មែរក្រហមនៅទីនោះ ដែលគេស្គាល់ថាជា “មិត្ត សៅ” គឺជាបុរសដែលមានការអត់ឱនម្នាក់ដែល “មិនដែលសម្លាប់មនុស្សសោះ”។ សៅ បានទទួចឲ្យមានរបបអាហារគ្រប់គ្រាន់សម្រាប់ប្រជាជន និងអនុញ្ញាតឲ្យមានសេរីភាពនៃការដើរហើរនៅក្នុងស្រុក។ លើសពីនេះទៅទៀត នី បន្ថែមថា៖

> ឪពុកខ្ញុំគឺជាសង្ឃរាជ។ នៅពេលដែលគាត់បានមកដល់ទីនេះដំបូង គាត់បានបន្តអធិដ្ឋាន និងមិនបោះបង់វាចោលឡើយ។ ប្រធានក្រុម និងតំបន់ថ្នាក់ទាបបានជូនដំណឹងដល់មិត្ត សៅ ថា មានបុរសវ័យចំណាស់ម្នាក់ដែលនៅតែបន្តកាន់សាសនា ជាខ្មែរមូស្លីមម្នាក់ដែលនៅតែអធិដ្ឋានដល់ព្រះអាឡោះដដែល។ “តើគួរធ្វើដូចម្តេច? កុំឲ្យគាត់ធ្វើទៀត”។ ប៉ុន្តែ សៅ បាននិយាយថា “ឲ្យគាត់ធ្វើអ្វីដែលគាត់ចង់ធ្វើទៅ ទៅតាមសាសនា និងទម្លាប់របស់គាត់ចុះ។ ឲ្យគាត់ធ្វើចុះ កុំទៅហាមឃាត់គាត់អី”។
>
> ប៉ុន្តែគំនិតរបស់ភ្នាក់ងារ ប៉ុល ពត គឺត្រូវលុបបំបាត់សាសនា។ ... នៅឆ្នាំ ១៩៧៧ សៅ ត្រូវបានគេសម្លាប់។ គាត់ត្រូវបានគេចោទប្រកាន់ពីបទក្បត់ជាតិ។ ... ប៉ុល ពតបាននិយាយថា គ្មានសាសនា គ្មានទីផ្សារ គ្មានលុយ។

នី អះអាងថា មិនមានការសម្លាប់មនុស្សនោះទេនៅក្រោមការគ្រប់គ្រងអំណាចរបស់ សៅ នៅឆ្នាំ ១៩៧៦ ប៉ុន្តែចាប់ពីខែ មករា ឆ្នាំ ១៩៧៧ “ការសម្លាប់ក៏ចាប់ផ្តើមមាន”។ កូនប្រុសទី ៤ និងបងប្អូនប្រុស ៣ នាក់របស់ នី ត្រូវបានគេសម្លាប់ទាំងអស់ នៅឆ្នាំ ១៩៧៧។ គាត់បាននិយាយថា បន្ទាប់មក នៅឆ្នាំ ១៩៧៨ គ្រួសារមូស្លីមចំនួន ១០៥ គ្រួសារមកពីទំនប់ក្នុងស្រុកជើងព្រៃត្រូវបានគេសម្លាប់រង្គាល។ “គ្មាននរណាម្នាក់បានរស់រានមានជីវិតឡើយ។ បងប្អូនជីដូនមួយរបស់ខ្ញុំដែលធ្លាប់ធ្វើជា ហ័តជី មីងរបស់ខ្ញុំ ជាដើម ត្រូវបាន_គេ

[99] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ណុប សុផុន ដែលរស់នៅភូមិជ្រនៀង ឃុំទ្រាន នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទីក្រុងភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៨៧។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

កៀង និងសម្លាប់ចោលទាំងអស់។ ពួកគេត្រូវបានដាក់នៅលើរទេះគោ ហើយដឹកយកទៅចំការលើ។ ... ពួកគេត្រូវបានគេសម្លាប់ និងទម្លាក់ចូលក្នុងប្រឡាយនៅចំការអណ្ដូង”។

លោក ទេស អូស្មាន់ អាយុ ៣២ ឆ្នាំ បានកើតនៅក្នុងគ្រួសារចាមមួយក្នុងភូមិចំការអណ្ដូង ក្នុងស្រុកចំការលើ (តំបន់ ៤២)។ ពួកខ្មែរក្រហមបានកាន់កាប់ភូមិនេះនៅឆ្នាំ ១៩៧០ ហើយដូច្នេះ ប្រជាជនចាមចំនួន ៥០០ នាក់នៅក្នុងភូមិនេះបានក្លាយជាប្រជាជនមូលដ្ឋាន។ ទោះយ៉ាងណា នៅឆ្នាំ ១៩៧៥ ពួកគេត្រូវបានគេជម្លៀសចេញពីភូមិ និងបំបែកគ្នា។ អូស្មាន់ បានអះអាងថា មានគ្រួសារចាមតែ ២០ គ្រួសារប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យនៅ គឺគ្រួសារ “មេដឹកនាំ កងឈ្លប ។ល។ អ្នកដែលមិនដឹងអី”។ ប្រជាជនមូលដ្ឋានដែល_នៅទាំងនេះ ដែលភាគច្រើននៃអ្នកភូមិចាមចំនួន ៥០០ នាក់ត្រូវគេចាត់ថ្នាក់ជាប្រជាជនថ្មី ដូចប្រជាជនដែលមកពីភ្នំពេញ ព្រោះពួកគេឥឡូវត្រូវបានគេជម្លៀសចេញពីផ្ទះសម្បែងរបស់ពួកគេរួចហើយ។ អាក្រក់ជាងនេះ_ទៅទៀត អត្រានៃអ្នកស្លាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្តបន្ទាប់គឺស្មើនឹងអត្រានៃអ្នកដែលនៅរស់រានមានជីវិត__ដល់ឆ្នាំ ១៩៧៩ គឺតែ ២០ គ្រួសារនោះឯង”។

ទេព អ៊ីប្រាហ៊ីម គឺជាបុគ្គលិកម្នាក់នៅក្រុមហ៊ុននាំចូលរបស់រដ្ឋឈ្មោះ សូណាព្រីម នៅពេលដែលពួកខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញនៅឆ្នាំ ១៩៧៥។ នៅពេលនោះ គាត់មានអាយុ ៣៤ ឆ្នាំ ជាមួយប្រពន្ធ និងកូនពីរនាក់។ ពួកគេបានដើរអស់រយៈពេលមួយខែទៅស្រុកចំការលើ រួមជាមួយនឹងគ្រួសារចាមដែលត្រូវគេជម្លៀសចំនួន ១៥០ គ្រួសារទៀត ទៅកាន់ភូមិចាមដ៏ធំនៅស្ពឺ ដែលមានប្រជាជនមូលដ្ឋានចាមចំនួន ៥.០០០ គ្រួសារ។ បន្ទាប់ពីបានពីរសប្ដាហ៍ គ្រួសារចាមទាំងអស់ លើកលែងតែ ៧០ គ្រួសារនៃគ្រួសារចាមទាំងនេះនៅស្ពឺត្រូវបានគេបំបែក។ វិហារឥស្លាមត្រូវបានបិទទ្វារ ហើយសាសនាក៏ត្រូវបានហាមឃាត់។ គ្រួសាររបស់ អ៊ីប្រាហ៊ីម ត្រូវបានគេដាក់នៅក្នុងភូមិស្ពឺ ក ដែលនៅក្បែរនោះ និងរៀបចំជាក្រុមប្រវាស់ដៃ។ អ៊ីប្រាហ៊ីម បានកត់សម្គាល់ថា ជនជាតិចិន មិនដូចជនជាតិចាមមូស្លីមទេ មិនត្រូវបានគេប្រព្រឹត្តដាក់អាក្រក់ៗទេ។ នៅចម្ងាយពីរគីឡូម៉ែត្រពីភូមិនេះគឺជាភូមិរបស់ជនជាតិចិន ដែលមិនត្រូវបានគេបំបែកឡើយ។

នៅដើមឆ្នាំ ១៩៧៦ ប្រជាជនចាម និងខ្មែរមួយចំនួនធំមកពីទ្រា និងផ្នែកផ្សេងៗទៀតនៃស្រុកក្រូចឆ្មារ និងភូមិភាគបូព៌ាត្រូវបានគេនាំខ្លួនតាមឡានដឹកទំនិញទៅកាន់ចម្ការកៅស៊ូចំការអណ្ដូង។ អ៊ីប្រាហ៊ីម បានឃើញ “រណ្ដៅដែលគេជីករួចរាល់” ដែលជាកន្លែងដែលពួកគេនឹងត្រូវកប់។ គាត់ជឿជាក់ថា ប្រជាជនចាម “រាប់រយនាក់រាប់ពាន់នាក់” ត្រូវបានសម្លាប់រង្គាលនៅទីនោះ។ នៅខែ មីនា ដល់ខែ មេសា ឆ្នាំ ១៩៧៦ សហករណ៍តូចៗត្រូវបានបង្កើតឡើង ហើយការហូបរួមគ្នាក៏ត្រូវបានដាក់ចេញ។ “គេលែងអនុញ្ញាតឲ្យយើងដើររកអាហារទៀតហើយ (ដែលពួកគេបាននិយាយថា “គ្មានពេល”) ដូច្នេះ យើងមានអ្វីហូបតិចជាងមុន។ ចំពោះរយៈពេលពីរខែ

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ដំបូង មានបបររាវៗច្រើន។ អ្នកខ្លះហូបអស់ ៧ ចាននៅពេលហូបម្ដងៗ។ ប៉ុន្តែក្រោយមក មានបបររាវៗតែពីរស្លាបព្រាប៉ុណ្ណោះសម្រាប់ម្នាក់ៗ។ ... យើងត្រូវបានគេបង្ខំឱ្យហូបសាច់ជ្រូក អ្នកខ្លះមិនចេះហូបនោះទេ ហើយក៏ក្អួតមកវិញ។ នៅត្រឹមពាក់កណ្ដាលឆ្នាំ ១៩៧៦ ប្រជាជនមូលដ្ឋានដែលធ្លាប់តែគាំទ្របដិវត្តន៍បានប្រែជាស្រងាកចិត្តអស់ មិនមែនដោយសារតែការខ្វះខាតម្ហូបអាហារប៉ុណ្ណោះទេ តែ_ដោយសារតែតម្រូវការឱ្យពួកគេធ្វើការធ្ងន់។ ថ្ងៃធ្វើការគឺចាប់ផ្ដើមនៅម៉ោង ៤:៣០ ព្រឹក (ឬសឹងតែម៉ោង ៣:៣០ ព្រឹកសម្រាប់កម្មករដែលខ្លាំងបំផុត) ដោយត្រូវដើរទៅកន្លែងធ្វើការចម្ងាយពី ៧ ទៅ ១៥ គីឡូ_ម៉ែត្រ។ ម៉ោងធ្វើការគឺចាប់ពីម៉ោង ៨ ព្រឹក ដល់ម៉ោង ៤ ល្ងាច ហើយនៅរដូវប្រមូលផល គឺរហូតដល់យប់_ទៀតផង។ ដំណាំនៅឆ្នាំ ១៩៧៦ គឺល្អ ប៉ុន្តែត្រូវបានគេលើកដាក់លើឡានដឹកទំនិញ និងដឹកចេញទៅឆ្ងាយ។ ជា_លទ្ធផល មានផ្ទុះរមួយដ៏ល្អ គឺការអត់ឃ្លាននៅឆ្នាំ ១៩៧៦-៧៧។

ឆ្នាំ ១៩៧៧ គឺជាឆ្នាំដែលពោរពេញដោយសោកនាដកម្មជាពិសេសសម្រាប់ អ៊ីប្រាហ៊ីម។ ប្រជាជនរស់នៅបានដោយសារចេក និងដំឡូងផ្វា។ កូនពីរនាក់របស់ អ៊ីប្រាហ៊ីម និងកូនពីរនាក់របស់ប្អូនប្រុសរបស់គាត់សុទ្ធតែបានស្លាប់នៅឆ្នាំ ១៩៧៧។ កាន់តែអាក្រក់ថែមទៀត ម្ដាយមីងរបស់គាត់ត្រូវបានចាប់ខ្លួន ហើយកូនប្រុសរបស់នាង ដែលជាបងប្អូនជីដូនមួយរបស់ អ៊ីប្រាហ៊ីម ត្រូវពួកខ្មែរក្រហមប្រាប់ឱ្យទៅសួរសុខទុក្ខម្ដាយរបស់គេនៅឯមន្ទីរពេទ្យ។ នៅទីនោះ ពួកគេបានសម្លាប់គាត់។ "ពួកគេបានអារពោះរបស់គាត់ និងបោះគាត់ចូលទៅក្នុងអណ្ដូង"។ អ៊ីប្រាហ៊ីម និយាយថា គាត់បានឃើញហេតុការណ៍នេះផ្ទាល់នឹងភ្នែក។ ក្រោយមក_កូនៗរបស់បុរសម្នាក់នេះត្រូវបានគេចាប់យកទៅផងដែរ។ ហើយកម្មាភិបាលចាម ៥ ឬ៦ នាក់ក៏ដូចគ្នា ដោយ_រួមទាំងកម្មាភិបាលមួយចំនួនទៀតមកពីភូមិស្ពឺ ក ផងដែរ។

*[រូបភាព]*

*រូបថតដោយ Nguyen Van Ku ដោយមានការផ្ដល់ជូនពី Kathleen Gough*

ស្ត្រីចាមមូស្លីមនៅដើមឆ្នាំ ១៩៨០។ សូមកត់ចំណាំមើលថាតើនាងកំពុងធ្វើអ្វី ចំពោះយើង វាហាក់ដូចជាថា នាងកំពុងត្បាញអំបោះដោយប្រើកង់ដាក់បញ្ច្រាសធ្វើជាកង់រវិល។

នៅដើមឆ្នាំ ១៩៧៧ អ៊ីប្រាហ៊ីម កំពុងតែធ្វើការនៅក្នុងកងនេសាទចល័តក្នុងស្រុកស្ទឹងត្រង់ តាមដងទន្លេមេគង្គទល់មុខនឹងស្រុកក្រូចឆ្មារ។ គាត់និយាយថា មានការឡោមព័ទ្ធចាប់ប្រជាជនចាមលើកទីពីរ ពីផ្នែកទាំងពីរនៃទន្លេ។ "ពួកគេបានផ្សព្វផ្សាយពាក្យចចាមអារាមដែលថា ប្រទេសម៉ាឡេស៊ីកំពុងតែយកប្រេងសាំង_ដើម្បី

Deleted: *Unrevised translation. A revised translation will be provided upon request.*

ប្តូរនឹងប្រជាជនចាម។ ពេលយើងឮដូចនោះ យើងទាំងអស់គ្នាបានមកជួបជុំគ្នា និងចង់ទៅ។ ... ឡាន_ដឹកទំនិញបានចូលមកឈប់នៅក្បែរទឹករៀងរាល់ថ្ងៃ។ ពួកគេបានឱ្យក្រុមរបស់យើងត្រឡប់ទៅផ្ទះវិញ។ ប៉ុន្តែយើងមិនបានឡើងលើឡានទាន់ពេលទេ។ ... ខ្ញុំថែមទាំងព្យាយាមរត់តាមពីក្រោយឡានទៀតផង"។ មានមនុស្សជាច្រើនកំពុងរង់ចាំឡើងលើឡាននោះ ប៉ុន្តែជាសំណាងល្អសម្រាប់ អ៊ីប្រាហ៊ីម ដែលគាត់មិនបានឡើង។ ប្រជាជនចាមបានឡើងត្រូវបានគេនាំឆ្លងទៅចម្ការកៅស៊ូចំការអណ្តូង។ រីឯប្រជាជនចាមនៅស្រុកចំការលើខ្លួនឯងផ្ទាល់ក៏ដូចគ្នាដែរ។

បន្ទាប់ពីត្រូវគេកៀងប្រមូល ពួកគេត្រូវគេប្រាប់ថា ពួកគេអាចទៅខេត្តបាត់ដំបងបាន ជាដើម។ អ្នកខ្លះត្រូវគេប្រាប់ថា ពួកគេកំពុងត្រូវគេយកទៅប្រទេសម៉ាឡេស៊ីជាថ្នូរនឹងប្រេងសាំង។ ពួកគេត្រូវគេនាំយកទៅនៅយប់មួយ។ គ្មាននរណាម្នាក់នៅសល់ឡើយក្នុងចំណោមអ្នកដែលមកពីភូមិស្ពឺ នៅកន្លែងដែលខ្ញុំរស់នៅនោះ។ ពីរថ្ងៃក្រោយពីពួកគេបានចាកចេញ ក្រមា និងអាវរបស់ពួកគេត្រូវគេយកត្រឡប់មកវិញ និងឱ្យទៅកូនៗរបស់ពួកគេ។ នោះឯងជារបៀបដែលពួកគេបានបាត់ខ្លួន។ ... ពួកគេត្រូវគេដឹកយកទៅបោះចូលក្នុងចំការអណ្តូង រួចសម្លាប់ចោលយ៉ាងលឿន។

ខ្ញុំក៏បានរស់នៅក្បែរចំការអណ្តូងដែរ។ ថ្ងៃមួយ ខ្ញុំបានទៅកាប់ចេកនៅទីនោះ។ ស្រុកទាំងមូលធុំក្លិនណាស់។ គ្មាននរណាម្នាក់នៅទីនោះទេ។

ក្នុងចំណោមប្រជាជនចាមថ្មី ១៥០ គ្រួសារដែលបានមកដល់ស្ពឺនៅឆ្នាំ ១៩៧៥ មានតែ ៤៣ គ្រួសារដែលត្រូវគេសម្លាប់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតនៅក្នុងឆ្នាំ ១៩៧៩។

នៅខែ ធ្នូ ឆ្នាំ ១៩៧៨ ការសម្លាប់រង្គាលលើកទីបីបានកើតឡើង។ "ទូកមួយហើយទូកមួយទៀត" បាននាំអ្នកជម្លៀសឆ្លងកាត់ពីភូមិភាគបូព៌ា។ "មនុស្សរាប់ម៉ឺននាក់" ក្នុងចំណោមពួកគេបានចុះចតនៅលើកោះមួយឆ្ងាយពីក្រូចឆ្មារ បន្ទាប់មក ត្រូវគេដឹកតាមទូកទៅស្ទឹងត្រង់ រួចតាមរថយន្តទៅកាន់ចម្ការកៅស៊ូចំការអណ្តូង។ ការសម្លាប់រង្គាលនេះគឺជាផ្នែកមួយនៃយុទ្ធនាការបង្ក្រាបទ្រង់ទ្រាយធំរបស់កម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងភូមិភាគបូព៌ាដែលបានចាប់ផ្តើមនៅខែ ឧសភា ឆ្នាំ ១៩៧៨។ នៅភូមិភាគឧត្តរខ្លួនឯងផ្ទាល់ ការបោសសម្អាតស្រដៀងគ្នានេះដែរបានកើតឡើងនៅចុងឆ្នាំ ១៩៧៦។

មេដឹកនាំនៃការបោសសម្អាតក្នុងតំបន់មុនគេនេះគឺ កែ ពក ជាលេខាភូមិភាគឧត្តរ (ឥឡូវនេះជា ភូមិភាគកណ្តាល) របស់បក្សកុម្មុយនីស្តកម្ពុជា និងប្អូនថ្លៃប្រុសរបស់គាត់ អឿន ជាលេខារបស់បក្សកុម្មុយនីស្តកម្ពុជាប្រចាំតំបន់ ៤២។ អ៊ីប្រាហ៊ីម បានរៀបរាប់ថា ប៉ោក មាន "មាឌធំ ធាត់ និងសម្បុរខ្មៅ" ហើយ អឿន វិញ "ទាប ហើយធាត់"។ គាត់បានឃើញ ប៉ោក តែម្តងគត់ នៅខែ កញ្ញា ឆ្នាំ ១៩៧៦។ "គាត់បាននាំភ្ញៀវជនជាតិ

Original EN: 01199562-01199594



Deleted: Unrevised translation. A revised translation will be provided upon request.

ចិនមកពីប៉េកាំងទៅមើលគេដាំស្រូវ។ ពួកគេមកថតស្រូវ ហើយពួកគេមានកាំភ្លើង។ គ្មានអ្នកណាម្នាក់ត្រូវគេអនុញ្ញាតឱ្យផ្លាស់ទីពីកន្លែងមួយទៅកន្លែងឡើយនៅពេលនោះ។ ... គាត់បានមកមើលដើមស្រូវធំៗដែលដាំដោយក្រុមមកពីភ្នំពេញរបស់យើង។ ស្រូវរបស់យើងគឺជាស្រូវល្អបំផុតហើយគាត់ ចូលមកមើលវា និងដកបទពិសោធពីវា"។ មិនយូរប៉ុន្មានបន្ទាប់ពីនោះ ការបោសសម្អាតបានចាប់ផ្តើមយ៉ាងពិតប្រាកដ ។

ជា ម៉ុច ដែលជាខ្មែរឆ្វេងនិយមមួយពេលម្នាក់ កំពុងធ្វើការជាកម្មករនៅទីរួមខេត្តកំពង់ចាមនៅពេលនោះ និងអាចសង្កេតឃើញការខ្វែងគំនិតគ្នាខាងក្នុងក្នុងចំណោមពួកខ្មែរក្រហម។ គាត់បាននិយាយថា នៅចុងឆ្នាំ ១៩៧៦៖

> ពួកគេបានបំបែកកងទ័ពចាស់ៗចោលទាំងអស់ ហើយបញ្ជូនពួកគេឱ្យត្រឡប់ទៅផ្ទះវិញ។ ... ពួកគេត្រូវបានជំនួសដោយកងទ័ពថ្មីដែលសុទ្ធតែជាក្មេងៗមកពីភូមិភាគនិរតី។ កម្មាភិបាលចាស់ៗ និងពួកមេដឹកនាំយោធាត្រូវគេចោទប្រកាន់ថាជាជនក្បត់ "ក្បាលយួនខ្លួនខ្មែរ"។ ការចោទប្រកាន់ទាំងនេះបានចាប់ផ្តើមនៅដើមឆ្នាំ ១៩៧៧។ ...
>
> មុនពេលឆ្នាំ ១៩៧៧ ពួកខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញតែទាហាន លន់ នល់ មួយចំនួនតូចប៉ុណ្ណោះ អ្នកខ្លះត្រូវគេសម្លាប់ អ្នកខ្លះទៀតត្រូវគេទុកជីវិតឱ្យ។ បន្ទាប់មក មួយរយៈពេលក្រោយមកពួកគេបានចាប់យកទាហានទាំងអស់ទៅ រហូតដល់គ្មានសល់នរណាម្នាក់។ បន្ទាប់មក ពួកកម្មាភិបាលភូមិភាគនិរតីបានចូលមក និងបានធ្វើទុក្ខបុកម្នេញប្រជាជនចាម ដែលដឹងត្រឹមតែថាក្លាយជាប្រជាជនចាមដោយរបៀបណា រួមនឹងប្រជាជនខ្មែរផងដែរ។ ក្រុមទាំងពីរនេះបានចាប់ផ្តើមបាត់ខ្លួន[100]។

ដំណើររឿងនេះបានបង្ហាញពីការផ្សារភ្ជាប់គ្នារវាងការធ្វើទុក្ខបុកម្នេញមកលើប្រជាជនចាម និងការធ្វើទុក្ខបុកម្នេញមកលើប្រជាជនខ្មែរ ដែលត្រូវគេចោទប្រកាន់ថា "ក្បាលយួន"។ ការប្រកាន់ពូជសាសន៍នេះហាក់ដូចជាជាក់លាក់នៅក្នុងករណីប្រជាជនចាម និងហាក់មិនសូវជាក់លាក់ទេនៅក្នុងករណីប្រជាជនខ្មែរ។

**២. ខេត្តកំពង់ធំ**

ឃុំបឹង ក្នុងស្រុកបារាយណ៍ខេត្តកំពង់ធំ រួមមានភូមិចាមចំនួនបី ដែលមានប្រជាជនសរុបប្រហែល ៤៥០ គ្រួសារ នៅឆ្នាំ ១៩៧៥។ ប៉ុន្តែនៅក្នុងតំបន់នេះ ការបែកខ្ញែកប្រជាជនចាមបានចាប់ផ្តើមរួចទៅហើយនៅត្រឹមពេលនោះ (សូមមើលផ្នែកទី II ខាងលើ)។ យោងតាម អូស អ៊ិល ជាកសិករចាមក្នុងតំបន់ម្នាក់ បានឱ្យដឹង

[100] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ជា មុច នៅព្រៃទទឹង ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៨០។

Deleted: Unrevised translation. A revised translation will be provided upon request.

ថា នៅខែ សីហា ឆ្នាំ ១៩៧៣ គ្រួសារចាមចំនួន ១០ គ្រួសារត្រូវគេជ្រើសរើសចេញពីភូមិនីមួយៗក្នុង_ចំណោមភូមិទាំងបី និងបញ្ជូនទៅភាគខាងជើងទៅឃុំក្រវ៉ា។

នៅឆ្នាំ ១៩៧៤ ឬឆ្នាំ ១៩៧៥ កសិករក្នុងតំបន់ម្នាក់ទៀត ឈ្មោះ យ៉ា អែល បានរំលឹកថា កូនស្រីរបស់គាត់ ដែលមានផ្ទៃពោះ បានធ្លាក់ខ្លួនឈឺ ហើយខ្លួនរបស់នាងឡើងហើម។ ដោយត្រូវគេចោទប្រកាន់ពី បទ_ធ្វើពុត នាងត្រូវបានគេសម្លាប់ រួមជាមួយប្តី និងកូនប្អូននាក់ទៀតរបស់នាង។ អែល បានត្អូញត្អែរទាំងក្រៀមក្រំថា "ការធ្វើទុក្ខបុកម្នេញ និងភាពអត់ឃ្លានរបស់ពួកយើងគឺគ្មានន័យអ្វីឡើយចំពោះពួកគេ"។

យ៉ា ម៉ាត់ បានទៅធ្វើការជាសិប្បករឲ្យពួកខ្មែរក្រហមនៅឃុំជើងឌើង។ គាត់បានអះអាងថា៖ "នៅឆ្នាំ ១៩៧៥ មានឃ្លាមួយដែលពួកគេធ្លាប់ណែនាំយើង"។

> គ្មានឯកសារណាមួយសរសេរថា ឥឡូវនេះ បើយើងមិនហូប [សាច់ជ្រូក] ទេ ពួកគេនឹងមិនឲ្យយើង "រស់នៅក្នុងបដិវត្តន៍នេះ" ឡើយ។ ពួកគេនឹងរំលាយពួកយើងចោល។ គ្មានពូជសាសន៍ចាម ឬប្រទេសចាមទេ។ គ្មានជាដាច់ខាត។ នៅប្រទេសវៀតណាម គេបានរំលាយចោលអស់ហើយ។ នៅប្រទេសចម្ប៉ាក៏ត្រូវគេរំលាយចោលដែរ។ យើងបានមករស់នៅក្នុងប្រទេសកម្ពុជា តែ [ត្រូវតែ] គ្មានចាម គ្មានចិន គ្មានអ្វីទាំងអស់។

នៅក្នុងខែ តុលា ឆ្នាំ ១៩៧៦ យោងតាម អូស អ៊ិល ប្រជាជននៅភូមិទាំងបីត្រូវគេជម្លៀសចេញ ៣០ គីឡូម៉ែត្រទៅទិសខាងជើង និងបំបែកគ្នាជា ៤ ឃុំ ១០ ទៅ ១៥ គ្រួសារទៅភូមិនីមួយៗ។ ពួកគេត្រូវគេដាក់នៅលាយជាមួយប្រជាជនមូលដ្ឋានដែលនៅទីនោះ ប៉ុន្តែបើទោះបីជាពួកគេជាប្រជាជនមូលដ្ឋានខ្លួនឯងក៏ដោយ ក៏ពួកគេលែងត្រូវបានគេទទួលស្គាល់ទៀតហើយ។ ឥឡូវនេះពួកគេត្រូវបានដាក់នៅក្នុងក្រុមតែមួយថាជាជនដែលគេជម្លៀសពីទីក្រុង ប្រជាជនថ្មី ឬប្រជាជនបញ្ញើ និងត្រូវបានគេហៅថា "កសិករបញ្ញើ" ឬក្រុមអន្តរការី "កសិករត្រៀម"។ គ្មានប្រជាជនចាមណាម្នាក់ត្រូវគេដាក់នៅក្នុងក្រុមទីបី ដែលជាក្រុម "ពេញសិទ្ធិ" ដែលគេអនុគ្រោះឲ្យច្រើនបំផុតនោះទេ។ ហេតុនេះហើយបានជាប្រជាជនចាម ក៏ដូចជាជនដែលគេជម្លៀសពីទីក្រុងដែរ ត្រូវបានគេច្រានចោលត្រង់ៗមិនឲ្យមានសិទ្ធិ។ ទន្ទឹមនឹងនេះដែរ ខ្មែរដែលមិនមែនជាមូស្លីមត្រូវបានគេនាំទៅរស់នៅក្នុងភូមិចាមដែលត្រូវគេជម្លៀសនៅឃុំបឹង។

យ៉ា ឡោះ ជាជាងម៉ាស៊ីនជនជាតិចាមម្នាក់ គឺជាម្នាក់ក្នុងចំណោមអ្នកដែលត្រូវគេជម្លៀសចេញទៅកាន់ឃុំបាក់ស្នា។ គាត់បាននិយាយថា ចាប់តាំងពីចុងឆ្នាំ ១៩៧៦ ទៅ "មនុស្សជាច្រើនត្រូវគេនាំយកទៅ ច្រើននាក់ទៀតត្រូវបានគេវាយដំ (រហូតដល់ស្លាប់) និងមានអាហារតិចតួច"។ មានគ្រួសារចាមមួយត្រូវបានគេប្រាប់ថា ពួកគេនឹង "រកដីថ្មី" សម្រាប់ដាំកៅស៊ូនៅចំការអណ្តូង ប៉ុន្តែពួកគេត្រូវបានគេដឹកតាមឡានទៅកាន់

Deleted: *Unrevised translation. A revised translation will be provided upon request.*

ការិយាល័យសន្តិសុខនៅកំពង់ថ្ម ដែលពួកគេបានបាត់ខ្លួននៅទីនោះ។ យ៉ា ឡោះ និយាយថា នៅដើមឆ្នាំ ១៩៧៦ ប្រជាជនចាមត្រូវគេបង្ខំឱ្យហូបសាច់ជ្រូកជាចាំបាច់ ក្រោមការគំរាមកំហែងថានឹងត្រូវគេចោទប្រកាន់ពីបទ "មិនធ្វើបដិវត្តន៍"។ "អ្នកភូមិដែលមានឋានៈខ្ពស់ជាងនេះមិនចាំបាច់ត្រូវហូបសាច់ជ្រូក និងសាច់_ក្តាមឡើយ។ ... យើងបានហូបសាច់ជ្រូក ហើយក៏បានក្អួតមកវិញ។ ពួកគេនឹងមិនឱ្យអំបិល ឬអ្វីផ្សេងទៀត_មកយើងទេ សូម្បីតែបបររាវៗក៏ដោយ នៅនឹងកន្លែងរបស់ខ្លួន។ ប៉ុន្តែ ព្រឹកស្អែកឡើងពួកគេ នឹងប្រើយើង_ឱ្យធ្វើការទៀត"។

យ៉ា អែល និយាយថា ពីឆ្នាំ ១៩៧៤ ដល់ឆ្នាំ ១៩៧៩ ឆ្នាំណាក៏មាន "ការលំបាកស្មើៗគ្នា" ដែរ។ ទោះជាយ៉ាងណា នៅពេលអ្នកស្តាប់បញ្ចេញយោបល់ថា ឆ្នាំ ១៩៧៧ គឺជាឆ្នាំដែលអាក្រក់ជាងគេបំផុតនោះ អែល បាននិយាយថា៖

> "នៅឆ្នាំ ១៩៧៧ ពួកគេបានជីកប្រឡាយមួយចំនួន។ ខ្ញុំបានសួរពួកគេថា ជីកធ្វើអ្វី។ ពួកគេបាននិយាយថា ដើម្បីយកដីទៅធ្វើភ្លឿងប្រក់ដំបូល។ ប៉ុន្តែ គេជីកដើម្បីកប់ពួកយើង បន្ទាប់ពីគេសម្លាប់ពួកយើងហើយ"។ យ៉ា ឡោះ រំលឹកអំពីរបៀបដែលរឿងរ៉ាវដែលបានកើតឡើងនៅឆ្នាំ ១៩៧៧។ "ប្រធានសន្តិសុខស្រុកឈ្មោះ វ៉ុន បានរៀបចំការប្រជុំមួយនៅឆ្នាំ ១៩៧៧។ ... គាត់បាននិយាយថា ប្រជាជនចាមមិនត្រូវគេទុកជីវិតឱ្យទេ។ ... គាត់បាននិយាយថា ក្នុងរយៈពេលបីថ្ងៃ ពួកយើងត្រូវបានគេកៀងប្រមូល និងសម្លាប់ចោល។ ខ្ញុំមិនបាននៅទីនោះទេ ប៉ុន្តែប្រធានកងយើង បានប្រាប់ខ្ញុំពីរឿងនោះ"។

ប្រជាជនចាមក្នុងតំបន់ម្នាក់ទៀតបានអះអាងថា ប្រធានកងម្នាក់នេះថែមទាំងបានប្រាប់គាត់ពីមូលហេតុដែលប្រជាជនចាម "មិនត្រូវគេទុកជីវិតឱ្យ" ដែលត្រូវគេរកឃើញ "នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសវៀតណាម"។ ឡោះ ជឿថា ប្រជាជនចាមក្នុងតំបន់ត្រូវបានជួយសង្គ្រោះជីវិតនៅពេលដែល នៅព្រឹកបន្ទាប់នោះ អ្នកនាំសារម្នាក់បានមកយក វ៉ុន ទៅ ហើយ វ៉ុន ក៏ត្រូវបានសម្លាប់ដោយថ្នាក់លើរបស់គាត់។ ដូចគ្នានឹងការសម្លាប់ សៅ នៅស្រុកជើងព្រៃនៅក្បែរនោះដែរ ព្រឹត្តិការណ៍នេះហាក់ដូចជាសញ្ញាសម្គាល់ប្រាប់ពីការមកដល់របស់ពួកខ្មែរក្រហមមកពីភូមិភាគនិរតីអញ្ចឹង។ ប៉ុន្តែ គោលនយោបាយរបស់ពួកគេគឺមិនអត់ឱនឱ្យចាមនោះទេ។

នៅខែ កក្កដា ឆ្នាំ ១៩៧៧ ក្នុងឃុំក្រវ៉ា ប្រជាជនចាម ២០ គ្រួសារត្រូវបានដឹកតាមឡានសន្តិសុខ ពីកំពង់ថ្ម និងស្វាយទង ចេញទៅបាត់ មិនដែលត្រឡប់មកវិញឡើយ។ យ៉ា ម៉ាត់ ដែលមានសាច់ញាតិនៅក្នុងចំណោមនោះដែរ បានចង្អុលបង្ហាញថា ពួកគេបាន "ហូបសាច់ជ្រូកហើយៗ និងធ្វើអ្វីៗផ្សេងទៀត ហើយ_ពួកគេនៅតែត្រូវគេសម្លាប់ទៀត"។ ម៉ាត់ ពន្យល់រឿងនេះដោយយោងទៅតាម "ឯកសារឆ្នាំ ១៩៧៨" មួយ ដែល

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ចេញពីថ្នាក់ដឹកនាំខ្មែរក្រហម “អំពីរដ្ឋធម្មនុញ្ញឆ្នាំ ១៩៧៥-៧៦ នៅទីក្រុងភ្នំពេញ” ដូចដែល ម៉ាត់ បានរៀបរាប់រួចហើយ។ គាត់បានរំលឹកថា ឯកសារនេះបានពិភាក្សាអំពី “វិទ្ធង្សនា” និងបន្តថា៖

> វាជាឯកសារលេខ ១៦៣ ទំព័រ ១៦៣ [?]។ ... វានិយាយថា យើងនឹងមិនទុកជីវិតឲ្យពួកចាមទេ ព្រោះបើទុកជីវិតឲ្យ ពួកគេនឹងប្រឆាំង (និងបង្កើត) បុនរាព្រឹត្តិនិយម។ ... វានិយាយថា ពូជសាសន៍ចាមគឺមិនត្រូវទុកទៀតឡើយ ព្រោះវាធ្លាប់មានប្រវត្តិប្រឆាំងនឹងបដិវត្តន៍សង្គមនិយម និងនៅក្នុងសម័យកាលចម្ប៉ាផងដែរ។ ... “ដូច្នេះ យើងអនុវត្តគោលនយោបាយលះបង់ពួកគេចោល ឥឡូវនេះ”។ ... “ពួកគេចាប់ដៃជាមួយនឹងវៀតណាម ដូច្នេះពួកគេទាំងអស់ត្រូវតែសម្លាប់ចោល។ វានិយាយថា ពួកចាមធ្លាប់បានបះបោរម្តងរួចមកហើយ គឺនៅភូមិភាគបូព៌ា។ មានការប្រឆាំងរបស់ពួកសេអ៊ីអា-កាហ្សេបេនៅក្នុងព្រៃ។ ... វានិយាយថា យើងបានរត់គេចខ្លួនពីការធ្វើទុក្ខបុកម្នេញនៅក្នុងប្រទេសវៀតណាម និងមិនអាចត្រូវបានគេជឿទុកចិត្តទៀតនោះទេ។ ... ឯកសារនេះនិយាយថា៖ “ឥឡូវនេះ ពួកគេត្រូវតែកម្ទេចចោល។ មិនថាពួកគេនៅផ្នែកមួយណាក៏ដោយ ពួកគេត្រូវតែកម្ទេចចោល”។

ដំណើររឿងរបស់ ម៉ាត់ គឺត្រូវគ្នានឹងដំណើររឿងដែលប្រាប់ដោយ អូស អ៊ិល ដែលបានអះអាងថាបានឃើញ “ឯកសារលេខ ១៦៣” ដ៏អាថ៌កំបាំងនោះ នៅខែ មិថុនា ឆ្នាំ ១៩៧៨។ ឯកសារនោះជាកម្មសិទ្ធិរបស់ យ៉ុង ដែលជាមន្ត្រីអធិការកិច្ចការងារសាធារណៈរបស់ អ៊ិល ដែលរស់នៅក្នុងភូមិចាន់ល្អុងដែលនៅក្បែរនោះ ក្នុងឃុំឈូកខ្សាច់ ស្រុកបារាយណ៍។ អ៊ិល បាននិយាយថា គាត់បានអានឯកសារនោះដោយសម្ងាត់នៅភូមិចាន់ល្អុង ដែលជាសំខាន់គឺជាភូមិកំណើតរបស់ កែ ពក ដែលជាលេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគកណ្តាលនៅពេលនោះ។ (អ៊ិល ក៏បាននិយាយដែរថា ថ្នាក់លើផ្ទាល់របស់ យ៉ុង រួមមាន កម្មាភិបាល អឿន និង ប៊ិន ដែលជាប្អូនថ្លៃប្រុស និងក្មួយប្រុសរបស់ ប៉ោក និង ប៉ុច កម្មាភិបាលភូមិភាគនិរតីដែលបានមកដល់នៅដើមឆ្នាំ ១៩៧៧។) គេមិនអាចទទួលបានច្បាប់ចម្លងពីឯកសារនេះបានទេ ឬស្ទូម្បីតែបញ្ជាក់ពីយថាភាពរបស់វាក៏ដោយ។

នៅឆ្នាំ ១៩៧៩ គ្រួសារចាម ៣៦៤ គ្រួសារមកពីភូមិចំនួនបីក្នុងឃុំបឹងបាននៅរស់រានមានជីវិតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកភូមិបានប្រាប់ខ្ញុំនៅឆ្នាំ ១៩៨០ ថា គ្រួសារចាមចំនួន ១២០ គ្រួសារបានបាត់បង់ជីវិត។ យ៉ាសយ៉ា អាស្នាត់ អាយុ ៣២ ឆ្នាំ បានកើតនៅក្នុងភូមិមួយក្នុងចំណោមភូមិទាំងបី គឺភូមិត្រពាំងឈូក។ ឪពុករបស់គាត់ អ៊ីម៉ា យ៉ាសយ៉ា គឺជាមេដឹកនាំសាសនានៅទីនោះក្នុងទសវត្សរ៍ឆ្នាំ ១៩៦០។ ដូចដែលបានរៀបរាប់ខាងលើ អាស្នាត់ បានរស់នៅក្រោមរបបខ្មែរក្រហមពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៣ បន្ទាប់មកបានទៅប្រទេសវៀតណាម។ ឥឡូវនេះ គាត់រស់នៅទីក្រុងញូយ៉ក ប៉ុន្តែមុនពេលរត់ភៀសខ្លួនទៅលោកខាង

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

លិច ដែលគាត់ផ្លៀតទៅលេងនៅភូមិកំណើតរបស់គាត់នៅខែ មីនា ឆ្នាំ ១៩៧៩ មិនយូរប៉ុន្មានក្រោយការផ្តួលរលំរបបកម្ពុជាប្រជាធិបតេយ្យដោយពួកវៀតណាម។ គាត់បានដឹងថា ឪពុកម្តាយ និងបងប្អូនប្រុសពីរនាក់របស់គាត់បានរួចជីវិតពីសម័យ ប៉ុល ពត ប៉ុន្តែបងប្អូនរបស់គាត់ពីរនាក់ទៀតត្រូវបានសម្លាប់ (ម្នាក់ត្រូវគេកាត់ក្បាល ម្នាក់ទៀតត្រូវគេវះយកពោះវៀន) ដោយពួកខ្មែរក្រហម។ អាស្នាត់ បានបាត់បង់សាច់ញាតិ និងមិត្តភក្តិជាច្រើន។ វិហារឥស្លាមក្នុងភូមិចំនួនពីរក្នុងចំណោមបីត្រូវបានបំផ្លាញ ហើយវិហារទីបីដំបូងត្រូវបានប្រើធ្វើជាកន្លែងចិញ្ចឹមជ្រូក បន្ទាប់មកធ្វើជាឃ្លាំងដោយពួកខ្មែរក្រហម។ យោងតាមរបាយការណ៍មួយរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាបានឲ្យដឹងថា វរជនប្រចាំភូមិម្នាក់ ឈ្មោះ ហ័តជី យុសូហ្វ អាអ្វូនី "ត្រូវបានគេបង្ខំឲ្យរស់នៅ និងហូបសាច់ជ្រូកនៅកន្លែងចិញ្ចឹមជ្រូកមួយរហូតដល់ស្លាប់នៅខែ កក្កដា ឆ្នាំ ១៩៧៥"[101]។

### ៣. ខេត្តព្រះវិហារ

ផ្នែកដែលនៅដាច់ស្រយាលជាងគេបំផុតនៃភូមិភាគឧត្តរ/កណ្តាលគឺខេត្តព្រះវិហារ ដែលជាតំបន់ព្រៃមួយយ៉ាងធំនៅភាគខាងជើងខេត្តកំពង់ធំ នៅតាមព្រំដែនថៃ។ នៅទីនោះ គ្មានប្រជាជនមូលដ្ឋានជាជនជាតិចាមនោះទេ ប៉ុន្តែប្រជាជនថ្មីបានចូលមកយ៉ាងច្រើននៅឆ្នាំ ១៩៧៥។

*[រូបភាព]*

*រូបថតដោយ Nguyen Van Ku ដោយមានការផ្តល់ជូនពី Kathleen Gough*

*ស្ត្រីចាមមូស្លីមនៅដើមឆ្នាំ ១៩៨០។ នៅពេលដែលពួកខ្មែរក្រហមបានផ្តើមឲ្យមានការហូបអាហាររួមគ្នា ប្រដាប់ប្រដាចម្អិនអាហារប្រចាំថ្ងៃដូចនៅខាងចុងបញ្ចប់នៃបន្ទប់នេះត្រូវគេរឹបអូស ហើយប្រជាជនត្រូវបានអនុញ្ញាតឲ្យមានតែស្លាបព្រាមួយគត់សម្រាប់ម្នាក់ៗ។*

ស៊ីម សាគ្រីយ៉ា អាយុ ៤៣ ឆ្នាំ បានចាកចេញពីទីក្រុងភ្នំពេញនៅខែ មេសា ឆ្នាំ ១៩៧៥ ទៅកាន់ភូមិចាមលើក្នុងស្រុកកោះធំ ខេត្តកណ្តាល ស្ថិតនៅភាគខាងត្បូងទីក្រុងភ្នំពេញ តាមបណ្តោយទន្លេបាសាក់ក្បែរព្រំដែនវៀតណាម។ ទោះជាយ៉ាងណា នៅខែ កក្កដា ឆ្នាំ ១៩៧៥ គាត់ និងប្រជាជនចំនួន ៧១០ គ្រួសារមកពីស្រុកនោះត្រូវបានគេជម្លៀសចេញម្តងទៀត។ ពួកគេត្រូវបានបញ្ជូនតាមទូកពីភាគខាងត្បូងទៅភាគខាងជើងប្រទេស ទៅខេត្តកំពង់ធំ និងបន្ទាប់មកតាមផ្លូវគោកទៅភូមិសំរោង ខេត្តព្រះវិហារ (តំបន់ ១០៣)។ ប្រជាជនថ្មី

[101] *ការបំផ្លាញសាសនាអ៊ីស្លាម* ទំព័រ ១០។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ទាំងអស់ចំនួន ៧១០ គ្រួសារ រួមមានប្រជាជនចាម ១០០ គ្រួសារចាម និងប្រជាជនចិនជាង ៦០ គ្រួសារ។ នៅសល់ប៉ុន្មានទៀតគឺប្រជាជនខ្មែរ។

មកទល់ឆ្នាំ ១៩៧៨ សាគ្រីយ៉ា អះអាងថា មានប្រជាជននៅរស់តែ ៧១ នាក់ប៉ុណ្ណោះ។ មានប្រជាជនចាមតែ ៤៥ នាក់ប៉ុណ្ណោះ រួមទាំងខ្លួនគាត់ផង គឺជាអ្នកដែលនៅរស់រានមានជីវិតក្នុងចំណោម ១០០ គ្រួសារ។ ប្រជាជនចិនតែ ៣ គ្រួសារប៉ុណ្ណោះដែលនៅរស់រានមានជីវិត។ គាត់និយាយថា "ប្រជាជនចិនបានស្លាប់ច្រើនបំផុតក្នុងចំណោមប្រជាជនទាំងអស់" ប៉ុន្តែតួលេខទាំងនេះបង្ហាញថា បើគិតតាមសមាមាត្រចំនួនដែលច្រើនជាងគេគឺស្ថិតក្នុងចំណោមប្រជាជនខ្មែរ។ ប្រជាជនចាមហាក់ដូចជាមិនមែនជាក្រុមដែលត្រូវបានគេជ្រើសរើសយកតែឯងនោះទេ បើទោះបីជាយ៉ាងហោចណាស់ពីរភាគបីនៃពួកគេបានស្លាប់ដោយសារ ការជម្លៀសប្រជាជនចេញទាំងបង្ខំទៅកាន់តំបន់ដែលគេមិនរាក់ទាក់ជាមួយក៏ដោយ[102]។

នៅទីនេះ គឺប្រជាជនបញ្ញើ ឬប្រជាជនថ្មីនេះហើយដែលត្រូវបានគេជ្រើសរើសយកមកគាបសង្កត់ច្រើនបំផុតដោយមិនគិតពីពូជសាសន៍របស់ពួកគេ។ ទោះជាយ៉ាងណា ប្រជាជនចាមដែលនៅតំបន់មូលដ្ឋានភាគច្រើន ដូចដែលយើងបានឃើញ ត្រូវបានជ្រើសរើសចេញសម្រាប់ការចាត់ថ្នាក់ថាជាប្រជាជនបញ្ញើ តាមការបង្គាប់ ដោយសារហេតុផលពូជសាសន៍ជាជាងដោយសារកន្លែងដើមរបស់ពួកគេ ដូចនៅក្នុងករណីសម្រាប់ពូជសាសន៍ផ្សេងទៀត។

នៅឆ្នាំ ១៩៧៥ យុស្វហ្វ ដែលនៅពេលនោះមានអាយុ ៦៧ ឆ្នាំ គឺជាពាណិជ្ជករដែលរស់នៅជិតផ្សារតាកែវក្នុងភូមិភាគនិរតី។ ក្នុងរយៈពេលមួយខែបន្ទាប់ពីខ្មែរក្រហមបានចូលកាន់កាប់ទីរួមខេត្តនៅខែ មេសា យុស្វហ្វ បានរស់នៅក្នុងវត្តមួយ។ (អ្វីដែលគួរឱ្យចាប់អារម្មណ៍ គេហៅវត្តនោះថាវត្តចម្ប៉ា។) ប៉ុន្តែ ម្ហូបអាហារបានអស់ ហើយ "យើងត្រូវគេបញ្ជូនទាំងដែទទេ" ទៅកោះធំក្នុងខេត្តកណ្តាល។ គាត់បានស្នាក់នៅទីនោះរយៈពេលបួនខែ។ បន្ទាប់មកត្រូវបានគេជម្លៀសចេញដោយដៃទទេម្តងទៀត តាមទូកទៅកាន់ខេត្តព្រះវិហារ។ យុស្វហ្វ បានទៅដល់ទីនោះជាមួយនឹងប្រជាជនថ្មីចាម និងខ្មែរចំនួន ១.៥០០ នាក់ទៀតនៅចុងឆ្នាំ ១៩៧៥ នៅ ប៉ុន្មានខែក្រោយក្រុមរបស់ ស៊ីម សាគ្រីយ៉ា ហើយត្រូវបានគេបញ្ជូនទៅស្រុកផ្សេងមួយទៀត។ នៅទីនោះ ពួក គេត្រូវបានគេបំបែកទៀត។ គ្រួសារចាមតែបួនប៉ុណ្ណោះត្រូវបានបញ្ជូនទៅភូមិប៉ាល់ហាល់ ជាមួយនឹង យុស្វហ្វ ព្រមទាំងប្រជាជនថ្មីខ្មែរ និងចិនចំនួន ៣០០ នាក់ទៀតផងដែរ។ ពួកគេបានចូលរួមជាមួយប្រជាជនមូលដ្ឋាន ជាកសិករប្រមាណ ១០០ នាក់ដែលជាអ្នកគាំទ្របដិវត្តន៍ រួមបញ្ចូលទាំងគ្រួសារនៃក្រុមជនជាតិភាគតិចកួយ

[102] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ស៊ីម សាគ្រីយ៉ា នៅច្រាំងចំរេះ ថ្ងៃទី ២ ខែ មករា ឆ្នាំ ១៩៨៧។

Deleted: Unrevised translation. A revised translation will be provided upon request.

៤ ឬ៥ គ្រួសារផងដែរ។ (យុស្ហូ បាននិយាយថា ក៏មានកម្មាភិបាលកួយថ្នាក់កណ្ដាលជាច្រើនផងដែរ នៅក្នុងខេត្តនេះ។) ប្រជាជនកួយ "រស់នៅដូចប្រជាជនខ្មែរដែរ ដោយគ្មានវប្បធម៌ដាច់ដោយឡែកនោះទេ"។ "ពួកគេនិយាយភាសាខ្មែរជាមួយពួកយើង ប៉ុន្តែនិយាយតែភាសាកួយប៉ុណ្ណោះនៅពេលនៅជាមួយប្រជាជនកួយគ្នា គេ" ។ វាហាក់ដូចជាមិនមានការហាមឃាត់ណាមួយលើភាសារបស់ពួកគេ ឬភាសាចាមឡើយ។

តាមពិត យុស្ហូ លើកឡើងថា កម្មាភិបាលខ្មែរក្រហមនៅទីនោះគឺ "ចិត្តល្អដាក់ពួកយើងខ្លះដែរ"។ "ពួកគេមិនតឹងតែងខ្លាំងនោះទេ។ ពួកគេមិនបានជេរប្រមាថពួកយើងឡើយ"។ ឆ្នាំដំបូង ឆ្នាំ ១៩៧៦ គឺ "នៅទន់ល្មម គ្រប់យ៉ាងមិនអីទេ"។ របបអាហារគ្រប់គ្រាន់ត្រូវបានចែកស្មើៗគ្នា ហើយម្ហូបអាហារត្រូវបានគេហូបដោយសេរីនៅផ្ទះខ្លួនឯង។ មានការសម្លាប់ដែល យុស្ហូ បានហៅថា "ការសម្លាប់ធម្មតា"៖ "ប្រជាជនមួយចំនួនតូចត្រូវបាននាំយកទៅ" ដោយពួកខ្មែរក្រហម។

នៅឆ្នាំ ១៩៧៧ ស្ថានភាពកាន់តែអាក្រក់ឡើងៗ។ មានការសម្លាប់បន្ថែមទៀត។ ក្មេងៗត្រូវបានគេនាំយកទៅរស់នៅដាច់ដោយឡែកពីឪពុកម្ដាយរបស់ពួកគេ។ ស្រូវអង្ករត្រូវគេ "បញ្ជូនចេញទាំងអស់"។ ការហូបអាហាររួមគ្នាត្រូវបានគេដាក់ចេញ។ ឆ្នាំង ខ្ទះ ស្លាបព្រា និងចានត្រូវបានគេរឹបអូសយកទាំងអស់ ហើយប្រជាជនត្រូវតែហូបរបបអាហារដែលមាន "ទំពាំងក្នុងសម្ល ដែលស្ងោរជាមួយនឹងអង្ករ និងចេកបន្តិចបន្តួច" ឬសម្លដែលដាក់អំបិល ដើមចេក និងកូនត្រីតូចៗ។ ពួកគេហូបរបបអាហាររបស់ខ្លួនដោយប្រើស្លាបព្រាមួយ ម្នាក់ដែលគេអនុញ្ញាតឲ្យទុក។ "ហេតុនេះហើយបានជាមានប្រជាជនឈឺ និងស្លាប់។ នៅពេលដែលប្រជាជនធ្លាក់ខ្លួនឈឺ ពួកគេបានបេះផ្លែដូង និងចាក់បញ្ចូលទឹកដូងចូលទៅក្នុងខ្លួនរបស់ពួកគេ។ វាមានតែធ្វើឲ្យ ខ្ញុំកាន់តែឈឺថែមប៉ុណ្ណោះ"។

យុស្ហូ អះអាងថា ពីចុងឆ្នាំ ១៩៧៧ ទៅ ប្រជាជនមូលដ្ឋានលែងពេញចិត្តនឹងបដិវត្តន៍នេះទៀតហើយ ព្រោះគ្រប់គ្នាខ្វះអាហារហូបចុកគ្រប់គ្រាន់ ហើយទាំងប្រជាជនចាស់ និងប្រជាជនថ្មីកំពុងតែត្រូវបានគេចាប់ ខ្លួន។ ឆ្នាំ ១៩៧៨ គឺជាឆ្នាំដែលកាន់តែអាក្រក់។ តំបន់ធំៗត្រូវបានជន់លិច ហើយការអត់ឃ្លានបានកើនឡើង ដល់កម្រិតខ្ពស់បំផុត។ "ប្រជាជនបានដាំដំឡូង និងពោតទុកហូបជំនួសបាយ"។

ប្រមាណជាពាក់កណ្ដាលឆ្នាំ ១៩៧៨ កម្មាភិបាលតាមមូលដ្ឋានត្រូវបានចាប់ខ្លួន និងសម្លាប់ចោល។ ក្រោយមកនៅឆ្នាំដដែលនេះ លេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគនិរតីគឺ ម៉ុក បានមកដល់តំបន់នេះ និងបានធ្វើការឃោសនាប្រឆាំងនឹងវៀតណាម។ "យើងមិនដែលបានជួបគាត់ទេ តែយើងភ័យខ្លាចទៅហើយគ្រាន់តែឮឈ្មោះគាត់។ ... គាត់បានបញ្ជាឲ្យមានការសម្លាប់ជាច្រើន សម្លាប់ប្រជាជនទាំងឡានៗ។ ប្រជាជនភ័យខ្លាចណាស់គ្រាន់តែឮសំឡេងឡាន"។ យុស្ហូ មិនបានផ្ដល់តួលេខនៃចំនួនអ្នកស្លាប់នៅភូមិប៉ាល់ហាល់ទេ។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ទោះជាយ៉ាងណា គាត់ និងក្រុមគ្រួសាររបស់គាត់បានរួចរស់ជីវិត ហើយវាហាក់ដូចជាច្បាស់ណាស់ដែលថា ប្រជាជនចាមមិនត្រូវបានគេជ្រើសរើសតែឯងសម្រាប់ការធ្វើទុក្ខបុកម្នេញនៅទីនោះទេ។ ដូចគ្នានឹងនៅភូមិសំរោង ស្ថានភាពរស់នៅអាក្រក់ៗបានកើតឡើងលើប្រជាជនគ្រប់ពូជសាសន៍ទាំងអស់។

## គ. ភូមិភាគនិរតី

ខ្ញុំបានសម្ភាសសមាជិកក្នុងសហគមន៍ចាមធំៗមួយចំនួន នៅក្នុងតំបន់រឹងមាំរបស់របបកម្ពុជាប្រជាធិបតេយ្យ គឺភូមិភាគនិរតី។ សហគមន៍ទាំងនេះស្ថិតនៅក្នុងខេត្តកណ្តាលតាមបណ្តោយដងទន្លេបាសាក់ក្រោមក្នុងស្រុកកោះធំ; នៅក្នុងខេត្តតាកែវ ក្នុងស្រុកទ្រាំងដែលសម្បូរដំណាំស្រូវ; និងនៅតំបន់ក្នុងទីក្រុងភ្នំពេញ។ ចំណុចសំខាន់ដែលគួរកត់សម្គាល់នៅទីនេះគឺថា ខេត្តតាកែវ ដែលជាតំបន់មូលដ្ឋានដើមរបស់មេបញ្ជាការយោធាដ៏ស្មោះត្រង់របស់ ប៉ុល ពត គឺ ម៉ុក បានជួបនឹងការប្រើប្រាស់ពាក្យដែលគេស្គាល់ថា “ប្រជាជនបញ្ញើ” ជាលើកដំបូង ហើយពាក្យនេះត្រូវបានប្រើមុនគេនៅទីនោះដើម្បីកំណត់អត្តសញ្ញាណប្រជាជនមូលដ្ឋានចាមដាច់ដោយឡែកពីគ្នាពីអ្នកភូមិខ្មែរ។

### ១. ស្រុកកោះធំ

ទីលំនៅតាមមាត់ច្រាំងទន្លេពីរ ដែលគេស្គាល់ថាជាភូមិចាម និងភូមិចាមលើ គឺជាផ្ទះរបស់គ្រួសារចាមប្រហែលជា ៥០០ គ្រួសារនៅដើមទសវត្សរ៍ឆ្នាំ ១៩៧០។ កងទ័ពខ្មែរក្រហមបានចូលមកដល់ភូមិចាមដំបូងនៅឆ្នាំ ១៩៧២។ យោងតាមប្រជាជនចាមក្នុងតំបន់ម្នាក់បានឲ្យដឹងថា៖ “គេមិនបានធ្វើទុក្ខបុកម្នេញយើង_ច្រើនទេ។ ពួកគេបានឲ្យយើងហូបអាហារមួយឆ្អែតនៅពេលនោះ។ ការសម្លាប់មនុស្សក៏ពុំមានច្រើនដែរ។ យើងបានធ្វើការរួមគ្នា”។ ទោះជាយ៉ាងណា នៅក្រោយជ័យជម្នះឆ្នាំ ១៩៧៥ “ពួកគេពិតជាបានធ្វើរឿងទាំងអស់នេះមែន” ។ ទ្រព្យសម្បត្តិឯកជនត្រូវបានគេរឹបអូស ហើយលុយត្រូវបានគេបំបាត់ចោល។ ប្រជាជនធ្វើការ “ទាំងយប់ទាំងថ្ងៃ” ជាមួយនឹងរបបអាហារដែលមិនគ្រប់គ្រាន់។

គ្រោះមហន្តរាយបានធ្លាក់មកដល់នៅជុំវិញខែ មេសា ឆ្នាំ ១៩៧៦។ ពួកខ្មែរក្រហមបានបិទទ្វារវិហារមូស្លីម ហាមឃាត់មិនឲ្យមានសាសនាឥស្លាម និងហាមឃាត់មិនឲ្យមានភាសាចាមជា “ភាសាបរទេស” ឡើយ។ អាក្រក់ជាងនេះទៀត សហគមន៍ចាមចំនួនពីរត្រូវបានគេបំបែក។ អ្នកខ្លះត្រូវគេបញ្ជូនទៅកាន់ភូមិជិតខាងក្នុងស្រុកកោះធំ ខ្លះទៀតទៅទិសពាយ័ព្យនៃប្រទេស ឆ្ងាយៗ ដូចជាខេត្តពោធិ៍សាត់ និងបាត់ដំបងជាដើម។ នៅក្នុងរោងបាយរួមក្នុងតំបន់ ប្រជាជនចាមត្រូវគេបង្ខំឲ្យហូបអាហារដែលមានដាក់សាច់ជ្រូក។ ការសម្លាប់ដោយសារការល្មើសនឹងបទប្បញ្ញត្តិបានចាប់ផ្តើមឡើងនៅឆ្នាំ ១៩៧៦ និងបានឈានដល់កំពូលនៅឆ្នាំ ១៩៧៧ នៅពេលដែលពួកខ្មែរក្រហមបានឆែកឆេរផ្ទះដើម្បីរកមាស។ គ្រួសារចាម ៥ ឬ៦ គ្រួសារបានរត់គេចខ្លួនទៅ

Deleted: *Unrevised translation. A revised translation will be provided upon request.*

ប្រទេសវៀតណាម។ សាច់ញាតិរបស់ពួកគេត្រូវបានធ្វើទុក្ខបុកម្នេញដោយពួកខ្មែរក្រហម។ “នៅឆ្នាំ ១៩៧៨ គ្មាននរណាម្នាក់អាចរត់គេចខ្លួនបានឡើយ ដោយសារតឹងតែងពេក”។

ប្រជាជនចាម ១០០ នាក់បានស្លាប់នៅក្នុងស្រុកនោះនៅចន្លោះឆ្នាំ ១៩៧៦ និងឆ្នាំ ១៩៧៩។ ប្រជាជនជាង ១០០ នាក់ទៀតបានស្លាប់បន្ទាប់ពីត្រូវបានគេបញ្ជូនទៅតាមបណ្តាខេត្តនានានៅភាគពាយ័ព្យ។ យោងតាមការសិក្សាមួយអំពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលចេញផ្សាយនៅឆ្នាំ ១៩៨២ គ្រួសារមូស្លីមនៅស្រុកកោះធំចំនួន ៨៣ គ្រួសារបានស្លាប់នៅខេត្តពោធិ៍សាត់តែឯង។ អ្នកដែលនៅរស់រានមានជីវិតតែម្នាក់គត់គឺ ហ័តជី អាម៉េដ។ ឪពុក ម្តាយ និងបងប្អូនបីនាក់របស់ ម៉ាត់ តុលឡោះ សុទ្ធតែបានស្លាប់នៅក្នុងខេត្តបាត់_ដំបងទាំងអស់។ តុលឡោះ ដែលឥឡូវនេះជាអនុប្រធានភូមិ អះអាងថា ភូមិពោធិ៍ទន្លេដែលនៅក្បែរនោះត្រូវ_បានប្រែក្លាយទៅជាមជ្ឈមណ្ឌលធ្វើទារុណកម្ម និងសម្លាប់មួយដ៏ធំ ដែលមានមនុស្សចំនួន ៣៥.០០០ នាក់ត្រូវបានសម្លាប់នៅទីនោះ ដែលរួមមានប្រជាជនចាមប្រមាណ ២០.០០០ នាក់ផងដែរ[103]។ តួលេខទាំងនេះប្រហែលជាត្រូវបានគេបំផ្លើស ប៉ុន្តែពាក្យបណ្តឹងនៃការសម្លាប់រង្គាលនៅភូមិពោធិ៍ទន្លេត្រូវបានគាំទ្រដោយជនភៀសខ្លួនមកពីកោះធំ ដែលគេសម្ភាសនៅក្នុងប្រទេសថៃ[104]។ ប្រជាជនចាមក្នុងតំបន់ក៏បានអះអាងដែរថា៖ “យើងត្រូវបានគេធ្វើទុកបុកម្នេញច្រើនជាងប្រជាជនខ្មែរ” នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ ១៩៨០ ភូមិចាមទាំងពីរត្រូវបានប្រមូលជាក្រុមឡើងវិញជាភូមិតែមួយ ហើយគ្រួសារចំនួន ២២២ គ្រួសារបាននៅរស់រានមានជីវិតដែលធ្លាប់តែមានចំនួន ៥០០ គ្រួសារនៅពេលមួយនោះ។ មកទល់ចុងឆ្នាំ ១៩៨២ ចំនួនប្រជាជនបានកើនពី ១.០៦០ ទៅ ១.១៣១ នាក់ត្រូវជា ២៣៤ គ្រួសារ[105]។

**២. ខេត្តតាកែវ**

ភូមិចាមប្រហែលជា ១០ ភូមិ នៅស្រុកទ្រាំង ខេត្តតាកែវត្រូវបានកាន់កាប់ដោយកងទ័ពខ្មែរក្រហមនៅឆ្នាំ ១៩៧២-៧៣។ នៅឆ្នាំ ១៩៧៣ ពួកមេដឹកនាំថ្មីបានដឹកនាំប្រជាជនទាំងអស់ទៅលើភ្នំ ក្នុងស្រុកអង្គរជ័យ ខេត្តកំពត ហើយពួកគេបានរស់នៅរយៈពេលមួយឆ្នាំនៅទីនោះ។

---

103 *សហគមន៍អ៊ីស្លាមនៅកម្ពុជា* (ភ្នំពេញ ឆ្នាំ ១៩៨៣) ទំព័រ ២៩-៣១។ នៅក្នុងសៀវភៅនេះ ភូមិចាមទាំងពីរមានឈ្មោះថា អន្លង់សលើ និងអន្លង់សក្រោម។

104 បទសម្ភាសន៍របស់ Nate Thayer ជាមួយ ម៉ាត់ ស្មាន អាយុ ២០ ឆ្នាំ និងសាឡេហ៍ អាយុ ២១ ឆ្នាំ នៅនងសាម៉េត ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៨៤។

105 *សហគមន៍អ៊ីស្លាមនៅកម្ពុជា* ទំព័រ ២៩។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ណោ ហ្កា ដែលជាស្ត្រីកសិករចាមមកពីភូមិស្នង់ មានអាយុ ៣៨ ឆ្នាំនៅពេលនោះ។ នាងត្រូវបានបញ្ជូនទៅកាន់ខេត្តកំពតរួមជាមួយនឹងគ្រួសារអ្នកភូមិ ១០០ គ្រួសារទៀត។ “ពួកគេមិនបានធ្វើទុក្ខបុកម្នេញយើងទេនៅទីនោះ។ ... មេដឹកនាំរបស់យើងក៏ចេញមកពីប្រជាជនចាមយើងដែរ។ ... ពួកគេនៅតែធ្វើល្អដាក់យើង ឲ្យយើងធ្វើការ និងមើលការខុសត្រូវដោយខ្លួនយើង។ ពួកគេបាននិយាយពាក្យល្អៗ។ ... នៅឆ្នាំ ១៩៧៤ ពួកគេបានបញ្ជូនយើងឲ្យត្រឡប់មកផ្ទះវិញជាង ១០០ គ្រួសារ”។ ... អ្នកភូមិចាមពីរនាក់ទៀតបានបន្ថែមថា មុនឆ្នាំ ១៩៧៥ ពួកខ្មែរក្រហមបានធ្វើឲ្យមានចំណាប់អារម្មណ៍មួយដ៏ល្អ និងតាមពិតមានការពេញនិយមជាខ្លាំង។ ពួកគេម្នាក់បានអះអាងថា ពួកគេបានរែកទឹក និងកើបលាមកសត្វមកឲ្យកសិករ។ “ពួកគេបានជួយយើងច្រើនណាស់ ... ដូចជាឪពុក និងកូនអញ្ចឹង”។

អ្វីដែលហាក់ដូចជាសំខាន់ខ្លាំងមែនទែនអំពីអំឡុងឆ្នាំ ១៩៧០-៧៥ គឺតាំងទីលំនៅថ្មីរបស់ប្រជាជនចាមនៅក្នុងភូមិភាគនិរតីទាំងនេះ។ ដូចដែលយើងបានឃើញរួចមកហើយ នៅឆ្នាំ ១៩៧៣-៧៤ មានការជម្លៀសប្រជាជនចាមស្រដៀងគ្នានេះដែរនៅភូមិភាគឧត្តរ (ប៉ុន្តែជាក់ស្តែងមិនមានទេនៅភូមិភាគបូព៌ា)។ នៅស្រុកអង្គរជ័យ ប្រជាជនចាមក្នុងភូមិភាគនិរតីត្រូវបានគេហៅជាផ្លូវការថា “ប្រជាជនមូលដ្ឋានបញ្ញើ” ដោយពួកខ្មែរក្រហម។ នេះគឺជាការប្រើពាក្យ “ប្រជាជនបញ្ញើ” ដែលគេស្គាល់ដំបូងគេបំផុត។ វាកើតមានទាំងមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញឆ្នាំ ១៩៧៥ ដែលប្រជាជនបានក្លាយជាប្រជាជនបញ្ញើជារួម ហើយការជម្លៀសប្រជាជនចេញពីភូមិចាមឆ្នាំ ១៩៧៦ នៅភូមិភាគឧត្តរ និងបូព៌ា ដែលប្រជាជនត្រូវបានគេដាក់ស្លាកថាជាប្រជាជនបញ្ញើ នៅពេលនោះ។ នៅភូមិភាគនិរតី ដែលជាបេះដូងរបស់បក្សពួក ប៉ុល ពត ប្រជាជនចាមហាក់ដូចជាប្រជាជនបញ្ញើគំរូដើមអញ្ចឹង។ សំខាន់បំផុត ប្រជាជនចាមក្នុងភូមិភាគនិរតីទាំងនេះនៅតែត្រូវបានគេហៅថាប្រជាជនបញ្ញើ សូម្បីតែនៅក្រោយពេលដែលពួកគេបានវិលត្រឡប់ទៅភូមិកំណើតរបស់ពួកគេវិញនៅឆ្នាំ ១៩៧៤ ក៏ដោយ។ នេះបង្ហាញថា ការបែងចែកថ្នាក់នេះគឺបម្រុងទុកពីដំបូងសម្រាប់ប្រជាជនចាម ដោយហេតុពូជសាសន៍ជាជាងមូលហេតុដែលជាការបង្ហាញពីការផ្លាស់ប្តូរទីលំនៅភូមិសាស្ត្ររបស់ខ្លួន។

គឺនៅក្រោយជ័យជម្នះខែ មេសា ឆ្នាំ ១៩៧៥ នេះហើយដែល ណោ ហ្កា និយាយថា “ការធ្វើទុក្ខបុកម្នេញបានចាប់ផ្តើម”។ ប្រជាជនចាម និងខ្មែរមួយចំនួនមកពីទីក្រុងភ្នំពេញ បានចូលមករស់នៅក្នុងភូមិមួយក្នុងតំបន់នោះបន្ទាប់ពីការជម្លៀសពីទីក្រុង។ អ្នកភូមិឥឡូវនេះមានកាតព្វកិច្ចធ្វើការ “ទាំងយប់ទាំងថ្ងៃ” លើគម្រោងធារាសាស្ត្រ។ ការសម្លាប់បានចាប់ផ្តើមឡើង។ ប្រជាជនខ្មែរត្រូវបានគេសម្លាប់ដោយសារបទល្មើសតូចតាច។ យ៉ាងហោចណាស់ម្នាក់រៀងរាល់ពីរខែម្តង។ សាសនាត្រូវបានគេហាមឃាត់ទាំងស្រុង។ គង់ មូន ដែលមាន

Deleted: *Unrevised translation. A revised translation will be provided upon request.*

អាយុ ៥៩ ឆ្នាំនៅពេលនោះ រំលឹកអំពីបទបញ្ជារបស់ពួកខ្មែរក្រហមថា គេអនុញ្ញាតឱ្យតែផលិតកម្មតែមួយគត់ គ្មានទេពិធីបុណ្យដែលគ្មានប្រយោជន៍។

នៅឆ្នាំ ១៩៧៦ ការហូបអាហាររួមគ្នាត្រូវបានផ្តួចផ្តើមឡើង ហើយការដាំដំណាំ និងស្វែងរកចំណីអាហារជាលក្ខណៈឯកជនត្រូវបានហាមឃាត់នៅក្នុងភូមិចាមនានា។ សាច់ជ្រូកត្រូវបានគេស្ងួក្នុងមុខម្ហូបមួយចំនួន ប៉ុន្តែប្រជាជនវ័យចាស់ៗជាធម្មតាមិនចេះហូបនោះទេ។ កសិករក្នុងតំបន់ម្នាក់រំលឹកថា ប្រធានភូមិចាមស្ទង់ ដែលជាបុរសម្នាក់ឈ្មោះ ស៊ឹម "បានអនុញ្ញាតឱ្យយើងមិនបាច់ហូបសាច់ជ្រូកបាន"។ គង់ មូន បន្ថែមថា កម្មាភិបាលមូលដ្ឋានចាម "បានមើលថែទាំប្រជាជន" ទៀតផង។

ប៉ុន្តែ នៅក្នុងឆ្នាំដដែលនោះ ស៊ឹម ត្រូវបានគេបណ្តេញចេញពីតំណែងប្រធានភូមិ។ គាត់ត្រូវបានគេចោទប្រកាន់ពីបទ "នាំប្រជាជនភាគតិចចាមមិនឱ្យហូបសាច់ជ្រូក"។ ឥឡូវនេះ វាបានក្លាយជាកាតព្វកិច្ចក្នុងការហូបសាច់ជ្រូក។ អ្នកដែលប្រកែកមិនព្រមធ្វើដូច្នេះនឹងត្រូវឱ្យហូបតែទឹកប៉ុណ្ណោះ។ ប្រជាជនមួយចំនួនភ័យខ្លាចនឹងភាពអត់ឃ្លាន និងបានព្យាយាមរត់គេចខ្លួនទៅប្រទេសវៀតណាម។ ពួកគេត្រូវបានចាប់ខ្លួន និងសម្លាប់ដោយពួកខ្មែរក្រហម។ កសិករម្នាក់ដែលជាសាច់ញាតិរបស់ជនរងគ្រោះនិយាយថា "ពួកខ្មែរក្រហមបានចោទប្រកាន់ពួកវៀតណាមថាសម្លាប់ប្រជាជនដែលពួកគេខ្លួនឯងផ្ទាល់ជាអ្នកសម្លាប់"។ ប្រធានភូមិចាមដែលត្រូវគេបណ្តេញចេញគឺ ស៊ឹម អាចរត់គេចខ្លួនទៅប្រទេសវៀតណាមបានក្នុងឆ្នាំ ១៩៧៧ ហើយគាត់បាន_ត្រឡប់មកផ្ទះវិញបន្ទាប់ពីការផ្តួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ ១៩៧៩។ កម្មាភិបាលចាមផ្សេង_ទៀតមិនមានសំណាងដូច្នោះទេ។ អ្នកខ្លះបានបាត់ខ្លួននៅក្នុងឆ្នាំ ១៩៧៦-៧៧ បន្ទាប់ពីត្រូវបានផ្ទេរពី__តំណែងរបស់ពួកគេដោយពួកខ្មែរក្រហម។ អ្នកខ្លះទៀតត្រូវបានគេសម្លាប់នៅឆ្នាំ ១៩៧៨។

នៅឆ្នាំ ១៩៧៧ ភាសាចាមត្រូវបានគេហាមឃាត់។ ណៅ ហ្គា រំលឹកថា កម្មាភិបាលខ្មែរក្រហមបាននិយាយថា ឥឡូវនេះមានតែភាសាខ្មែរមួយគត់ដែលត្រូវបានគេអនុញ្ញាតឱ្យប្រើ។ គ្មានទេភាសាវៀតណាម ចិនថ្វា ពោលគឺមានតែពូជសាសន៍ខ្មែរតែមួយគត់។ គ្រប់គ្នាគឺដូចគ្នាទាំងអស់"។ ណៅ ហ្គា អះអាងថា ពួកខ្មែរក្រហម "ស្អប់" ចាមណាស់។ នាងបានលើកសម្តីរបស់ចៅហ្វាយស្រុកទ្រាំង ឈ្មោះ សឿន ដែល_បានប្រាប់អ្នកដែលមកប្រជុំធំៗជាច្រើនលើកនៅឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ ថា ប្រជាជនចាមគឺ "អស់_សង្ឃឹមហើយ"។ គាត់បានបន្តថា៖ "ពួកគេបានបោះបង់ប្រទេសរបស់ខ្លួនទៅឱ្យអ្នកដទៃហើយ។ ពួកគេគ្រាន់_តែដាក់សំណាញ់បង់ត្រីលើស្មា ហើយដើរចេញទៅ ទុកឱ្យវៀតណាមគ្រប់គ្រងលើប្រទេសរបស់ខ្លួន"។ ការ_ប្រកាសពីរឿងប្រកាន់ពូជសាសន៍ទាំងនេះ ដោយផ្អែកលើការជ្រើសរើសព្រឹត្តិការណ៍ពីសតវត្សរ៍ទី ១៦ មក បាន__ធ្វើឱ្យ

Deleted: *Unrevised translation. A revised translation will be provided upon request.*

ណៅ ហ្គា លែងមានវិញ្ញាណ។ នាងបានស្ម័គ្រចិត្តប្រាប់ការពន្យល់នេះ៖ "ខ្ញុំមិនបានដឹងអំពីរឿងនោះទេ វាបានកើតឡើងជាយូរមកហើយ។ ខ្ញុំមិនដឹងថាតាំងពីជំនាន់ណាមកផង"។

មិនយូរប៉ុន្មាន ពួកខ្មែរក្រហមបានប្រកាសថា ប្រជាជនចាមត្រូវតែ "លាយសាច់លាយឈាមជាមួយប្រជាជនខ្មែរ"។ បន្ទាប់មកប្រជាជនចាមត្រូវបានគេជម្លៀសចេញពីលំនៅដ្ឋានរបស់ពួកគេ។ តាមពិតទៅ នេះគឺជាលើកទីពីរ តែលើកនេះ សហគមន៍ចាមទាំងដប់ត្រូវបានគេបំបែកតែម្តង យ៉ាងហោចណាស់ក្នុងឃុំបី។ តាមពិតទៅ ភូមិស្នង់របស់ ណៅ ហ្គា ត្រូវបានដុតកម្ទេចចោលដោយពួកខ្មែរក្រហម។ ប្រជាជននៅទីនោះត្រូវគេបែងចែកទៅក្នុងចំណោមភូមិចំនួន ៨ នៅឃុំត្រឡាច។ ៤ ឬ ៥ គ្រួសារត្រូវបានបញ្ជូនទៅភូមិ ខ្លះ ហើយ ៦ ឬ ៨ គ្រួសារទៅភូមិផ្សេងទៀត។ ណៅ ហ្គា ដែលបានទៅភូមិកន្ទួតជាមួយគ្រួសារចាម ៥ គ្រួសារទៀតបាននិយាយថា "គេមិនឱ្យយើងរស់នៅជាមួយគ្នាឡើយ"។ "របប ប៉ុល ពត មិនទុកចិត្តយើងទេ។ ពួកគេមិនឱ្យយើងធ្វើអ្វីបានទេ។ ពួកគេមិនឱ្យយើងចូលទៅក្នុងផ្ទះបាយរបស់ពួកគេឡើយ។ ... ពួកគេខ្លាចយើងដាក់ថ្នាំពុលក្នុងម្ហូបអាហារ ឬអ្វីមួយ"។ ជាក់ស្តែង ការរើសអើងដ៏ពេញនិយមប្រឆាំងនឹងប្រជាជនចាមបានរស់រាននៅក្នុងចលនាខ្មែរក្រហម ដែលផ្តល់ដោយការរើសអើង និងគោលនយោបាយដែលគេបានអប់រំបន្ថែមទៀតរបស់មេដឹកនាំចលនានេះ។

ណៅ ហ្គា និយាយថា ប្រជាជនចាមទាំងអស់ត្រូវបានគេហៅថាប្រជាជនបញ្ញើ "សូម្បីតែប្រជាជនមូលដ្ឋាន" ក៏ដោយ។ នេះគឺដោយសារតែពួកគេគឺជា "ជនជាតិភាគតិច"។ នាងបានបន្ថែមទៀតថា "ខ្មែរគឺជា "អ្នកពេញសិទ្ធិ" និង "អ្នកត្រៀម" ដែលប្រហែលជាលើកលែងតែប្រជាជនខ្មែរដែលត្រូវគេជម្លៀសចេញពីទីប្រជុំជនប៉ុណ្ណោះ ដែលគេនឹងហៅថា ប្រជាជនបញ្ញើ។ ប៉ុន្តែ ប្រជាជនចាមត្រូវបានគេចាត់ថ្នាក់នៅក្នុងក្រុមនោះដោយសារតែការរើសអើងពូជសាសន៍។ គង់ មូន និយាយថា "ហ៊ាតជី ទាំងអស់បានស្លាប់នៅឆ្នាំ ១៩៧៧" មានហ៊ាតជី ដែលទទួលបានការអប់រំ ៥ នាក់មានដើមកំណើតពីភូមិស្នង់។ មូន និយាយថា ពួកគេត្រូវបានពួកខ្មែរក្រហមយកទៅភ្នំតូចៗនៅជិតតានីក្នុងខេត្តកំពត។ ពួកគេបានបាត់ខ្លួន និងប្រហែលជាត្រូវបានគេសម្លាប់នៅទីនោះ។ មូន ខ្លួនឯងបានបាត់បង់សាច់ញាតិចំនួន ៤ នាក់នៅឆ្នាំ ១៩៧៧-៧៨។ ពួកគេខ្លះអត់ឃ្លានរហូតដល់ស្លាប់ប្រសើរជាងហូបសាច់ជ្រូក។ ណៅ ហ្គា បានបាត់បង់បងប្អូនប្រុស៣ នាក់ដោយសារការអត់ឃ្លាន។ នៅក្នុងក្រុមរបស់នាងដែលមានគ្រួសារចាមចំនួន ៥ នៅភូមិកន្ទួត មានម្នាក់បានស្លាប់ដោយសារជំងឺ ហើយនៅក្នុងភូមិផ្សេងៗទៀត ប្រជាជនចាមយ៉ាងហោចណាស់ ៤ នាក់ ត្រូវបានគេសម្លាប់ដោយសារប្រកែកមិនព្រមហូបសាច់ជ្រូក"។ នាងនិយាយថា "ពួកគេត្រូវបានគេចោទប្រកាន់ថាជាសង្ឃរាជនៅក្នុងសង្គមចាស់"។ នៅឆ្នាំ ១៩៧៨ គ្រួសារចិនទាំងមូលចំនួន ៤ នៅភូមិកន្ទួតក៏ត្រូវបានសម្លាប់ដោយពួកខ្មែរក្រហមផងដែរ។ ការ

Deleted: *Unrevised translation. A revised translation will be provided upon request.*

សម្លាប់រង្គាលនេះបានកើតឡើង ស្របពេលជាមួយនឹងការសម្លាប់អតីតកម្មាភិបាលចាមដែលបានបន្តរស់នៅក្នុងតំបន់នោះបន្ទាប់ពីត្រូវគេដកចេញពីតំណែងរបស់ខ្លួន។

ប្រជាជនបានធ្វើការងារលំបាកបំផុតក្នុងឆ្នាំ ១៩៧៨។ ណៅ ហ្គា បានធ្វើការនៅវាលស្រែក្នុងរយៈពេល ១៣ ម៉ោងក្នុងមួយថ្ងៃ។ របបអាហារគឺមិនគ្រប់គ្រាន់ទេ ពោលគឺមានតែដំឡូងផ្លា និងត្រកួនជាជាងបាយ។ ប៉ុន្តែសាច់ជ្រូកត្រូវបានគេដាក់ឲ្យហូបពីរដងក្នុងមួយខែនៅឆ្នាំ ១៩៧៨ និងត្រូវតែមានអ្នកដែលគេបង្ខំឲ្យហូបបើមិនដូច្នោះទេនឹងត្រូវគេសម្លាប់។ ប្រជាជនចាមខ្លះដែលបានហូបសាច់ជ្រូកបានក្អួតចេញមកវិញ។ ណៅ ហ្គា និយាយថា រយៈពេលដែលមានការធ្វើទុក្ខបុកម្នេញខ្លាំងជាងគេបំផុតគឺនៅឆ្នាំ ១៩៧៧-៧៨។

## ៣. ទីក្រុងភ្នំពេញ

អតីតភូមិព្រែកតាពើ (ព្រែកប្រា) នៅភាគខាងត្បូងនៃទីក្រុងភ្នំពេញ ក្បែរជាយក្រុងតាខ្មៅគឺជាភូមិរបស់ប្រជាជនចាមមូស្លីមជាង ៣.០០០ នាក់នៅឆ្នាំ ១៩៧៥។ នៅឆ្នាំ ១៩៧៩ មានប្រជាជនប្រហែលជា ៦០០ នាក់ប៉ុណ្ណោះដែលបាននៅរស់រានមានជីវិត បើយោងតាម ហាក់កែម តុលឡោះ ម៉ាត់។ (ចំនួនប្រជាជននៅឆ្នាំ ១៩៤០ ដែលបានរាយការណ៍ដោយលោក Marcel Ner នៅពេលដែលគាត់បានចូលរួមក្នុងពិធីបុណ្យមួយនៅភូមិនោះ គឺ ៨០០ នាក់)។ ម៉ាត់ បាននិយាយនៅឆ្នាំ ១៩៨៣ ថា "មិត្តអ្នកភូមិរបស់យើងជាង ៤ ភាគ ៥ ត្រូវបានកាត់បន្ថយដោយពួកខ្មែរក្រហម"។ គាត់បានលើកឡើងអំពីការបំបែកប្រជាជន ការបង្ខំឲ្យធ្វើពលកម្ម ភាពអស់កម្លាំង ភាពអត់ឃ្លាន ជំងឺ និងការធ្វើបាប រួមទាំងការបង្ខំឲ្យហូបសាច់ជ្រូកទៀតផងថាជា "វិធីសាស្ត្រសាមញ្ញនៃការធ្វើទុក្ខបុកម្នេញ"។ ការសម្លាប់រង្គាលដែលអាក្រក់បំផុតគឺនៅឆ្នាំ ១៩៧៨ ដោយរួមទាំងការសម្លាប់ ហាក់កែម ហ័តជី អ៊ីទ្រីស ដែល ម៉ាត បាននិយាយថាត្រូវបានគេព្យួរជើងឡើងលើពីមែកឈើ ហើយទម្លាក់ចូលក្នុងធុងទឹកក្ដៅដាំពុះ។ នៅត្រឹមចុងឆ្នាំ ១៩៨០ អ្នកដែលនៅរស់រានមានជីវិតក្នុងភូមិព្រែកតាពើបានកើនឡើងដល់ ១.០០៥ នាក់ និងនៅត្រឹមឆ្នាំ ១៩៨៧ ឡើងដល់ប្រហែលជា ១.៣០០ នាក់។

*[រូបភាព]*

*រូបថតដោយ Ben Kierman ដោយមានការផ្ដល់ជូនពី Ben Kierman*

*ប្រជាជនចាមមូស្លីមនៅឯវិហារឥស្លាមច្រាំងចំរេះក្បែរទីក្រុងភ្នំពេញ ឆ្នាំ ១៩៨១។ ច្រាំងចំរេះ ឥឡូវនេះគឺជាមជ្ឈមណ្ឌលជីវិតចាម។*

*[រូបភាព]*

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*រូបថតដោយ Ben Kierman ដោយមានការផ្ដល់ជូនពី Ben Kierman*
*ប្រជាជនចាមមូស្លីមនៅឯវិហារឥស្លាម Noor Alihsan នៅច្រាំងចំរេះ ឆ្នាំ ១៩៨០។*

សហាគមន៍ចាមដ៏ធំបំផុតនៅក្នុងទីក្រុងភ្នំពេញត្រូវបានបង្កើតឡើងនៅច្រាំងចំរេះ នៅជាយក្រុងភាគខាងជើងទីក្រុង។ យើងបានកត់សម្គាល់ឃើញរួចហើយអំពីចំនួនអ្នកស្លាប់ក្នុងចំណោមគ្រួសារចាម ១៥០ មកពីតំបន់នេះដែលត្រូវគេជម្លៀសចេញទៅកាន់ភូមិភាគឧត្តរនៅឆ្នាំ ១៩៧៥ ថា៖ មានគ្រួសារដែលមិនពេញលេញចំនួន ៤៣ គ្រួសារប៉ុណ្ណោះដែលនៅរស់រានមានជីវិតនៅក្នុងឆ្នាំ ១៩៧៩។ អ្នកផ្សេងទៀតបានទៅភូមិភាគនិរតីនិងភូមិភាគបូព៌ា ដូចដែលយើងនឹងឃើញ។ ការស្ទង់មតិមួយលើក្រុមគ្រួសារចាមដែលនៅរស់ចំនួន ១២ គ្រួសារនៅឃុំច្រាំងចំរេះ ២ ក្នុងឆ្នាំ ១៩៨៦ ដែលធ្វើឡើងដោយសហការជាមួយលោក Gregory Stanton បានផ្ដល់លទ្ធផលដូចខាងក្រោមនេះ៖ មានប្រជាជន ១១១ នាក់នៅក្នុង ១២ គ្រួសារនៅដើមឆ្នាំ ១៩៧៥។ យ៉ាងហោចណាស់ ៧ នាក់ក្នុងចំណោមប្រជាជនទាំងនេះបាន “ស្លាប់” នៅឆ្នាំដំបូង ដែលមាន ២ នាក់ដែលត្រូវគេសម្លាប់; ៤ នាក់បានស្លាប់ក្នុងឆ្នាំ ១៩៧៦; ១៣ នាក់បានស្លាប់ក្នុងឆ្នាំ ១៩៧៧ ដែលមាន ៥ នាក់ត្រូវគេសម្លាប់; ២ នាក់បានស្លាប់ក្នុងឆ្នាំ ១៩៧៨; ១៣ នាក់ទៀតបានស្លាប់នៅពេលណាមួយក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩ ដែលធ្វើឱ្យចំនួនសរុបនៃអ្នកដែលបានស្លាប់ក្នុងរយៈពេល ៤ ឆ្នាំនេះគឺ ៣៩ នាក់ ឬ ៣៥ ភាគរយនៃសមាជិកគ្រួសារចំនួន ១១១ នាក់។ សំណាកគំរូនេះរួមបញ្ចូលទាំងគ្រួសារមួយក្នុងចំណោម ៩ គ្រួសារដែលបានភៀសខ្លួនទៅប្រទេសវៀតណាមក្នុងឆ្នាំ ១៩៧៥ និងអ្នកដែលនៅរស់រានមានជីវិតទាំងអស់។ ក្នុងចំណោម ១១ គ្រួសារផ្សេងទៀត មានតែមួយគ្រួសារគត់ដែលមិនបានបាត់បង់សមាជិកណាម្នាក់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

នៅឆ្នាំ ១៩៤០ លោក Marcel Ner បានរាយការណ៍ថា មានប្រជាជនចាមចំនួន ៣៤០ គ្រួសារ នៅច្រាំងចំរេះ[106]។ នៅត្រឹមឆ្នាំ ១៩៧៥ មានជាង ១.០០០ គ្រួសារ។ នៅឆ្នាំ ១៩៨៦ មានគ្រួសារតែ ២៨០ ប៉ុណ្ណោះដែលនៅសល់នៅទីនោះ។ (ប៉ុន្តែ ពួកគេត្រូវបានបញ្ចូលជាមួយនឹងគ្រួសារចាមមកពីផ្នែកផ្សេងៗទៀតនៃប្រទេសចំនួន ១.៦០០ គ្រួសារ។ ប្រជាជនទាំងនេះ ដោយបានប្រមូលផ្តុំនៅកន្លែងមួយ ដែលឥឡូវនេះគេហៅថាមជ្ឈមណ្ឌលជីវិតចាម ត្រូវគេសន្មតថាតំណាងឱ្យប្រជាជនចាមដែលបាត់ខ្លួនពីភូមិផ្សេងៗទៀតរហូតដល់ទៅ ១០.០០០ នាក់។)

[106] Ner, “ជនមូស្លីម” ទំព័រ ១៦៦។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

សហគមន៍ចាមដែលធំមួយទៀតនៅទីក្រុងនេះគឺជ្រោយចង្វារ ត្រើយម្ខាងនៃទន្លេសាបភាគខាងកើតទីក្រុងភ្នំពេញ។ នៅឆ្នាំ ១៩៤០ លោក Ner បានរាយការណ៍ថា មានគ្រួសារចាមចំនួន ៣០០ គ្រួសារនៅទីនោះ (បូករួមទាំងពីរគ្រួសារដែលដឹកនាំដោយពួកម៉ាឡេមកពីប្រទេសសិង្ហបុរី)[107]។ មកទល់ឆ្នាំ ១៩៧៥ ពេលដែលអ្នកភូមិនេះត្រូវពួកខ្មែរក្រហមជម្លៀស ពួកគេអាចនឹងមានចំនួនប្រហែលជា ៩០០ គ្រួសារ។ នៅឆ្នាំ ១៩៧៩ និងឆ្នាំ ១៩៨០ មានតែ ៧០ គ្រួសារប៉ុណ្ណោះដែលបានត្រឡប់មកនៅទីនោះវិញ។ មកទល់ឆ្នាំ ១៩៨៥ គ្រួសារចាមសរុបចំនួន ៨០ បានវិលត្រឡប់ទៅកាន់ជ្រោយចង្វារវិញ[108]។

## ឃ. ភូមិភាគបស្ចិម និងភូមិភាគពាយព្យ

ភូមិភាគនិរតី ដើមឡើយរាប់បញ្ចូលទាំងខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងកោះកុងផងដែរ។ ប៉ុន្តែនៅពាក់កណ្តាលឆ្នាំ ១៩៧៥ តំបន់ដែលស្ថិតនៅភាគខាងជើងផ្លូវជាតិលេខ ៤ ត្រូវបានបំបែកចេញពីភូមិភាគនិរតី ហើយភូមិភាគបស្ចិមថ្មីមួយក៏ត្រូវបានបង្កើតឡើង។ លេខាបក្សប្រចាំភូមិភាគនេះគឺ ជូ ជេត (ដែលបានប៉ះទង្គិចជាមួយ ម៉ុក ក្នុងអំឡុងពេលសង្គ្រាម)។ ភូមិភាគបស្ចិមគឺជាតំបន់មួយដែលក្រីក្របំផុតក្នុងប្រទេស។ ដូចដែល ប៉ុល ពត បានថ្លែងនៅក្នុងសុន្ទរកថាទៅកាន់កម្មាភិបាលភូមិភាគនេះនៅខែ មិថុនា ឆ្នាំ ១៩៧៦ ថា "មានភ្នំនៅគ្រប់ទីកន្លែង ហើយដីគ្មានជីជាតិទ"[109]។ តំបន់ឆ្នេរដែលពិបាករស់នៅ ភ្នំ និងព្រៃឈើនៅភាគខាងលិចមានឥទ្ធិពលលើតំបន់វាលទំនាបដែលសម្បូរដោយដីខ្សាច់ និងភ្លៀងធ្លាក់តិចតួចនៅក្នុងខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំង។ ខេត្តកំពង់ឆ្នាំងត្រូវបានស្រោចស្រពដោយបឹងទន្លេសាប ដែលមានសក្តានុពលយ៉ាងខ្លាំងសម្រាប់ការនេសាទ ប៉ុន្តែទឹកជំនន់ជន់លិចតំបន់ធំៗក្នុងរយៈពេលជាច្រើនខែជារៀងរាល់ឆ្នាំ។

មានសហគមន៍ចាមធំតែមួយគត់នៅភូមិភាគបស្ចិមនេះ។ វារួមមានភូមិចំនួន ៣ នៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលមានប្រជាជនចាមប្រមាណ ៥.០០០ នាក់នៅឆ្នាំ ១៩៤០។ លោក Marcel Ner

---

[107] ដូចឯកសារខាងលើ ទំព័រ ១៦៥។

[108] Michael Vickery, ប្រទេសកម្ពុជា៖ នយោបាយ សេដ្ឋកិច្ច និងសង្គម (ឡុងដ៍៖ Frances Pinter និង Boulder, CO៖ Lynne Reinner, ឆ្នាំ ១៩៨៦) ទំព័រ ១៦៤។ អ្នកផ្តល់ព័ត៌មានរបស់លោក Vickery ដាក់ចំនួនប្រជាជននៅឆ្នាំ ១៩៧៥ ថាមានតែ ១៥០ គ្រួសារ ដែលហាក់ដូចជាមិនទំនង។ យ៉ាងហោចណាស់មានគ្រួសារចាមចំនួន ៤០០ គ្រួសារនៅទីនោះ។ សូមមើល Vu Can "សហគមន៍ម៉ូស្លីមដែលនៅរស់រានមានជីវិត"។ *Vietnam Courier* ៤ (ឆ្នាំ ១៩៨២)។ ទំព័រ ៣១។

[109] សូមមើល Chanthou Boua, David P. Chandler, និង Ben Kiernan (eds.), ប៉ុលពតរៀបផែនការអនាគត៖ ឯកសារសម្ងាត់របស់ថ្នាក់ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៦-៧៧ (New Haven, CT៖ សាកលវិទ្យាល័យយេល។ ក្រុមប្រឹក្សាស្តីពីការសិក្សាពីតំបន់អាស៊ីអាគ្នេយ៍ ចេញផ្សាយនៅឆ្នាំ ១៩៨៨ ខាងមុខ ឯកសារលេខ ២)។

Deleted: បស្ចឹម

Deleted: *Unrevised translation. A revised translation will be provided upon request.*

បានចាត់ទុកភូមិចាមទាំងនេះថាជាភូមិចាមដែលមាន “ទំនៀមទម្លាប់ចាមដ៏ស្មោះត្រង់ជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា” ដែលបានទទួលឥទ្ធិពលពីម៉ាឡេ ឬការរៀបការឆ្លងសាសន៍តិចតួចណាស់។ “នៅក្នុងវិហារឥស្លាម និងសាលារៀនគម្ពីរកូរ៉ានរបស់ពួកគេ ការបង្រៀន និងធម្មទេសនាធ្វើឡើងជាភាសាចាម ហើយចំណេះដឹងនៃភាសាអារ៉ាប់គឺមានក្រឹត្យក្រមទៅតាមអក្ខរក្រម និងរូបមន្តមួយចំនួន។ ពួកគេអភិរក្សសាស្ត្រាស្លឹករឹតចាមមួយចំនួនដែលប្រាប់ពីប្រវត្តិរបស់ខ្លួនគួរឱ្យច្រណែន។ ប្រជាជនជាច្រើនចេះអានសាស្ត្រាស្លឹករឹត_នោះ និងហាក់ដូចជាចេះចាំវគ្គវែងៗបានយ៉ាងស្ទាត់ទៀតផង។ ស្ត្រីចាមរក្សាបាននូវសិទ្ធិអំណាចដែលថា ពួកគេត្រូវតែធ្វើស្របតាមប្រពៃណីចាម[110]។

Deleted: អម្ម

**១. កំពង់ស្ពឺ**

សះ រ៉ោះ កើតនៅស្រុកកំពង់ត្រឡាច នៅឆ្នាំ ១៩៤៩។ មកទល់ឆ្នាំ ១៩៧៥ នាងបានរៀបការ និងរស់នៅក្នុងទីក្រុងភ្នំពេញ។ ប្ដីរបស់នាង ដែលជាជនជាតិចាមដូចគ្នា គឺជាគ្រូបង្រៀនម្នាក់។ ជាមួយប្ដី កូន ៤ នាក់ និងប្អូនស្រីរបស់នាង សះ រ៉ោះ ត្រូវបានគេជម្លៀសចេញទៅភាគខាងលិចនៃរដ្ឋធានីនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥។ ពួកគេទាំង ៧ នាក់បានទៅខេត្តកំពង់ស្ពឺជាមួយក្រុមគ្រួសារជនជាតិចាម ៣ គ្រួសារផ្សេងទៀត។ ពួកគេបានរស់នៅនៅទីនោះអស់ ៤ ខែ។ ទន្ទឹមនឹងនេះដែរ ក្រុមគ្រួសារចាម ២ គ្រួសារមកពីកំពង់ត្រឡាចក៏បានមកដល់ខេត្តកំពង់ស្ពឺដែរ បន្ទាប់ពីត្រូវពួកខ្មែរក្រហមបណ្ដេញចេញពីភូមិកំណើតរបស់ពួកគេ បើទោះបីជាពួកគេជាប្រជាជនមូលដ្ឋានក៏ដោយ។ កាន់តែអាក្រក់ទៅទៀត នៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩៧៥ ឪពុក បងប្រុស និងបងស្រីរបស់ សែន ម៉ាថាយ ត្រូវបានគេសម្លាប់ដោយសារតែពួកគេនិយាយភាសាចាម និងអធិស្ឋានដល់ព្រះអាឡោះ ហើយនៅថ្ងៃដដែលនោះ ឪពុក និងបងប្រុសរបស់ រស់ សាម៉ាត់ ត្រូវគេសម្លាប់ដោយសារពួកគេមិនព្រមហូបសាច់ជ្រូក[111]។ ទោះយ៉ាងណា សះ រ៉ោះ បានឆ្លងកាត់រឿងគ្រាន់បើជាងនេះ។

ប្ដីរបស់ រ៉ោះ ត្រូវគេដាក់ឱ្យធ្វើជាជាងដែក ធ្វើឧបករណ៍កសិកម្ម។ អ្នកដែលនៅសល់ប៉ុន្មានក្នុងគ្រួសារត្រូវទៅធ្វើការនៅវាលស្រែ ប៉ុន្តែត្រូវបានគេផ្ដល់របបអាហារដែលពួកគេអាចចម្អិន និងហូបជាលក្ខណៈឯកជន។ ពួកគេក៏បានយកម្ហូបអាហារមួយចំនួនតាមខ្លួនពីភ្នំពេញផងដែរ ហើយដូច្នេះ ពួកគេមានអាហារូបត្ថម្ភគ្រប់គ្រាន់។ ពួកខ្មែរក្រហមបានដឹងអំពីសាវតាររបស់ប្ដីរបស់ រ៉ោះ ប៉ុន្តែមិនបានធ្វើបាបគាត់ទេ។ រ៉ោះ និយាយថា

---

[110] Ner, “ជនមូស្លីម” ទំព័រ ១៧០។

[111] *ការបំផ្លាញសាសនាអ៊ីស្លាម*, ទំព័រ ១១-១២។

Deleted: *Unrevised translation. A revised translation will be provided upon request.*

តាមការពិត "ពួកខ្មែរក្រហមនៅខេត្តកំពង់ស្ពឺរាងស្រួលបន្តិច ... មិនពិបាកខ្លាំងទេ។ ... ការសម្លាប់គឺគ្មានទេ។ ... ប្រជាជនមូលដ្ឋានគឺសុខសប្បាយ។ យើងអាចសុំឲ្យពួកគេជួយយើងបានទៀតផង"។

**២. ខេត្តពោធិ៍សាត់ និងបាត់ដំបង**

ទោះយ៉ាងណា នៅខែ កញ្ញា ឆ្នាំ ១៩៧៥ គ្រួសារចាមទាំង ៤ ត្រូវបាន "ជ្រើសរើស" ឲ្យទៅភូមិភាគពាយ័ព្យនៃប្រទេស រួមជាមួយនឹងគ្រួសារខ្មែរជាច្រើនទៀតមកពីតំបន់នោះ។ ការផ្លាស់លំនៅនេះបានបង្ហាញពីគ្រោះមហន្តរាយមួយ។ ក្នុងចំណោមប្រជាជនចាម ២៦ នាក់ដែលបានចាកចេញពីទីក្រុងភ្នំពេញជាមួយគ្នា មានតែ ១៣ នាក់ប៉ុណ្ណោះដែលនៅរស់ដល់ ៣ ឆ្នាំក្រោយ។

នៅពេលមកដល់ស្រុកបាកាន ខេត្តពោធិ៍សាត់ ជនចំណូលថ្មីទាំងនេះត្រូវបានគេបែងចែកមួយគ្រួសារទៅសហករណ៍នីមួយៗ។ គ្រួសាររបស់ សះ រ៉ោះ ត្រូវបានបញ្ជូនទៅតាឡូ ដែលជាសហករណ៍មួយមានប្រជាជនជាង ១.០០០ គ្រួសារ។ "ពេលយើងទៅដល់ភ្លាម យើងត្រូវតែប្រគល់របស់របរទាំងអស់របស់យើង ហើយទទួលបានមកវិញតែសម្លៀកបំពាក់ ២ ឈុតម្នាក់ប៉ុណ្ណោះ។ គេមិនឲ្យយើងមានទ្រព្យសម្បត្តិទេ។ ... យើងហូបអាហាររួមគ្នា ដែលមានតែបបររាវៗ និងស្លឹកចេក រួមនឹងឪឡឹក។ នៅពាក់កណ្តាលឆ្នាំ ១៩៧៦ បន្ទាប់ពីបង្ហើបប្រាប់ថាគាត់គឺជាគ្រូបង្រៀន ប្តីរបស់ រ៉ោះ ត្រូវបានគេយកទៅ "កសាង"។ "តាំងពីនោះមក គ្មាននរណាម្នាក់ដឹងដំណឹងពីគាត់ទេ"។ ៦ ខែក្រោយមក កូនរបស់ រ៉ោះ ពីរនាក់ និងប្អូនស្រីរបស់នាងបានស្លាប់ទាំងអស់បន្តបន្ទាប់គ្នាក្នុងរយៈពេលមួយខែ។ នៅឆ្នាំ ១៩៧៦ ប្រជាជនជាង ១០ នាក់ត្រូវគេសម្លាប់នៅក្នុងភូមិរបស់ សះ រ៉ោះ ប៉ុន្តែ "នៅឆ្នាំ ១៩៧៧ មានអ្នកដែលត្រូវគេសម្លាប់ជាច្រើន ដែលគេបានយកមកពីគ្រប់ទីកន្លែង"។ ស្ត្រី ៧ នាក់ក្នុងចំណោមស្ត្រី ៣០ នាក់នៅក្នុងក្រុមការងាររបស់ រ៉ោះ បានស្លាប់នៅឆ្នាំ ១៩៧៧។ ហើយនៅឆ្នាំ ១៩៧៨ មានការសម្លាប់រង្គាលលើជនភៀសខ្លួនថ្មីមកពីភូមិភាគបូព៌ាចំនួន ៣.០០០ នាក់។ រ៉ោះ ក្រោយមកបានទទួលឯកសិទ្ធិដោយត្រូវបានគេតំឡើងឋានៈជាប្រជាជនមូលដ្ឋានម្នាក់។ "ពួកគេបានទុកខ្ញុំមួយឡែក និងខ្ពស់មួយរយៈ ខណៈពេលដែលពួកគេបានធ្វើទុក្ខបុកម្នេញប្រជាជនដែលមកពីភូមិភាគបូព៌ា។ "វាហាក់ដូចជាមិនមានភ័ស្តុតាងណាមួយនៅក្នុងដំណើររឿងរបស់ រ៉ោះ បង្ហាញថា ប្រជាជនចាមត្រូវបានជ្រើសរើសយកមកធ្វើបាបដោយការរើសអើងតែឯង ដូចដែលគេធ្វើដាក់អ្នកមកពីភូមិភាគបូព៌ាទេ។ ប៉ុន្តែ ជោគវាសនារបស់នាងគឺជួបនឹងទុក្ខភ័យណាស់ ហើយការកត់ត្រាទុកនូវការអត្ថាធិប្បាយដ៏ក្តុកក្តួលរបស់នាងគឺមានតម្លៃណាស់៖ "ប្តីរបស់ខ្ញុំត្រូវបានគេយកទៅដំបូងគេបង្អស់។ គាត់បានស្លាប់ បាត់ខ្លួនជារៀងរហូត។ ពេលនោះ ខ្ញុំកំពុងមានផ្ទៃពោះ ៧ ខែ។ វាជាពេលដ៏ពិបាកខ្លាំងណាស់ ត្រូវស្ទូងស្រូវក្នុងស្រែដែលលិចទឹក។ ... ខ្ញុំនៅសល់តែម្នាក់ឯងប៉ុណ្ណោះបន្ទាប់ពីរឿងនោះមក"។

Deleted: *Unrevised translation. A revised translation will be provided upon request.*

Pin Yatay នៅក្នុងសារណារបស់គាត់ *ភាពសុខសាន្តមរណៈ* បានកត់ត្រាសកម្មភាពមួយចំនួនរបស់ប្រជាជនចាមក្នុងខេត្តពោធិ៍សាត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានចាត់ទុកពួកគេថាជា "គោលដៅពេញនិយមនៃភាពសប្បាយដែលធ្វើឲ្យអ្នកដទៃឈឺចាប់របស់របបខ្មែរក្រហម" និងបានពន្យល់ពីរបៀបដែលពួកគេបាន "រៀបចំខ្លួនឯងជាក្រុមដើម្បីឆ្លៀតលួចបេះពោត" ដើម្បីរស់។

សហគមន៍នេសាទរបស់ពួកគេ (ពួកគេរស់នៅជុំវិញបឹងទន្លេសាប) ត្រូវបានដកចេញទាំងឫសដោយរបបថ្មី។ ដោយហេតុនោះហើយ ពួកគេបានកើតចិត្តស្អប់យ៉ាងខ្លាំងចំពោះពួកខ្មែរក្រហម។ បើទោះបីជាពួកគេត្រូវបែកខ្ញែកដោយសារម្ចាស់ថ្មីរបស់ប្រទេសនេះក៏ដោយ ក៏ប្រជាជនខ្មែរឥស្លាមបានទទួលជោគជ័យក្នុងការបង្កើតបណ្ដាញសម្ងាត់ដ៏ពិតប្រាកដមួយ។ ពួកគេបានចូលទៅក្នុងក្រុមតូចៗដើម្បីលួចផ្លែពោតពីចម្ការ។

ទោះជាយ៉ាងណា លោក Yatay បញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើប្រជាជនចាមត្រូវបានជ្រើសរើសសម្រាប់ការរើសអើងពិសេសមែននោះ វាមានតែនាំពួកគេឲ្យជិតស្និទ្ធទៅនឹងមិត្តរងគ្រោះខ្មែរប៉ុណ្ណោះ។

យើងគឺជាទាសករដែលត្រូវគេបង្អត់អាហារ។ ... ក្នុងចំណោមប្រជាជនថ្មី មានប្រជាជនគ្រប់ប្រភេទ។ អ្នកដែលត្រូវគេធ្វើទុក្ខបុកម្នេញគឺមកពីគ្រប់មជ្ឈដ្ឋាន។ មានចាម ឬខ្មែរឥស្លាម ចិន សូម្បីតែ_វៀតណាមដែលមិនទាន់បានត្រឡប់ទៅប្រទេសរបស់ពួកគេវិញ។ យើងលែងមានផ្នត់គំនិតខុសគ្នា__ទៀតហើយ។ យើងគឺជាប្រជាជនថ្មីដែលគេតម្រង់ទិសឲ្យប្រឆាំងនឹងប្រជាជនចាស់។ យើង បានឆ្លង_កាត់ទុក្ខវេទនា និងការឈឺចាប់ដ៏ស្ងាត់ស្ងៀមជាមួយគ្នា។ យើងមិនបរិហារគ្នាទៅវិញទៅមកទេ[112]។

តូ ហូសាន ក៏បានកើតនៅកំពង់ត្រឡាចផងដែរ ប៉ុន្តែបានផ្លាស់ទៅបាត់ដំបងនៅត្រឹមឆ្នាំ ១៩៧៥ នៅពេលពួកខ្មែរក្រហមចូលកាន់កាប់។ គាត់មានអាយុ ១៩ ឆ្នាំនៅពេលនោះ ហើយជាមួយនឹងគ្រួសាររបស់គាត់ដែលមានគ្នា ៩ នាក់ គាត់ត្រូវបានគេជម្លៀសចេញទៅកាន់ទីជនបទនៃខេត្តបាត់ដំបង។ ពួកគេបានទៅភូមិកាងហាត់ ក្នុងស្រុកសង្កែ ដែលនៅទីនោះពួកគេបានដឹងថាមានវិហារឥស្លាមធ្វើពីឈើតូចមួយ។ សហគមន៍មូស្លីមដែលនៅក្នុងតំបន់បានចាកចេញពីតំបន់នោះ ប៉ុន្តែគ្រួសារមូស្លីមចំនួន ១១ ក៏បានមកដល់ភូមិកាងហាត់ផងដែរ ពីក្រុងប៉ៃលិន រួមទាំងគ្រួសារជ្វា ៣ គ្រួសារទៀត។ អ្នកដែលនៅសេសសល់គឺជាប្រជាជនចាម។ ក្នុងរយៈពេល

[112] Pin Yatay, *ភាពសុខសាន្តមរណៈ* (ប៉ារីស៖ Laffont, ឆ្នាំ ១៩៧៩) ទំព័រ ២៣១-៣២, ២៥៣។ (សូមមើលផងដែរការបកប្រែជាភាសាអង់គ្លេស Pin Yathay, ប្រឹងរស់ឡើង កូនប្រុស (Bloomsbury និង New York៖ Free Press, ឆ្នាំ ១៩៨៧)។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ប្រហែលបីខែដំបូង ពួកគេទាំងអស់គ្នាត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិសាសនាឥស្លាម ប៉ុន្តែ ក្រោយមកវិហារឥស្លាមនោះត្រូវបានបិទ ហើយសាសនាទាំងអស់ត្រូវពួកខ្មែរក្រហមហាមឃាត់។

បន្ទាប់មក នៅដើមឆ្នាំ ១៩៧៦ សហករណ៍ត្រូវបានបង្កើតឡើង ជាមួយនឹងការហូបអាហាររួមគ្នា ហើយគេបានបញ្ជាក់យ៉ាងច្បាស់ដល់ប្រជាជនមូស្លីមថា ពួកគេនឹងត្រូវហូបម្ហូបដែលដាក់សាច់ជ្រូកលើកណាក៏ដោយដែលគេដាក់ឲ្យហូប។ មុខម្ហូបទាំងនេះគឺកម្រមានណាស់ ប៉ុន្តែ ហូសាន និយាយថា៖ “ប្រសិនបើមានជ្រូកឈឺស្លាប់ យើងត្រូវហូបសាច់ជ្រូក ៣ ថ្ងៃ”។ មូលហេតុដែលប្រជាជនចាមត្រូវតែហូបសាច់ជ្រូកគឺជា_បទបញ្ជាដែលវណ្ណៈ និងលក្ខខណ្ឌរស់នៅត្រូវតែដូចគ្នាសម្រាប់អ្នករាល់គ្នា។

*[រូបភាព]*

*រូបថតដោយ* Ben Kierman *ដោយមានការផ្តល់ជូនពី* Ben Kierman

*ប្រជាជនចាមមូស្លីមនៅកំពង់ត្រឡាច នៅឆ្នាំ ១៩៨០*

ការងារគឺមានលក្ខណៈជាសមូហភាព ពុទ្ធសាសនា និងឥស្លាមសាសនាត្រូវបានលុបបំបាត់ចោលដូចគ្នា ហើយ “អ្វីដែលប្រជាជនខ្មែរធ្វើ ប្រជាជនខ្មែរឥស្លាមក៏ត្រូវធ្វើដូចគ្នាដែរ”។

> មានបុរសម្នាក់ ឈ្មោះថា ស្មាន់ ជាសង្ឃរាជម្នាក់មកពីឃុំងស្បែក ត្រូវបានគេបាញ់សម្លាប់ចោលដោយសារប្រកែកមិនព្រមហូបសាច់ជ្រូក។ គាត់បាននិយាយថា គាត់សុខចិត្តស្លាប់ជាជាងឲ្យគាត់ហូបសាច់ជ្រូក។ គាត់ជាមនុស្សដំបូងគេបង្អស់ ហើយយើងទាំងអស់គ្នាបានរង់ចាំមើលតើនឹងមានរឿង_អ្វីកើតឡើង។ គ្រប់គ្នាភ័យខ្លាចខ្លាំងណាស់។ បន្ទាប់មក ពួកគេបានប្រើគាត់ជាមេរៀន។ ពួកគេសម្លាប់គាត់ដោយសារតែគាត់ជាអ្នកតវ៉ាប្រឆាំងមុនគេ។ ... ដូច្នេះយើងទាំងអស់គ្នាបានចាប់ផ្តើមហូបសាច់ជ្រូកបន្តិចម្តងៗ។ យើងមានការភ័យខ្លាចណាស់។

នៅពេលដែលសហករណ៍ត្រូវគេបង្កើតឡើងនៅដើមឆ្នាំ ១៩៧៦ ពួកខ្មែរក្រហមបានរៀបចំការប្រជុំមួយ ហើយប្រធានសហករណ៍ឈ្មោះ ហាម បានប្រកាសថា មានតែភាសាខ្មែរមួយគត់ដែលគេអនុញ្ញាតឲ្យប្រើបានពីពេលនេះតទៅ។ ហូសាន បន្ថែមថា៖ “មិនមែនតែភាសាចាមមួយទេ តែគ្រប់ភាសាទាំងអស់ ឧទាហរណ៍ភាសាចិន ឬឡាវ ដែលត្រូវបានគេហាមឃាត់។ យើងក៏មិនអាចនិយាយភាសាចាមលួចលាក់នៅតាមផ្ទះបានដែរ។ ប្រសិនបើពួកគេឮ យើងនឹងត្រូវបាត់ខ្លួនហើយ។ សូម្បីតែនៅពេលយប់ ពួកកងឈ្លបនឹងចូលមកក្នុងផ្ទះ និងលួចស្តាប់។ ... ប្រជាជនចាមមួយចំនួនត្រូវបានគេសម្លាប់ដោយសារនិយាយភាសាចាម”។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ការប្រមូលផលជាលើកដំបូងក្រោមប្រព័ន្ធសហករណ៍នេះត្រូវគេរឹបអូស។ “ពួកគេនឹងមិនឲ្យយើងហូបឡើយ ទោះបីជាការផលិតបានផលខ្ពស់ក៏ដោយ។ ពួកគេបានយកវាចេញទៅទាំងអស់តាមឡានដឹកទំនិញ។ “ជាលទ្ធផល ការអត់ឃ្លានបានចាប់វាយប្រហារពីខែ មីនា ដល់ខែ មេសា ឆ្នាំ ១៩៧៧។ “ប្រជាជនស្ទើរតែពាក់កណ្ដាល” ក្នុងឃុំបានស្លាប់គឺ ជាង ៤០០ នាក់ក្នុងចំណោមប្រជាជនសរុប ៩០០ គ្រួសារ។ ក្នុងចំណោមគ្រួសារចាមចំនួន ១២ គ្រួសារ មានមនុស្ស ៤ នាក់បានស្លាប់ដោយសារការអត់ឃ្លាន និងជំងឺ រួមទាំងសាច់ញាតិម្នាក់របស់ ហូសាន ផងដែរ។

ឆ្នាំ ១៩៧៨ គឺជាឆ្នាំដែលជួបប្រទះនឹងការអត់ឃ្លានតិច ប៉ុន្តែរបបការងារច្រើន។ គម្រោងទំនប់នៅ_លើទន្លេសង្កែបានអះអាងថា “យ៉ាងហោចណាស់ មានប្រជាជន ១០ នាក់បានស្លាប់ជារៀងរាល់ថ្ងៃ” ស្ទើរ_តែពេញមួយឆ្នាំ។ ក៏មាន “ការសម្លាប់ដោយសម្ងាត់ជាច្រើន” ផងដែរ។ លទ្ធផលគឺថា នៅឆ្នាំ ១៩៧៩ មាន_ប្រជាជនពេញវ័យប្រមាណជា ៦០០ នាក់ប៉ុណ្ណោះដែលបានរស់រានមានជីវិតក្នុងចំណោមប្រជាជន ៩០០ គ្រួសារនៅក្នុងឃុំនៅឆ្នាំ ១៩៧៥។ គ្រួសារចាមទាំង ១២ បានបាត់បង់សមាជិករបស់ខ្លួន ៤ នាក់៖ ពួកគេទំនងជាមិនបានទទួលរងគ្រោះច្រើនជាងប្រជាជនខ្មែរទេ ថ្វីបើជាក់ស្តែងពួកគេត្រូវគេជ្រើសរើសសម្រាប់ការប្រព្រឹត្តដាក់ជាពិសេសដូចជា ការបង្ខំយ៉ាងអាក្រក់ហាមឃាត់លើភាសា និងទំនៀមទម្លាប់ របបអាហាររបស់ពួកគេជាដើម។

**៣. កំពង់ត្រឡាច**

ហាម៉ាត់ បានកើតនៅស្រុកកំពង់ត្រឡាចនៅឆ្នាំ ១៩៤៣ ប៉ុន្តែក្រោយមកបានផ្លាស់ទៅរស់នៅក្នុងទីក្រុង និងបានក្លាយជាអ្នកនេសាទនៅច្រាំងចំរេះ។ ពេលដែលខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ “ភូមិច្រាំងចំរេះទាំងមូលត្រូវគេជម្លៀសប្រជាជនចេញ” ទៅកាន់កំពង់ត្រឡាច។ ទោះយ៉ាងណា ប្រជាជនចាមដូចជា ហាម៉ាត់ ដែលមកពីស្រុកនោះ មិនត្រូវបានគេអនុញ្ញាតឲ្យវិលត្រឡប់ទៅភូមិកំណើតរបស់ពួកគេវិញទេ។ ប្រជាជនថ្មីត្រូវបានគេបែងចែកជាក្រុមៗ និងបំបែកទៅតាមភូមិ និងសហករណ៍នានា។ ហាម៉ាត់ ត្រូវបានបញ្ជូនទៅសហករណ៍មួយដែលគេហៅថា ស្ទឹងស្លូត។ (ម្ដាយរបស់គាត់ត្រូវបានបំបែកចេញពីគាត់ ហើយត្រូវគេបញ្ជូនទៅកន្លែងផ្សេងទៀត។) នៅស្ទឹងស្លូត មានគ្រួសារចាម ៤០ គ្រួសារ; គ្រួសារខ្មែររួមមានប្រជាជនមូលដ្ឋានប្រហែល ១០ គ្រួសារ។

នៅខែ សីហា ឆ្នាំ ១៩៧៦ ហាម៉ាត់ និយាយថា “ប្រជាជនចាមទាំងអស់ត្រូវបានគេសម្លាប់នៅស្ទឹងស្លូត”។ “គ្មានគ្រួសារណាមួយនៅសល់ទេ។ ... ខ្ញុំបានឃើញគេយកប្រជាជនចេញទៅ ពួកគេទាំងមួយគ្រួសារៗតែម្តង។ ... ប្រសិនបើខ្ញុំមិនបានចាកចេញទេ ខ្ញុំក៏មុខជាស្លាប់ដែរ”។ ហាម៉ាត់ ត្រូវបានផ្ទេរយ៉ាងត្រេកអរទៅក្រុមនេសាទនៅលង្វែក និងបានវិលត្រឡប់ទៅកាន់ស្ទឹងស្លូតវិញតែម្តងគត់ក្នុងឆ្នាំ ១៩៧៨។ គាត់បានដឹងថា ស្វ

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ម្បីតែកុមារចាមនៅទីនោះក៏បានដើរតាមឪពុកម្ដាយពួកគេទៅស្លាប់ដែរ។ ហាម៉ាត់ រំលឹកដល់ពាក្យសម្ដីរបស់ពួកខ្មែរក្រហមថា "ដកស្មៅត្រូវដកទាំងឫស"។ គាត់គឺជាអ្នកដែលនៅរស់រានមានជីវិតតែម្នាក់គត់ក្នុងចំណោមគ្រួសារចាមចំនួន ៤០ គ្រួសារ។

សុខ សុឃុន ជនជាតិខ្មែរដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ បានរស់នៅក្នុងភូមិជាមួយគ្នានេះ គឺភូមិស្ទឹងស្លូត នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានអះអាងថា នៅរវាងខែ កញ្ញា និងខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ប្រជាជនថ្មីចាម និងចិនចំនួន ១០.០០០ នាក់ ត្រូវបានគេសម្លាប់នៅក្នុងឃុំអំពិលទឹក ស្រុកកំពង់ត្រឡាចក្រោម[113]។ ប៉ុន្តែ ប្រជាជនខ្មែរក៏បានទទួលរងនូវការឈឺចាប់ខ្លោចផ្សាផងដែរ។ ហាម៉ាត់ និយាយថា ក្នុងចំណោមប្រជាជនថ្មីចំនួន ១៧.០០០ នាក់ដែលបានមកដល់ឃុំនេះក្នុងឆ្នាំ ១៩៧៥ មានតែ ៣.០០០ នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតនៅក្នុងឆ្នាំ ១៩៧៩។

ឃុំឈូកសដែលនៅជិតខាងនោះបានជួបប្រទះនឹងគ្រោះមហន្តរាយស្រដៀងគ្នានេះដែរ បើទោះបីជាប្រជាជនភាគច្រើនក្នុងឃុំនេះជាប្រជាជនមូលដ្ឋានក៏ដោយ។ ក្នុងចំណោមប្រជាជនចំនួន ៨.៥០០ នាក់ក្នុងឆ្នាំ ១៩៧០ មានតែប្រជាជន ៣.៣០០ នាក់ប៉ុណ្ណោះដែលបានរួចរស់ជីវិតនៅក្នុងឆ្នាំ ១៩៧៩។ អ្នកស្រុកចំនួន ៤.០០០ នាក់ត្រូវបានគេសម្លាប់នៅក្នុងឆ្នាំ ១៩៧៧-៧៨ តែឯង[114]។ ការកត់ត្រាពីសាវតានៃសោកនាដកម្មនេះគឺជារឿងសំខាន់។

ពួកខ្មែរក្រហមបានកាន់កាប់តំបន់នេះជាលើកដំបូងនៅឆ្នាំ ១៩៧០ នេះបើយោងតាម កា ជូ ដែលជាជាងដែកជនជាតិចាមក្នុងស្រុកម្នាក់ដែលមានអាយុ ៤៥ ឆ្នាំនៅពេលនោះ។ គាត់រំលឹកថា៖

> ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧២ ពួកគេបានប្រើនយោបាយ មិនបានសម្លាប់មនុស្សនោះទេ។ ស្ថានភាពគឺនៅល្អ។ ... ប្រជាជនពិតជាជឿជាក់លើពួកគេ។ ពួកគេចង់បានសេរីភាព សុភមង្គល និងម្ហូបអាហារ។ ... ពួកខ្មែរក្រហមបាននិយាយថា ប្រសិនបើយើងមិនតស៊ូទេ សាសនា និងជាតិរបស់យើងនឹងបាត់បង់ទាំងអស់។ ... ពួកចក្រពត្តិអាមេរិកនឹងគ្រប់គ្រងប្រទេសយើង ហើយលុបបំបាត់សាសនា និងពូជសាសន៍យើង ប្រែក្លាយពួកយើងឲ្យទៅជាជនជាតិអាមេរិក។
>
> ពួកគេបាននិយាយថា ប្រសិនបើយើងមិនតស៊ូខ្លាំងក្លាទេ "ត្រូវប្រយ័ត្នខ្លួនទៅ បើមិនដូច្នោះទេយើងនឹងចប់ដូចចម្បាំងអភ្លើង។ ... ឥឡូវអ្នកបានចូលមករស់នៅក្នុងប្រទេសកម្ពុជាអ្នកត្រូវតែតស៊ូឲ្យ

[113] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ សុខ សុឃុន នៅទីក្រុងភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៨០។

[114] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ កា ជូ នៅឈូកស ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ១៩៨០។

Deleted: Unrevised translation. A revised translation will be provided upon request.

បានខ្លាំងក្លា”។ ពួកគេបាននិយាយថា៖ “កុំយកគំរូតាមចម្ប៉ាដែលមិនចេះតស៊ូនោះ។ ហេតុនេះហើយបានជាអ្នករាល់គ្នាគ្មានប្រទេសជាតិនោះ”។

យន្តហោះ បេ-៥២ របស់អាមេរិកបានចាប់អនុវត្តការវាយឆ្មក់ដោយការទម្លាក់គ្រាប់បែកនៅក្នុងឃុំនេះនៅពេលនោះ។ នៅឃុំឈូកស ប្រជាជនចាម ២០ នាក់បានស្លាប់ និងរងរបួសនៅក្នុងការ ទម្លាក់គ្រាប់បែក បេ-៥២ និងអ្នកផ្សេងទៀតបានស្លាប់ និងរងរបួសនៅក្នុងការវាយឆ្មក់តាមអាកាសខ្នាតតូច។ គឺនៅពេលដែលការទម្លាក់គ្រាប់បែករបស់អាមេរិកខ្លាំងនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៣ នោះហើយដែលពួកខ្មែរក្រហមបានចាត់វិធានការខ្លាំងក្លា។ កម្មាភិបាលក្នុងតំបន់ត្រូវបានផ្លាស់ប្តូរថ្មី ហើយភូមិនានាត្រូវបានជម្លៀសចេញ។ សមាជិកនៃក្រុមរបស់ កា ជូ ត្រូវបានបញ្ជូនចូលទៅក្នុងព្រៃចម្ងាយ ៣០ គីឡូម៉ែត្រ ដែលនៅទីនោះទ្រព្យសម្បត្តិ និងការងាររបស់ពួកគេត្រូវបានក្លាយជាសមូហភាព។ ការអត់ឃ្លានបានចាប់ផ្តើម និងបន្តនៅក្នុងឆ្នាំ ១៩៧៤ នៅពេលដែលការហូបអាហាររួមគ្នាត្រូវបានគេដាក់ចេញ ដោយមានតែ “មួយឆ្នាំងសម្រាប់ភូមិទាំងមូល”។ នៅត្រឹមឆ្នាំ ១៩៧៥-៧៦ ប្រជាជនចាមត្រូវបានគេបង្ខំឱ្យហូបអាហារដែលមានដាក់សាច់ជ្រូកជាមួយនឹងការគំរាមសម្លាប់ ឬដកឱ្យហូបតែអំបិល។

នៅខែ មិថុនា ឆ្នាំ ១៩៧៣ ផងដែរ សាសនាត្រូវលុបបំបាត់ចោល ហើយក្មេងស្រីចាមត្រូវបានបង្ខំឱ្យកាត់សក់ឱ្យខ្លីដូចក្មេងប្រុស។ នៅទីបញ្ចប់ ខែ មិថុនា ឆ្នាំ ១៩៧៣ គេបានសេចក្តីប្រកាសអំពីផែនការដែលស្រដៀងគ្នានោះរបស់ពួកខ្មែរក្រហមថា៖ “ខ្មាំងទាំងអស់ត្រូវតែកម្ទេចចោល ... មិនមែនត្រឹមតែខ្មាំងពីសម័យ លន់ នល់ ទេ ប៉ុន្តែខ្មាំងនៅក្នុងឃុំផងដែរ”។ ខ្មាំងចុងក្រោយនេះត្រូវពួកខ្មែរក្រហមហៅថា ខ្មាំងផ្ទៃក្នុង។ ដូច ដែល កា ជូ រំលឹកវាថា “ប្រសិនបើពួកគេសួរយើងពីអ្វីមួយ ហើយយើងឆ្លើយពីរឿងអ្វីដែលអាក្រក់ ឬក្នុងន័យប្រឆាំង នោះយើងនឹងបាត់ខ្លួនចាប់ពីថ្ងៃនោះជារៀងរហូត”។

នៅឆ្នាំ ១៩៧៤ និងឆ្នាំ ១៩៧៥ ប្រជាជនចាមទាំងអស់ដែលពីមុនកាន់តំណែងជាប្រធានសហករណ៍ ឬប្រធានកងត្រូវបានគេដកចេញពីតំណែង។ កា ជូ និយាយថា៖ “ពួកគេបានបាត់បង់សិទ្ធិរបស់ពួកគេ។ ទោះបីជាប្រជាជនចាមដែលបានប្រយុទ្ធការពាររបបខ្មែរក្រហមក្តី ក៏ត្រូវបានគេដកចេញ [ពីកងកម្លាំងប្រដាប់អាវុធ] និងដាក់បញ្ចូលទៅក្នុងក្រុមនេសាទត្រីដែរ។ គ្មានប្រជាជនចាមណាមានសេរីភាព ឬសិទ្ធិឡើយនៅពេលនោះ”។

នៅរង្វង់ពេលជាមួយគ្នានោះដែរ សហគមន៍ចាមត្រូវបានគេបំបែកខ្ចាត់ខ្ចាយ បែកខ្ញែកគ្នាជាង ៨ ឬ ៩ ឃុំ នៅស្រុកកំពង់ត្រឡាច ជាក្រុមៗដែលមាន “២ គ្រួសារ ៥ គ្រួសារ ឬរហូតដល់ទៅ ២០ គ្រួសារក្នុងមួយភូមិ” នេះបើយោងតាម សុះ ម៉ែន ដែលជាកសិករក្នុងស្រុកម្នាក់ទៀតដែលមានអាយុខ្ទង់ ២០ ឆ្នាំនៅពេលនោះ។

Deleted: ដូចដែល

Deleted: *Unrevised translation. A revised translation will be provided upon request.*

កា ជូ យល់ស្របថា "គេមិនឱ្យមានក្រុមធំៗនោះទេ" ត្រឹមតែ ២០ ទៅ ៣០ នាក់ប៉ុណ្ណោះដែលគេទុកឱ្យនៅក្នុងភូមិចាមនីមួយៗ។ សុះ ម៉ែន បន្ថែមថា៖

> ហេតុនេះហើយបានជាពីមួយឆ្នាំទៅមួយឆ្នាំ យើងឃើញថា ផែនការរបស់ពួកគេកាន់តែតឹងទៅៗ ប៉ុន្តែប្រជាជនក្នុងឃុំឈូកសមិនអាចរកវិធីណាមួយដើម្បីគេចផុតពីការដាក់នឹមរបស់ពួកគេឡើយ។ ... នៅខែ មករា ឆ្នាំ ១៩៧៤ [យើងត្រូវធ្វើការ] ១៤ ម៉ោងក្នុងមួយថ្ងៃ។ គ្មានពេលសម្រាកទាល់តែសោះ ចន្លោះពីម៉ោង ៤ ព្រឹកដល់ម៉ោង ១០ យប់ លើកលែងតែពេលឈប់សម្រាកហូបបបររាវៗតែប៉ុណ្ណោះ។ កម្លាំងរបស់ប្រជាជនបានក្រៀមស្វិត។ អ្នកវ័យក្មេងៗបានក្លាយចាស់ទាំងអស់។

មេដឹកនាំមូស្លីមក្នុងតំបន់ចាប់ផ្តើមត្រូវគេសម្លាប់ពីឆ្នាំ ១៩៧៤ តទៅ។ សុះ ម៉ែន បានប្រាប់ឈ្មោះជនរងគ្រោះពីរនាក់ គឺ មិត និង កូប។ កា ជូ បន្ថែមឈ្មោះរបស់ ហាក់កែម របស់គាត់ឈ្មោះ ម៉េត និងឥស្សរជនម្នាក់ទៀតឈ្មោះ រ៉ុន។ ពួកគេត្រូវគេសម្លាប់នៅឆ្នាំ ១៩៧៥ បន្ទាប់ពីត្រូវគេសួរចម្លើយអំពីសាសនារបស់ពួកគេ។ នៅឆ្នាំ ១៩៧៥ ប្រជាជនថ្មីប្រហែល ៥០០ នាក់ ទាំងចាមទាំងខ្មែរ មកពីភ្នំពេញ និងក្រុងបាត់ដំបងបានមកដល់ ហើយក្នុងរយៈពេលបួនឆ្នាំបន្ទាប់មក ហ័តជី ប្រហែល ១០ នាក់ត្រូវគេសម្លាប់។ កា ជូ អះអាងថាបានចងក្រងបញ្ជីឈ្មោះបុរសដែលមានការចេះដឹងចំនួន ១៥០ នាក់ មកពីឃុំឈូកស ដែលត្រូវគេសម្លាប់ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០។

នៅពាក់កណ្តាល ឬចុងឆ្នាំ ១៩៧៦ កូនត្រូវគេបំបែកចេញពីឪពុកម្តាយរបស់ពួកគេ។ បន្ទាប់ពីអាយុបានមួយឆ្នាំ ទារកត្រូវបានគេដាក់នៅក្នុងមជ្ឈមណ្ឌលក្នុងព្រៃ និងបញ្ចុកបបររាវៗ និងទឹកដោះគោ។ ពេលបានអាយុ ៣ ឆ្នាំ ពួកគេត្រូវបានគេយកទៅ "កសាង" ដើម្បីរៀនសូត្រពីដំណាំដាំ លើកភ្លឺ និង "អាន និងសរសេរតិចតួច"។ សុះ ម៉ែន រំលឹកថា៖

> បន្ទាប់ពីបានច្រើនថ្ងៃមក ក្មេងៗនឹងនឹកឪពុកម្តាយ និងក្រុមគ្រួសាររបស់ពួកគេណាស់ ហើយបានរត់ត្រឡប់មកលេងជាមួយពួកគេវិញ។ ពួកខ្មែរក្រហមនឹងចាប់ពួកគេវាយ។ គ្មានការអាណិតអាសូរអ្វីទាំងអស់។ ក្មេងខ្លះត្រូវបានគេវាយដំ ដប់ដង ឬច្រើនជាងនេះដោយសារតែរឿងនេះ។ ក្មេងមួយចំនួនតូចមិនបានរត់ត្រឡប់មក [ផ្ទះ] វិញទេ ដោយសារតែពួកគេបានហូបតែបបររាវៗតិចតួច និងត្រូវធ្វើការដូចជាមនុស្សពេញវ័យដែរ។

ទោះជាយ៉ាងណា ឆ្នាំដែលលំបាកជាងគេបំផុតគឺឆ្នាំ ១៩៧៧-៧៨។ "គេមិនឱ្យយើងហូបឆ្អែតទេ ... ហើយធ្វើការគ្មានសម្រាកទៀត។ នៅរដូវដាំដុះ ប្រជាជន ១០ នាក់ត្រូវគេចាត់ឱ្យធ្វើការលើផ្ទៃដីមួយហិកតា។ ប្រសិនបើការងារនេះមិនបានបញ្ចប់ទេ គោលដៅលើបុគ្គលម្នាក់ៗត្រូវបានគេកំណត់។ "ប្រសិនបើអ្នកមិនអាច

Deleted: *Unrevised translation. A revised translation will be provided upon request.*

ធ្វើប៉ុនោះបានគេ អ្នកត្រូវគេចោទថាជា កាហ្សេបេ"។ វាគឺនៅក្នុងអំឡុងពេលនេះហើយដែលប្រជាជនជាង ៥.០០០ នាក់ត្រូវបានគេសម្លាប់ក្នុងឃុំឈូកស។

**IV. សេចក្តីសន្និដ្ឋាន**

តើគេរៀបរាប់អំពីជោគវាសនារបស់ប្រជាជនចាម និងប្រជាជនមូស្លីមដទៃទៀតនៅកម្ពុជាក្នុងអំឡុងពេលនៃសម័យ ប៉ុល ពត ថាយ៉ាងដូចម្តេច? ជាបឋម ពួកគេពិតជាបានជួបនូវអត្រាស្លាប់យ៉ាងរន្ធត់។ នៅក្នុងរយៈពេលបួនឆ្នាំនោះ ចំនួនពួកគេបានធ្លាក់ពី ២៥០.០០០ នាក់ (ប្រហែលជាច្រើនជាងនេះ) មកត្រឹមប្រមាណ ១៧៣.០០០ នាក់[115] ដែលជាការខាត់បង់ខាងស្ថិតិយ៉ាងហោចណាស់ ៧៧.០០០ នាក់ ដែលគេត្រូវតែបន្ថែមយ៉ាងហោចណាស់ ១០.០០០ នាក់ផ្សេងទៀតនៃប្រជាជនចាមដែលកើតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ សូម្បីតែនៅកម្រិតសន្មតដ៏ទាបនៃអត្រាកំណើនប្រជាជនមួយភាគរយក្នុងមួយឆ្នាំ ដែលទាបជាងអាត្រាធម្មតាពីមុនដល់ទៅបីដង។ គេហាក់ដូចជាពុំអាចប្រកែកបានទេថា ជាងមួយភាគបីនៃប្រជាជនចាម ពោលគឺប្រហែល ៩០.០០០ នាក់ បានស្លាប់បាត់បង់ជីវិតនៅក្នុងដៃនៃរបបប៉ុលពត។ ទំហំនៃការសន្និដ្ឋានខាងស្ថិតិនេះ គឺពិតជាត្រូវបានបញ្ជាក់អះអាងដោយដំណើររឿងជាលក្ខណៈបុគ្គលជាច្រើនដែលបានបង្ហាញនៅក្នុងការសិក្សានេះ។ វាគឺជាទ្រង់ទ្រាយនៃការបំផ្លិចបំផ្លាញមនុស្សជាតិក្នុងសមាមាត្រខ្ពស់ជាងចំនួនអ្នកស្លាប់_តាមការប៉ាន់ប្រមាណក្នុងចំណោមប្រជាជនខ្មែរទាំងអស់ (មនុស្សជាងមួយលាននាក់បានស្លាប់ ក្នុងចំណោម_មនុស្ស ៧ ទៅ ៨ លាននាក់ក្នុងឆ្នាំ ១៩៧៥)។

គេនៅតែឆ្ងល់ថាតើប្រជាជនចាមត្រូវគេរើសអើង ឬក៏ត្រូវគេធ្វើទុក្ខបុកម្នេញ *ដោយសារតែពួកគេជាជនជាតិចាម* ពោលគឺ ដោយសារមូលហេតុពូជសាសន៍ ឬយ៉ាងណា។ របបកម្ពុជាប្រជាធិបតេយ្យបានអះអាងថាប្រព្រឹត្តចំពោះប្រជាជនរបស់ខ្លួនទាំងអស់ដូចៗគ្នា ដោយមិនប្រកាន់ពូជសាសន៍។ ហើយការអះអាងនេះក៏ត្រូវបានជនជាតិភាគតិចចាមទទួលយកដែរ។ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ជាជនជាតិចាមចំនួន ៤៦ នាក់

---

[115] នៅខែ ធ្នូ ឆ្នាំ ១៩៨២ ចំនួនប្រជាជនចាមនៅក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជារាប់ឃើញមាន ១៨២.២៥៦ នាក់។ (*សហគមន៍អ៊ិស្លាមនៅកម្ពុជា* ទំព័រ ១៧-១៨)។ ដោយសន្មតថា អត្រាកំណើនប្រជាជនមាន ៣ ភាគរយក្នុងមួយឆ្នាំចាប់ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨២ ចំនួនប្រជាជនចាមក្នុងខែ មករា ឆ្នាំ ១៩៧៩ គួរតែមាន ១៦១.៣៥០ នាក់ បូក ១១.៧០០ នាក់ ដែលបានរត់គេចទៅបរទេស។ សូមមើល "ចាម" ដោយ ពោធិ៍ ធម្មា ក្នុង *"សេចក្តីផ្តើមទៅកាន់ចំណេះដឹងពីឧបទ្វីបឥណ្ឌូចិន"* (ប៉ារីស ឆ្នាំ ១៩៨៣) ទំព័រ ១២៧-៣១។ សូមមើលកំណត់ចំណាំលេខ ៣៨ សម្រាប់ការពិភាក្សាអំពីតួលេខចំនួនប្រជាជនចាមមុនឆ្នាំ ១៩៧៥។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

ដែលត្រូវចោទសួរចំពោះប្រធានបទនេះ មាន ៣០ នាក់បាននិយាយថា ជនជាតិចាមត្រូវគេរើសអើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងរបៀបមួយចំនួន ប៉ុន្តែ ១៦ នាក់បាននិយាយថា ជនជាតិចាមមិនត្រូវបានគេរើសអើងឡើយ។ ភាគច្រើននៃក្រុមខាងក្រោយនេះ ហាក់ជឿថាការធ្វើទុក្ខបុកម្នេញជាពិសេសលើជនជាតិចាមពិតជាកើតឡើង ប៉ុន្តែពួកគេមិនគិតថារឿងនេះជា*ការរើសអើង*ទេ ដោយសារគេធ្វើវាដើម្បីធ្វើឲ្យពួកគេមានអាកប្បកិរិយាដូចខ្មែរទាំងស្រុង។

**តារាង ៣**

**ឈ្មោះមួយចំនួននៃបញ្ញវ័ន្តឥស្លាម**

**ដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ**

| ឈ្មោះ | ការសិក្សាខ្ពស់ | ប្រទេស | មុខតំណែង | ទីកន្លែងស្លាប់ | កាលបរិច្ឆេទ |
|---|---|---|---|---|---|
| ១. ហ័តជី អ៊ីទ្រីស | (១៥ ឆ្នាំ) | អារ៉ាប៊ី សាអ៊ូឌីត | *ហាក់កែម* ខេត្តកណ្តាល | ? | កញ្ញា ១៩៧៨ |
| ២. ទូន មហាម៉េត សេន | Medina; សាកលវិទ្យាល័យ Al-Azhar ទីក្រុងគែរ ១៩៦៣-៦៧ | អារ៉ាប៊ី សាអ៊ូឌីត អេហ្ស៊ីប | មេដឹកនាំមូស្លីមនៅបាត់ដំបង | បូករោទ៍ សង្កែ បាត់ដំបង (ធ្វើអត្តឃាត) | ១៩៧៦ |
| ៣. ទូន ស្រុង យុសូហ្វ | សាកលវិទ្យាល័យ Al-Azhar ទីក្រុងគែរ | អេហ្ស៊ីប | *ហាក់កែម* គីឡូម៉ែត្រលេខ ៧ ភ្នំពេញ | ក្រហមក មេស ព្រះចន្ទ ព្រៃវែង | ពាក់កណ្តាលឆ្នាំ ១៩៧៥ |
| ៤. ទូន អ៊ីម៉ាម សុលេម៉ានយុសូហ្វ | Al-Azhar | អេហ្ស៊ីប | | ទ្រា ក្រូចឆ្មារ កំពង់ចាម | ១៩៧៦ |
| ៥. ទូន អ៊ីសាក ហូសាន | Al-Azhar | អេហ្ស៊ីប | | ក្រចេះ | ? |
| ៦. ទូន អេម កូបាន | Al-Azhar | អេហ្ស៊ីប | | ? | ? |
| ៧. តួ ហាកគីម រីសា ហ័ | Al-Azhar | អេហ្ស៊ីប | អង្គរបាន កំពង់ចាម | ? | ? |

Deleted: *Unrevised translation. A revised translation will be provided upon request.*

| | | | | | |
|---|---|---|---|---|---|
| តជី អ៊ីស្មែល | | | | | |
| ៨. ទួន អ៊ីម៉ាម សិន អាស្លាត | | ឥណ្ឌា | | ? | ? |
| ៩. ទួន មហាម៉េត អាម៉េត | | ម៉ាឡេស៊ី | | ស្ពឺ ចំការលើ កំពង់ចាម | ១៩៧៦ |
| ១០. ទួន អ៊ីម៉ាមី មូសា | | ម៉ាឡេស៊ី ឥណ្ឌា | | ? | ? |
| ១១. ទួន សុន មហាម៉េត | សាកលវិទ្យាល័យ Tinpan | ឥណ្ឌា | | ក្រូចឆ្មារ កំពង់ចាម | ១៩៧៦ |

ប្រភព៖ បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយជនជាតិចាមក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ដូច្នេះ ចំណុចសំខាន់គឺថាតើប្រជាជនចាមត្រូវគេធ្វើទុកបុកម្នេញ ឬយ៉ាងណា។ ការពិតដែលថា ពូជសាសន៍ផ្សេងទៀតត្រូវគេធ្វើទុកបុកម្នេញដែរនោះគឺមិនមានពាក់ព័ន្ធទេ។ ច្បាស់ណាស់ អាចនឹងមានការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាច្រើនប្រភេទ។ (ឧទាហរណ៍ ឧក្រិដ្ឋកម្មណាស៊ីប្រឆាំងនឹងពួកយូដាគឺពិតជាអំពើប្រល័យពូជសាសន៍ ថ្វីបើអំបូរជីពស៊ីក៏រងអំពើប្រល័យពូជសាសន៍ដោយពួកណាស៊ីផងដែរក្តី។ នៅពេលសួរថាតើជនជាតិចាមមូស្លីមត្រូវគេបង្ខំឲ្យហូបសាច់ជ្រូកដែរឬទេ អ្នកផ្តល់បទសម្ភាសន៍ ៤១ នាក់ បាននិយាយថា មែន ហើយមានតែ ៦ នាក់ប៉ុណ្ណោះដែលនិយាយថា ទេ។ ដូចគ្នានេះដែរ នៅពេលសួរថាតើការប្រើប្រាស់ភាសាចាមត្រូវបានហាមឃាត់ដោយអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យដែរឬទេ ៣៦ នាក់បាននិយាយថា មែន ហើយមានតែម្នាក់ប៉ុណ្ណោះដែលនិយាយថា ទេ។ នៅពេលសួរថាតើប្រជាជនចាម ត្រូវគេបំបែក ឬលែងឲ្យនៅជុំគ្នាដែរឬទេ អ្នកផ្តល់បទសម្ភាសន៍ ៥១ នាក់ បាននិយាយថា មែន ហើយគ្មាននរណាឡើយដែលនិយាយថា ទេ។ ច្បាស់ណាស់ ជនជាតិចាមត្រូវគេធ្វើទុក្ខបុកម្នេញ ហើយគោលដៅជាក់លាក់មួយគឺភាពខុសគេនៃវប្បធម៌របស់ពួកគេ។ បើទោះជាចំណុចនេះគ្រាន់តែជាការអនុវត្តបទប្បញ្ញត្តិដូចគ្នាទៅលើប្រជាពលរដ្ឋគ្រប់គ្នានៃរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏គេត្រូវតែទទួលស្គាល់ដែរថា លក្ខណៈទាំងស្រុងនៃការអនុវត្តបទប្បញ្ញត្តិទាំងនេះ និងការអនុវត្តយ៉ាងតឹងរ៉ឹងរបស់ពួកវា តំណាងឲ្យការវាយប្រហារធ្ងន់ធ្ងរលើក្រុមជនជាតិភាគតិចដូចជាជនជាតិចាម។ ការលុបបំបាត់របស់របបកម្ពុជាប្រជាធិបតេយ្យលើសាសនាទាំងអស់អាចនឹងត្រូវបានគេហៅថា “គ្មានការរើសអើង” ប៉ុន្តែទោះយ៉ាងណា ក៏វានៅតែជាការសង្កត់សង្កិនដដែល។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

*[រូបភាព]*

*ខិត្តប័ណ្ណអង្គការ Oxfam America សម្រាប់ការប្រុងប្រយ័ត្ន ការដង្ហែក្បួន និងសេវារំលឹកនៅឯអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉កក្នុងរដូវស្លឹកឈើជ្រុះ ឆ្នាំ ១៩៨៨ ជំរុញឲ្យមានការដកអសនៈរបស់ ប៉ុល ពត និងពួកខ្មែរក្រហមនៅឯអង្គការសហប្រជាជាតិ ផ្តល់ជំនួយមនុស្សធម៌ និងការអភិវឌ្ឍទៅកម្ពុជា និងការលើកទឹកចិត្តឲ្យសហរដ្ឋអាមេរិក ប្រទេសចិន និងអង្គការសហប្រជាជាតិ ឲ្យស្វែងរកយ៉ាងសកម្មនូវដំណោះស្រាយនយោបាយដែលមានការត្រួតពិនិត្យពីអន្តរជាតិ ដែលធានាថា ប៉ុល ពត និងពួកមេដឹកនាំខ្មែរក្រហមនឹងមិនត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ទៅកម្ពុជាវិញ។ វាហាក់បង្ហាញថាយ៉ាងហោចណាស់មានមនុស្សមួយចំនួនដែលយកចិត្តទុកដាក់ពីរឿងនេះផងដែរ!*

**តារាង ៤**
**ការបោះឆ្នោតនៅអង្គការសហប្រជាជាតិលើ**
**បញ្ហាកម្ពុជា ឆ្នាំ ១៩៨០-៨១**
**(បណ្តាប្រទេសមូស្លីម)**

| ប្រឆាំងនឹងអាសនៈរបស់ របបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត | អនុបវាទ (ឬ "គ្មានការបោះឆ្នោត") | គាំទ្រអាសនៈរបស់ របបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត |
|---|---|---|
| ១. អាហ្វហ្គានីស្ថាន | ១. លីបង់ | ១. បារ៉ែន |
| ២. អាល់ហ្សេរី | ២. ម៉ាលី | ២. បង់ក្លាដែស |
| ៣. យេម៉ែនប្រជាធិបតេយ្យ | ៣. ទុយនេស៊ី | ៣. ហ្សីប៊ូទី |
| ៤. លីប៊ី | ៤. តង់ហ្សានី | ៤. អេហ្ស៊ីប |
| ៥. ស៊ីរី | ៥. អ៊ិនយេម៉ែន | ៥. ឥណ្ឌូនេស៊ី |
| ៦. ឆាដ | ៦. អ៊ីរ៉ង់ | ៦. គុយវ៉ែត |
| | ៧. អ៊ីរ៉ាក់ | ៧. ម៉ាឡេស៊ី |
| | ៨. យ៉េរដាន់ | ៨. ម៉ាល់ឌីវ |

Deleted: *Unrevised translation. A revised translation will be provided upon request.*

| | | |
|---|---|---|
| | | ៩. ម៉ូរីតានី<br>១០. ម៉ារ៉ុក<br>១១. នីហ្សេ<br>១២. នីហ្សេរីយ៉ា<br>១៣. អូម៉ង់<br>១៤. ប៉ាគីស្ថាន<br>១៥. កាតា<br>១៦. អារ៉ាប៊ីសាអ៊ូឌីត<br>១៧. សេណេហ្គាល់<br>១៨. ស៊ូដង់<br>១៩. សូម៉ាលី<br>២០. តួកគី<br>២១. អារ៉ាប់រួម អេមីរ៉ាត |

ប៉ុន្តែ ករណីដ៏រឹងមាំមួយដែលអាចឲ្យគេសន្និដ្ឋានបានថា ជនជាតិចាមមិនត្រឹមតែត្រូវគេធ្វើទុក្ខបុកម្នេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវគេរើសអើង ពោលគឺ *ត្រូវគេធ្វើទុក្ខបុកម្នេញដោយសារពួកគេជាជនជាតិចាម*។ ពិតណាស់ គ្មានកំណត់ត្រាណាមួយថា សមាជិកណាម្នាក់នៃក្រុមជនជាតិភាគច្រើន ពោលគឺ ជនជាតិខ្មែរត្រូវគេបង្ខំឲ្យហូបសាច់ជ្រូក ទេ។ ជាក់ស្តែង ជនជាតិចាមត្រូវគេត្រួតពិនិត្យ ជាពិសេសចំពោះចំណុចនេះ។ ចំណុចទីពីរ ហើយដែលកាន់តែសំខាន់គឺ ភាសាខ្មែរមិនត្រូវគេហាមឃាត់ទេ។ ផ្ទុយទៅវិញ អ្នកនិយាយភាសាដទៃទៀតជាពិសេសភាសាចាម ត្រូវគេបង្ខំឲ្យទំនាក់ទំនងដោយប្រើតែភាសាខ្មែរ។ តើចំណុចនេះមិនមែនជាការរើសអើងទេឬ? ហើយចុងក្រោយ ថ្វីបើសហគមន៍ខ្មែរមកពីទីក្រុងត្រូវគេបំបែក គេមិនអាចនិយាយបានទេថា ប្រជាជនខ្មែរតាមភូមិភាគច្រើនត្រូវគេបំបែកដែរនោះ។ ប៉ុន្តែ *សហគមន៍ជនជាតិចាមទាំងអស់ មិនថា_មកពីទីក្រុង ឬតាមជនបទ ប្រជាជនថ្មី ឬប្រជាជនមូលដ្ឋាន សុទ្ធតែត្រូវគេបំបែក*។ ហើយភូមិចាមមិនមែន_ត្រូវគេបំបែកដោយចៃដន្យទេ ប៉ុន្តែពួកគេពិតជាត្រូវបំបែកដោយចេតនាជាក្រុមតូចៗដោយមានចំនួនគ្រួសារថេ (បើ

Deleted: *Unrevised translation. A revised translation will be provided upon request.*

ទោះជាខុសគ្នាតាមតំបន់ក្តី) ហើយគេត្រូវធានា ថាក្រុមទាំងនេះមិនអាចមានទំនាក់ទំនងជាមួយគ្នាបាន។ ជាថ្មីម្តងទៀត គេអាចមើលឃើញយ៉ាងច្បាស់ពីការរើសអើង ព្រោះថា សហគមន៍ភូមិខ្មែរភាគច្រើនមិនត្រូវបានបំបែកខ្លាំងទេ។ ទាល់តែ*រាល់*ភូមិកម្ពុជាបានបំបែកដោយចេតនា និង*រាល់*ប្រជាជនខ្មែរគ្រប់ពូជសាសន៍ ត្រូវគេបង្ខំឱ្យមានអាកប្បកិរិយាក្នុងរបៀបដែលពួកគេទាំងអស់គ្នាមិនធ្លាប់ធ្វើស្មើៗគ្នា ដូច ជាឱ្យហូប__*ទំពាំង* និងនិយាយតែ*ភាសាអង់គ្លេស* នោះទើបគេអាចសន្និដ្ឋានថាមិនមានការរើសអើង ពូជសាសន៍នៅក្នុង__គោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យចំពោះជនជាតិចាម។ ប៉ុន្តែ ពិតជាមានការរើសអើងបែប_នេះមែន។

យើងបានឃើញថាជនជាតិចាមក្នុងចំណោមប្រជាជនថ្មី (ឬ ប្រជាជនបញ្ញើ) ដែលត្រូវជម្លៀសចេញពីទីក្រុង មិនមែនសុទ្ធតែត្រូវជ្រើសរើសសម្រាប់ការធ្វើបាបដោយសារតែពួកគេជា*ជនជាតិចាម*នោះឡើយ។ផ្ទុយទៅវិញ ពួកគេបានទទួលការធ្វើបាបក្នុងនាមជាប្រជាជនថ្មី ដោយសារតែពួកគេមានប្រភពដើមមកពីទីក្រុងជាក់ស្តែងដោយមិនគិតពីពូជសាសន៍របស់ពួកគេទេ។ ទោះយ៉ាងណា យើងក៏បានឃើញផងដែរអំពីរបៀបដែលប្រជាជនមូលដ្ឋានជាជនជាតិចាម (ភាគច្រើននៃប្រជាជនចាមនៅក្នុងប្រទេសកម្ពុជា) ត្រូវបានជម្លៀស និងបំបែកដោយចេតនាចេញពីភូមិរបស់ពួកគេ និងត្រូវបានបញ្ចុះឋានៈឱ្យក្លាយជាប្រជាជនបញ្ញើ ដោយសារពួកគេជាជនជាតិចាម។ ដូចដែលលោក Stephen Heder បានកត់សម្គាល់ អ្នកបញ្ញើ "ស្ថិតនៅក្រោមគេក្នុងបញ្ជីចែកអាហារ និងនៅលើគេក្នុងបញ្ជីសម្លាប់ និងគ្មានសិទ្ធិនយោបាយទេ"[116]។ ចំពោះការធ្វើបាបនេះ ប្រជាជនមូលដ្ឋានជាជនជាតិចាម ត្រូវបានជ្រើសរើសដោយចេតនា ដោយសារតែពូជសាសន៍របស់ពួកគេ និងទទួលការរើសអើងពីប្រជាជនមូលដ្ឋានជាជនជាតិខ្មែរ ដែលផ្ទុយទៅវិញមិនត្រូវបានធ្វើបាបបែបនេះទេ ដោយសារតែពូជសាសន៍របស់ពួកគេ។ ដូច្នេះ មានមូលដ្ឋានយ៉ាងរឹងមាំសម្រាប់ករណីដែលថា របបកម្ពុជាប្រជាធិបតេយ្យបានធ្វើយុទ្ធនាការធ្វើទុក្ខបុកម្នេញខាងពូជសាសន៍ប្រឆាំងនឹងជនជាតិចាម។

ដូចដែលបានរៀបរាប់ពីខាងដើម អនុសញ្ញាអន្តរជាតិស្តីពីអំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ កំណត់និយមន័យពាក្យ អំពើប្រល័យពូជសាសន៍ ថាជាអំពើនានាដូចជា "ការសម្លាប់សមាជិកនៃក្រុម" ដែលធ្វើឡើងជាមួយនឹង "ចេតនាចង់បំផ្លាញចោលទាំងស្រុង ឬដោយផ្នែកនូវក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាជាដើម"។ ឥឡូវនេះ គ្មានអ្វីគួរសង្ស័យទេថា របបកម្ពុជាប្រជាធិបតេយ្យមាន បំណងបំផ្លាញក្រុមសាសនាចាមមូស្លីម "បែបនោះ"។ ក្រុមប្រជាជនចាមមិនត្រឹមតែត្រូវបំបែកក្នុងចំណោមប្រជាជនខ្មែរប៉ុណ្ណោះទេ ប៉ុន្តែពួកគេ

[116] Stephen R. Heder, *មុខរបររបស់ប្រជាជនកម្ពុជា និងការតស៊ូ* (បាងកក៖ សាកលវិទ្យាល័យជូឡាឡុងកូន ឆ្នាំ ១៩៨០) ទំព័រ ៦។

Deleted: កង

Deleted: *Unrevised translation. A revised translation will be provided upon request.*

ត្រូវគេហាមឃាត់ផងដែរដោយការគំរាមកំហែងដោយកម្លាំងមិនឲ្យប្រតិបត្តិសាសនាឥស្លាម___របស់ពួកគេ។ (ការពិតដែលថា ប្រជាជនខ្មែរត្រូវគេហាមឃាត់ផងដែរមិនឲ្យប្រតិបត្តិពុទ្ធសាសនាគឺមិនទាក់ទង__ទេទៅនឹងចំណុចពិសេសនេះ។ ការសម្លាប់រង្គាលជាប្រព័ន្ធដោយអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យលើសហគមន៍ និងមេដឹកនាំសាសនាចាម (សូមមើលតារាង ១, ២, និង ៣) កុំបាច់និយាយអីដល់ការសម្លាប់រង្គាលទ្រង់ទ្រាយ_ធំនៃប្រជាជនចាមធម្មតារាប់ម៉ឺននាក់ គឺជាភស្តុតាងបន្ថែមទៀតនៃចេតនាប្រល័យពូជសាសន៍របស់របប_ខ្មែរ_ក្រហម។

ការផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យដោយកងទ័ពវៀតណាម និងការបង្កើតឡើងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានៅខែ មករា ឆ្នាំ ១៩៧៩ មិនបានបញ្ចប់នូវស្ថានភាពអាក្រក់របស់ជនជាតិចាមទេ។ អំពើប្រល័យពូជសាសន៍ត្រូវបានបញ្ឈប់ សាសនាឥស្លាមត្រូវគេស្តារឡើងវិញ ប៉ុន្តែដូចជាប្រជាជនខ្មែរគ្រប់គ្នាដែរ ប្រជាជនចាមបានទទួលរងគ្រោះពីការជាប់គាំងនយោបាយអន្តរជាតិ ដែលបានទទួលតាំងពីពេលនោះមក។ នៅឆ្នាំ ១៩៧៩ ឆ្នាំ ១៩៨០ និងជាថ្មីម្តងទៀតនៅឆ្នាំ ១៩៨១ អង្គការសហប្រជាជាតិបានសម្រេចចិត្តថា របបកម្ពុជាប្រជាធិបតេយ្យជាតំណាងស្របច្បាប់ដែលរបស់ប្រជាជនកម្ពុជា។ ដូច្នេះ នៅឆ្នាំ ១៩៨៨ កម្ពុជាប្រជាធិបតេយ្យដែលជារបបប្រល័យពូជសាសន៍ដែលត្រូវគេបណ្តេញចេញពីអំណាច នៅតែកាន់កាប់អសនៈរបស់កម្ពុជាក្នុងវេទិកាពិភពលោកដដែល។ គ្មានប្រទេសលោកខាងលិចណាមួយបានប្រឆាំងជំទាស់នឹងការកាន់តំណែងរបស់របបកម្ពុជាប្រជាធិបតេយ្យលើអសនៈនៅអង្គការសហប្រជាជាតិទេ ហើយប្រទេសភាគច្រើនរួមទាំងសហរដ្ឋអាមេរិកបានបោះឆ្នោតគាំទ្រវា។ ប្រទេសមូស្លីមក៏មានកំណត់ត្រាមិនល្អប្រសើរជាងនេះប៉ុន្មានដែរ។ ប្រទេសចំនួន ៦ បានបោះឆ្នោតប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ហើយប្រទេសចំនួន ៨ បានបោះឆ្នោតអនុបវាទ ប៉ុន្តែ ប្រទេសចំនួន ២១ ពិតជាបានបោះឆ្នោតគាំទ្ររបប ប៉ុល ពត[117]។ ចំណាត់ថ្នាក់ទាំងបីនេះមានបង្ហាញនៅក្នុងតារាង ៤។

នៅឆ្នាំ ១៩៧៤ ក្នុងអំឡុងពេលជជែកពិភាក្សាគ្នាផ្សេងទៀតរបស់អង្គការសហប្រជាជាតិស្តីពីបញ្ហាប្រទេសកម្ពុជា លោក Gaffar Peang-Meth បានលើកឡើងនូវយោបល់ដូចតទៅ ដែលនៅតែហាក់ដូចជានៅតែពាក់ព័ន្ធមកទល់សព្វថ្ងៃនេះ៖

---

[117] សូមមើល Anthony Barnett, "ក្លិបអ្នកគាំទ្រ ប៉ុល ពត៖ នៅតែបើកចំហសម្រាប់ធុរកិច្ច "នៅក្នុង *កេរដំណែល៖ ការតស៊ូរបស់កម្ពុជា និងវៀតណាម* ដោយ John Pilger និង Anthony Barnett, (New Statesman, ឡុងដ៍ ឆ្នាំ ១៩៨២) ទំព័រ ១៣៥-៤១។

**Deleted:** *Unrevised translation. A revised translation will be provided upon request.*

> អស់អ្នកដែលបានដឹងពីជោគវាសនារបស់ប្រជាជនខ្មែរមូស្លីម មុខជាឆ្ងល់ចំពោះអ្វីដែលគណៈប្រតិភូអារ៉ាប់មួយចំនួនកំពុងធ្វើនៅឯអង្គការសហប្រជាជាតិកាលពីឆ្នាំមុន នៅពេលដែលពួកគេបានបោះឆ្នោតគាំទ្រអសនៈរបស់រដ្ឋាភិបាល សីហនុ ដែលគ្រប់គ្រងដោយពួកកុម្មុយនីស្ត ...។ វាដល់ពេលហើយដែលពិភពមូស្លីមត្រូវមានប្រតិកម្មគាំទ្រដល់បងប្អូនមូស្លីមរបស់ខ្លួន"[118]។

ប្រសិនបើនោះជារឿងពិតចំពោះឆ្នាំ ១៩៧៤ នោះជាអកុសលវាក៏ត្រូវគ្នាផងដែរចំពោះឆ្នាំ ១៩៨៨។ នៅឆ្នាំ ១៩៨០ លោក ទូន អ៊ីប្រាហ៊ីម បានស្នើសុំដល់ "ជនជាតិអេហ្សីប និងអារ៉ាប់ទាំងអស់"៖ "សូមកុំទទួលស្គាល់ឲ្យសោះចំពោះអ្នកដែលបានបង្ខំយើងឲ្យហូបសាច់ជ្រូក ពោលគឺ ក្រុម ប៉ុល ពត"[119]។ ការទទូចនេះ និងការទទូចស្រដៀងគ្នាផ្សេងទៀតភាគច្រើននៅតែមិនត្រូវបានគេឆ្លើយតប។

ប្រជាជនចាមដែលរស់រានមានជីវិត គឺមិនមែនគ្រាន់តែជា "កុមារកំព្រានៃអំពើប្រល័យពូជសាសន៍" នោះទេ។ ពួកគេក៏មិនបានទទួលកេរតំណែលពីពិភពឥស្លាមផងដែរ។ ឥឡូវនេះ ពួកគេជា "កូនចៅដែលបាត់បង់" នៃវប្បធម៌ឥស្លាម។ ប៉ុន្តែ ដូចគ្នានឹងទេវធីតាលើផែនដីដើមរបស់ខ្លួនគឺ ពោធិ៍ឥន្ទ្រនាគាដែលបានរស់រានមានជីវិតរហូតដល់ថ្ងៃបច្ចុប្បន្ននេះតាមរយៈការបន្តំឈ្មោះ ដំបូងឡើយជាអាទិទេពហិណ្ឌូឈ្មោះ អុម៉ា បន្ទាប់មកជាព្យាការីមូស្លីមឈ្មោះ អេវ៉ា និងសូម្បីតែជា "Black Virgin" របស់វៀតណាម ប្រជាជនចាម វប្បធម៌របស់ពួកគេនៅកម្ពុជាក៏បានរស់រានមានជីវិតផងដែរ។

*[រូបភាព]*

[118] Peang-Meth, "អ៊ីស្លាម" ទំព័រ ២៥៥។

[119] ទូន អ៊ីប្រាហ៊ីម, បទសម្ភាសន៍ជាមួយអ្នកនិពន្ធ នៅទីក្រុងភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៨០។

Deleted: *Unrevised translation. A revised translation will be provided upon request.*